# ព្រះ

# អភិធម្មត្ថសង្គហៈ

## បរិច្ឆេទទី ៦

# រូបសង្គហវិភាគ


រៀបរៀងដោយ

បណ្ឌិតធម្មាចារ្យ រស់ សុជាត


ព.ស ២៥៤១

# អភិធម្មត្ថសង្គហៈ

## បរិច្ឆេទទី ៦

## រូបសង្គហវិភាគ

នមោតស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

------- ◎ -------

### សង្គហគាថា

សមុទ្ទេសា វិភាគាច សមុដ្ឋានា កលាបតោ
បវត្តិក្កមតោ ចេតិ បញ្ចធា តត្ថ សង្គហោ

ការសម្ដែងសង្គ្រោះរូប ក្នុងបរិច្ឆេទទី ៦ នេះ ព្រះអនុរុទ្ធាចារ្យ សម្ដែងជា **៥ ន័យ** គឺ :

**១. រូបសមុទ្ទេសន័យ** ការសម្តែងរូបដោយសង្ខេប ដើម្បីឲ្យដឹងឲ្យជ្រាប នូវលក្ខណៈ ។

**២. រូបវិភាគន័យ** ការសម្តែងនូវរូបដោយពិស្តារ ដោយចំណែកជាពួក ៗ ។

**៣. រូបសមុដ្ឋានន័យ** ការសម្តែងនូវហេតុឲ្យកើតរូប ដោយសមុដ្ឋាន ៤ ។

**៤. រូបកលាបន័យ** ការសម្តែងនូវរូបដែលកើតឡើង ជាសំណុំ ជាក្រុម ៗ ។

**៥. រូបបវត្តិក្កមន័យ** ការសម្តែងនូវការកើតឡើង និង ការរលត់របស់រូបតាមលំដាប់ ដោយសេចក្តីផ្សេងគ្នានៃ ភព កាល និង សត្វដែលកើតក្នុងភូមិនានា ។

**រូបស័ព្ទ** នេះមានវចនត្ថៈថា **រុប្បតីតិ រូបំ** ប្រែថា ឈ្មោះថា **រូប** ព្រោះអត្ថថា បែកធ្លាយ គឺ រមែងបែកធ្លាយដោយបច្ច័យដែលជាសត្រូវ មានការក្តៅ និង ការត្រជាក់ជាដើម ។

ក្នុងបដិច្ចសមុប្បាទ សម្តែង **លក្ខណាទិចតុកៈរបស់រូប**

ដោយសេចក្ដីថា :

**-រុប្បន លក្ខណំ** មានការបែកធ្លាយ ជាលក្ខណៈ ។

**-វិកិរណ រសំ** មានការខ្ចាត់ខ្ចាយរាត់រាយ ជាកិច្ច ។

**-អព្យាកត បច្ចុប្បដ្ឋានំ** មានការមិនប្រាកដ មិនដាច់ស្រេច ជាខាងណា ជាផល ។

**-វិញ្ញាណ បទដ្ឋានំ** មានវិញ្ញាណ ជាហេតុជិត ។

ក្នុងបរមត្ថទីបនី លោកពោលថា :

**រូប** មានការបែកធ្លាយ ជាលក្ខណៈ ។
មានការមិនដឹងអារម្មណ៍ ជាកិច្ច ។
មានសភាវៈជាសម្បយោគ(ការប្រកបរួម) ជាផល ។
មានវិញ្ញាណ ជាហេតុជិត ។

# ១. រូបសមុទ្ទេសន័យ

រូបមាន ២៨ គឺ និប្ផន្នរូប ១៨ និង អនិប្ផន្នរូប ១០ ។

**និប្ផន្នរូប ១៨** គឺ មហាភូតរូប ៤ បសាទរូប ៥ វិសយរូប ៤ ភាវរូប ២ ហទយរូប ១ ជីវិតរូប ១ និងអាហាររូប ១ ។

**អនិប្ផន្នរូប ១០** គឺ បរិច្ឆេទរូប ១ វិញ្ញត្តិរូប ២ វិការរូប ៣ និង លក្ខណរូប ៤ ។

រូបទាំង ២៨ នេះ បើបែងចេញជាប្រភេទធំៗ មាន ២ ប្រភេទ គឺ មហាភូតរូប ៤ និង ឧបាទាយរូប ២៤ ។

**មហាភូតរូប** គឺ រូបដែលជាធំ ហើយនឹងប្រាកដជាក់ច្បាស់ ដោយលក្ខណៈរបស់ខ្លួន និងដោយសណ្ឋានរបស់ខ្លួន ក្នុងសន្តាននៃរបស់មានជីវិត និងមិនមានជីវិត ។

**ឧបាទាយរូប** គឺ រូបដែលកើតឡើងដោយអាស្រ័យមហា-ភូតរូប ។

ប៉ុន្តែបើចែករូបទាំង ២៨ នេះ ចេញជាប្រភេទតូចៗ មានរូប ១១ ប្រភេទ គឺ :

**១.មហាភូតរូប ៤** បានដល់ បឋវីធាតុ អាបោធាតុ តេជោ-ធាតុ វាយោធាតុ ។

**២.បសាទរូប ៥** បានដល់ ចក្ខុបសាទរូប សោតបសាទរូប ឃានបសាទរូប ជិវ្ហាបសាទរូប កាយបសាទរូប ។

**៣.វិសយរូប ៤** បានដល់ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ។

**៤.ភាវរូប ២** បានដល់ ឥត្ថីភាវរូប បុរិសភាវរូប ។

**៥.ហទយរូប ១** បានដល់ ហទយវត្ថុរូប ។

**៦.ជីវិតរូប ១** បានដល់ ជីវិតិន្ទ្រិយរូប ។

**៧.អាហាររូប ១** បានដល់ កវឡិង្ការាហារ ។

**៨.បរិច្ឆេទរូប ១** បានដល់ អាកាសធាតុ ។

**៩.វិញ្ញត្តិរូប ២** បានដល់ កាយវិញ្ញត្តិរូប និងវចីវិញ្ញត្តិរូប។

**១០.វិការរូប ៣** បានដល់ រូបលហុតា រូបមុទុតា រូបកម្មញ្ញតា ។

**១១.លក្ខណរូប ៤** បានដល់ ឧបចយរូប សន្តតិរូប ជរតារូប អនិច្ចតារូប ។

ក្នុងបណ្តារូបទាំង ២៨ នេះ ក្នុងបាលីចែកជា ២ ពួក គឺ សភាវរូប និង អសភាវរូប ។

**សភាវរូប** បានដល់ មហាភូតរូប ៤ បសាទរូប ៥ វិសយរូប ៤ ភាវរូប ២ ហទយរូប ១ ជីវិតរូប ១ អាហាររូប ១ ។

រូប ១៨ នេះមានឈ្មោះហៅ បាន ៥ យ៉ាង គឺ :

**១.សភាវរូប** គឺ រូបដែលមានសភាវៈរបស់ខ្លួន ចំពោះខ្លួនផ្ទាល់ មិនច្រឡំគ្នា ។

**២.សលក្ខណរូប** គឺ រូបដែលមានលក្ខណៈ គឺ អនិច្ចំ ទុក្ខំ អនត្តា ។

**៣.និប្ផន្នរូប** គឺ រូបដែលកើតឡើង សម្រេចហើយពីសមុដ្ឋាន គឺកម្ម ចិត្ត ឧតុ អាហារ ។

**៤.រូបរូប** គឺ រូបដែលមានការប្រែប្រួល វិនាសបែកធ្លាយជាធម្មតា ព្រោះបច្ច័យ ។

**៥.សម្មសនរូប** គឺ រូបដែលគួរដល់ការពិចារណា ដោយសភាពជា អនិច្ចំ ទុក្ខំ អនត្តា ។

ចំណែក **អសភាវរូប ១០** ទៀត បានដល់ បរិច្ឆេទរូប ១ វិញ្ញត្តិរូប ២ វិការរូប ៣ លក្ខណរូប ៤ ទាំងអស់នេះក៏មានឈ្មោះ ហៅបាន ៥ យ៉ាងដែរ គឺ អសភាវរូប ១

អសលក្ខណរូប ១ អនិប្ផន្នរូប ១ អរូបរូប ១ និង អសម្មសនរូប ១ ៕

# អង្គធម៌របស់រូប ២៨

| | | |
|---|---|---|
| **១.បឋវីធាតុ** | បានដល់ | រូបរឹង ឬ ទន់ ។ |
| **២.អាបោធាតុ** | បានដល់ | រូបជ្រាបហូរ ឬ កកខន់ ។ |
| **៣.តេជោធាតុ** | បានដល់ | រូបក្តៅ ឬ ត្រជាក់ ។ |
| **៤.វាយោធាតុ** | បានដល់ | រូបកម្រើក តឹង ញ័រ ។ |
| **៥.ចក្ខុបសាទរូប** | បានដល់ | ភាពថ្លានៃភូត ដែលអាចទទួលរូបារម្មណ៍បាន ។ |
| **៦.សោតបសាទរូប** | បានដល់ | ភាពថ្លានៃភូត ដែលអាចទទួលសទ្ទារម្មណ៍បាន ។ |
| **៧.ឃានបសាទរូប** | បានដល់ | ភាពថ្លានៃភូត ដែលអាចទទួលគន្ធារម្មណ៍បាន ។ |
| **៨.ជិវ្ហាបសាទរូប** | បានដល់ | ភាពថ្លានៃភូត ដែលអាចទទួលរសារម្មណ៍បាន ។ |

| | | |
|---|---|---|
| ៩.កាយបសាទរូប | បានដល់ | ភាពថ្លានៃភូត ដែលអាចទទួលផោដ្ឋព្វារម្មណ៍បាន ។ |
| ១០.រូបារម្មណ៍ | បានដល់ | ពណ៌ ។ |
| ១១.សទ្ទារម្មណ៍ | បានដល់ | សម្លេង ។ |
| ១២.គន្ធារម្មណ៍ | បានដល់ | ក្លិន ។ |
| ១៣.រសារម្មណ៍ | បានដល់ | រស ។ |
| ១៤.ផោដ្ឋព្វារម្មណ៍ | បានដល់ | រឹងទន់ ក្តៅត្រជាក់ តឹងញ័រ។ |
| ១៥.ឥត្ថីភាវរូប | បានដល់ | រូបដែលជាហេតុនៃភាពជាស្ត្រី។ |
| ១៦.បុរិសភាវរូប | បានដល់ | រូបដែលជាហេតុ នៃភាពជាបុរស ។ |
| ១៧.ហទយវត្ថុរូប | បានដល់ | រូបដែលកើត តាំងនៅក្នុងបេះដូង និង ជាទីអាស្រ័យកើតរបស់ចិត្ត និងចេតសិក ។ |
| ១៨.ជីវិតរូប | បានដល់ | រូបដែលរក្សាកម្មជរូប ។ |
| ១៩.អាហាររូប | បានដល់ | រូបដែលនាំឲ្យអាហារជរូបកើត។ |
| ២០.បរិច្ឆេទរូប | បានដល់ | អាកាសធាតុ ដែលឃាំងរារាំងរវាងរូបកលាប និងរូបកលាប។ |

| | | |
|---|---|---|
| **២១.កាយវិញ្ញត្តិរូប** | បានដល់ | ចលនាផ្សេងៗនៃរាងកាយ ។ |
| **២២.វចីវិញ្ញត្តិរូប** | បានដល់ | ចលនាផ្សេងៗ នៃវាចា ។ |
| **២៣.រូបលហុតា** | បានដល់ | សភាពស្រាលនៃនិប្ផន្នរូប ។ |
| **២៤.រូបមុទុតា** | បានដល់ | សភាពទន់នៃនិប្ផន្នរូប ។ |
| **២៥. រូបកម្មញ្ញតា** | បានដល់ | សភាពគួរដល់ការងារនៃនិប្ផន្នរូប ។ |
| **២៦.ឧបចយរូប** | បានដល់ | ការកើតឡើងគ្រាដំបូង និងគ្រាក្រោយ ៗ របស់និប្ផន្នរូប ។ |
| **២៧.សន្តតិរូប** | បានដល់ | ការកើតបន្តគ្នា របស់និប្ផន្នរូបរហូតដល់អស់អាយុ ។ |
| **២៨.ជរតារូប** | បានដល់ | ភាពចាស់ជរានៃនិប្ផន្នរូប ។ |
| **២៩.អនិច្ចតារូប** | បានដល់ | ការរលត់នៃនិប្ផន្នរូប ។ |

# ទីកើតនៃ
# រូប ២៨ ក្នុងរាងកាយសត្វ

ក្នុងរាងកាយរបស់សត្វទាំងឡាយ អាចពិចារណារកទីកន្លែង

កើត របស់រូបនីមួយៗ ក្នុងរូបទាំង ២៨ បាន ដូចតទៅនេះ គឺ :

១. **មហាភូតរូប ៤** កើតនៅក្នុង សព៌ាង្គកាយ ។
២. **ចក្ខុបសាទ** កើតនៅក្នុង គ្រាប់ភ្នែក ។
៣. **សោតបសាទ** កើតនៅក្នុង រន្ធត្រចៀក ។
៤. **ឃានបសាទ** កើតនៅក្នុង រន្ធច្រមុះ ។
៥. **ជីវ្ហាបសាទ** កើតនៅត្រង់ អណ្ដាត ។
៦. **កាយបសាទ** កើតនៅក្នុង សព៌ាង្គកាយ ។

៧. **រូបារម្មណ៍**
៨. **សទ្ទារម្មណ៍** } កើតបានក្នុង សព៌ាង្គកាយ ។

៩. **គន្ធារម្មណ៍**
១០. **រសារម្មណ៍**
១១. **ផោដ្ឋព្វារម្មណ៍** } កើតនៅក្នុង សព៌ាង្គកាយ ។

១២. **ឥត្ថីភាវៈ** កើតនៅក្នុង សព៌ាង្គកាយស្ត្រី ។
១៣. **បុរិសភាវៈ** កើតនៅក្នុង សព៌ាង្គកាយបុរស ។
១៤. **ហទយវត្ថុ** កើតនៅត្រង់ បេះដូង ។

| | | | |
|---|---|---|---|
| ១៥. ជីវិតិន្ទ្រិយ | កើតនៅក្នុង | សព៌ាង្គកាយ | ។ |
| ១៦. អាហាររូប | កើតនៅក្នុង | សព៌ាង្គកាយ | ។ |
| ១៧. អាកាសរូប | កើតនៅក្នុង | សព៌ាង្គកាយ | ។ |
| ១៨. កាយវិញ្ញត្តិ | កើតបានក្នុង | សព៌ាង្គកាយ | ។ |
| ១៩. វចីវិញ្ញត្តិ | កើតបានត្រង់ | មាត់ | ។ |
| ២០. វិការរូប ៣ | កើតបានក្នុង | សព៌ាង្គកាយ | ។ |
| ២១. លក្ខណរូប ៤ | កើតនៅក្នុង | សព៌ាង្គកាយ | ។ |

.....................

# រូប ១១ ពួក
# ពួកទី ១

## អំពីមហាភូតរូប ៤

មហាភូតរូប សំដៅដល់ រូបដែលជាធំ បានដល់ បឋវី អាបោ តេជោ វាយោ ។

ក្នុង អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណី សម្ដែងថា ដែលហៅថា **មហាភូតៈ** ដោយហេតុទាំង ៥ នេះ គឺ :

- ព្រោះប្រាកដជារបស់ធំ ១
- ព្រោះដូចជាអ្នកលេងល្បិច ១
- ព្រោះត្រូវថែទាំ រក្សាច្រើន ១
- ព្រោះវិការ (ប្រែប្រួល) ធំ ១
- ព្រោះជារបស់ធំ ដែលមានពិត ១

# ១. បឋវីធាតុ

**បឋវី** មានវចនត្ថៈថា បត្ថីនត្ថេន បឋវី ឈ្មោះថា បឋវី ព្រោះអត្ថថា រឹង ។

ដែលឈ្មោះថា **ធាតុ** ព្រោះអត្ថថា ទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួន ព្រោះអត្ថថា មិនមែនសត្វ មិនមែនជីវៈ ។ **ធាតុ** គឺ **បឋវី** ឈ្មោះថា **បឋវីធាតុ** ។

កាលណាប្រៀបធៀបនឹងមហាភូតរូបដទៃ ៣ ទៀត បឋវីធាតុនេះ មានលក្ខណៈរឹង ។ បើក្នុងវត្ថុណា មានបឋវីច្រើន ជាប្រធានលក្ខណៈរឹងនេះ ក៏ប្រាកដច្បាស់ ។ ដូចជា ឥដ្ឋ ឬ ថ្ម ដី ឈើជាដើម ហើយបើវត្ថុណាមានបឋវីធាតុតិច លក្ខណៈរឹងនោះ ក៏ប្រាកដមិនច្បាស់ កាលបើប៉ះត្រូវ ក៏ដឹងបានថា ជាលក្ខណៈទន់បានសេចក្តីថា ភាពរឹងនោះមានតិច យ៉ាងនោះឯង ទើបធ្វើឲ្យដឹងថាទន់ ។

ដូច្នេះធម្មជាតិដែលមានលក្ខណៈរឹងក្តី ទន់ក្តីក្នុងកាលដែលបានប៉ះត្រូវហើយ ចាត់ជាបឋវីធាតុទាំងអស់ ព្រោះក្រៅអំពីបឋវីធាតុហើយ រូបដទៃទៀតមិនអាចធ្វើឲ្យដឹងរឹង ឬទន់ប្រាកដដល់ការប៉ះត្រូវ

នោះបានឡើយ ។

ដូច្នេះ **បឋវីធាតុ** មានលក្ខណៈ ២ គឺ :

**១. កក្ខឡបឋវី** បឋវីមានភាពរឹង ជាលក្ខណៈ ។

**២. អថទ្ធបឋវី** បឋវីមានភាពទន់ ជាលក្ខណៈ ។

ន័យម្យ៉ាងទៀត **បឋវី** មានវចនត្ថៈថា **សហជាតរូបានិ បថនិ បតិដ្ឋហន្តិ ឯត្ថាតិ បឋវី** ប្រែថា ធម្មជាតិដែលជាទីតាំង ជាទីអាស្រ័យរបស់រូប ដែលកើតរួមទាំងឡាយនោះ ឈ្មោះថា **បឋវី** ប្រៀបបីដូចជាផែនដី ជាទីអាស្រ័យនៃដើមឈើ មនុស្ស សត្វទាំងឡាយ ។

បានសេចក្តីថា កាលណាវៀរចាកបឋវីធាតុហើយ រូបរាងសណ្ឋាន ពណ៌សម្បុរ រហូតដល់សេចក្តីដឹងច្បាស់នូវរូប សម្លេង ក្លិន រស និងផោដ្ឋព្វៈ ទាំងនេះក៏ប្រាកដឡើងមិនបានឡើយ ។

# លក្ខណាទិចតុកៈរបស់បឋវី

- **កក្ខឡត្ត លក្ខណា** មានភាពរឹង ជាលក្ខណៈ ។
- **បតិដ្ឋាន រសា** មានការតាំងនៅមាំ ជាកិច្ច ។

**-សម្បដិច្ឆន្ន បច្ចុប្បដ្ឋានា** មានការទទួលរងទុក នូវរូបដទៃ ៗ ជាផល ។

**-អវសេសធាតុត្តយ បទដ្ឋានា** មានធាតុសល់ ៣ ទៀត ( គឺ អាបោ តេជោ វាយោ ) ជាហេតុជិត ។

# បឋវីធាតុមាន ៤ យ៉ាង

**១ បរមត្ថបឋវី ឬ លក្ខណបឋវី** បានដល់ ធាតុដីដែល មានភាពរឹង ឬភាពទន់ ជាសភាវៈ ។

**២ សសម្ភារបឋវី ឬ សុត្តន្តបឋវី** បានដល់ ធាតុដីដែលមានចំណែកប្រកប មានទាំងខាងក្នុងកាយ និងខាងក្រៅកាយ។

សសម្ភារបឋវីដែលមានខាងក្នុងកាយ ហៅថា **អជ្ឈត្តិក-បឋវី** ដែលនៅខាងក្រៅកាយ ហៅថា **ពាហិរបឋវី** ។

**អជ្ឈត្តិកបឋវី** នេះជា ឧបាទិន្នករូប មាននៅក្នុងរូបរាងកាយរបស់សត្វ ។

ធាតុដីខាងក្នុង អដ្ឋកថាចែកទុកមាន ២០ យ៉ាង ដោយចាត់

ជា ៤ ពួក គឺ :

| ពួកតចបញ្ចកៈ | | ពួកវក្កបញ្ចកៈ | |
|---|---|---|---|
| **១.កេសា** | សក់ | **៦.មំសំ** | សាច់ |
| **២.លោមា** | រោម | **៧.នហារូ** | សរសៃ |
| **៣.នខា** | ក្រចក | **៨.អដ្ឋិ** | ឆ្អឹង |
| **៤.ទន្តា** | ធ្មេញ | **៩.អដ្ឋិមិញ្ជំ** | ខួរក្នុងឆ្អឹង |
| **៥.តចោ** | ស្បែក | **១០.វក្កំ , ទាច** | តម្រងបស្សាវៈ |

| ពួកបប្ផាសបញ្ចកៈ | | ពួកមត្ថលុង្គបញ្ចកៈ | |
|---|---|---|---|
| **១១.ហទយំ** | បេះដូង | **១៦.អន្តំ** | ពោះវៀនធំ |
| **១២.យកនំ** | ថ្លើម | **១៧.អន្តគុណំ** | ពោះវៀនតូច |
| **១៣.កិលោមកំ** | វាវ | **១៨.ឧទរិយំ** | អាហារថ្មី |
| **១៤.បិហកំ** | ក្រពះ | **១៩.ករីសំ** | អាហារចាស់ |
| **១៥.បប្ផាសំ** | សួត | **២០.មត្ថលុង្គំ** | ខួរក្នុងក្បាល |

**ពាហិរបឋវី** ជា **អនុបាទិន្នករូប** មាននៅខាងក្រៅនៃរូប
រាងកាយសត្វ ដូចមានឈ្មោះថា ដែក ស្ពាន់ ទង់ដែង សំរឹទ្ធិ សំណ

កែវមណី មាស ប្រាក់ ជាដើម ។

**៣. កសិណបឋវី ឬ អារម្មណបឋវី** បានដល់ បឋវីកសិណ ឬ ដីដែលជាអារម្មណ៍របស់សមថកម្មដ្ឋាន ។

**៤. សម្មុតិបឋវី ឬ បកតិបឋវី** បានដល់ ធាតុដីដែល សម្មុតិ ហៅថា ដី ផ្ទៃដី ផែនដី ៕

## ២. អាបោធាតុ

**អាបោ** ស័ព្ទនេះមានវចនត្ថៈថា **អាបេតិ សហជាតរូបេសុ ព្យាបេត្វា តិដ្ឋតីតិ អាបោ** ធម្មជាតិណា រមែងផ្សព្វផ្សាយ ជ្រួតជ្រាបទូទៅ ក្នុងរូបដែលកើតជាមួយនឹងខ្លួន ហើយតាំងនៅក្នុងរូបទាំង នោះ ធម្មជាតិនោះ ឈ្មោះថា **អាបោ** ។

ន័យម៉្យាងទៀត **អប្បាយតិ សហជាត រូបានិ សុដ្ឋុ ព្រូហេតិ វឌ្ឍេតីតិ អាបោ** ធម្មជាតិណា ធ្វើឲ្យសហជាតរូបទាំងឡាយចម្រើនឡើង គឺ ពូនផ្តុំ កកណែន ធម្មជាតិនោះ ឈ្មោះថា **អាបោ** ។

ន័យម៉្យាងទៀត **សហជាតរូបានិ អវិប្បកិណ្ណានិ កត្វា ភុសោ បាតិរក្ខតីតិ អាបោ** ធម្មជាតិណា រមែងគ្រប់គ្រងរក្សា សហជាតរូបយ៉ាងហ្មត់ចត់ មិនឲ្យរាត់រាយរតាត់រតាយបាន ធម្មជាតិនោះ ឈ្មោះថា **អាបោ** ។

ដូច្នេះ **អាបោធាតុ** ធាតុទឹក មាន ២ លក្ខណៈ គឺ :

**១. បគ្ឃរណ អាបោ** មានការហូរជ្រាប ជាលក្ខណៈ ។

**២. អាពន្ធន អាបោ** មានការកក ពូនផ្តុំ ជាលក្ខណៈ ។

អាបោធាតុនេះ បើមានចំនួនច្រើនក្នុងវត្ថុណា រមែងធ្វើវត្ថុនោះឲ្យរាវហើយហូរបាន ។ ប៉ុន្តែបើមានចំនួនតិចវិញ ក៏ធ្វើឲ្យវត្ថុនោះទៅជាកក ពូនផ្តុំ ជាដុំ ជាផែន ស្អិតល្អួត ជាប់គ្នា ជារូបរាងសណ្ឋានផ្សេងៗ ដូចជាផែនដី ភ្នំ ទំពាំង ភ្លុក ស្នែង ជាដើម ។

បើក្នុងវត្ថុណា មានអាបោធាតុច្រើនជាងបឋវីធាតុ ក៏ធ្វើឲ្យបឋវីធាតុមានអំណាចតិច ទើបជាហេតុ ឲ្យវត្ថុនោះទន់ ជ្រាយរាវហើយហូរទៅមកបាន ។ ដូច្នេះវត្ថុដែលហូរនោះ គឺ បឋវីធាតុនោះឯងដែលហូរ មិនមែនអាបោធាតុហូរទេ ពីព្រោះអាបោធាតុ ជាធាតុប៉ះត្រូវដឹងតាមកាយមិនបាន គឺ ដឹងបានតាមតែផ្លូវចិត្តប៉ុណ្ណោះ ។

អាបោធាតុដែលមានប្រក្រតីជា **អាពន្ធនលក្ខណៈ** តែកាលណា ត្រូវឱណ្ហតេជោហើយ **បគ្ឃរណលក្ខណៈ** នឹងប្រាកដ គឺហូរទៅបាន បានដល់ អាបោធាតុដែលនៅក្នុងដែក មាស ក្រមួន ជាដើម ។

អាបោធាតុដែលមានប្រក្រតីជា **បគ្ឃរណលក្ខណៈ** តែកាលណាត្រូវសីតតេជោហើយ **អាពន្ធនលក្ខណៈ** អាចនឹងប្រាកដ គឺ កក ពូនផ្តុំបាន បានដល់ អាបោធាតុដែលនៅក្នុងទឹក ក្នុងប្រេង ជាដើម ។

# លក្ខណាទិចតុកៈរបស់អាបោ

- **បគ្ឃរណ លក្ខណា អាពន្ធន លក្ខណា វា** មានការហូរជ្រាប ឬ មានការ កក ពូនផ្តុំ ជាលក្ខណៈ ។
- **ឧបព្យូហាន រសា** មានការចូលទៅពូនផ្តុំប្រមែប្រមុម ជាកិច្ច ។
- **សង្គហ បច្ចុប្បដ្ឋានា** មានការប្រមែប្រមូល កាន់យកទុក ជាផល ។

**-អវសេសធាតុត្តយ បទដ្ឋានា** មានធាតុសល់ ៣ ទៀត ជាហេតុជិត ។

# អាបោធាតុមាន ៤ យ៉ាង

**១. បរមត្ថអាបោ** ឬ **លក្ខណអាបោ** បានដល់ធាតុទឹក ដែលជាបរមត្ថ ។

**២. សសម្ភារអាបោ** ឬ **សុត្តន្តអាបោ** បានដល់ធាតុទឹក ព្រមទាំងគ្រឿងប្រកប ។

អាបោធាតុក្នុងរាងកាយ ហៅថា **អជ្ឈត្តិកអាបោ** , អាបោធាតុដែលនៅខាងក្រៅរាងកាយ ហៅថា **ពាហិរអាបោ** ។

**អជ្ឈត្តិកអាបោ** ជាឧបាទិន្នករូប មាននៅក្នុងរាងកាយរបស់សត្វ នៅក្នុងធាតុវិភង្គចែកទុកមាន ១២ យ៉ាង ដោយចាត់ជា ២ ពួក គឺ :

| **ពួកមេទឆក្កៈ** | | **ពួកមុត្តឆក្កៈ** | |
|---|---|---|---|
| **១. បិត្តំ** | ប្រមាត់ | **៧. អស្សុ** | ទឹកភ្នែក |

| | | | |
|---|---|---|---|
| **២.សេម្ហំ** | ស្លេស្ម | **៨.វសា** | ខ្លាញ់រាវ |
| **៣.បុព្វោ** | ខ្ទុះ | **៩.ខេឡោ** | ទឹកមាត់ |
| **៤.លោហិតំ** | ឈាម | **១០.សិង្ឃាណិកា** | ទឹកសំបោរ |
| **៥.សេទោ** | ញើស | **១១.លសិកា** | ទឹករំអិល |
| **៦.មេទោ** | ខ្លាញ់ខាប់ | **១២.មុត្តំ** | ទឹកមូត្រ |

**ពាហិរអាបោ** បានដល់ ធាតុទឹកខាងក្រៅជា **អនុបា-ទិន្នករូប** ដូចមានឈ្មោះថា ទឹកឫសឈើ ទឹកដើមឈើ ទឹកផ្កាឈើ ទឹកផ្លែ ឈើជាដើម ។

**៣. កសិណអាបោ** ឬ **អារម្មណអាបោ** បានដល់ អាបោកសិណ ឬទឹកដែលជាអារម្មណ៍របស់សមថកម្មដ្ឋានមានទឹកក្នុង បាត្រ ក្នុងពាង ក្នុងផ្តិល ជាដើម ។

**៤. សម្មតិអាបោ** ឬ **បកតិអាបោ** បានដល់ ធាតុទឹក ដែលសម្មតិគ្នាថា ទឹកផឹក ទឹកងូត ជាដើម ៕

# ៣. តេជោធាតុ

**តេជោ** ស័ព្ទនេះមានវចនត្ថៈថា **តេជេតិ បរិបាចេតីតិ តេជោ** ធាតុដែលឈ្មោះថា **តេជោ** ព្រោះអត្ថថា ធ្វើឲ្យក្ដៅ ធ្វើឲ្យទុំ ធ្វើឲ្យឆ្អិន ធ្វើឲ្យជោរ ។

វត្ថុផ្សេងៗជាច្រើន ដូចជាអាហារជាដើម ឆ្អិនបានដោយកំដៅ តែអាហារខ្លះ ក៏អាចឆ្អិនបានដោយភាពត្រជាក់ដូចគ្នា ។ ដូច្នេះ តេជោធាតុ បានដល់ ធាតុភ្លើងមាន ២ លក្ខណៈ គឺ :

**១. ឧណ្ហតេជោ** មានចំហាយក្ដៅ ជាលក្ខណៈ ។
**២. សីតតេជោ** មានចំហាយត្រជាក់ ជាលក្ខណៈ ។

# លក្ខណាទិចតុកៈរបស់តេជោ

- **ឧណ្ហត្ត លក្ខណា** មានការក្ដៅ ជាលក្ខណៈ ។
- **បរិបាចន រសា** មានការដុតដាំ រោលឆ្អើរ ជាកិច្ច ។

- **មន្ទវានុប្បទាន បច្ចុប្បដ្ឋានា** មានការបង្កើន ឲ្យកាន់តែទន់ទៅ ជាផល ។

- **អវសេសធាតុត្តយ បទដ្ឋានា** មានធាតុសល់ ៣ ទៀត ជាហេតុជិត ។

# តេជោធាតុមាន ៤ យ៉ាង

**១. បរមត្ថតេជោ** ឬ **លក្ខណតេជោ** បានដល់ ធាតុភ្លើង ដែលជាបរមត្ថ ។

**២. សសម្ភារតេជោ** ឬ **សុត្តន្តតេជោ** បានដល់ ធាតុភ្លើង ព្រមទាំងគ្រឿងប្រកប ។

តេជោធាតុដែលនៅក្នុងរាងកាយ ហៅថា **អជ្ឈត្តិកតេជោ** បើនៅខាងក្រៅ ហៅថា **ពាហិរតេជោ** ។

**អជ្ឈត្តិកតេជោ** ជាឧបាទិន្នករូបដែលមាននៅក្នុងរាងកាយសត្វ មាន ៥ យ៉ាង គឺ :

**១. ឧស្មាតេជោ** ភ្លើងដែលមានជាប្រចាំនៅក្នុងរាងកាយសត្វ ធ្វើឲ្យរាងកាយកក់ក្តៅ ។

**២. សន្តាប្បនតេជោ** ភ្លើងដែលធ្វើឲ្យក្តៅខ្លាំង ទៅជាគ្រុន ។

**៣. ទហនតេជោ** ភ្លើងមានកំរិតកំដៅខ្ពស់ អាចដុតបំផ្លាញរាងកាយឲ្យវិបរិតទៅបាន ។

**៤. ជិរណតេជោ** ភ្លើងដែលធ្វើឲ្យរាងកាយចាស់ជរា ទ្រុឌទ្រោម សក់ស្កូវ ជាដើម ។

**៥. បាចកតេជោ** ភ្លើងដែលធ្វើនាទីរំលាយអាហារ ។

តេជោធាតុ ២ គឺ **ឧស្មាតេជោ** និង **បាចកតេជោ** តែងតែមានប្រចាំនៅក្នុងរាងកាយរបស់សត្វ ។ តេជោធាតុ ដែលនៅសល់ ៣ ទៀត មិនមាននៅប្រចាំទេ ហើយដែលប្រាកដមានឡើងនោះ ក៏ព្រោះមកអំពី **ឧស្មាតេជោ** មានការវិបរិតទៅជា **សន្តា-ប្បនតេជោ** ឬ **ទហនតេជោ** ឬទៅជា **ជិរណតេជោ** នោះឯង ។

**ពាហិរតេជោ** ជាអនុបាទិន្នករូប ជាធាតុភ្លើងខាងក្រៅមានភ្លើងធ្យូង ភ្លើងអុស ភ្លើងសម្រាមជាដើម ។

**៣.កសិណតេជោ** ឬ **អារម្មណតេជោ** បានដល់តេជោកសិណ ឬ ភ្លើងដែលជាអារម្មណ៍របស់ សមថៈ ។

**៤.សម្មតិតេជោ** ឬ **បកតិតេជោ** បានដល់ ភ្លើងដែលសម្មតិគ្នាថា ភ្លើងអគ្គីសនី ភ្លើងចង្កៀង ជាដើម ។

# ៤. វាយោធាតុ

**វាយោ** ស័ព្ទនេះមានវចនត្ថៈថា **វាយតិ សហជាតធម្មេ អបតមានេ កត្វា វហតីតិ វាយោ** ប្រែថា ធាតុណា អាចនាំទៅនូវរូបដែលកើតព្រមជាមួយខ្លួន ធ្វើឲ្យតាំងនៅស្ងៀម មិនចល័តមិនធ្វើចលនា ព្រោះហេតុនោះ ធាតុនោះ ឈ្មោះថា **វាយោ** បានដល់ ខ្យល់ដែលធ្វើឲ្យតឹង ។

ក្នុងរាងកាយរបស់សត្វ ដូចជាសេចក្ដីដឹងខ្លួនថា តឹង រួយស្រយង់ ស្រពន់ ឈឺពើតចុកចាប់ ឬពេលដែលប្រឹងដៃប្រឹងជើង ឬខណៈដែលភ្នែកសម្លឹងមិនពព្រិច វេលានោះ វាយោធាតុ ក៏ប្រាកដដោយសេចក្ដីព្យាយាមរបស់ខ្លួនឯង ។ ចំពោះនៅខាងក្រៅរាងកាយសត្វវិញ ដូចពោះវៀនកង់ ឬបាល់ដែលសប់ខ្យល់ចូលទៅហើយ ឬទឹកក្នុងតម្រងទឹកបិទវន្ត ឬ ខ្យល់ដែលទ្រទឹក ទឹកទ្រផែនដី ។

ន័យម្យ៉ាងទៀត មានវចនត្ថៈថា **វាយតិ ទេសន្តរុប្បត្តិហេតុភាវេន ភូតសង្ឃាតំ បាបេតីតិ វាយោ** ប្រែថា ធាតុណា

តែងធ្វើឲ្យពពួកមហាភូតរូប ដែលកើតព្រមជាមួយខ្លួន ចល័តទៅទីដទៃ ដោយសេចក្ដី ជាហេតុឲ្យមានចលនា ពីកន្លែងមួយទៅកន្លែងមួយ ដូច្នេះ ធាតុនោះ ឈ្មោះថា **វាយោ** បានដល់ ខ្យល់ដែលធ្វើឲ្យកម្រើកញ័រ ។

ដូចជាសត្វទាំងឡាយធ្វើនូវឥរិយាបថផ្សេងៗបាន ឬពព្រិចភ្នែកបាន បត់ដៃបត់ជើង បន្ទោបង់ឧច្ចារៈបស្សាវៈ ឲ្យអាហារធ្លាក់ទៅក្នុងក្រពះ ប្រសូតបុត្រជាដើម ទាំងនេះដែលប្រព្រឹត្តទៅបាន ក៏ដោយអំណាចធាតុខ្យល់ទាំងអស់ ។ ចំពោះធាតុខ្យល់នៅខាងក្រៅរាងកាយសត្វវិញ ធ្វើឲ្យវត្ថុរបស់របរផ្សេងៗចល័ត ញ័រ កម្រើកចាកពីទីកន្លែងដើមទៅបាន ។

ដូច្នេះ **វាយោធាតុ** បានដល់ ធាតុខ្យល់មាន ២ លក្ខណៈ គឺ :

**១. វិត្ថម្ភនវាយោ** មានភាពតឹង ជាលក្ខណៈ ។

**២. សមុទីរណវាយោ** មានភាពកម្រើកញ័រ ជាលក្ខណៈ ។

# លក្ខណាទិចតុកៈរបស់វាយោ

- **វិត្ថម្ភន លក្ខណា** មានការរឹងតឹង ជាលក្ខណៈ ។

- **សមុទីរណ រសា** មានការញ៉ូរ ជាកិច្ច ។
- **អភិនីហារ បច្ចុប្បដ្ឋានា** មានការនាំចេញ ជាផល ។
- **អវសេសធាតុត្តយ បទដ្ឋានា** មានធាតុសល់ ៣ ទៀត ជាហេតុជិត ។

# វាយោធាតុមាន ៤ យ៉ាង

**១. បរមត្ថវាយោ** ឬ **លក្ខណវាយោ** បានដល់ ធាតុខ្យល់ ដែលមានសភាពជាបរមត្ថ ។

**២. សសម្ភារវាយោ** ឬ **សុត្តន្តវាយោ** បានដល់ ធាតុខ្យល់ ព្រមទាំងគ្រឿងប្រកប មានទាំងខាងក្នុង និង មានទាំងខាងក្រៅ ។ វាយោធាតុដែលនៅក្នុងរាងកាយសត្វ ហៅថា **អជ្ឈត្តិក-វាយោ** និង ដែលនៅខាងក្រៅ ហៅថា **ពាហិរវាយោ** ។

## អជ្ឈត្តិកវាយោ មាន ៦ យ៉ាង គឺ :

**១. ឧទ្ធង្គមវាយោ** ខ្យល់ដែលបក់ឡើងទៅលើ ។

**២. អធោគមវាយោ** ខ្យល់ដែលបក់ចុះមកក្រោម ។

**៣. កុច្ឆិសយវាយោ** ខ្យល់ដែលខាំងនៅក្នុងផ្ទៃពោះ ។

**៤. កោដ្ឋាសយវាយោ** ខ្យល់ដែលខាំងនៅក្នុងក្រពះក្នុងពោះវៀន ។

**៥.អង្គមង្គានុសារិវាយោ** ខ្យល់ដែលរត់តាមអវយវៈ តូចធំពាសពេញសព៌ាង្គកាយ ។

**៦. អស្សាសបស្សាស** ខ្យល់ដកដង្ហើមចេញ ដកដង្ហើមចូល ។

**ពាហិរវាយោ** ខ្យល់ខាងក្រៅ មានខ្យល់ទិសខាងជើង ខ្យល់ទិសខាងត្បូង ខ្យល់ព្យុះ ជាដើម ។

**៣. កសិណវាយោ** ឬ **អារម្មណវាយោ** បានដល់វាយោកសិណ ឬ ខ្យល់ដែលជាអារម្មណ៍របស់សមថកម្មដ្ឋាន ។

**៤. សម្មតិវាយោ** ឬ **បកតិវាយោ** បានដល់ ខ្យល់ដែលបក់ទៅបក់មកជាធម្មតា ។

**មហាភូតរូប**ទាំងឡាយ មានសេចក្តីប្រែប្រួលព្រោះបច្ច័យ ។ ប៉ុន្តែចំពោះលក្ខណៈរបស់ធាតុនោះ ប្រែប្រួលទៅដែរនោះ មិនបានទេ។

បើពោលដោយសណ្ឋាន ក៏ធំសំបើមណាស់ បើពោលដោយសភាវៈ ក៏ប្រាកដច្បាស់ជាងរូបដទៃៗ នានា ៕

# ពួកទី ២
# អំពី បសាទរូប ៥

ពាក្យថា **បសាទរូប** បានដល់ **បសាទ + រូប** ប្រែថា រូបថ្លា ។ ក្នុងបរមត្ថទីបនី សម្ដែងវចនត្ថៈថា **បសីទន្តីតិ បសាទា** បសាទៈ ព្រោះអត្ថថា ថ្លា ។

ក្នុងអភិធម្មត្ថវិភាវិនី សម្ដែងថា **ចតុមហាភូតានំ បសន្នភាវ ហេតុ លក្ខណត្តា បសាទរូបំ** បសាទរូប ព្រោះអាស្រ័យដោយមហាភូតរូប ៤ មានសភាពថ្លា ជាលក្ខណៈ ។

**បសាទរូប ៥** គឺ : **១.** ចក្ខុបសាទរូប
**២.** សោតបសាទរូប **៣.** ឃានបសាទរូប
**៤.** ជីវ្ហាបសាទរូប **៥.** កាយបសាទរូប ។

# ១. ចក្ខុបសាទ

**ចក្ខុបសាទ** មានវចនត្ថៈថា **ចក្ខុវិញ្ញាណដ្ឋិតំ ហុត្វា សមវិសមំ ចក្ខតិ អាចិក្ខន្តំ វិយ ហោតីតិ ចក្ខុ** រូបណាជាទីតាំងនៃចក្ខុវិញ្ញាណ និងមានសភាពនៅដូចជាប្រាប់ឲ្យចក្ខុវិញ្ញាណដឹងក្នុង អារម្មណ៍ថា អារម្មណ៍ល្អ អារម្មណ៍មិនល្អ ដូច្នេះ រូបនោះឈ្មោះថា **ចក្ខុ** បានដល់ **ចក្ខុបសាទ** ។

ដួងភ្នែកទាំងមូល មិនឈ្មោះថា ចក្ខុបសាទទេ ត្រង់ដែលឈ្មោះថា ចក្ខុបសាទនោះ ជាធម្មជាតិរូបមួយប្រភេទ ដែលកើតពីកម្ម ជាតួប្រស្រីដែលមានសភាពថ្លា ដូចជាកញ្ចក់ឆ្លុះ ជាគ្រឿងទទួលនូវរូបារម្មណ៍ តាំងនៅត្រង់កណ្តាលកែវភ្នែកខ្មៅ មានក្រពេញដូចជាប៉ុយសំឡី ៧ ជាន់ ជ្រាបផ្តិតដោយប្រេង ទំហំប្រមាណប៉ុនក្បាលចៃ ។

**ចក្ខុបសាទរូប**នេះ កាលបានទទួលនូវការទំនុកបម្រុង ផ្ទុងផ្តើម (ឧបការៈ)ពីធាតុ ៤ ផង ឧបត្ថម្ភគាំទ្រដោយ ឧតុ ចិត្ត និងអាហារផង អនុបាលចិញ្ចឹមរក្សាដោយអាយុ គឺជីវិតិន្ទ្រិយ៍ផង ហើយនិងហែហាមកំដរដោយគោចររូប មានវណ្ណៈ គន្ធៈជាដើមផង

ក៏មាននាទីធ្វើឲ្យសម្រេចកិច្ច ២ យ៉ាង គឺ ជាវត្ថុ ដែលជាទីតាំងនៃចក្ខុវិញ្ញាណ ១ និងជាទ្វារ ដែលជាទីកើតនូវចក្ខុទ្វារវិថីចិត្ត ១ ។

# លក្ខណាទិចតុកៈរបស់ចក្ខុបសាទ

| | |
|---|---|
| -រូបាភិឃាតារហ ភូតប្បសាទលក្ខណំ | មានសភាពថ្លា នៃមហាភូតរូប ដែលសមគួរប៉ះខ្ទប់នឹងរូបារម្មណ៍ ជាលក្ខណៈ ។ |
| -រូបេសុ អាវិញ្ឆន រសំ | មានការទាញ ស្រូបយកនូវរូបារម្មណ៍ ជាកិច្ច ។ |
| -ចក្ខុវិញ្ញាណស្ស អាធារភាវបច្ចុប្បដ្ឋានំ | មានការជាទីរងទ្រ ជាទីអាស្រ័យនៅរបស់ចក្ខុវិញ្ញាណ ជាផល។ |
| -ទដ្ឋុកាមតា និទាន កម្មជភូតបទដ្ឋានំ | មានមហាភូតរូប ដែលកើតពីកម្ម ដោយសភាវៈ ជាអ្នកចង់ប្រាថ្នាដើម្បី នឹងឃើញជាហេតុ ជាហេតុជិត ។ |

# ចក្ខុមាន ២ ប្រភេទ

**១. មំសចក្ខុ** បានដល់ ភ្នែកសាច់ មាន ២ យ៉ាង ។
**២. បញ្ញាចក្ខុ** បានដល់ ភ្នែក គឺ បញ្ញា មាន ៥ យ៉ាង ។

**មំសចក្ខុ ២** យ៉ាងនោះ គឺ បសាទចក្ខុ គឺ ចក្ខុបសាទនោះ ១ និង សសម្ភារចក្ខុ បានដល់ ដុំសាច់នៅក្នុងរណ្តៅភ្នែកនោះ ១ ។

**-ពោលដោយសង្ខេប** សសម្ភារចក្ខុ នេះ មានបំណែកប្រកបដោយរូប ១៤ គឺ មហាភូតរូប ៤ វណ្ណៈ គន្ធៈ រសៈ ឱជា សម្ភវៈ(ការកើត) សណ្ឋាន(ការតាំងនៅ) ជីវិត ភាវៈ កាយបសាទ និង ចក្ខុបសាទ ។

**-បើពោលដោយពិស្តារ** មានបំណែកប្រកបដោយរូប ៤៤ គឺ រូប ១០ គឺធាតុ៤ វណ្ណៈ គន្ធៈ រសៈ ឱជា សម្ភវៈ និងសណ្ឋាន ដែលអាស្រ័យធាតុ ៤ កើតឡើង ទាំងនេះ កើតពីសមុដ្ឋាន ៤ ទើប មាន ៤០(១០×៤) និងរូប ៤ ទៀត គឺ ជីវិត ភាវៈ កាយបសាទ និង ចក្ខុបសាទ ដែលកើតដោយមានកម្មជាសមុដ្ឋានតែម្យ៉ាង ។

**បញ្ញាចក្ខុ ៥** យ៉ាងនោះ គឺ ពុទ្ធចក្ខុ ១ សមន្តចក្ខុ ១ ញាណចក្ខុ ១ ទិព្វចក្ខុ ១ និងធម្មចក្ខុ ១ ។ បណ្ដាចក្ខុទាំង ៥ នេះ គឺ :

**-ពុទ្ធចក្ខុ** បានដល់ អាសយានុសយញ្ញាណ និង ឥន្ទ្រិយបរោបរិយត្តញ្ញាណ ( គឺមហាកិរិយាញាណសម្បយុត្តចិត្ត ៤ ដួង ) ជាចក្ខុរបស់ព្រះពុទ្ធ ប្រមើលមើលលោក ឃើញពពួកសត្វដែលមានកិលេស ដូចជាធូលីតិច ឬ ច្រើនក្នុងភ្នែក ។ ល ។

**-សមន្តចក្ខុ** បានដល់ សព្វញ្ញុតញ្ញាណ បញ្ញាដែលត្រាស់ដឹងធម៌ទាំងពួង ទាំងបញ្ញត្តិ និង ទាំងបរមត្ថ ( គឺ មហាកិរិយាញាណសម្បយុត្តចិត្ត ) ។

**-ញាណចក្ខុ** បានដល់ ភ្នែក គឺ បញ្ញា បានកើតឡើងឃើញធម៌ ក្នុងអរហត្តមគ្គចិត្ត ។

**-ទិព្វចក្ខុ** បានដល់ ភ្នែកដ៏បរិសុទ្ធ( គឺអភិញ្ញាចិត្ត ២ ដួង )។

**-ធម្មចក្ខុ** បានដល់ មគ្គ ៣ ខាងក្រោម ជាភ្នែកប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើង ។

# ២. សោតបសាទរូប

សោតបសាទ មានវចនត្ថៈថា **សោតវិញ្ញាណដ្ឋិតំ ហុត្វា សទ្ទំ សុណាតីតិ សោតំ** រូបណា ជាទីតាំងនៃសោតវិញ្ញាណចិត្ត និងតែងស្ដាប់នូវសម្លេង ដូច្នេះរូបនោះ ឈ្មោះថា **សោតះ** បាន ដល់ សោតបសាទ(ន័យអម) ។

ន័យម្យ៉ាងទៀត ដោយន័យត្រង់ **សទ្ទំ សុណន្តិ ឯតេ-នាតិ វា សទ្ទេ សុយ្យន្តិ ឯតេនាតិ សោតំ** ចិត្ត-ចេតសិក តែងឮសម្លេងដោយរូបនោះ ដូច្នេះ រូបដែលជាហេតុឲ្យចិត្តចេតសិក ឮនោះ ឈ្មោះថា **សោតះ** ឬសត្វទាំងឡាយតែងឮសម្លេងដោយ រូបនោះ ដូច្នេះរូប ដែលជាហេតុឲ្យសត្វទាំងឡាយឮនោះ ឈ្មោះថា **សោតះ** បានដល់ សោតបសាទ ។

**សោតបសាទរូបនេះ** តាំងនៅក្នុងប្រទេសដែលមានសណ្ឋាន ដូចវង់ចិញ្ចៀន មានរោមពណ៌ក្រហម ខ្ចីល្អិត ដុះក្នុងរន្ធនៃសសម្ភារ-សោតះ ដែលធាតុ ៤ បានទំនុកបម្រុងផ្គងផ្ដើមហើយ ដែលឧតុ ចិត្ត និង អាហារឧបត្ថម្ភគាំទ្រ ដែលអាយុគឺជីវិតរូប អនុបាលបីបាច់

រក្សា ដែលគោចររូបទាំងឡាយ មានវណ្ណៈជាដើមកំដរហែហម ក៏ធ្វើឲ្យសម្រេច កិច្ច ២ យ៉ាង គឺ ជាវត្ថុ ដែលជាទីតាំងនៃសោតវិញ្ញាណ ១ និងជាទ្វារ ដែលជាទីកើតនូវសោតទ្វារវិថីចិត្ត ១ ។

# លក្ខណាទិចតុកៈរបស់សោតបសាទ

| | |
|---|---|
| -សទ្ទាភិឃាតារហ ភូតប្បសាទលក្ខណំ | មានសភាពថ្លា នៃមហាភូតរូប ដែលសមគួរប៉ះខ្ទប់នឹងសទ្ទារម្មណ៍ ជាលក្ខណៈ ។ |
| -សទ្ទេសុ អាវិញ្ឆន រសំ | មានការទាញ ស្រូបយក នូវសទ្ទារម្មណ៍ ជាកិច្ច ។ |
| -សោតវិញ្ញាណស្ស អាធារភាវ បច្ចុប្បដ្ឋានំ | មានការជាទីរងទ្រ ជាទីអាស្រ័យនៅនៃសោតវិញ្ញាណ ជាផល។ |
| -សោតុកាមតា និទានកម្មជ្ជភូត បទដ្ឋានំ | មានមហាភូតរូបដែលកើតពីកម្ម ដោយភាវៈជាអ្នកចង់ប្រាថ្នា ដើម្បីនឹងឮសម្លេងជាហេតុ ជាហេតុជិត ។ |

# សោតៈមាន ៣ យ៉ាង

**១.ទិព្វសោតៈ** បានដល់ សោតញាណ ឬ ទិព្វសោត គឺ អភិញ្ញាចិត្ត ២ ដួង ។

**២.តណ្ហាសោតៈ** បានដល់ សោតៈ គឺក្រសែតណ្ហា ក្នុងលោក។

**៣.មំសសោតៈ** បានដល់ បសាទសោតៈ គឺ សោតបសាទ និង សសម្ភារសោតៈ ដែលជាត្រចៀក ព្រម ដោយ គ្រឿងប្រកប ។

# ៣. ឃានបសាទរូប

ឃានបសាទរូប សម្ដែងដោយបរិយាយន័យ(ន័យអម) មានវចនត្ថៈថា **ឃាយតីតិ ឃានំ** រូបណា តែងធុំក្លិន រូបនោះឈ្មោះថា **ឃានៈ** បានដល់ ឃានបសាទ ។ សេចក្ដីពិត ឃានវិញ្ញាណកើតឡើងទេ ជាអ្នកធុំ និងដឹងនូវក្លិនបាន ប៉ុន្តែការដឹង ការធុំក្លិនរបស់ឃានវិញ្ញាណនេះ តាំងនៅក្នុងឃានបសាទ ទើបលើកយកឃានបសាទមកសម្ដែង ដូចពាក្យនិយាយគ្នាថា “ វត្តនេះកាន់វិន័យល្អ ” ដូច្នោះ ។

ន័យម៉្យាងទៀត សម្តែងដោយនិប្បរិយាយន័យ(ន័យត្រង់) មានវចនត្ថៈថា **ឃាយន្តិ ឯតេនាតិ ឃានំ វា ឃាយីយន្តិ ឯតេនាតិ ឃានំ** ប្រែថា ចិត្តនិងចេតសិក រមែងធុំនូវក្លិនដោយរូបនេះ ដូច្នេះ រូបដែលជាហេតុនៃការធុំក្លិន របស់ចិត្តនិងចេតសិកនេះ ទើបឈ្មោះថា **ឃានះ** ឬសត្វទាំងឡាយ រមែងធុំនូវក្លិនដោយរូបនេះ ដូច្នេះរូបដែលជា ហេតុនៃការធុំក្លិន របស់សត្វទាំងឡាយនេះ ទើបឈ្មោះថា **ឃានះ** បាន ដល់ ឃានបសាទ ។

**មំសឃានះ** មាន ២ យ៉ាង គឺ បសាទឃានះ និង សសម្ភារឃានះ ។

**បសាទឃានះ** គឺ ឃានបសាទនេះ ជាធម្មជាតិរូបមួយបែប ដែលកើតពីកម្ម មានសភាពថ្លាបរិសុទ្ធ ជាគ្រឿងទទួលនូវក្លិនផ្សេងៗ មានសណ្ឋានដូចជើងពពែ តាំងនៅក្នុងខ្ទង់ច្រមុះ គឺ ក្នុងរន្ធនៃ **សសម្ភារឃានះ**(ច្រមុះ) ។

អាស្រ័យដោយការបានទទួលនូវឧបការពី ធាតុ ៤ ផង បាននូវការឧបត្ថម្ភ ដោយឧតុ ចិត្ត អាហារផង បាននូវការអនុបាលដោយអាយុផង និងបាននូវការហែហមកំដរដោយគោចររូបផង **ឃានបសាទរូប** ក៏មាននាទីឲ្យសម្រេចកិច្ច ២ យ៉ាង គឺជា

វត្ថុ ដែលជាទីតាំងនៃឃានវិញ្ញាណចិត្ត ១ និងជាទ្វារ ដែលជាទីកើតនៃឃានទ្វារវិថីចិត្ត ១ ។

# លក្ខណាទិចតុកៈរបស់ឃានបសាទ

| | |
|---|---|
| **-គន្ធាភិឃាតារហ ភូតប្បសាទលក្ខណំ** | មានសភាពថ្លា នៃមហាភូតរូប ដែលសមគួរប៉ះខ្ទប់នឹងក្លិន ជាលក្ខណៈ ។ |
| **-គន្ធេសុ អាវិញ្ឆន រសំ** | មានការទាញ-ស្រូបយក នូវគន្ធារម្មណ៍ ជាកិច្ច ។ |
| **-ឃានវិញ្ញាណស្ស អាធារភាវ បច្ចុប្បដ្ឋានំ** | មានការជាទីរងទ្រ ជាទីអាស្រ័យនៅនៃឃានវិញ្ញាណ ជាផល ។ |
| **- ឃាយិតុកាមតា និទានកម្មជ្ជភូត បទដ្ឋានំ** | មានមហាភូតរូប ដែលកើតពីកម្ម ដោយភាវៈជាអ្នកចង់ប្រាថ្នាដើម្បីនឹងធុំក្លិនជាហេតុ ជាហេតុជិត ។ |

# ៤. ជិវ្ហាបសាទរូប

ជិវ្ហាបសាទរូប មានវចនត្ថៈថា **ជីវិតំ អវ្ហាយតីតិ ជិវ្ហា** រូបណា មានសភាពហាក់ដូចជា ហៅនូវរសដែលនាំមកនូវជីវិត ដូច្នេះ រូបនោះ ឈ្មោះថា **ជិវ្ហា** ។

ន័យម្យ៉ាងទៀត មានវចនត្ថៈថា **ជីវិតំ អវ្ហាយន្តិ ឯតេ-នាតិ ជិវ្ហា** ប្រែថា ចិត្ត និង ចេតសិក តែងហៅមកនូវរស ដោយរូបនេះ ដូច្នេះ រូបនេះទើបឈ្មោះថា **ជិវ្ហា** បានដល់ **ជិវ្ហាបសាទរូប** ។

**មំសជិវ្ហា** មាន ២ យ៉ាង គឺ បសាទជិវ្ហា និងសសម្ភារជិវ្ហា។

**បសាទជិវ្ហា** គឺ **ជិវ្ហាបសាទ** នេះជាធម្មជាតិរូបមួយបែប ដែលកើតពីកម្ម មានសភាពថ្លាបរិសុទ្ធ ជាគ្រឿងទទួលនូវរសផ្សេងៗ មានសណ្ឋានដូចចុងស្រទាប់ផ្កាឧប្បល តាំងនៅកណ្តាលនៃ **សស-ម្ភារជិវ្ហា** (អណ្តាត) ។

អាស្រ័យដោយការបានទទួលនូវឧបការពីធាតុ ៤ ផង បាន

នូវការឧបត្ថម្ភដោយ ឧតុ ចិត្ត អាហារផង បានទូវការអនុបាល ដោយអាយុផង និង បានទូវការហែហមកំដរ ដោយគោចររូបផង ជីវ្ហាបសាទរូប ក៏មាននាទីសម្រេចកិច្ច ២ យ៉ាង គឺ ជាវត្ថុ ដែល ជាទីតាំងនៃជីវ្ហាវិញ្ញាណចិត្ត ១ និងជាទ្វារ ដែលជាទីកើតនៃជីវ្ហា-ទ្វារវិថីចិត្ត ១ ។

# លក្ខណាទិចតុកៈរបស់ជីវ្ហាបសាទ

| | |
|---|---|
| **-រសាភិឃាតារហ ភូតប្បសាទលក្ខណំ** | មានសភាព ថ្លានៃមហាភូតរូប ដែលសមគួរប៉ះខ្ទប់នឹងរស ជាលក្ខណៈ ។ |
| **-សេសុ អាវិញ្ឆន រសំ** | មានការទាញ-ស្រូបយក នូវរសារម្មណ៍ ជាកិច្ច ។ |
| **-ជីវ្ហាវិញ្ញាណស្ស អាធារភាវ បច្ចុប្បដ្ឋានំ** | មានការជាទីរងទ្រ ជាទីអាស្រ័យនៅរបស់ជីវ្ហាវិញ្ញាណ ជាផល។ |
| **-សាយិតុកាមតា និទាន** | មានមហាភូតរូប ដែលកើតពី |

**កម្មជ្ជភូត បទដ្ឋានំ** កម្ម ដោយភាវៈជាអ្នកចង់ប្រាថ្នា ដើម្បីនឹងលិទ្ធភ្លក្សនូវរសជា ហេតុ ជាហេតុជិត ។

# ៥. កាយបសាទរូប

កាយបសាទ មានវចនត្ថៈថា **កុច្ឆិតានំ កេសាទីនំ បាបធម្មានញ្ច អាយោតិ កាយោ** ប្រែថា រូបណា ជាទីប្រជុំនៃចំណែកផ្សេងៗ មានសក់ជាដើមដែលគួរខ្ពើម និងជាទីប្រជុំនៃអកុសលធម៌ ដូច្នេះរូបនោះ ឈ្មោះថា **កាយៈ** បានដល់ កាយទាំងអស់ គឺ រូបកាយ និង នាមកាយ ។

ចំពោះកាយបសាទ ឈ្មោះថា **កាយៈ** នោះ ជាការសម្តែងដោយន័យអម គឺថា យក **កាយៈ** ដែលជាឈ្មោះរបស់កាយទាំងអស់ មកតាំងក្នុងកាយបសាទ ដែលជាចំណែកមួយនៃរាងកាយនោះ ឬជាទីអាស្រ័យកើត ។

# កាយ ៤ យ៉ាង

១. **បសាទកាយ** គឺ កាយបសាទរូប ។

២. **រូបកាយ** គឺ រូបធម៌ទាំងអស់ ។

៣. **នាមកាយ** គឺ ចិត្ត និង ចេតសិក ។

៤. **បញ្ញត្តិកាយ** គឺ សមូហបញ្ញត្តិ ។

ក្នុងទីនេះ កាយបសាទរូប ប្រៀបបានទៅនឹងសរសៃអំបោះជ័រ ដែលមានសភាពថ្លាផ្សាយទៅពាសពេញសរីរៈ ។ **រូបកាយ** និង **នាមកាយ** មានអត្ថច្បាស់លាស់ហើយ ចំណែក សមូហបញ្ញត្តិ នោះ បានដល់ បញ្ញត្តិធម៌ដែលរួមគ្នា ដូចពាក្យថា ហ្វូងដំរី ហ្វូងគោ កងទ័ព កងរថ ជាដើម ។

# កាយ ៤ យ៉ាងទៀត

ក្នុងបរមត្ថទីបនី (ខុ.ឥតិវុត្តកៈ) ពោលថា :

១. **ចោបនកាយ** បានដល់ ចលនានៃកាយ ឬ ការធ្វើឲ្យកម្រើកនៃកាយ ។

**២. ករជកាយ** បានដល់ កាយដែលកើតអំពីធូលីក្នុងទឹក ។

**៣. សមូហកាយ** បានដល់ កាយដែលប្រជុំគ្នា ។

**៤. បសាទកាយ** បានដល់ កាយបសាទ ។

បណ្ដាកាយទាំង ៤ នេះ ការសង្រួមកាយ និងវាចា ដែលធ្វើឲ្យមានចលនា ឬធ្វើឲ្យកម្រើក ឈ្មោះថា **ចោបនកាយ** ។ កាយដែលកើតពីធូលីក្នុងទឹក ឈ្មោះថា **ករជកាយ** ។ សមូហ-កាយ បានដល់ វិញ្ញាណកាយ ៦ មានចក្ខុវិញ្ញាណជាដើម និងផស្សកាយ ៦ មានចក្ខុសម្ផស្សជាដើម ។ ការពាល់ត្រូវនូវផោដ្ឋព្វៈបានដោយកាយ ឈ្មោះថា **កាយបសាទ** គឺ កាយបសាទរូបនោះឯង ។

កាយបសាទរូបនេះ ជាធម្មជាតិរូបម្យ៉ាង ដែលកើតពីកម្មមានសភាពថ្លាបរិសុទ្ធ ជាគ្រឿងទទួលនូវផោដ្ឋព្វៈផ្សេងៗ មានរឹង ទន់ក្ដៅ ត្រជាក់ តឹង ញ័រ ។ កាយបសាទនេះ កើតមាននៅក្នុងរាងកាយទូទៅ វៀរលែងតែ សក់ រោម ក្រចក ធ្មេញ ដែលផុះផុតពីកាយ ស្បែកដែលក្រាស់ៗ និងទីតាំងនៃតេជោធាតុ ដែលកើតពីកម្ម (បាចកតេជោ) ដែលជាទីផ្ទុកនៃអាហារថ្មីក្រោមពោះវៀនធំ ហើយក៏

មិនលាយឡំនឹងបសាទដទៃៗដែរ ព្រោះមានលក្ខណៈផ្សេងៗគ្នា កាលបានទទួលនូវឧបការៈ នូវការឧបត្ថម្ភ ការអនុបាល ការហែហមកំដរជាដើម មានប្រការដូចបានពោលរួចហើយ ទើបមាននាទីឲ្យសម្រេចកិច្ច ជាវត្ថុ និងជាទ្វារ តាំងនៅគួរដល់វិថីចិត្តទាំងឡាយ មានកាយវិញ្ញាណ ជាដើម ។

# លក្ខណាទិចតុកៈរបស់កាយបសាទ

**-ផោដ្ឋព្វាភិឃាតារហ ភូតប្បសាទ លក្ខណំ** មានសភាពថា នៃមហាភូតរូប ដែលសមគួរប៉ះខ្ទប់នឹងផោដ្ឋព្វៈ ជាលក្ខណៈ ។

**-ផោដ្ឋព្វេសុ អាវិញ្ឆន រសំ** មានការទាញ-ស្រូប យកនូវផោដ្ឋព្វារម្មណ៍ ជាកិច្ច ។

**-កាយវិញ្ញាណស្ស អាធារភាវ បច្ចុប្បដ្ឋានំ** មានការជាទីរងទ្រ ជាទីអាស្រ័យនៅនៃកាយវិញ្ញាណ ជាផល ។

**-ផុសិតុកាមតា និទាន** មានមហាភូតរូប ដែលកើតពី

**កម្មជភូត បទដ្ឋានំ**　　កម្ម ដោយភាវៈជាអ្នកចង់ប្រាថ្នា ដើម្បីនឹងប៉ះពាល់ត្រូវ ជាហេតុ ជាហេតុជិត ។

# ពួកទី ៣
# អំពីវិសយរូប ឬ គោចររូប ៧

វិសយរូប ឬហៅថា គោចររូប បានដល់ រូបដែលជាអារម្មណ៍របស់ចិត្ត និងចេតសិកដែលកើតតាមទ្វារភ្នែក ទ្វារត្រចៀក ទ្វារច្រមុះ ទ្វារអណ្តាត និង ទ្វារកាយ ។

**វិសយរូប ៤** គឺ វណ្ណៈ(រូប) សទ្ទៈ(សម្លេង) គន្ធៈ(ក្លិន) រសៈ(រស) ចំណែកផោដ្ឋព្វៈ គឺ រូបដែលប៉ះខ្ទប់នឹងកាយ បានដល់ បឋវីផោដ្ឋព្វៈ តេជោផោដ្ឋព្វៈ និង វាយោផោដ្ឋព្វៈ រួម ៣ រូប ទៀតត្រូវជា **វិសយរូប ៧** ។

**គោចររូប** មានវចនត្ថៈថា **គោចររូបន្នាម បញ្ចវិញ្ញាណវិសយភាវតោ** ប្រែថា រូប (ពណ៌) ជាដើមឈ្មោះថា **គោចររូប** ព្រោះជាអារម្មណ៍របស់បញ្ចវិញ្ញាណ ។ **គាវោ ឥន្ទ្រិយានិ ចរន្តិ**

**ឯត្ថាតិ គោចរំ** ប្រែថា ឈ្មោះថា **គោចរ** ព្រោះអត្ថថា ជាទីត្រាច់ទៅនៃគោ គឺ ឥន្ទ្រីយ៍ទាំងឡាយ ។

ក្នុងអភិធម្មត្ថវិភាវិនី សម្តែងថា **គោចររូប**ទាំង ៥ នេះ មានសភាពជាអារម្មណ៍នៃវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម ជាលក្ខណៈ ឬថារូបទាំងនេះ មានការប៉ះខ្ទប់នឹងបសាទ ៥ មានចក្ខុបសាទជាដើម ជាលក្ខណៈ ។

# ១. រូបារម្មណ៍

រូបារម្មណ៍(ពណ៌) មានវចនត្ថៈថា **រូបយតិ ហទយង្គតភាវំ បកាសេតីតិ រូបំ** ប្រែថា រូបណា តែងប្រកាសសម្តែង ដល់នូវសេចក្តីដឹងរបស់ចិត្ត ឲ្យប្រាកដ ដូច្នេះរូបនោះ ឈ្មោះថា **រូបារម្មណ៍** ។

ឬថា **រូបយតិ ទព្វំ បកាសេតីតិ រូបំ** រូបណាតែងប្រកាសសម្តែង នូវវត្ថុ របស់របរ រូបរាង សណ្ឋាន ឲ្យប្រាកដ ដូច្នោះរូបនោះ ឈ្មោះថា **រូបារម្មណ៍** ។ ដូចជាការដឹងបានថា អ្នកនោះកំពុងសប្បាយ ចិត្ត កំពុងខ្មាស ឬដឹងបាន នូវវត្ថុផ្សេងៗ នូវរូបរាងសណ្ឋានរបស់ មានជីវិតក្តី ឥតមានជីវិតក្តី អ្នកដទៃដឹងបាន

ក៏ព្រោះរូបារម្មណ៍នោះឯង ជាអ្នកសម្តែងធ្វើ ឲ្យប្រាកដ ។

# លក្ខណាទិចតុកៈរបស់រូប

**-ចក្ខុបដិហនន លក្ខណំ** មានការប៉ះខ្ទប់នឹង ចក្ខុបសាទ ជាលក្ខណៈ ។

**-ចក្ខុវិញ្ញាណស្ស វិសយភាវ រសំ** មានសភាពជា អារម្មណ៍របស់ចក្ខុវិញ្ញាណ ជាកិច្ច ។

**-តស្សេវ គោចរ បច្ចុប្បដ្ឋានំ** មានភាពជាគោចរ របស់ចក្ខុ-វិញ្ញាណនោះឯង ជាផល ។

**-ចតុមហាភូត បទដ្ឋានំ** មានមហាភូតរូប ៤ ដែលកើតពីសមុដ្ឋាន ៤ ជាហេតុជិត ។

# ២. សទ្ទារម្មណ៍

សទ្ទារម្មណ៍ (សម្លេង) បានដល់ សម្លេងដែលជាអារម្មណ៍របស់សោតវិញ្ញាណ ។

សទ្ទារម្មណ៍ មានវចនត្ថៈថា **សទ្ទីយតិ ឧច្ចារីយតីតិ សទ្ទោ** ប្រែថា រូបណា ដែលគេបញ្ចេញមកបាន គឺអាចឲ្យឮ ដូច្នេះ រូបនោះ ឈ្មោះថា **សទ្ទះ** បានដល់ សម្លេងដែលកើតពីចិត្ត ។

ម្យ៉ាងទៀត មានវចនត្ថៈថា **សប្បតិ សោតវិញ្ញេយ្យ-ភាវំ គច្ឆតីតិ សទ្ទោ** ប្រែថា រូបណា តែងដល់នូវសភាពដែលធ្វើឲ្យសោតវិញ្ញាណដឹងបាន ដូច្នេះរូបនោះ ឈ្មោះថា **សទ្ទះ** បានដល់ សម្លេងដែលកើតពីចិត្ត ឬឧតុ សំដៅយកសម្លេងរបស់សភាវៈដែលមានជីវិត និងទាំងមិនមានជីវិតទាំងអស់ ។

# លក្ខណាទិចតុកៈរបស់សទ្ទះ

| | |
|---|---|
| **-សោតបដិហនន លក្ខណំ** | មានការប៉ះខ្ទប់នឹងសោតបសាទជាលក្ខណៈ ។ |
| **-សោតវិញ្ញាណស្ស វិសយភាវ រសំ** | មានសភាពជា អារម្មណ៍របស់សោតវិញ្ញាណ ជាកិច្ច ។ |
| **-តស្សេវ គោចរ បច្ចុប្បដ្ឋានំ** | មានសភាពជាគោចរ របស់ |

-ចតុមហាភូត បទដ្ឋានំ

សោតវិញ្ញាណនោះឯង ជាផល។ មានមហាភូតរូប ៤ ដែលកើតពីសមុដ្ឋាន ២ គឺ ចិត្ត និងឧតុ ជាហេតុជិត ។

# ៣. គន្ធារម្មណ៍

គន្ធារម្មណ៍ (ក្លិន) បានដល់ ក្លិន ដែលជាអារម្មណ៍របស់ឃានវិញ្ញាណ ។

គន្ធារម្មណ៍ មានវចនត្ថៈថា **គន្ធយតិ អត្តនោ វត្ថុំ សូចេតីតិ គន្ធោ** ប្រែថា រូបណា រមែងប្រកាស សម្តែង ប្រាប់ឲ្យវត្ថុទីអាស្រ័យរបស់ខ្លួន ប្រាកដ ដូច្នេះរូបនោះ ឈ្មោះថា **គន្ធៈ** ។

ដូចជា ផ្កាក្រអូប ឬទឹកអប់ផ្សេងៗ របស់ទាំងនេះនៅទីណាក៏ដោយ កាលបើក្លិនមានឱកាសភាយចេញមកហើយ ក៏រមែងធ្វើឲ្យគេទាំងឡាយដឹងបានភ្លាមថា នេះជាក្លិនផ្កា នេះជាក្លិនទឹកអប់ និងដឹងថាផ្កាឬទឹកអប់នោះៗនៅត្រង់ទីនេះ ឬនៅត្រង់ទីនោះ ហាក់ដូចជាក្លិននេះកាលបានរួមគ្នា និងវាយោធាតុហើយ ក៏ទៅផ្សាយដំណឹងឲ្យគេទាំង-ឡាយដឹង ។ ដូច្នេះហើយ ក្លិននេះទើបមានសភាព ដូចជាបញ្ជាក់ឲ្យ

ដឹងថា វត្ថុរបស់របរនោះៗ នៅត្រង់នេះ យ៉ាងនេះឯង ។

# គន្ធៈ ៤ យ៉ាង

**១.សីលគន្ធៈ** គឺ សម្មាវាចា សម្មាកម្មន្ត សម្មាអាជីវៈ ។
**២.សមាធិគន្ធៈ** គឺ សម្មាវាយាម សម្មាសតិ សម្មាសមាធិ ។
**៣.បញ្ញាគន្ធៈ** គឺ សម្មាទិដ្ឋិ សម្មាសង្កប្បៈ ។
**៤.អាយតនគន្ធៈ** គឺ គន្ធារម្មណ៍ ។

# លក្ខណាទិចតុកៈរបស់គន្ធៈ

**-ឃានបដិហនន លក្ខណំ** មានការប៉ះខ្ទប់នឹង ឃានបសាទជាលក្ខណៈ ។

**-ឃានវិញ្ញាណស្ស វិសយភាវរសំ** មានសភាពជា អារម្មណ៍របស់ឃានវិញ្ញាណ ជាកិច្ច ។

**-តស្សេវ គោចរ បច្ចុប្បដ្ឋានំ** មានសភាពជា គោចររបស់ឃានវិញ្ញាណនោះឯងជាផល ។

**-ចតុមហាភូត បទដ្ឋានំ** មានមហាភូតរូប ៤ ដែលកើតពីសមុដ្ឋាន ៤ ជាហេតុជិត ។

# ៤. រសារម្មណ៍

រសារម្មណ៍ (រស) បានដល់ រស ដែលជាអារម្មណ៍របស់ជីវ្ហាវិញ្ញាណ ។

**រសារម្មណ៍** មានវចនត្ថៈថា **រសីយតិ អស្សាទីយតីតិ រសោ** ប្រែថា រូបណាជីវ្ហាវិញ្ញាណតែងត្រេកអរ ពេញចិត្ត ដូច្នេះរូបដែលជីវ្ហាវិញ្ញាណពេញចិត្តនោះ ឈ្មោះថា **រស** ។

អធិប្បាយថា រសារម្មណ៍ បានដល់ រសផ្សេងៗនោះ ទោះជារសល្អក្តី មិនល្អក្តី ក៏រមែងជាទីពេញចិត្តសម្រាប់ជីវ្ហាវិញ្ញាណទាំងអស់ ។ ឯពាក្យថា ពេញចិត្ត ក្នុងទីនេះ សំដៅដល់ការដឹងរសនោះឯង មិនសំដៅយកបុគ្គលទេ ព្រោះថា បុគ្គលនោះតែងពេញចិត្តក្នុងរសដែលល្អៗប៉ុណ្ណោះ ។

# រសមាន ៤ យ៉ាង

**១. ធម្មរស** បានដល់ មគ្គចិត្តុប្បាទ ៤ ។

២. អត្ថរស បានដល់ ផលចិត្តុប្បាទ ៤ ។
៣. វិមុត្តិរស បានដល់ ព្រះនិព្វាន ។
៤. អាយតនរស បានដល់ រសារម្មណ៍ ដូចជា រសប្រៃ រសផ្អែមជាដើម ។

# លក្ខណាទិចតុកៈរបស់រស

-ជីវ្ហាបដិហនន លក្ខណំ មានការប៉ះខ្ទប់នឹង ជីវ្ហាបសាទជាលក្ខណៈ ។

-ជីវ្ហាវិញ្ញាណស្ស វិសយភាវ រសំ មានសភាពជា អារម្មណ៍របស់ជីវ្ហាវិញ្ញាណ ជាកិច្ច ។

-តស្សេវ គោចរ បច្ចុប្បដ្ឋានំ មានសភាពជាគោចររបស់ជីវ្ហា-វិញ្ញាណនោះឯង ជាផល ។

-ចតុមហាភូត បទដ្ឋានំ មានមហាភូតរូប ៤ ដែលកើតពីសមុដ្ឋាន ៤ ជាហេតុជិត ។

# ៥. ផោដ្ឋព្វារម្មណ៍

ផោដ្ឋព្វារម្មណ៍ បានដល់ ផោដ្ឋព្វៈដែលជាអារម្មណ៍របស់កាយវិញ្ញាណ ។

ផោដ្ឋព្វារម្មណ៍ មានវចនត្ថៈថា **ផុសិតព្វន្តិ ផោដ្ឋព្វំ** ប្រែថា រូបណា កាយបសាទគប្បីពាល់ត្រូវ ដូច្នេះរូបនោះ ឈ្មោះថា **ផោដ្ឋព្វៈ** ។

ផោដ្ឋព្វារម្មណ៍ មាន ៣ យ៉ាង គឺ :

១. **បឋវីផោដ្ឋព្វារម្មណ៍** បានដល់ រឹង ទន់ ។

២. **តេជោផោដ្ឋព្វារម្មណ៍** បានដល់ ក្តៅ ត្រជាក់ ។

៣. **វាយោផោដ្ឋព្វារម្មណ៍** បានដល់ តឹង ធូរ ។

ដូច្នេះ ផោដ្ឋព្វារម្មណ៍ទាំង ៣ នេះ ក៏គឺបានដល់ មហាភូតរូប ៣ វៀរអាបោនោះឯង ។

ចំពោះ **អាបោធាតុ** កាយបសាទប៉ះខ្ទប់មិនបានទេ ដូច្នេះហើយបានជាមិនរាប់ចូលក្នុងផោដ្ឋព្វារម្មណ៍ ។

ក្នុងទឹកធម្មតា ឬទឹករឹង មានអាបោធាតុច្រើនណាស់ តែពេល

ដែលយើងជ្រលក់ដៃទៅ ហើយដឹងថា ត្រជាក់ ក្តៅ រឹង ទន់បាន នោះ ក៏ព្រោះតែបឋវី តេជោ នៅក្នុងទឹកនោះឯង ។ ឯអាបោវិញ មិនមែនជារូបត្រូវប៉ះខ្ទប់បានឡើយ ដូច្នេះ ទើបដឹងដោយកាយវិញ្ញាណ មិនបាន គឺ ដឹងបានតាមតែការនឹកគិតប៉ុណ្ណោះឯង ។ ដូចនៅពេល ដែលយើងឃើញនូវវត្ថុ មានរូបរាងមូល ជ្រុងទ្រវែងបាននោះ តាម ពិត មូល ជ្រុង ទ្រវែងនោះៗ យើងមិនបានឃើញទេ យើងឃើញ បាន ត្រឹមតែពណ៌ផ្សេងៗប៉ុណ្ណោះ ត្រង់ដឹងថា វត្ថុនោះ មូល ជ្រុង ទ្រវែងនោះ យើងដឹងបានដោយការនឹកគិត ព្រោះ មូល ជ្រុង ទ្រវែង មិនមែនជារូបារម្មណ៍ គឺជាធម្មារម្មណ៍ ដូច្នេះ ទើបឃើញ ដោយភ្នែកមិនបាន ដឹងបានតែដោយចិត្តតាមមនោទ្វារប៉ុណ្ណោះ ។ ចំពោះអាបោ ក៏យ៉ាងនោះដែរ ប៉ះខ្ទប់មិនបាន ព្រោះមិនមែនជា ផោដ្ឋព្វារម្មណ៍ទេ គឺជាធម្មារម្មណ៍ ដែលអាចដឹងបានដោយអាស្រ័យ ការនឹកគិតប៉ុណ្ណោះ ។

# លក្ខណាទិចតុកៈរបស់
# ផោដ្ឋព្វារម្មណ៍

**-កាយបដិហនន លក្ខណំ**　　មានការប៉ះខ្ទប់នឹង កាយបសាទ ជាលក្ខណៈ ។

| | |
|---|---|
| **-កាយវិញ្ញាណស្ស វិសយភាវរសំ** | មានភាពជា អារម្មណ៍របស់កាយវិញ្ញាណ ជាកិច្ច ។ |
| **-តស្សេវ គោចរ បច្ចុប្បដ្ឋានំ** | មានសភាពជា គោចររបស់កាយវិញ្ញាណនោះឯងជាផល ។ |
| **-ចតុមហាភូត បទដ្ឋានំ** | មានមហាភូតរូប ៤ ដែលកើតពីសមុដ្ឋាន ៤ ជាហេតុជិត ។ |

ដូច្នេះ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ និងផោដ្ឋព្វារម្មណ៍៣ រួមជា ៧ រូបនេះ ឈ្មោះថា **វិសយរូប** ក៏ព្រោះ ជាប្រភេទនៃរូប ដែលជាអារម្មណ៍របស់ចិត្ត ចេតសិក ដែលកើតតាម ទ្វារភ្នែក ទ្វារត្រចៀក ទ្វារច្រមុះ ទ្វារអណ្តាត ទ្វារកាយដោយចំពោះ និងដែលហៅថា **គោចររូប** នោះ ព្រោះជាទីគោចរ (អារម្មណ៍) ឬជាទីត្រាច់ទៅនៃឆទ្វារិកចិត្ត គឺ ចិត្តចេតសិកដែលកើតក្នុងទ្វារទាំង ៦ ៕

# ពួកទី ៤
# អំពី ភាវរូប ២

ភាវៈ ២ បានដល់ **ឥត្ថីភាវៈ** ភាពជាស្រី និង**បុរិសភាវៈ** ភាពជាបុរស ។

**ឥត្ថីភាវរូប** គឺ រូបដែលសម្តែងភាពជាស្រី ។

**បុរិសភាវរូប** គឺ រូបដែលសម្តែងភាពជាប្រុស ។

រូបទាំង ២ នេះ ជាសុខុមរូប កើតពីកម្មជាសមុដ្ឋាន ផ្សាយទៅនៅពាសពេញសរីរៈទាំងអស់ ដូចជាកាយិន្ទ្រីយ៍ដែរ ។

## ១. ឥត្ថីភាវរូប

**ឥត្ថីភាវរូប** មានវចនត្ថៈថា **ឥត្ថិយា ភាវោ ឥត្ថីភាវោ** រូបណា ជាហេតុនៃភាពជាស្រី រូបនោះ ឈ្មោះថា **ឥត្ថីភាវៈ** ។

# លក្ខណាទិចតុក្កៈរបស់ឥត្ថីភាវៈ

| | |
|---|---|
| **-ឥត្ថីភាវ លក្ខណំ** | មានភាពជាស្រី ជាលក្ខណៈ ។ |
| **-ឥត្ថីតិ បកាសន រសំ** | មានការប្រកាសថា ជាស្រី ជាកិច្ច ។ |
| **-ឥត្ថីលិង្គាទីនំ ការណភាវ បច្ចុប្បដ្ឋានំ** | មានហេតុការណ៍ នៃភេទស្រី ជាដើម ជាផល ។ |
| **-ចតុមហាភូត បទដ្ឋានំ** | មានមហាភូតរូប ៤ ដែលកើតពីកម្ម ជាហេតុជិត ។ |

ក្នុងអភិធម្មត្ថវិភាវិនី សម្តែងថា **ឥត្ថីលិង្គនិមិត្តកុត្តាកប្ប-ហេតុភាវ លក្ខណំ ឥត្ថត្តំ** ប្រែថា ភាពជាស្រី មានភាវៈនៃស្រី គឺ ភេទ និមិត្ត កុត្តៈ អាកប្បៈ ជាហេតុ ជាលក្ខណៈ ។

ប៉ុន្តែក្នុងអដ្ឋកថា ពណ៌នាទុកអំពីភេទស្រី ដោយប្រការដទៃថា រាងកាយនៃសត្វទាំងឡាយ ដែលមាននៅក្នុងលោកនេះ ដែលនឹងអាចដឹងថា ជាភេទស្រីបាននោះ ដោយអាស្រ័យការសម្តែងចេញមក

នូវគ្រឿងសំគាល់ ឲ្យដឹង ៤ យ៉ាង គឺ :

**១.លិង្គ** រូបរាងសណ្ឋាន មាន ដៃ ជើង ភ្នែក ភេទជាដើម ។

**២.និមិត្ត** គ្រឿងចំណាំ ដូចជាសម្លេង ការញញឹមជាដើម ។

**៣.កុត្ត** និស្ស័យ គឺ ការប្រព្រឹត្តិផ្សេង ៗ ដូចការលេង ការលក់ដូរ ការវាយតប់ជាដើម ។

**៤.អាកប្ប** អាការកិរិយា ដូចជាការដើរ ឈរ អង្គុយ ដេក បរិភោគ និយាយ ជាដើម ។

គ្រឿងសម្តែងឲ្យដឹងនូវភេទ ៤ យ៉ាងនេះ រមែងប្រាកដទៅតាម **ឥត្ថីភាវរូប** ។ កាលណា គ្រឿងសម្តែងឲ្យដឹងទាំង ៤ យ៉ាងនេះ កើតឡើង ដោយអាស្រ័យឥត្ថីភាវរូបគ្រប់គ្រងហើយ ក៏រមែងមានរូបរាងសណ្ឋាន កិរិយា អាការ ចរិយាមាយាទជាស្រី ។

# ២. បុរិសភាវរូប

បុរិសភាវរូប មានវចនត្ថៈថា **បុរិសស្ស ភាវោ បុរិសភាវោ** រូបណាជាហេតុនៃភាពជាប្រុស រូបនោះ ឈ្មោះថា **បុរិសភាវៈ**។

# លក្ខណាទិចតុកៈរបស់
# បុរិសភាវរូប

- **បុរិសភាវ លក្ខណំ** មានភាពជាប្រុស ជាលក្ខណៈ។
- **បុរិសោតិ បកាសន រសំ** មានការប្រកាសថា ជាប្រុស ជាកិច្ច ។
- **បុរិសលិង្គាទីនំ ការណភាវ បច្ចុប្បដ្ឋានំ** មានហេតុការណ៍ នៃភេទប្រុស ជាដើម ជាផល ។
- **ចតុមហាភូត បទដ្ឋានំ** មានមហាភូតរូប ៤ ដែលកើតពីកម្ម ជាហេតុជិត ។

ក្នុងអភិធម្មត្ថវិភាវិនី សម្ដែងថា **បុរិសលិង្គនិមិត្តកុត្តាកប្បហេតុភាវ លក្ខណំ បុរិសត្តំ** ប្រែថា ភាពជាប្រុស មានភាវៈនៃ ប្រុស គឺ ភេទ និមិត្ត កុត្តៈ អាកប្បៈ ជាហេតុ ជាលក្ខណៈ ។

ន័យនៃភាពជាប្រុស ដែលខុសពីស្រី មាន ៤ យ៉ាង គឺ :

**១.លិង្គ** រូបរាងសណ្ឋាន មាន ដៃ ជើង ភ្នែក ភេទ ជាដើម ។

**២.និមិត្ត** គ្រឿងសំគាល់ មានពុកមាត់ ពុកចង្កាជាដើម។

**៣.កុត្ត** និស្ស័យ គឺ ការប្រព្រឹត្តិផ្សេងៗ ដូចការលេង ការវាយតប់ ជាដើម ។

**៤.អាកប្ប** អាការកិរិយា ដូចជា ការដើរ ឈរ អង្គុយ ដេក បរិភោគ និយាយ ជាដើម ។

ភាវរូបទាំង ២ គឺ ភាពជាស្រីនិងប្រុស របស់បុគ្គលអ្នកកើតក្នុងសម័យដើមកប្ប តែងប្រាកដឡើងក្នុងបវត្តិកាល ។ លុះក្នុងសម័យក្រោយមក ភាវរូបទាំង ២ នេះ ក៏ប្រាកដឡើងក្នុងបដិសន្ធិកាល ។ ប៉ុន្តែទោះជាប្រាកដ ឡើងក្នុងបដិសន្ធិកាលក៏ដោយ ក៏អាចមានការផ្លាស់ប្តូរបាន ក្នុងបវត្តិកាល គឺ ភេទស្រីប្រាកដដល់បុរសខ្លះៗ ភេទប្រុសប្រាកដដល់ស្រីខ្លះៗ ។

បណ្តាភេទទាំង ២ នោះ ភេទប្រុសជាឧត្តមភេទ ភេទស្រីជាហីនភេទ ។ ភេទប្រុស តែងអន្តរធាន ព្រោះអាស្រ័យអកុសលមានកម្លាំង (ពលវអកុសលកម្ម) ភេទស្រី តែងប្រាកដឡើងដោយកុសលដែលទុព្វល(ទុព្វលកុសលកម្ម) ។ ប៉ុន្តែភេទស្រី កាលណាអន្តរធាន

រមែងអន្តរធានទៅ ព្រោះអកុសលដែលទុព្វល ( ទុព្វលអកុសលកម្ម ) ភេទប្រុស រមែងប្រាកដឡើងដោយកុសលដែលមានកម្លាំង ( ពលវ-កុសលកម្ម ) គឺភាវៈទាំង ២ នេះ តែងអន្តរធានទៅដោយអកុសល និង តែងប្រាកដឡើងដោយកុសល ។

ចំណែកអបាយសត្វដែលកើត ជាភេទឈ្មោល-ញី ក៏ដោយ អំណាចពលវអកុសលកម្ម ឬ ទុព្វលអកុសលកម្ម ដូចគ្នា ៕

# ពួកទី ៥
# អំពីហទយរូប

ហទយរូប មានវចនត្ថៈថា **ហទន្តិ សត្តា តំតំ អត្ថំ វា ប្ហូរេន្តិ ឯតេនាតិ ហទយំ** ប្រែថា សត្វទាំងឡាយតែងគិត តែងធ្វើរបស់ជាប្រយោជន៍ និងមិនជាប្រយោជន៍នោះៗ ឲ្យកើតឡើង ឲ្យពេញបាន ដោយអាស្រ័យរូបនោះ ដូច្នេះរូប នោះឈ្មោះថា **ហទយរូប** ។

វចនត្ថៈមួយទៀតថា **ហទយមេវ មនោធាតុ មនោ-**

**វិញ្ញាណធាតូនំ និស្សយត្ថា វត្ថុចាតិ ហទយវត្ថុ** ប្រែថា ហទយៈ នោះឯង ជាវត្ថុ ព្រោះជាទីអាស្រ័យនៃមនោធាតុ និង មនោវិញ្ញាណធាតុទាំងឡាយ ដូច្នេះហើយ ហទយ នោះ ទើប ឈ្មោះថា **ហទយវត្ថុ** ។

ការងាររបស់សត្វទាំងឡាយ ដែលប្រព្រឹត្តទៅរាល់ថ្ងៃនេះ បើ ធ្វើក្នុងអំពើណាដែលល្អ ដែលជាប្រយោជន៍ ហៅថា **កុសលកម្ម** តែបើធ្វើក្នុងអំពើណាដែលមិនល្អ មិនជាប្រយោជន៍ ក៏ហៅថា **អកុសលកម្ម** ។ កុសលកម្មក្តី ឬ អកុសលកម្មក្តី អាចកើតឡើង បាន ក៏ត្រូវអាស្រ័យហទយវត្ថុរូបកើតដែរ ចំពោះក្នុងបញ្ចវោការភូមិ នោះ បើមិនមានហទយវត្ថុរូបកើតឡើងទេ ការប្រព្រឹត្តិទៅនៃការងារ ផ្សេងៗ រហូតដល់ការនឹកគិត ដឹងរឿងរ៉ាវផ្សេង ៗ ក៏មិនបានឡើយ ប្រហែលគ្នានឹងរូបទីងមោងអ៊ុចឹងដែរ ។

ហទយរូប នេះមាន ២ យ៉ាង គឺ :

**១.មំសហទយរូប** គឺសសម្ភារហទយរូប បានដល់ ហទយរូប ដែលជាដុំសាច់បេះដូង មានលក្ខណៈ ដូចផ្កាឈូកក្រពុំសំយុងចុះ ។

**២.វត្ថុហទយរូប** គឺជាសុខុមរូប កើតពីកម្មជាសមុដ្ឋាន តាំង

នៅក្នុងទីចន្លោះ ដែលមានលក្ខណៈ ដូចជាអណ្តូង មានប្រមាណប៉ុនគ្រាប់ផ្លែបុសនាគ នៅខាងក្នុងមំសហទយរូប ។ ក្នុងទីចន្លោះនោះមានទឹកលោហិតនៅរក្សា ប្រមាណមួយទូកដៃ ជាទីអាស្រ័យកើតឡើងនៃមនោធាតុ និង មនោវិញ្ញាណធាតុ ។

ក្នុងមោហវិច្ឆេទនីពោលថា រីឯទឹកលោហិត ដែលដក់នៅនោះ របស់អ្នកមាន :

- **រាគចរិត** មានពណ៌ក្រហម ។
- **ទោសចរិត** មានពណ៌ខ្មៅ ។
- **មោហចរិត** មានពណ៌ ដូចទឹកលាងសាច់ ។
- **វិតក្កចរិត** មានពណ៌ ដូចក្រដាសស្រោមសណ្តែកខ្មៅ ។
- **សទ្ធាចរិត** មានពណ៌លឿង ដូចផ្កាកណិការ ។
- **ពុទ្ធិចរិត** មានពណ៌ថ្លាភ្លឺបរិសុទ្ធ ដូចកែវមណីឆ្នៃហើយ ។

ហទយវត្ថុរូបនេះ ដែលត្រូវមហាភូតរូបទាំងឡាយឧបការហើយ ដែលត្រូវអាយុអនុបាលរក្សា ដែលត្រូវបានគោចររូប មានពណ៌ជាដើមហែហម និងដែលត្រូវ ឧតុ ចិត្ត និង អាហារ ជួយឧបត្ថម្ភនោះ តែងនៅសភាពជាវត្ថុ ជាទីអាស្រ័យនៃមនោធាតុ និង មនោវិញ្ញាណធាតុ និង ធម៌ដែលកើតរួមជាមួយធាតុទាំង ២ នោះ

ឲ្យសម្រេច ប្រព្រឹត្តទៅតាមការគួរ ។

# លក្ខណាទិចតុក:របស់ ហទយរូប

| | |
|---|---|
| -មនោធាតុ មនោវិញ្ញាណ-ធាតូនំ និស្សយ លក្ខណំ | ជាទីអាស្រ័យនៃមនោធាតុ និងមនោវិញ្ញាណធាតុ ជាលក្ខណៈ។ |
| -តាសញ្ញេវ ធាតូនំ អាធារន រសំ | មានការឧបត្ថម្ភ ជ្រោមជ្រែងធាតុទាំង ២ នោះឯងជាកិច្ច ។ |
| -តុព្វាហន បច្ចុប្បដ្ឋានំ | មានការជ្រោងឡើងនូវធាតុទាំងនោះឲ្យប្រព្រឹត្តទៅ ជាផល ។ |
| -ចតុមហាភូត បទដ្ឋានំ | មានមហាភូតរូប ៤ ដែលកើតពីកម្ម ជាហេតុជិត ។ |

# ពួកទី ៦
# អំពីជីវិតរូប

ជីវិតរូប ឬ ជីវិតិន្ទ្រិយរូប មានវចនត្ថៈថា **ជីវន្តិ សហ-ជាតធម្មា ឯតេនាតិ ជីវិតំ** ប្រែថា សហជាតរូបទាំងឡាយតែងរស់នៅបាន ដោយសាររូបនោះ ដូច្នេះ រូបដែលជាហេតុឲ្យសហជាតរូប ទាំងឡាយ រស់នៅបាននោះ ឈ្មោះថា **ជីវិតរូប** ។

ពាក្យថា **សហជាតរូបទាំងឡាយ** ក្នុងទីនេះ បានដល់កម្មជរូប ។

**តទេវ កម្មជរូបបរិបាលនេ អធិប្បច្ចយោគតោ ឥន្ទ្រិយន្តិ ជីវិតិន្ទ្រិយំ** ប្រែថា ជីវិតនោះហ្នឹងឯង ឈ្មោះថា ឥន្ទ្រីយ៍ ព្រោះមានភាពជាធំ ក្នុងការគ្រប់គ្រងកម្មជរូប ដូច្នេះ ជីវិតរូបនោះ ឈ្មោះថា **ជីវិតិន្ទ្រីយ៍** ។

កម្មជរូបទាំងឡាយកើតឡើងជាប់តគ្នាបាន និង តាំងនៅបាននោះ ក៏ព្រោះដោយសារមានជីវិតរូប ជាអ្នករក្សា ។ ឯកម្មជរូបនេះសូម្បីតែថា ជារូបដែលកើតពីកម្មក៏ពិតមែន ប៉ុន្តែកម្មមិនមែនជាអ្នក

រក្សា ព្រោះកម្មដែលជាសមុដ្ឋានរបស់រូបទាំងនេះ ជាអតីតកន្លងទៅហើយ ទើបមិនមានអំណាច ក្នុងការរក្សារូបដែលកើតពីខ្លួនបាន ដូច្នេះ ត្រូវមានរូបដោយចំពោះ ជាអ្នករក្សា គឺជីវិតរូបនោះឯង ប្រៀបបីដូចទឹកដែលរក្សា ផ្កានៅក្នុងថូផ្កាដូច្នោះ ។

ចំណែក ចិត្តជរូប(រូបកើតពីចិត្ត) ឧតុជរូប(រូបកើតពីឧតុ) អាហារជរូប(រូបកើតពីអាហារ) មិនចាំបាច់មានរូប ដោយចំពោះជាអ្នករក្សា ដើម្បីឲ្យកើតឡើងជាប់តគ្នា និង តាំងនៅបានរហូតដល់អាយុរបស់ខ្លួនឡើយ ព្រោះរូបទាំងអស់នេះ មានសមុដ្ឋានជាបច្ចុប្បន្ននៃខ្លួននោះៗឯង ជាអ្នករក្សា ។

# លក្ខណាទិចតុកៈរបស់ ជីវិតរូប

**-សហជាតរូបានុបាល លក្ខណំ** មានការតាមរក្សា សហជាតរូបដែលកើតព្រមជាមួយនឹងខ្លួន ជាលក្ខណៈ ។

**- តេសំ បវត្តន រសំ** មានការញ៉ាំងសហជាតរូប ទាំងនោះឲ្យប្រព្រឹត្តទៅ ជាកិច្ច ។

**-តេសញ្ញេវ ថបន បច្ចុប្បដ្ឋានំ** មានការតាំងនៅបាន នៃរូបធម៌នោះឯង ជាផល ។

**-យាបយិតព្វភូត បទដ្ឋានំ** មានភូតរូប ដែលញុំាងរូបធម៌ឲ្យប្រព្រឹត្តទៅបាននោះ ជាហេតុជិត ។

# ពួកទី ៧
# អំពីអាហាររូប

អាហាររូប បានដល់ កវឡិង្ការាហារ មានវចនត្ថៈថា **កពឡំ ករីយតីតិ កពឡិង្ការោ** ប្រែថា ភោជនណា ដែលបុគ្គលធ្វើឲ្យទៅជាដុំ(ជាដុំបាយ ដុំនំ) ដូច្នេះ ភោជននោះ ឈ្មោះថា **កវឡិង្ការ** ។

**អាហរីយតីតិ អាហារោ** ភោជនណា ដែលបុគ្គលទំពាស៊ីលេបទៅ ដូច្នេះ ភោជននោះ ឈ្មោះថា **អាហារ** ។

**កពឡិង្ការោ ច សោ អាហារោ ចាតិ កពឡិង្ការាហារ** ភោជនដែលបុគ្គលធ្វើឲ្យទៅជាដុំផងទំពាស៊ីលេប

បានផង ដូច្នេះ ភោជននោះ ឈ្មោះថា **កវឡិង្ការាហារ** ។

ដូច្នេះ **កវឡិង្ការាហារ** ដែលពោលមកនេះ សំដៅដល់អាហារទាំងអស់ដែលសត្វស៊ីបរិភោគ ប៉ុន្តែក្នុងទីនេះ សំដៅយក **អាហាររូប គឺ ឱជា** ដែលមាននៅក្នុងអាហារផ្សេងៗ ដែលសត្វស៊ីបរិភោគទៅ រំលាយល្អហើយ បម្រុងរក្សារាងកាយសត្វនោះឲ្យល្វតលាស់ ។

ឱជា ស័ព្ទនេះមានវចនត្ថៈថា **អត្តនោ ឧទយានន្តរំ រូបំ ជនេតីតិ ឱជា** ធម្មជាតិណាធ្វើឲ្យរូបកើតជាប់តគ្នា ព្រមនឹងការកើតរបស់ខ្លួន ដូច្នេះ ធម្មជាតិនោះ ឈ្មោះថា **ឱជា** ។

**កវឡិង្ការាហារ** មានដុំបាយ ទឹកជាដើម កាលណាសត្វស៊ីបរិភោគចូលទៅ បាចកតេជោ គឺ ភ្លើងធាតុ ក៏ធ្វើនាទីរំលាយអាហាររឹតច្របាច់ យកតែឱជា(អាហារល្អិត) ទៅបម្រុងចិញ្ចឹមរាងកាយ ។

ដូច្នេះ ឱជារូបនេះ កាលជ្រាបចូលទៅនៅក្នុងរាងកាយសត្វទាំងឡាយហើយ តែងធ្វើឲ្យអាហារជរូបកើតឡើងភ្លាម គឺថា ឱជា-រូបនេះ ធ្វើឲ្យរាងកាយសត្វទាំងឡាយ មានកម្លាំងធំធាត់ឡើងបាន ។

ចំណែករាងកាយសត្វដែលល្វតលាស់ពេញទីហើយ ឱជារូប

នេះ ក៏ធ្វើឲ្យរាងកាយសំបូរណ៍ និងឲ្យមានជីវិតរស់នៅបានតទៅ ។

# លក្ខណាទិចតុកៈរបស់ អាហាររូប

- **ឱជា លក្ខណំ** មានឱជា ជាលក្ខណៈ គឺមានការធ្វើឲ្យរូបលូតលាស់ឡើង ជាលក្ខណៈ ។

- **រូបាហរណ រសំ** មានការនាំប្រយោជន៍ មកដល់រូប ជាកិច្ច ។

- **កាយុបត្ថម្ភន បច្ចុប្បដ្ឋានំ** មានការឧបត្ថម្ភ ជ្រោមជ្រែងកាយ ជាផល ។

- **អជ្ឈោហរិតព្វ បទដ្ឋានំ** មានអាហារ ដែលគប្បីបរិភោគ ជាហេតុជិត ។

រូបធម៌ ៧ ពួក តាមដែលពោលមកនេះ ហៅថា សភាវរូប សលក្ខណរូប និប្ផន្នរូប រូបរូប និង សម្មសនរូប កាលបើចែក

ចេញជារូបមួយៗបាន ១៨ រូប ។ បើចែកចេញជាឋាន គឺ ទីតាំងនៅក្នុងរាងកាយសត្វ ញែកបានជា ២ ប្រភេទ គឺ :

**១.សព្វដ្ឋានិករូប** រូបដែលតាំងនៅក្នុងកាយទាំងអស់ មាន ១៣ រូប គឺ មហាភូតរូប ៤ កាយបសាទរូប ១ វណ្ណរូប ១ សទ្ទរូប ១ គន្ធរូប ១ រសរូប ១ ភាវរូប ២ ជីវិតរូប ១ និង អាហាររូប ១ ។

**២.បទេសិករូប** រូបដែលតាំងនៅចំពោះក្នុងកន្លែងខ្លះៗ មាន ៥ រូប គឺ ចក្ខុបសាទរូប ១ សោតបសាទរូប ១ ឃានបសាទរូប ១ ជិវ្ហាបសាទរូប ១ និង ហទយរូប ១ ។

- សទ្ទរូប(សម្លេង) អាចារ្យខ្លះពោលថាជា បទេសិករូប គឺ បំណងយកសម្លេងដែលកើតតាមផ្លូវវាចា ៕

# ពួកទី ៨
# អំពីបរិច្ឆេទរូប

**បរិច្ឆេទរូប** បានដល់ អាកាសធាតុ នោះឯង ។ **អាកាស** ស័ព្ទនេះមានវចនត្ថៈថា **នកស្សតីតិ អកាសោ អកាសោយេវ អាកាសោ** ប្រែថា ទីណា សរសេរ គូសវាស មិនបាន ដូច្នេះ ទីនោះ

ឈ្មោះថា **អាកាស** ។ ទីដែលសរសេរគូសវាសមិនបាននោះឯង ឈ្មោះថា **អាកាស** និងឈ្មោះថា **ធាតុ** ព្រោះអត្ថថា មិនមែនជីវិត ដូច្នេះហើយ ទើបឈ្មោះថា **អាកាសធាតុ** ។

# អាកាស ៤ យ៉ាង

អកាស មាន ៤ យ៉ាង គឺ :

**១. អជដាកាស** ឬ **តុច្ឆាកាស** បានដល់ អាកាស ទីល្ហល្ហេវទទេ គឺខាងក្រោម គិតតាំងពីខាងក្រោមខ្យល់ដែលទ្រទឹកៗទ្រដីចុះទៅ និងខាងលើ គឺគិតតាំងពីលើអរូបព្រហ្មឡើងទៅ ។

**២. បរិច្ឆិន្នាកាស** បានដល់ ចន្លោះទទេ ដែលមានតែមកណ្ដាប់ព្រំដែនកំណត់ ដូចចន្លោះទ្វារបង្អួច ប្រឡោះមាត់ ប្រហោងច្រមុះ ចន្លោះក រន្ធត្រចៀក លំហផ្ទៃមេឃ ជាដើម ។

**៣. កសិណុគ្ឃាដិមាកាស** បានដល់ អាកាសដែលបានបើកចេញពីកសិណទាំង ៩ វៀរអាកាសកសិណ ។

**៤. បរិច្ឆេទាកាស** បានដល់ ចន្លោះប្រឡោះទទេ ដែលឃាំងរវាងរូបនិងរូប ឬ រវាងកលាបរូបនិងកលាបរូប គឺ បរិច្ឆេទរូបនោះឯង ។

ក្នុងអជដាកាសក្តី បរិច្ឆិន្នាកាសក្តី កសិណុគ្ឃាដិមាកាសក្តី ទាំងអស់នេះតែងមានបរិច្ឆេទាកាស គឺ បរិច្ឆេទរូប នៅជាមួយជានិច្ច។

ម្យ៉ាងទៀត ក្នុងបណ្តារបស់មានជីវិត និងមិនមានជីវិត ទាំង-ឡាយនោះ បើមិនមានព្រំដែន គឺបរិច្ឆិន្នាកាសហើយ របស់ទាំងនោះ ក៏នឹងមិនអាចធ្វើឲ្យដឹងដល់រូបរាងសណ្ឋាន និង ចំនួនបានឡើយ ។ ឯត្រង់ដែលយើងដឹងបាននោះ ក៏ដោយសារបរិច្ឆិន្នាកាសនោះឯង យ៉ាងណាក្តី បណ្តារូបដែលមានជីវិត និង មិនមានជីវិតទាំងឡាយ នោះ ប្រសិនបើមិនមានបរិច្ឆេទរូបហើយ ចំនួនរូបកលាបក៏កំណត់ មិនបានទីបំផុត នៃរូបក៏មានមិនបាន ព្រំដែនរបស់រូបក៏មានមិនបាន គឺរូបទាំងអស់នោះ នឹងជាប់គ្នាទៅជាជួរ ទៅជាផ្ទាំងទាំងអស់ កាល បើយ៉ាងនេះ ឧទយព្វយញ្ញាណក្តី ភង្គញ្ញាណក្តី ដែលទាក់ទិនជាមួយ រូបធម៌ ក៏កើតឡើងមិនបាន ព្រោះមិនអាចប្រចក្សឃើញនូវការកើត ការរលត់ របស់រូបបាន ។

# លក្ខណាទិចតុកៈរបស់
# បរិច្ឆេទរូប

**-រូបបរិច្ឆេទ លក្ខណំ** មានការឃាំង រាំងនូវរូប-

កលាប ជាលក្ខណៈ ។

**-រូបបរិយន្តប្បកាសន រសំ** មានការប្រកាសទីបំផុតរបស់រូបជាកិច្ច ។

**-រូបមរិយាទ បច្ចុប្បដ្ឋានំ ឆិទ្ទវិវរភាវ បច្ចុប្បដ្ឋានំ វា** មានដែនកំណត់របស់រូបជាផល ឬមានភាពជាចន្លោះ- ប្រហោងជារន្ធ ជាផល ។

**-បរិច្ឆិន្ន បទដ្ឋានំ** មានរូប ដែលអាកាសឃាំងទុក ជាហេតុជិត ។

កាលបើមានយ៉ាងនេះហើយ ទើបអាចកំណត់បានថា ខាងលើមានត្រឹមនេះ ខាងក្រោមមានត្រឹមនេះ បណ្តោយមានត្រឹមនេះ ទទឹងមានត្រឹមនេះ ។

ម្យ៉ាងទៀត មានវចនត្ថៈថា **ទ្វេមេ ភិក្ខវេ ធម្មា និច្ចធុវា សស្សតា អវិបរិណាម ធម្មា យតមេ ទ្វេ អាកាសោ ច និព្វានញ្ច** ប្រែថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលទៀងខ្ជាប់ខ្ជួន ឋិតថេរ មិនប្រែប្រួលនោះ មាន ២ ប្រការ ធម៌នោះ គឺ

អាកាស និង ព្រះនិព្វាន ។

# ពួកទី ៩
# អំពីវិញ្ញត្តិរូប ២

វិញ្ញត្តិរូប ជារូប សម្តែងអាការពិសេស ឲ្យដឹងបំណងនៃគ្នា និងគ្នាបាន ហើយកើតនៅក្នុងការកម្រើកនិងការនិយាយ មានវចនត្ថៈថា :

**អធិប្បាយំ វិញ្ញាបេតីតិ វិញ្ញត្តិ** ប្រែថា រូបណា ធ្វើឲ្យអ្នកដទៃដឹងពីបំណងបាន រូបនោះ ឈ្មោះថា **វិញ្ញត្តិ** ។

ឬ **វិញ្ញាយតីតិ វិញ្ញត្តិ** ប្រែថា រូបណា គប្បីដឹងបានដោយខ្លួនឯង រូបនោះ ឈ្មោះថា **វិញ្ញត្តិ** ។

ឬន័យម៉្យាងទៀតថា **វិញ្ញាបេន្តិ ជនា វិញ្ញាយន្តិ វា ជនេហិ អញ្ញមញ្ញស្ស ចិត្តា និ ឯតាយាតិ វិញ្ញត្តិ** ប្រែថា ជនទាំងឡាយដឹងចិត្តសន្តានទ្វៃគ្នានិងគ្នាបាន ដោយអាស្រ័យរូបនោះ ដូច្នោះ រូបដែលជាហេតុឲ្យដឹងចិត្ត សន្តានទ្វៃគ្នា និង គ្នាបាននោះ ឈ្មោះថា **វិញ្ញត្តិ** ។

ដូច្នេះ វិញ្ញត្តិរូបនោះ ទើបមាន ២ រូបដូចគ្នា គឺ កាយ-វិញ្ញត្តិរូប ១ និងវចីវិញ្ញត្តិរូប ១ ដែលជាវិការរបស់និប្ផន្នរូប មានចិត្តជាសមុដ្ឋាន ធ្វើឲ្យកាយ និង វាចាកម្រើក ។

បុថុជ្ជន ព្រះសេក្ខបុគ្គល និង ព្រះអសេក្ខបុគ្គល តែងឲ្យវិញ្ញត្តិរូបទាំង ២ កើតដោយចិត្ត ៣២ ដួង ប៉ុណ្ណោះ គឺ កាមាវចរជវនចិត្ត ២៩ ដួង (គឺអកុសលចិត្ត ១២ មហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ ហសិតុប្បាទចិត្ត ១ ) អភិញ្ញាចិត្ត ២ ដួង និងមនោទ្វារាវជ្ជន ចិត្ត ១ ដួង ។

# ១. កាយវិញ្ញត្តិរូប

កាយវិញ្ញត្តិរូប មានវចនត្ថៈថា **កាយេន វិញ្ញត្តិ កាយវិញ្ញត្តិ** ប្រែថា អាការពិសេសដែលធ្វើឲ្យដឹងបំណងបាន ដោយការកម្រើកកាយ ដូច្នោះ អាការពិសេស គឺ ការកម្រើកកាយនោះ ឈ្មោះថា **កាយវិញ្ញត្តិ** ។

កាយវិញ្ញត្តិរូប នេះ មាន ២ យ៉ាង គឺ :

**១-ពោធនកាយវិញ្ញត្តិ** សំដៅដល់ ការកម្រើកកាយ ដោយ

មានបំណងឲ្យអ្នកដទៃណាមួយដឹងសេចក្តី ដូចជា បក់ដៃ ឬ ហោយដៃជាដើម ។

**២-បវត្តនកាយវិញ្ញត្តិ** សំដៅដល់ ការកម្រើកកាយ ដែលប្រព្រឹត្តទៅជាធម្មតា ដោយមិនមានចិត្តបំណងឲ្យអ្នកដទៃណាមួយដឹងសេចក្តី ដូចជា ការដើរ ឈរ អង្គុយ ដេក តាមធម្មតារបស់យើងនោះឡើយ ។ ប៉ុន្តែអាការទាំងនោះ គេដទៃតែងតែដឹងបានថា យើងកំពុងដើរ ឈរ អង្គុយ ដេក ហើយដែរ ។

# លក្ខណាទិចតុកៈរបស់ កាយវិញ្ញត្តិរូប

**-វិញ្ញាបន　លក្ខណំ**　មានការធ្វើឲ្យដឹងក្នុងន័យ ក្នុងសេចក្តី ដោយការកម្រើកកាយជាលក្ខណៈ ។

**-អធិប្បាយបកាសន រសំ**　មានការប្រកាស សម្តែងបំណងជាកិច្ច ។

**- កាយវិប្ផន្ទន ហេតុភាវ**　មានហេតុ គឺ កាយកម្រើក ជា

| | |
|---|---|
| **បច្ចុប្បដ្ឋានំ** | ផល ។ |
| **- ចិត្តសមុដ្ឋាន វាយោធាតុ** | មានវាយោធាតុ តាំងឡើងពីចិត្ត |
| **បទដ្ឋានំ** | ជាហេតុជិត ។ |

ពិតមែន ចំពោះបច្ចុប្បដ្ឋាន គឺ ផល មានការឈានទៅមុខ ឬត្រឡប់ថយក្រោយជាដើមនោះ គឺថា កាលណា ចិត្តគិតកើតឡើងថា “យើងនឹងឈានទៅមុខ” ជាដើមយ៉ាងនេះ រមែងញ៉ាំងរូប ៨ រូបឲ្យកើតឡើង(គឺអវិនិព្ភោគរូប៨) ក្នុងខណៈនៃចិត្តដែលកើតឡើងនោះ ។ វាយោធាតុដែលមាន ចិត្តជាសមុដ្ឋាន ខាងក្នុងនៃរូបកលាបទាំងនោះឯង រមែងជ្រោមជ្រែង ទ្រទ្រង់នូវរូបកាយដែលកើតព្រមនឹងខ្លួននោះឲ្យកម្រើក គឺថា វាយោធាតុដែលតាំងឡើងដោយជវនចិត្តដួងទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ ទប់ជ្រោមជ្រែងនូវរូបកាយដែលកើតព្រមនឹងខ្លួន ឲ្យតាំងនៅ ប៉ុន្តែមិនអាចឲ្យកម្រើកបានទេ ។ អាស្រ័យដោយបានវាយោធាតុ ដែលតាំងឡើងដោយជវនចិត្ត ៦ ដួងមុន ជាបច្ច័យឧបត្ថម្ភហើយ វាយោធាតុដែលតាំងឡើងដោយជវនចិត្តទី៧ ក៏អាចជ្រោមជ្រែងទ្រទ្រង់ ដើម្បីញ៉ាំងរូបកាយដែលកើតព្រមនឹងខ្លួន ឲ្យកម្រើក មានឈានទៅមុខ ត្រឡប់ថយក្រោយជាដើមបាន ។

# ២. វចីវិញ្ញត្តិរូប

វចីវិញ្ញត្តិរូប រូបដែលសម្តែងការកម្រើកវាចា គឺការនិយាយ មានវចនត្ថៈថា **វចិយា វិញ្ញត្តិ វចីវិញ្ញត្តិ** ប្រែថា អាការពិសេស ដែលធ្វើឲ្យដឹងបំណងដោយការនិយាយ ដូច្នេះ អាការពិសេស គឺ ការនិយាយនោះ ឈ្មោះថា **វចីវិញ្ញត្តិ** ។

វចីវិញ្ញត្តិរូប មាន ២ យ៉ាង គឺ :

**១-ពោធនវចីវិញ្ញត្តិ** សំដៅដល់ការពោលវាចា ដោយប៉ង ប្រាថ្នាឲ្យអ្នកដទៃណាមួយ ដឹងសេចក្តីបាន ដូចកូកហៅឈ្មោះ ឬ ពោលជំរាបរឿងរ៉ាវផ្សេងៗ ។

**២-បវត្តនវចីវិញ្ញត្តិ** សំដៅដល់ ការពោលវាចា ដោយមិន ប៉ងប្រាថ្នាឲ្យអ្នកដទៃណាមួយដឹងន័យសេចក្តីទេ ដូចថ្ងៃងឧទានសម្លេង ចេញមក ច្រៀងឬអានសៀវភៅជាដើម មិនចង់ឲ្យអ្នកណាដឹងសេចក្តី ទេ តែអ្នកដទៃឮសម្លេងនិយាយ ឬ ច្រៀងចេញមកនោះ តែងដឹង តែងជ្រាបន័យសេចក្តីបាន ។

# លក្ខណាទិចតុកៈរបស់ វចីវិញ្ញត្តិរូប

- **វិញ្ញាបន លក្ខណំ** មានការធ្វើឲ្យដឹងក្នុងន័យ ក្នុងសេចក្តី ដោយការនិយាយ ជាលក្ខណៈ ។

- **អធិប្បាយបកាសន រសំ** មានការប្រកាស សម្តែងបំណងជាកិច្ច ។

- **វចីឃោស ហេតុភាវ បច្ចុប្បដ្ឋានំ** មានហេតុ គឺសម្លេងលាន់ឮជាពាក្យ ជាផល ។

- **ចិត្តសមុដ្ឋាន បឋវីធាតុ បទដ្ឋានំ** មានបឋវីធាតុ តាំងឡើងពីចិត្តជាហេតុជិត ។

ពាក្យថា បច្ចុប្បដ្ឋានគឺជាផលនោះ គឺថា កាលចិត្តគិតកើតឡើងថា “យើងនឹងពោលពាក្យនោះៗ” យ៉ាងនេះ រមែងញ៉ាំងរូប ៨ រូបឲ្យកើតឡើង (គឺអវិនិព្ភោគរូប៨) ក្នុងខណៈនៃចិត្តដែលកើតឡើង

នោះ ។ បឋវីធាតុដែលមានចិត្តជាសមុដ្ឋាន ខាងក្នុងនៃរូបកលាប ទាំងនោះឯង រមែងខ្ទប់នឹងឧបាទិន្នករូប ហើយសម្លេងក៏កើតឡើង ព្រោះការប៉ះខ្ទប់នោះ ។ សម្លេងមានចិត្តជាសមុដ្ឋាននេះ មិនមែនវិញ្ញត្តិទេ ប៉ុន្តែវិការមួយនៃបឋវីធាតុ ដែលមានចិត្តគិតពោលពាក្យជាសមុដ្ឋាន ជាហេតុឲ្យខ្ទប់នឹងឧបាទិន្នករូប ដែលប្រព្រឹត្តទៅក្នុងស្ថានកើតនៃអក្ខរៈ ឈ្មោះថា **វចីវិញ្ញត្តិ** ។

ស្ថាន គឺ កន្លែងដែលឲ្យកើតសម្លេង មាន ៦ កន្លែងគឺ ក១ ពិដាន១ ក្បាលឬអញ្ចាញធ្មេញ១ ធ្មេញ១ បបូរមាត់១ ច្រមុះ ១ ហើយនិងគ្រឿងជំនួយទៀត គឺ អណ្តាត ។

វចីវិញ្ញត្តិរូប នេះផ្សេងពីកាយវិញ្ញត្តិរូប ដោយសេចក្តីថា សម្លេងតែងកើតព្រមជាមួយនឹងការខ្ទប់នៃបឋវីធាតុ នឹងឧបាទិន្នករូបប៉ុណ្ណោះ ហើយការខ្ទប់ទៀតសោត ក៏រមែងមានក្នុងជវនចិត្តទី ១ តទៅ ។

វិញ្ញត្តិរូបដែលបានពោលហើយ ទាំង ២ នេះ អ្នកណាមួយបានសម្តែងកិរិយាអាការបក់ដៃ ឬពោលឡើង ហើយអ្នកដទៃគប្បីដឹងនូវបំណងរបស់អ្នកនោះបាន ពីព្រោះការបក់ដៃ ឬ ការនិយាយនោះមានអាការពិសេសកើតជាមួយ អាការពិសេសនេះឯង ឈ្មោះថាវិញ្ញត្តិរូប ។

បើអាការពិសេសនោះ កើតឡើងដោយអាស្រ័យតាមផ្លូវកាយ ក៏ហៅថា **កាយវិញ្ញត្តិរូប** បើអាការពិសេសនោះ កើតឡើងដោយផ្លូវវាចា ក៏ហៅថា **វចីវិញ្ញត្តិរូប** ។

ប្រសិនមិនមានវិញ្ញត្តិរូបទាំង ២ នេះទេ អាការកម្រើកទាំង-ឡាយរបស់សត្វ ក៏មិនខុសអ្វីពីការកម្រើកនៃស្លឹកឈើ ឬមែកឈើឡើយ ហើយចំពោះសម្លេងរបស់សត្វវិញ ក៏មិនខុសអ្វីពីសម្លេងផ្គរលាន់ ឬសម្លេងភ្លៀងធ្លាក់នោះដែរ ។ កាលបើមានយ៉ាងនេះហើយ មនុស្សទាំងឡាយ ក៏មិនអាចដឹងកិរិយាអាការ ដែលសម្តែងចេញពីចិត្តសន្តាននៃគ្នានិងគ្នាបានឡើយ ។ ដូច្នេះអាការពិសេសដែលកើតនៅក្នុង អាការកម្រើកតាមកាយ និងការនិយាយរបស់មនុស្សទាំងឡាយនោះ ត្រូវតែមាន ដែល ហៅថា **វិញ្ញត្តិរូប** នោះឯង ៕

# ពួកទី ១០
# អំពី វិការរូប ៣

វិការរូប មានវចនត្ថៈថា **វិសេសោ អាការោ វិការោ** ប្រែថា អាការដែលជាពិសេសរបស់ និប្ផន្នរូប ឈ្មោះថា **វិការ** ។

ព្រះបាលីនេះសម្តែងឲ្យឃើញថា វិការរូបនេះ មិនមានសភាវៈរបស់ខ្លួនឯងដោយចំពោះទេ តែជាអាការពិសេសរបស់និប្ផន្នរូប ដែលកើតឡើងនោះប៉ុណ្ណោះឯង ។

វិការរូប មាន ៣ រូប គឺ :

១. **រូបលហុតា** រូបស្រាល ។
២. **រូបមុទុតា** រូបទន់ ។
៣. **រូបកម្មញ្ញតា** រូបដែលគួរដល់ការងារ ។

# ១. រូបលហុតា

រូបលហុតា មានវចនត្ថៈថា **លហុនោ ភាវោ លហុតា** ប្រែថា អាការដែលស្រាល ឈ្មោះថា **លហុតា** ។

**រូបស្ស លហុតា រូបលហុតា** ប្រែថា អាការស្រាលនៃនិប្ផន្នរូប ឈ្មោះថា **រូបលហុតា** បានដល់ រូបដែលធ្វើអាការឲ្យរាងកាយ ស្រាល ស្រួល មិនធ្ងន់ រហ័ស ក្នុងពេលប្រើឥរិយាបថ ឬ ការនិយាយចរចាផ្សេងៗ ប្រៀបបីដូចជាមនុស្សដែលមិនមានរោគបៀតបៀនដូច្នោះ ។

# លក្ខណាទិចតុក:របស់
# រូបលហុតា

- **អទន្ធតា　លក្ខណា** មានភាពស្រាល មិនយឺត ជាលក្ខណៈ ។
- **រូបានំ គរុភាវ វិនោទនរសា** មានការកម្ចាត់បង់នូវភាពធ្ងន់នៃរូប ជាកិច្ច ។
- **លហុបរិវត្តិតា បច្ចុប្បដ្ឋានា** មានភាពរហ័សវាងវៃ ជាផល។
- **លហុរូប　បទដ្ឋានា** មាននិប្ផន្នរូបដែលស្រាល ជាហេតុជិត ។

# ២. រូបមុទុតា

រូបមុទុតា មានវចនត្ថៈថា **មុទុនោ ភាវោ មុទុតា** ប្រែថា អាការដែលទន់ ឈ្មោះថា **មុទុតា** ។

**រូបស្ស មុទុតា រូបមុទុតា** ប្រែថា អាការទន់នៃនិប្ផន្នរូប

ឈ្មោះថា **រូបមុទុតា** បានដល់ អាការទន់ មិនរឹងនៃរាងកាយ ក្នុងពេលដែល ឱន ងើយ ពត់ខ្លួន ពត់ប្រាណ ជាដើមនោះបាន ស្រួល ប្រៀបដូចជាស្បែកសត្វ ដែលគេសម្លាប់ល្អហើយ ។

# លក្ខណាទិចតុកៈរបស់ រូបមុទុតា

- **អថទ្ធតា លក្ខណា** មានភាពទន់មិនរឹងជាលក្ខណៈ។
- **រូបានំ ថទ្ធភាវ វិនោទន រសា** មានការកម្ចាត់បង់នូវភាពរឹងនៃរូប ជាកិច្ច ។
- **សព្វក្រិយាសុ អវិរោធិតា បច្ចុប្បដ្ឋានា** មានការមិនជំទាស់ ដល់ការប្រព្រឹត្តិទាំងពួង មានឥរិយាបថជាដើម ជាផល ។
- **មុទុរូប បទដ្ឋានា** មាននិប្ផន្នរូបដែលទន់ ជាហេតុជិត ។

# ៣. រូបកម្មញ្ញតា

រូបកម្មញ្ញតា មានវចនត្ថៈថា **កម្មនិ សាធុ កម្មញ្ញំ** ប្រែថា សេចក្ដីល្អក្នុងការងារផ្សេងៗ ឈ្មោះថា **កម្មញ្ញះ** ។

**កម្មញ្ញស្ស ភាវោ កម្មញ្ញតា** ប្រែថា ភាវៈដែលជាសេចក្ដីល្អក្នុងការងារផ្សេងៗ ឈ្មោះថា **កម្មញ្ញតា** ។

**រូបស្ស កម្មញ្ញតា រូបកម្មញ្ញតា** ប្រែថា ភាវៈដែលជាសេចក្ដីល្អក្នុងការងារផ្សេងៗរបស់និប្ផន្នរូប ឈ្មោះថា **រូបកម្មញ្ញតា** បានដល់ អាការដែលសមគួរដល់ការងារនៃរាងកាយ គឺ ត្រូវការធ្វើអ្វីៗក្នុងឥរិយាបថណាៗ ឬ ត្រូវពោលវាចាអ្វីៗ ក៏ធ្វើបានស្រួលតាមបំណង ប្រៀបដូចជា មាសដែលគេរំលាយបានល្អហើយ សមគួរដល់ការធ្វើគ្រឿងប្រដាប់ផ្សេងៗដូច្នោះ ឧទាហរណ៍ បញ្ចុកអាហារ ឬ ទំពា ជាដើម ។

# លក្ខណាទិចតុកៈរបស់
# រូបកម្មញ្ញតា

**-កម្មញ្ញភាវ លក្ខណា** មានការសមគួរដល់ការងារ ជាលក្ខណៈ ។

**-អកម្មញ្ញភាវ វិនោទន រសា** មានការកម្ចាត់បង់ នូវភាពមិនសមគួរដល់ការងារ ជាកិច្ច ។

**-អទុព្វលភាវ បច្ចុប្បដ្ឋានា** មានការមិនទុព្វល គឺមិនខ្សោយ មិនថមថយ ជាផល ។

**-កម្មញ្ញរូប បទដ្ឋានា** មាននិប្ផន្នរូបដែលគួរដល់ការងារ ជាហេតុជិត ។

វិការរូប ទាំង ៣ នេះ តែងកើតមាននឹងរបស់ដែលមានជីវិតប៉ុណ្ណោះ ក្នុងខណៈដែលមានសេចក្តីសប្បាយកាយ សប្បាយចិត្ត មិនអាពាធ តែងកើតឡើងព្រមគ្នាទាំង ៣ ទាំងមិនប្រាសចាកពីគ្នាឡើយ តែ អាចលើសខ្វះជាងគ្នាបាន ដោយវិការនោះៗ ។

វិការរូបនេះ ជួនកាលក៏រាប់ថា មាន ៥ រូប ទាំងនេះដោយរាប់វិញ្ញត្តិរូប ២ ចូលរួមក្នុងវិការរូបផងដែរ ព្រោះជារូបដែលកើតបាននឹងរបស់មានជីវិតដូចគ្នា គឺថាការកម្រើកកាយនិងវាចានោះតែងប្រកបដោយ រូបលហុតា-មុទុតា-កម្មញ្ញតា សម្តែងការកម្រើក

ឥរិយាបថ ធំតូច ឬ ការនិយាយដែលប្រព្រឹត្តទៅបានដោយស្រួល មិនមានអាការ ទាស់អ្វីឡើយ ដូច្នេះហើយ ទើបវិការរូបនេះ ជួនកាលក៏រាប់ថា មាន ៥ យ៉ាង ។

# ពួកទី ១១
# អំពីលក្ខណរូប ៤

លក្ខណរូប គឺ រូបដែលមានកាលវេលាជាគ្រឿងចំណាំ កំណត់វិនិច្ឆ័យបាន ដូចមានវចនត្ថៈថា **លក្ខីយន្តិ វិនិច្ឆីយន្តិ ធម្មា ឥមេ សង្ខតាតិ ឯតេនាតិ លក្ខណំ** ប្រែថា ធម៌ទាំងឡាយដែលបណ្ឌិតកំណត់វិនិច្ឆ័យបានថា ធម៌ទាំងឡាយនេះ ជាសង្ខតៈដោយការអាស្រ័យរូបនេះ ដូច្នេះ រូបដែលជាហេតុនៃការកំណត់វិនិច្ឆ័យបាននោះ ទើបឈ្មោះថា **លក្ខណៈ** ។

រូបដែលជាហេតុនៃការកំណត់វិនិច្ឆ័យសង្ខតធម៌នោះ រមែងជារូបដែលបង្ហាញកាលវេលា ប្រាប់អាការតាក់តែងនៃសង្ខតធម៌នោះ បានដល់ លក្ខណរូប ៤ យ៉ាង គឺ ឧបចយរូប សន្តតិរូប ជរតារូប និង **អនិច្ចតារូប** ។

ធម៌មាន ២ យ៉ាង គឺ សង្ខតធម៌ ១ អសង្ខតធម៌ ១ ។

**សង្ខតធម៌** សំដៅយក ធម៌ទាំងឡាយដែលត្រូវតាក់តែង ដោយបច្ច័យផ្សេងៗ ដូច រូបធម៌រមែងអាស្រ័យ កម្ម ចិត្ត ឧតុ និង អាហារជាអ្នកតាក់តែង ។ ចំណែកនាមធម៌ គឺចិត្តចេតសិកនោះ រមែងអាស្រ័យ អតីតកម្ម អារម្មណ៍ និង ទ្វារ ជាអ្នកតាក់តែង ។ ដូច្នេះ **សង្ខតធម៌** គឺ ធម៌ដែលត្រូវបច្ច័យតាក់តែង បានដល់ **ចិត្ត ចេតសិក** និង **រូប** ។

**អសង្ខតធម៌** សំដៅយក ធម៌ដែលមិនត្រូវតាក់តែងដោយ ហេតុបច្ច័យណាៗឡើយ បានដល់ **និព្វាន** ( បញ្ញត្តិផ្សេងៗ ក៏ សង្គ្រោះជា អសង្ខតធម៌ដែរ ) ។

ម៉្យាងទៀត ក្នុងបណ្តាធម៌ដែលត្រូវតាក់តែងដោយបច្ច័យនេះ តែងមានខណៈ ៣ ខណៈ គឺ **ឧប្បាទខណៈ** ការកើតឡើង ១ , **ឋិតិខណៈ** ការតាំងនៅ ១ , **ភង្គខណៈ** ការរលត់ទៅ ១ , បើ ប្រៀបធៀបនឹងភាវៈ នៃសេចក្តីប្រព្រឹត្តិទៅរបស់សត្វ ក៏បានដល់ **ជាតិ ជរា** និង **មរណៈ** ប៉ុន្តែបើចំពោះ **លក្ខណរូប** គឺ រូបដែល ប្រាប់កំណត់កាលវេលា ក្នុងការតាក់តែងសង្ខតធម៌វិញ ក៏បានដល់ **ឧបចយៈ សន្តតិ** ( ទាំង ២ នេះ បានដល់ ជាតិ ) , **ជរតា**

(បានដល់ ការតាំងនៅ) , **អនិច្ចតា** (បានដល់ ការរលត់ទៅ) ហើយនឹងតែងមានសាមញ្ញលក្ខណៈ ៣ គឺ **អនិច្ចលក្ខណៈ** សេចក្តីមិនទៀង ១ , **ទុក្ខលក្ខណៈ** សេចក្តីជាទុក្ខ ១ និង **អនត្តលក្ខណៈ** ភាពមិនមែនខ្លួន ១ ។

# ១. ឧបចយរូប

ឧបចយរូប សំដៅដល់ រូបដែលកើតឡើងជាខណៈដំបូងក្នុងបដិសន្ធិកាល មានវចនត្ថៈថា **អាទិតោ ឧបរិតោ ច ចយោតិ ឧបចយោ** ប្រែថា ការកើតឡើងជាដំបូង និងការកើតឡើងជាខាងក្រោយៗ រហូតដល់រូបដែលគួរកើតឡើងបានគ្រប់ នៃនិប្ផន្នរូប ឈ្មោះថា **ឧបចយៈ** ។

ក្នុងបដិសន្ធិខណៈនៃសត្វទាំងឡាយ កម្មជរូបដែលកើតឡើងមុនដំបូងនៃភពឈ្មោះថា **ឧបចយៈ** ហើយរួមរហូតទៅដល់ការកើតឡើងនៃកម្មជរូប ដែលកើតនៅមិនទាន់គ្រប់ របស់គព្ភសេយ្យកសត្វដែលតែងនៅមានការកើតជារឿយៗ រហូតដល់សប្តាហ៍ទី១១ កម្មជរូបទើបកើតឡើងគ្រប់បរិបូរណ៍ ។ ដូច្នេះការកើតឡើងនៃកម្មជរូបដែលកើតបន្តបន្ទាប់ ពីបដិសន្ធិខណៈដំបូងមក រហូតដល់រូបកើតឡើងគ្រប់

បរិបូរណ៍ ឈ្មោះថា **ឧបចយៈ** ។

ចំណែកសត្វដែលជា **សំសេទជកំណើត** និង **ឱបបាតិក** កំណើតនោះ ក្នុងបដិសន្ធិខណៈ កម្មជរូបកើតឡើងគ្រប់តែម្តង ។

ដូច្នេះកម្មជរូបដែលកើតឡើង ចំពោះក្នុងបដិសន្ធិខណៈប៉ុណ្ណោះ ដែលឈ្មោះថា **ឧបចយៈ** ។

ចិត្តជរូប ឧតុជរូប អាហារជរូប ក៏ដូចគ្នា គឺ កាលណាកើតឡើងដំបូងក្តី កើតឡើងខាងក្រោយៗរហូតមានអវយវៈរបស់សត្វគ្រប់បរិបូរណ៍ក្តី ក៏ឈ្មោះថា **ឧបចយៈ** ដែរ ។

# លក្ខណាទិចតុក:របស់
# ឧបចយរូប

- **អាចយ លក្ខណោ** មានការកើតឡើងជាដំបូង ជាលក្ខណៈ ។

- **រូបានំ ឧម្មុជ្ជាបន រសោ** មានការធ្វើឲ្យរូប បានកើតចំរើនឡើង ជាកិច្ច ។

- **បរិបុណ្ណភាវ បច្ចុប្បដ្ឋានោ** មានសភាពគ្រប់បរិបូរណ៍ នៃរូបជាផល ។

- **ឧបចិតរូប បទដ្ឋានោ** មានរូបដែលកំពុងនឹងកើត ជាហេតុជិត ។

# ២ - សន្តតិរូប

សន្តតិរូប សំដៅដល់ ការកើតឡើងបន្តជាប់គ្នានៃនិប្ផន្នរូប មានវចនត្ថៈថា **សំ បុនប្បុនំ តតិ សន្តតិ** ប្រែថា ការកើតឡើងជារឿយៗ នៃនិប្ផន្នរូប ឈ្មោះថា **សន្តតិ** ។

ម្យ៉ាងទៀត **សម្ពន្ធាតតិ សន្តតិ** ប្រែថា ការកើតឡើងបន្តជាប់គ្នានៃនិប្ផន្នរូប ឈ្មោះថា **សន្តតិ** ។

កាលកម្មជរូបកើតឡើង គ្រប់បរិបូរណ៍ហើយ តពីនោះមក កម្មជរូបដែលកើតឡើងបន្តជាប់គ្នា រហូតដល់អស់ជីវិតនោះ ហៅថា **សន្តតិ** ។

ចិត្តជរូប ឧតុជរូប អាហារជរូប ក៏ដូចគ្នាអ៊ីចឹងដែរ កាលរូបទាំងនេះកើតឡើងគ្រប់បរិបូរណ៍ហើយ តពីនោះមករូបទាំងនេះកើតឡើងបន្តជាប់តគ្នាជារឿយៗ រហូតដល់អស់ជីវិតក៏ហៅថា **សន្តតិ** ។

# លក្ខណាទិចតុកៈរបស់សន្តតិរូប

- **បវត្តិ លក្ខណា** មានការចម្រើន ជាលក្ខណៈ។
- **អនុប្បពន្ធន រសា** មានការបន្តជាប់គ្នា ជាកិច្ច ។
- **អនុប្បច្ឆេទ បច្ចុប្បដ្ឋានា** ការមិនដាច់ពីគ្នា ជាផល ។
- **អនុប្បពន្ធរូប បទដ្ឋានា** មានរូបដែលនៅបន្តជាប់គ្នា ជាហេតុជិត ។

ក្នុងអត្ថសាលិនី និង វិសុទ្ធិមគ្គអដ្ឋកថា បានធ្វើនូវសេចក្ដីឧបមាឧបចយរូប និង សន្តតិរូប ថា ដូចអ្នកជីកអណ្ដូងក្បែរមាត់ទន្លេ ។ កាលជីករួចហើយថ្មីៗ ក៏មានទឹកផ្ដើមហូរចូលមកក្នុងអណ្ដូង ។ ការហូរគ្រាដំបូងនេះ ប្រៀបដូច ឧបចយរូប ដែលកើតឡើងក្នុងកាលគ្រាដំបូង តមកទឹកនោះក៏ហូរចូលមកជារឿយៗរហូតដល់ពេញ នេះប្រៀបដូច ឧបចយរូប ដែលកើតក្នុងកាលជាខាងក្រោយដែលតមកពីបដិសន្ធិខណៈ លុះទឹកពេញអណ្ដូងហើយ ក៏ហៀរចេញទៅតាមផ្ទៃដី នេះប្រៀបដូច សន្តតិរូប ។

# ៣. ជរតារូប

ជរតារូប សំដៅដល់ រូបដែលសម្ដែងភាវៈនៃសេចក្ដីចាស់នៃនិប្ផន្នរូប មានវចនត្ថៈថា **ជរានំ ភាវោ ជរតា** ប្រែថា ភាវៈនៃសេចក្ដីចាស់របស់និប្ផន្នរូប ឈ្មោះថា **ជរតា** ។

# លក្ខណាទិចតុកៈរបស់ជរតារូប

- **រូបបរិបាក លក្ខណា** មានការទ្រមគ្រាំគ្រានៃរូប ជាលក្ខណៈ ។
- **ឧបនយន រសា** មានការនាំទៅ នូវសេចក្ដីវិនាស គឺ ខិតចូលទៅជិតសេចក្ដីស្លាប់ ជាកិច្ច ។
- **នវភាវាបគមន បច្ចុប្បដ្ឋានា** មានការប្រាសពីសភាពថ្មី ផ្លាស់ទៅជាចាស់ ជាផល ។
- **បរិបច្ចនាមរូប បទដ្ឋានា** មានរូបដែលកំពុងគ្រាំគ្រា ជាហេតុជិត ។

តាមធម្មតា **ចតុជ្ជនិប្ផន្នរូប** គឺ រូបដែលកើតឡើងពីសមុដ្ឋាន ទាំង ៤ មាន កម្ម ចិត្ត ឧតុ និង អាហារ ទាំងនេះ កាលកើតឡើងហើយ អាយុរបស់រូបទាំងនោះ មានអាយុបាន ៥១ អនុខណៈនៃចិត្ត ។ ក្នុងចំនួន ៥១ អនុខណៈ នេះ ជាខណៈកើត ១ ខណៈ គឺ ខណៈទី ១ និងជាខណៈរលត់ ១ ខណៈ គឺ ខណៈទី ៥១ ចំណែកខណៈទី ២ រហូតដល់ខណៈទី ៥០ មានចំនួន ៤៩ អនុខណៈ នេះជាខណៈដែលតាំងនៅនៃនិប្ផន្នរូបនោះឈ្មោះថា **ជរតារូប** ដែលជាស្ថានទី មានសភាពកាន់តែចាស់គ្រាំគ្រាឡើងៗនោះឯង ។

# ៤. អនិច្ចតារូប

អនិច្ចតារូប សំដៅដល់ រូបដែលកំពុងបែកធ្លាយរលត់ មានឈ្មោះហៅថា មរណរូប ឬ ភង្គរូប ក៏បាន មានវចនត្ថៈថា **អនិច្ចតា ភាវោ អនិច្ចតា** ប្រែថា ភាវៈនៃសេចក្តីរលត់នៃនិប្ផន្នរូប ឈ្មោះថា **អនិច្ចតា** ។

## លក្ខណាទិចតុកៈរបស់
## អនិច្ចតារូប

- **បរិភេទ លក្ខណា** មានការបែកធ្លាយ ជាលក្ខណៈ។
- **សំសីទន រសា** មានការលិចស្រុតចុះទៅ ជាកិច្ច។
- **ខយវយ បច្ចុប្បដ្ឋានា** មានការសូន្យទៅ អស់ទៅ ជាផល ។
- **បរិភិជ្ជមានរូប បទដ្ឋានា** មានរូបដែលកំពុងវិនាស ជាហេតុជិត ។

អនិច្ចតារូប នេះ សំដៅយក ខណៈរលត់របស់រូប គឺ ខណៈទី ៥១ នោះឯង ។ ដូច្នេះ **ជរតារូប** និង**អនិច្ចតារូប** ទាំង ២ នេះ មាននៅក្នុងនិប្ផន្នរូបដែលកើតឡើងតាំងពីបដិសន្ធិខណៈជាដើមទៅរហូតដល់ខណៈដែលសត្វនោះស្លាប់ ។

លក្ខណរូបទាំង ៤ ដែលបានសម្តែងរួចមកហើយនេះ សម្តែងតាមបរមត្ថន័យ ហៅថា **បរមត្ថជាតិ បរមត្ថជរា បរមត្ថ-មរណៈ** ។

ជាតិ ជរា មរណៈ ដែលសម្តែងទុកក្នុងព្រះសូត្រនោះ ហៅថា **សម្មតិជាតិ សម្មតិជរា សម្មតិមរណៈ** គឺ ខណៈដែលសត្វ

ទាំងឡាយ កើតក្នុងគភ៌មាតា រហូតដល់ប្រសូតចេញមក ហៅថា **ជាតិ** គឺ កើត , ខណៈដែលអស់ជីវិត គឺ ស្លាប់ ហៅថា **មរណៈ** និងនៅក្នុងរវាងកើត និង ស្លាប់នោះ ហៅថា **ជរា** ។

សេចក្តីពិត សភាពនៃជរាមាន ២ យ៉ាង គឺ :

**១. បដិច្ឆន្នជរា** គឺ សេចក្តីជរាដែលមិនប្រាកដ ។
**២. បាកដជរា** គឺ សេចក្តីជរាដែលប្រាកដ ។

បណ្តាសត្វទាំងឡាយ ដែលប្រសូតពីគភ៌មាតាហើយ ដល់ធំពេញកំលោះក្រមុំឡើង ដែលអាការសក់ស្កូវ ធ្មេញបាក់ជាដើម នៅមិនទាន់ប្រាកដទេនោះ ក្នុងរវាងនេះភាពជរាក៏មានហើយដែរ ប៉ុន្តែគឺជាភាពជរាមួយបែប ហៅថា **បដិច្ឆន្នជរា** គឺ ភាពជរាដែលមិនប្រាកដ ។ កាលអ្នកនោះកន្លងផុតវ័យកំលោះក្រមុំ ចូលដល់អាការសក់ស្កូវ ធ្មេញបាក់ជាដើម ប្រាកដឡើងហើយ ភាពជរាក៏បង្ហាញឲ្យដឹង ទើបហៅថា **បាកដជរា** គឺ ភាពជរាដែលប្រាកដ ។

សូម្បីក្នុងបណ្តារូបទាំងឡាយដែលជា អនិន្ទ្រិយពន្ធរូប គឺ រូបដែលមិនមានជីវិត ដូចជាភ្នំ ដើមឈើ ដី ទឹក ជាដើម និង វត្ថុផ្សេងៗដែលមាននៅក្នុងលោកនេះ ក៏រមែងមានភាពជរាចូលមកគ្រប

សង្កត់ញាំញីដូចគ្នាទាំងអស់។ ភាពជរានៃវត្ថុទាំងនេះ ក៏មាន ២ យ៉ាង ដូចគ្នា ពួករូបខ្លះក៏មានតែ បដិច្ឆន្នជរា តែម្យ៉ាង បានដល់ ដី ទឹក ភ្នំ ព្រះអាទិត្យ ព្រះចន្ទ ពេជ្រ ត្បូង កែវ ទាំងនេះជាដើម ជាភាពជរាដែលមិនប្រាកដ ឬហៅថា **អវីចិជរា** គឺជរាដែលដឹងបានដោយលំបាក ព្រោះមិនមានឱកាសនឹងបានឃើញ ។

ចំណែកដើមឈើនិងវត្ថុផ្សេងៗក្រៅពី ដី ទឹក ភ្នំ ព្រះអាទិត្យ ព្រះចន្ទ ពេជ្រ ត្បូង កែវជាដើមទាំងនេះ មានទាំង បដិច្ឆន្នជរា ទាំង បាកដជរា ។ ដូច្នេះជរានៅក្នុងរូបប្រភេទសនេះ ហៅថា **សវីចិជរា** គឺ ភាពជរាដែលដឹងបានងាយ ព្រោះមានឱកាសអាចប្រាកដឲ្យឃើញបាន ។

ក្នុងអដ្ឋសាលិនីអដ្ឋកថារូបកណ្ឌ សម្តែង ជាតិ ជរា មរណៈថា ធម៌ទាំង ៣ នេះ ប្រហែលនឹងបច្ចាមិត្ត ៣ នាក់ តាមស្វែងរក តាមនាំបបួល តាមបៀតបៀន កាប់សម្លាប់សត្វលោកជានិច្ច ។

កាលបើសរុបសេចក្តីក្នុងលក្ខណរូប ៤ ទៅ ក៏មានត្រឹមតែ ៣ យ៉ាងប៉ុណ្ណោះ គឺមានលក្ខណៈកើតឡើង ១ លក្ខណៈតាំងនៅ ១ និងលក្ខណៈរលត់ ១ **ឧបចយៈ** និង **សន្តតិ** រួមនៅក្នុងការកើត **ជរតា** នៅក្នុងការតាំងនៅ **អនិច្ចតា** នៅក្នុងការរលត់ ។

ដូច្នេះលក្ខណរូបនេះ បង្ហាញនូវសាមញ្ញលក្ខណៈរបស់និប្ផន្នរូប ដែលនឹងអាចផ្ទុះបញ្ចាំងឲ្យវិបស្សនាបញ្ញា ឃើញនូវសភាពជាត្រៃ-លក្ខណ៍បាន ៕

# ២. រូបវិភាគន័យ

**រូបវិភាគន័យ** ជាការចែករូបចេញដោយពិស្តារ ដើម្បីឲ្យដឹងទូលំទូលាយឡើង គឺថា ជាការសម្តែងការចែករូប ២៨ ចេញជា **មាតិកា** ឬ **មេបទ** ។ ក្នុងទីនេះ មានមាតិកា ២ គឺ ឯកមាតិកា ១ និង ទុកមាតិកា ១ ។

## ១. ឯកមាតិកា

**ឯកមាតិកា** ជាការសម្តែងមេបទរបស់រូបធម៌ទាំង ២៨ រូប ដែលមានអត្ថ និងមានប្រភេទតែម្យ៉ាងដូចគ្នា ។ តាមអត្ថក្នុងសភាវៈរូប ២៨ ទាំងអស់នេះ មានឈ្មោះ ៨ យ៉ាង គឺ :

**១.**ឈ្មោះថា **អហេតុកៈ** រូបដែលឈ្មោះថា សហេតុកៈ មិនមាន ព្រោះមិនប្រកបដោយហេតុ ៦ ណា

មួយ មានអលោភហេតុជាដើម ។

២.ឈ្មោះថា **សប្បច្ចយះ** រូបដែលឈ្មោះថា អប្បច្ចយះ មិនមាន ព្រោះមានបច្ច័យ ៤ បានដល់ កម្ម ចិត្ត ឧតុ អាហារ ជាសមុដ្ឋានធ្វើឲ្យ រូបកើត ។

៣.ឈ្មោះថា **សាសវះ** រូបដែលឈ្មោះថា អនាសវះ មិនមាន ព្រោះរមែងជាអារម្មណ៍របស់សាសវធម៌ គឺ កាមាសវះ ភវាសវះ ទិដ្ឋាសវះ និង អវិជ្ជាសវះ ។

៤.ឈ្មោះថា **សង្ខតះ** រូបដែលឈ្មោះថា អសង្ខតះ មិនមាន ព្រោះត្រូវតាក់តែងដោយបច្ច័យ៤ ដែល មានកម្ម ចិត្ត ឧតុ និង អាហារ ជា តួការតាក់តែង ។

៥.ឈ្មោះថា **លោកិយះ** រូបដែលឈ្មោះថា លោកុត្តរះ មិនមាន ព្រោះជាធម៌ដែលសង្គ្រោះចូលក្នុងសង្ខារ លោកនៃឧបាទានក្ខន្ធ មានសភាព ដែលត្រូវវិនាសជានិច្ច ។

៦.ឈ្មោះថា **កាមាវចរះ** រូបដែលឈ្មោះថា រូបាវចរះ អរូបាវចរះ

មិនមាន ព្រោះជាទីស្នុះទៅនៃកាម-តណ្ហា ឬ ជាអារម្មណ៍របស់កាមាវចរចិត្ត ម្យ៉ាងប៉ុណ្ណោះ ។

**៧.**ឈ្មោះថា **អនារម្មណៈ** រូបដែលឈ្មោះថា សារម្មណៈ មិនមាន ព្រោះមិនអាចទទួលដឹងអារម្មណ៍ បាន ដូចជា ចិត្ត ចេតសិក ដែលជានាមធម៌ឡើយ ។

**៨.**ឈ្មោះថា **អប្បហាតព្វៈ** រូបដែលឈ្មោះថា បហាតព្វៈ មិនមាន ព្រោះរូបទាំងអស់ មិនមែនជាកិលេសដែលនឹងគប្បីប្រហារ មានតទង្គប្ប-ហានជាដើមឡើយ ។

រូប ២៨ ទាំងអស់នេះ ជាការសម្តែងដោយចំណែកតែមួយ មិនមានប្រភេទដែលផ្ទុយគ្នាដោយប្រការណាមួយឡើយ ដូច្នេះ ទើបមាន ឈ្មោះថា **ឯកមាតិកា** ។

# ២. ទុកមាតិកា

**ទុកមាតិកា** ជាការសម្តែងមេបទ នៃរូបធម៌ទាំង ២៨ នោះ

ជា ២ ចំណែក ឬ ជាគូៗ គឺ មានប្រភេទដែលផ្ទុយគ្នា ។ រូប-ធម៌ទាំងអស់ កាលបើចែកចេញជាគូៗហើយ គឺចែកបាន ១១ គូ ដូចតទៅនេះ :

# គូទី ១
# អជ្ឈត្តិករូប និង ពាហិររូប

**អជ្ឈត្តិករូប** គឺ រូបខាងក្នុង មាន ៥ បានដល់ បសាទរូប ៥ ។

**ពាហិររូប** គឺ រូបខាងក្រៅ សំដៅយក រូបដែលក្រៅពី បសាទរូប ៥ មាន ២៣ បានដល់ រូបដែលនៅសល់ ២៣ ។

ពាក្យថា **រូបខាងក្នុង** នេះមិនបានសំដៅយក រូបដែលកើតឡើង ខាងក្នុងរាងកាយសត្វទាំងឡាយទេ គឺ សំដៅដល់រូបដែលមានប្រយោជន៍ ជួយឲ្យចិត្តទទួលនូវអារម្មណ៍ ជាបញ្ចទ្វារនៃចិត្ត និងជួយធ្វើកិច្ចការដល់សត្វទាំងឡាយបានច្រើន ។ រាងកាយនៃសត្វទាំងឡាយ បើមិនមានបសាទរូប ៥ នោះហើយ ក៏មិនអាចនឹងធ្វើ

អ្វីៗ បានដែរ មិនខុសពីកំណាត់ឈើ ឬ តុក្កតាឡើយ ។ ដូច្នេះ បសាទរូបទាំង ៥ នេះ ទើបចាត់ថា ជារូបមានប្រយោជន៍ច្រើន ទើបតាំងឈ្មោះថា **រូបខាងក្នុង** ដូចជាមនុស្សដែលមានប្រយោជន៍ជួយកិច្ចការផ្សេងៗ បានច្រើន គេក៏តែងហៅថា អ្នកខាងក្នុង ដូចគ្នា។

ចំណែករូបដែលនៅសល់ ២៣ ទៀត ហៅថា **រូបខាងក្រៅ** ព្រោះមិនមានសេចក្ដីសំខាន់ក្នុងរាងកាយស្មើនឹង បសាទរូបទេ ប្រៀបដូចជាមនុស្សខាងក្រៅ ជួយកិច្ចការបានខ្លះ តែមិនច្រើនដូចអ្នកខាងក្នុងឡើយ ។

## គូទី ២
## វត្ថុរូប និង អវត្ថុរូប

**វត្ថុរូប** គឺ រូបដែលជាទីអាស្រ័យកើតនៃចិត្ត និង ចេតសិក មាន ៦ បានដល់ បសាទរូប ៥ និង ហទយរូប ១ ។

**អវត្ថុរូប** គឺ រូបដែលមិនជាទីអាស្រ័យកើតនៃចិត្ត និង ចេតសិក មាន ២២ បានដល់ រូបដែលនៅសល់ ២២ ។

ធម្មជាតិចិត្តនិងចេតសិកនៃសត្វទាំងឡាយ ដែលកើតក្នុងបញ្ច-វោការភូមិនោះ នឹងកើតឡើងគឺ ត្រូវមានទីអាស្រ័យដូចអណ្តាតភ្លើង ដែលត្រូវអាស្រ័យប្រឆេះឲ្យកើតជាដួងភ្លើង ឲ្យភ្លឺយ៉ាងណា ចិត្ត និង ចេតសិកក៏ដូចគ្នា រមែងត្រូវការទីតាំង ទីអាស្រ័យ ឲ្យកើតការដឹង អារម្មណ៍ផ្សេងៗបាន ។ ទីអាស្រ័យកើតនៃ ចិត្ត និង ចេតសិក នោះ បានដល់ បសាទរូប ៥ ហទយរូប ១ ពោលគឺ បសាទរូប ៥ ជាទីអាស្រ័យកើតនៃ ទ្វិបញ្ចវិញ្ញាណចិត្ត ១០ និងចេតសិកប្រកប ៧ ហទយរូប ១ ជាទីអាស្រ័យកើតនៃចិត្ត ៧៥ (វៀរទ្វិបញ្ចវិញ្ញាណ ១០ អរូបវិបាកចិត្ត ៤) និង ចេតសិក ៥២ រូបទាំង ៦ នេះ ហៅថា **វត្ថុរូប** ។

ចំណែករូបដែលនៅសល់ ២២ ទៀត មិនមែនជាទីអាស្រ័យនៃចិត្តនិងចេតសិកទេ ទើបបានឈ្មោះថា **អវត្ថុរូប** ។

# គូទី ៣
# ទ្វាររូប និង អទ្វាររូប

**ទ្វាររូប** គឺ រូបដែលជាហេតុនៃការកើតឡើងបញ្ចទ្វារវិថី និង ជាហេតុនៃ កាយកម្ម វចីកម្ម មាន ៧

រូប បានដល់ បសាទរូប ៥ និង វិញ្ញត្តិរូប ២ ។

**អទ្វាររូប** គឺ រូបដែលមិនមែនជាហេតុនៃការកើតឡើងនៃបញ្ចទ្វារវិថី និង កាយកម្ម វចីកម្ម មាន ២១ រូប បានដល់ រូបដែលនៅសល់ ២១ ។

ធម្មតាសត្វទាំងឡាយ ដែលកើតក្នុងបញ្ចវោការភូមិនោះ ការកើតឡើងនៃវិថីចិត្តក្តី ឬ ការកើតឡើងនៃកាយកម្ម និង វចីកម្មទាំងនេះក្តី រមែងត្រូវអាស្រ័យទ្វាររូប ៧ ជាហេតុ ពោលគឺ ការកើតឡើងនៃបញ្ចទ្វារវិថីនោះ ត្រូវមានបសាទរូប ៥ ជាហេតុឲ្យកើត ដូច្នោះ បសាទរូប ៥ នេះ ទើបមានឈ្មោះថា **ឧប្បត្តិទ្វារ** មានន័យថា រូបដែលជាហេតុនៃការកើតឡើងនៃបញ្ចទ្វារវិថី ។

ចំណែកការកើតឡើងនៃការប្រព្រឹត្តិផ្សេងៗ នឹងជា សុចរិតក្តី ទុច្ចរិតក្តី វៀរកាយវិញ្ញត្តិចេញហើយ ការប្រព្រឹត្តិនោះៗ ភាគច្រើនក៏កើតឡើងមិនបាន ។ ការពោលវាចាផ្សេងៗ ដែលជាសុចរិត ឬ ទុច្ចរិតនោះក៏ដូចគ្នា នឹងកើតឡើងបាន ក៏ត្រូវអាស្រ័យវចីវិញ្ញត្តិ វៀរវចីវិញ្ញត្តិចេញហើយ ការនិយាយផ្សេងៗក៏កើតឡើងមិនបាន ។ ដូច្នេះ វិញ្ញត្តិរូបទាំង ២ នេះ ទើបមានឈ្មោះថា **កម្មទ្វារ** មានន័យថា រូប

ដែលជាហេតុឲ្យកើត កាយកម្ម វចីកម្ម ។

ចំណែករូបដែលនៅសល់ ២១ ទៀត ក្រៅពីបសាទរូប ៥ និង វិញ្ញត្តិរូប ២ រូបទាំងនេះ មិនមែនជារូបដែលជាហេតុឲ្យកើតវិថីចិត្ត និង ឲ្យកើតកាយកម្ម វចីកម្មទេ ទើបឈ្មោះថា **អទ្វាររូប** ។

# គូទី ៤
# ឥន្ទ្រិយរូប និង អនិន្ទ្រិយរូប

**ឥន្ទ្រិយរូប** គឺ រូបដែលជាធំ ជាអ្នកគ្រប់គ្រងក្នុងការឃើញជាដើម មាន ៨ បានដល់ បសាទរូប ៥ ភាវរូប ២ និង ជីវិតរូប ១ ។

**អនិន្ទ្រិយរូប** គឺ រូបដែលមិនជាធំ មិនមែនជាអ្នកគ្រប់គ្រង មាន ២០ បានដល់ រូបដែលនៅសល់ ២០ ។

រូបដែលគ្រប់គ្រង មានសភាពជាធំក្នុងការទទួលដឹងអារម្មណ៍ផ្សេងៗ មានការឃើញ ការឮ ការដឹងក្លិនជាដើម ការឃើញនឹង

កើតឡើងបាន គឺ ត្រូវអាស្រ័យ**ចក្ខុបសាទ**ជាធំ ជាអ្នកគ្រប់គ្រង បើគ្មានចក្ខុបសាទទេ ការឃើញរមែងកើតឡើងមិនបាន ឬ ការដែលនឹងឃើញបានឆ្ងាយ បានជិត ច្បាស់ ឬ មិនច្បាស់នោះ អាស្រ័យដោយចក្ខុបសាទ បើចក្ខុបសាទល្អ មានកម្លាំងច្រើន ក៏ឃើញបានឆ្ងាយនិងឃើញបានច្បាស់ ។ ដោយចក្ខុបសាទជាធំ ជាអ្នកគ្រប់គ្រងក្នុងការឃើញទាំងអស់ ទើបបានឈ្មោះថា **ឥន្ទ្រិយរូប** ។ **សោតបសាទ ឃានបសាទ ជិវ្ហាបសាទ** និង **កាយបសាទ** ក៏ប្រព្រឹត្តទៅមានទំនងដូចគ្នា ទើបបានឈ្មោះថា **ឥន្ទ្រិយរូប** ដែរ ។

**ឥត្ថីភាវរូប** ជាធំ ជាអ្នកគ្រប់គ្រងសភាពជាភេទស្រីទូទៅ ក្នុងសរីរៈរាងកាយនៃសត្វ មិនឲ្យប្រឡំនឹងភេទដទៃ ។

**បុរិសភាវរូប** ជាធំ ជាអ្នកគ្រប់គ្រងសភាពជាភេទប្រុសទូទៅ ក្នុងសរីរៈរាងកាយនៃសត្វ។

ដោយភាវរូបទាំង ២ នេះ គ្រប់គ្រងនូវភាពជាធំ ក្នុងភេទស្រី ឬ ភេទប្រុស ទូទៅក្នុងសរីរៈនៃសត្វយ៉ាងនេះ ទើបមានឈ្មោះថា **ឥន្ទ្រិយរូប** ។

**ជីវិតរូប** ជាធំ ជាអ្នកគ្រប់គ្រងក្នុងការរក្សាកម្មជរូបដែលកើតព្រមនឹងខ្លួន ឲ្យតាំងនៅរហូតដល់គ្រប់អាយុនៃរូប ពោលគឺ កាលណាកម្មជរូបប្រាកដឡើង ក៏មានជីវិតរូបកើតព្រមជាមួយ ហើយធ្វើនាទីរក្សារូប ដែលកើតពីកម្មនោះ ។ ដោយជីវិតរូបជាធំ ជាអ្នកគ្រប់គ្រងក្នុងការរក្សាកម្មជរូប ដែលកើតព្រមនឹងខ្លួនយ៉ាងនេះ ទើបមានឈ្មោះថា **ឥន្ទ្រិយរូប** ។

ចំណែករូបដែលសល់ពីនោះ ២០ រូបទៀត មិនបានជាធំ ជាអ្នកគ្រប់គ្រងក្នុងកិច្ចណាៗទេ ទើបមានឈ្មោះថា **អនិន្ទ្រិយរូប** ។

# គូទី ៥
# ឱឡារិករូប និង សុខុមរូប

**ឱឡារិករូប** ជារូបគ្រោតគ្រាត គឺ រូបដែលប្រាកដ ច្បាស់ មាន ១២ រូប បានដល់ បសាទរូប ៥ និង វិសយរូប ៧ ។

**សុខុមរូប** ជារូបល្អិត គឺ រូបដែលមិនប្រាកដច្បាស់ មាន ១៦ រូប បានដល់ រូបដែលនៅសល់ ១៦ ។

បសាទរូប ៥ និង វិសយរូប ៧ រួម ១២ រូបនេះ ជារូបគ្រោតគ្រាត មិនមែនសំដៅយកសេចក្តីគ្រោតគ្រាតនៃរូបនោះទេ គឺសំដៅយកការប្រាកដច្បាស់ គឺរូបទាំងនេះ កាលណាពិចារណាដោយបញ្ញាហើយ ក៏ប្រាកដបានច្បាស់ច្រើន ដូចរូប សម្លេង ក្លិន រស និងត្រជាក់ក្តៅ រឹងទន់ តឹងញ័រ រមែងងាយស្រួលដឹងបាន ព្រោះប្រាកដច្បាស់ ជារូបដែលឃើញបាន ឮបាន ធុំក្លិនបាន ក្រេបរសបាន និងប៉ះពាល់បាន ឯបសាទរូបទាំង ៥ ក៏ត្រូវធ្វើការរួមនឹងវិសយរូប ៧ ទាំងនោះដែរ ទើបចាត់ជា **ឱឡារិករូប** ព្រោះធ្វើការនឹងបញ្ចទ្វារជាមួយគ្នា ។

ចំណែករូបដែលនៅសល់ ១៦ រូបទៀត រូបទាំងនោះ កាលណាពិចារណាដោយបញ្ញាហើយ ក៏មិនប្រាកដច្បាស់ ដូចអាបោ គឺ រូបទឹក ដែលសម្តែងការហូរ ឬ ការកកផ្តុំ ហទយរូប ជីវិតរូប ជាដើម រមែងលំបាកដឹងបាន ព្រោះមិនប្រាកដច្បាស់ ដូច្នេះឯង រូបដែលនៅសល់ ទើបឈ្មោះថា **សុខុមរូប** ជារូបដែលដឹងមិនបាន តាមបញ្ចទ្វារ ដឹងបានចំពោះតែមនោទ្វារប៉ុណ្ណោះ ។

# គូទី ៦

# សន្តិកេរូប និង ទូរេរូប

**សន្តិកេរូប** គឺ រូបជិត សំដៅយករូបដែលងាយស្រួលដឹងបាន មាន ១២ រូប បានដល់ បសាទរូប ៥ និង វិសយរូប ៧ ។

**ទូរេរូប** គឺ រូបឆ្ងាយ សំដៅយករូបដែលលំបាកដឹងបាន មាន ១៦ រូប បានដល់ រូបដែលនៅសល់ ១៦ ។

បសាទរូប ៥ និង វិសយរូប ៧ ដែលជាឱឡារិករូប នោះឯង ជាសន្តិកេរូបនោះ ។ សន្តិកេរូបនេះ សំដៅដល់រូបជិត ព្រោះជារូបដែលកើតឡើងជានិច្ចជាកាលមិនដែលដាច់ ពោលគឺ រូបដែលឲ្យកើតការឃើញ ការឮ ការធុំក្លិន ការដឹងរស និង ការដឹងនូវផោដ្ឋព្វៈ មានជានិច្ច មិនស្ងៀមទំនេរ ជារបស់ជិតដែលកើតឡើងជារឿយៗនោះឯង កាលពិចារណាដោយបញ្ញា រមែងដឹងដោយងាយ ដូចជាមនុស្សដែលនៅជិត រមែងហៅប្រើបានងាយ យ៉ាងណា **សន្តិកេរូប** ទើបសំដៅយក រូបជិត ក៏យ៉ាងនោះដែរ ។

ចំណែករូបដែលនៅសល់ ១៦ រូបទៀត ជារូបដែលពិចារណាដោយបញ្ញាហើយ ក៏នៅតែលំបាកដឹងបាន ព្រោះមិនបានកើតឡើងជារឿយៗ ដូច្នេះ ទើបឈ្មោះថា **ទូររូប** គឺ រូបឆ្ងាយ ។

# គូទី ៧
# សប្បដិឃរូប និង អប្បដិឃរូប

**សប្បដិឃរូប** គឺ រូបដែលប៉ះត្រូវគ្នានិងគ្នាបាន មាន ១២ រូប បានដល់ បសាទរូប ៥ និង វិសយរូប ៧ ។

**អប្បដិឃរូប** គឺ រូបដែលប៉ះត្រូវគ្នា និង គ្នាមិនបាន មាន ១៦ រូប បានដល់ រូបដែលនៅសល់ ១៦ ។

បសាទរូប ៥ និងវិសយរូប ៧ រួម ១២ រូបនេះ ជារូបដែលប៉ះត្រូវគ្នានិងគ្នាបានតាមសភាវៈ ដូច ចក្ខុបសាទប៉ះត្រូវនឹងរូបារម្មណ៍ , សោតបសាទប៉ះត្រូវនឹងសទ្ទារម្មណ៍ , ឃានបសាទប៉ះត្រូវនឹងគន្ធារម្មណ៍ , ជិវ្ហាបសាទប៉ះត្រូវនឹងរសារម្មណ៍ , កាយបសាទប៉ះ

ត្រូវនឹងផោដ្ឋព្វារម្មណ៍ , នុ៎ះក៏គឺ ការប៉ះត្រូវគ្នានិងគ្នារវាងបសាទរូប ៥ និងវិសយរូប ៧ ជាហេតុឲ្យទ្វិបញ្ចវិញ្ញាណចិត្តកើតឡើង ដូច្នេះឯង រូបដែលប៉ះត្រូវគ្នានិងគ្នាបាននោះ ទើបឈ្មោះថា **សប្បដិឃ-រូប** ។

ចំណែករូបដែលនៅសល់ ១៦ ទៀតនោះ ជារូបដែលប៉ះត្រូវគ្នានិងគ្នាមិនបានតាមសភាវៈឡើយ ទើបឈ្មោះថា **អប្បដិឃរូប** ។

# គូទី ៨
# ឧបាទិន្នករូប និង អនុបាទិន្នករូប

**ឧបាទិន្នករូប** គឺ រូបដែលកើតឡើងពីអកុសលកម្មនិងលោកិយកុសល មាន ១៨ រូប បានដល់ កម្មជរូប ១៨ ។

**អនុបាទិន្នករូប** គឺ រូបដែលមិនបានកើតពីអកុសលកម្មនិងលោកិយកុសល មាន ៤០ រូប បានដល់ ចិត្តជរូប ១៥ ឧតុជរូប ១៣ អាហារជរូប ១២ ។

កម្មជរូប ១៨ បានដល់ មហាភូតរូប ៤ បសាទរូប ៥ វណ្ណរូប ១ គន្ធរូប ១ រសរូប ១ អាហាររូប ១ ភាវរូប ២ ហទយរូប ១ ជីវិតរូប ១ បរិច្ឆេទរូប ១ ឈ្មោះថា **ឧបាទិន្នករូប** ក៏ព្រោះជាផលដែលកើតពីអកុសលកម្ម និងលោកិយកុសលកម្មដែលមានតណ្ហានិងទិដ្ឋិកាន់យក គឺ ចូលទៅធ្វើឲ្យជាអារម្មណ៍ ។ ដោយយ៉ាងនេះឯង កម្មជរូប ១៨ នេះ ទើបឈ្មោះថា **ឧបាទិន្នករូប** ។

ចំណែករូបដែលកើតពី ចិត្ត ឧតុ និង អាហារ រូបទាំងនេះមិនមែនកើតឡើងដោយសភាពជាផលរបស់ អកុសលកម្ម និងលោកិយកុសលកម្មទេ តែជាផលដែលកើតពី ចិត្ត ឧតុ និង អាហារប៉ុណ្ណោះ ទើបឈ្មោះថា **អនុបាទិន្នករូប** ។

# គូទី ៩
# សនិទស្សនរូប និង អនិទស្សនរូប

**សនិទស្សនរូប** គឺ ជារូបដែលឃើញបានដោយភ្នែក មាន ១ បានដល់ វណ្ណរូប គឺ រូបារម្មណ៍។

**អនិទស្សនរូប** គឺ រូបដែលឃើញដោយភ្នែកមិនបាន

មាន ២៧ រូប បានដល់ រូបដែល
នៅសល់ ២៧ ។

**វណ្ណរូប** បានដល់ រូបារម្មណ៍ គឺ ពណ៌ផ្សេងៗតែម្យ៉ាងប៉ុណ្ណោះ ជារូបដែលអាចឃើញបានដោយភ្នែក ទើបឈ្មោះថា **សនិទស្សនរូប**។

ចំណែករូបនៅសល់ ២៧ ទៀតនោះ ជារូបដែលមិនអាចឃើញបានដោយភ្នែក ទើបឈ្មោះថា **អនិទស្សនរូប** ។

# គូទី ១០
# គោចរគាហិករូប និងអគោចរគាហិករូប

**គោចរគាហិករូប** គឺ រូបដែលអាចទទួលចាប់នូវ បញ្ចារម្មណ៍បាន មាន ៥ បានដល់ បសាទរូប ៥ ។

**អគោចរគាហិករូប** គឺ រូបដែលមិនអាចទទួលចាប់នូវ បញ្ចារម្មណ៍បាន មាន ២៣ រូប បានដល់ រូបដែលនៅសល់ ២៣ ។

បសាទរូប ៥ ឈ្មោះថា **គោចរគាហិករូប** ព្រោះជារូបដែលមានសភាពថា អាចទទួលបញ្ចារម្មណ៍បាន ពោលគឺ ចក្ខុ-បសាទអាចទទួលរូបារម្មណ៍ ធ្វើឲ្យកើតការឃើញ , សោតបសាទអាចទទួលសទ្ទារម្មណ៍ ធ្វើឲ្យកើតការឮ , ឃានបសាទអាចទទួលគន្ធារម្មណ៍ ធ្វើឲ្យកើតការធុំក្លិន , ជិវ្ហាបសាទអាចទទួលរសារម្មណ៍ ធ្វើឲ្យកើតការដឹងរស , កាយបសាទអាចទទួលផោដ្ឋព្វារម្មណ៍ ធ្វើឲ្យកើតការដឹងផោដ្ឋព្វៈ ។

ក្នុងបណ្ដាគោចរគាហិករូបទាំង ៥ រូបនេះចែកចេញជា ២ គឺ :

**១. អសម្បត្តគោចរគាហិករូប** គឺបសាទរូបដែលអាចទទួលអារម្មណ៍ ដែលមិនទាន់មកដល់ខ្លួនបាន មាន ២ រូប បានដល់ ចក្ខុបសាទរូប និង សោតបសាទរូប ។

**២. សម្បត្តគោចរគាហិករូប** គឺ បសាទរូបដែលអាចទទួលអារម្មណ៍ ដែលមកដល់ខ្លួន គឺ បានប៉ះត្រូវហើយនោះឯង បានដល់ ឃានបសាទរូប ជិវ្ហាបសាទរូប និង កាយបសាទរូប ។

ធម្មតា**ចក្ខុបសាទ**តែងទទួលរូបារម្មណ៍បាន ដោយអាស្រ័យពន្លឺ ប៉ះត្រូវវត្ថុនោះ ហើយក៏ចាំងមកប៉ះខ្ទប់នឹងចក្ខុបសាទ ធ្វើឲ្យកើតការឃើញឡើង មិនមែនវត្ថុដែលសម្ដែងរូបារម្មណ៍នោះ មកប៉ះត្រូវនឹងចក្ខុបសាទចំៗទេ ។ បើរូបារម្មណ៍នោះ ចូលមកដល់ហើយ

ចក្ខុបសាទ ក៏មិនអាចទទួលបាន ដូចលូកដៃដាក់ដល់ភ្នែក យើងមិនអាចមើលដៃនោះឃើញដែរ ដូច្នេះអាចពោលថា ចក្ខុបសាទរមែងទទួលបានតែរូបារម្មណ៍ដែលនៅក្នុងរយៈដ៏សមគួរដល់ការឃើញ មិនទាន់មកដល់ ប៉ុណ្ណោះ ។

**សោតបសាទ** ក៏ដូចគ្នា គឺ ទទួលសទ្ទារម្មណ៍បានដោយអាស្រ័យរន្ធត្រចៀក(បរិច្ឆិន្នាកាស) បើសម្លេងនោះចូលទៅដល់សោតបសាទ ដែលនៅខាងក្នុងរន្ធត្រចៀកហើយនោះ សោតបសាទក៏មិនអាចទទួលសម្លេងនោះបាន គឺ ឮមិនបាន ឯការដែលឮនោះមិនមែនសម្លេងដែលចូលដល់សោតបសាទទេ ជាសម្លេងដែលនៅក្នុងរយៈដ៏សមគួរដល់ការឮ ប៉ុណ្ណោះ ។

ដូច្នោះ **ចក្ខុបសាទ** និង **សោតបសាទ** ទាំង ២ នេះទើបឈ្មោះថា **អសម្បត្តគោចរគាហិករូប** ។

ចំណែក ឃានបសាទ ជិវ្ហាបសាទ កាយបសាទ ទាំង ៣ នេះត្រូវទទួលយកអារម្មណ៍ដែលមកដល់ បើអារម្មណ៍នៅមិនទាន់មកដល់ក៏មិនអាចទទួលបាន ដូច ឃានបសាទ ត្រូវទទួលគន្ធារម្មណ៍ដែលមកដល់ គឺ ប៉ះខ្ទប់ហើយ ទើបដឹងក្លិន ។ ជិវ្ហាបសាទត្រូវទទួលរសារម្មណ៍ ដែលមកដល់ គឺ ប៉ះខ្ទប់ហើយ ទើបដឹងរស ។ កាយបសាទត្រូវទទួល ផោដ្ឋព្វារម្មណ៍ដែលមកដល់ គឺ ប៉ះខ្ទប់ហើយ

ទើបដឹងផោដ្ឋព្វៈ ។

បើគន្ធារម្មណ៍ រសារម្មណ៍ និង ផោដ្ឋព្វារម្មណ៍ មកមិនទាន់ដល់ គឺ មិនទាន់ចូលមកប៉ះខ្ទប់ទេ ក៏មិនអាចដឹងក្លិន ដឹងរស និង ដឹងផោដ្ឋព្វារម្មណ៍បានឡើយ ។ ដូច្នោះ បសាទរូបទាំង ៣ គឺ ឃានបសាទ ជីវ្ហាបសាទ និង កាយបសាទ ទើបឈ្មោះថា **សម្បត្តគោចរគាហិករូប** ។

ចំណែករូបដែលនៅសល់ ២៣ ទៀត ឈ្មោះថា **អគោ-ចរគាហិករូប** ព្រោះមិនអាចទទួលអារម្មណ៍បាន ។

# គូទី ១១
# អវិនិព្ភោគរូប និង វិនិព្ភោគរូប

**អវិនិព្ភោគរូប** គឺ រូបដែលបែកចេញពីគ្នាមិនបាន មាន ៨ រូប បានដល់ មហាភូតរូប ៤ វណ្ណរូប ១ គន្ធរូប ១ រសរូប ១ អាហាររូប ១ ។

**វិនិព្ភោគរូប** គឺ រូបដែលបែកចេញពីគ្នាបាន មាន

២០ រូប បានដល់ រូបដែលនៅសល់
២០ ។

មហាភូតរូប ៤ វណ្ណរូប ១ គន្ធរូប ១ រសរូប ១ អាហាររូប ១ រួម ៨ រូបនេះឈ្មោះថា **អវិនិព្ភោគរូប ៨** ។ រូបទាំង ៨ នេះ ត្រូវកើតឡើងរួមគ្នាជានិច្ច មិនថានឹងកើតពីសមុដ្ឋានណា ឬ កើតក្នុងរូបដែលល្អិតតូចបំផុតយ៉ាងណាក៏ដោយ បានសេចក្ដីថា បណ្ដារូបទាំងឡាយក្នុងលោកនេះ សូម្បីរូបនោះមានសភាពល្អិតតូចឆ្មាបំផុត មានប្រមាណប៉ុន បរិមាណូក៏ដោយ យ៉ាងតិចណាស់ ក៏ត្រូវប្រកបដោយ អវិនិព្ភោគរូប ៨ នេះដែរ អត់ពីអវិនិព្ភោគរូប ៨ មិនបានឡើយ ដូច្នោះហើយ ទើបជារូបដែលបែកចេញពីគ្នាមិនបាន ។

ចំណែករូបដែលនៅសល់ ២០ រូបទៀតនោះ ទោះជារូបបែកចេញពីគ្នាបាន មិនបានកើតរួមគ្នាទាំង ២០ រូបក៏ពិតមែន តែគង់កើតរួមគ្នាបានតែចំពោះកលាបៈ ពួកក្រុម សំណុំរបស់ខ្លួនប៉ុណ្ណោះដែរ ដូច្នោះហើយ ទើបឈ្មោះថា **វិនិព្ភោគរូប** ។ វិនិព្ភោគរូបទាំងនេះ ទោះជាបែកចេញពីគ្នាបានក៏ពិតមែន ប៉ុន្តែកាលកើតឡើង ក៏ត្រូវកើតរួមគ្នានឹងអវិនិព្ភោគរូប ៨ ជានិច្ច នឹងកើតតែឯង ដោយមិនមានអវិនិព្ភោគរូប ៨ រួមជាមួយ មិនបានឡើយ ៕

# ៣. រូបសមុដ្ឋានន័យ

**រូបសមុដ្ឋានន័យ** ជាន័យសម្តែងពីធម៌ដែលជាហេតុឲ្យរូបកើតឡើង គឺ សម្តែងពីការកើតឡើងនៃរូបធម៌ទាំងពួងនោះ ត្រូវអាស្រ័យ **ហេតុ-បច្ច័យ**ឲ្យកើត ។

ក្នុងបរមត្ថទីបនីដីកា បានសម្តែងវចនត្ថៈនៃសមុដ្ឋាន ទុកថា **សមុដ្ឋាតិ រូបំ ឯតេនាតិ សមុដ្ឋានំ** ប្រែថា ធម្មជាតិណា ធ្វើឲ្យរូបកើតឡើង ធម្មជាតិនោះ ឈ្មោះថា សមុដ្ឋាន គឺ សំដៅយកបច្ច័យដែលតាក់តែងឲ្យរូបធម៌កើតឡើងនោះឯង ឈ្មោះថា **សមុដ្ឋាន** ។

**កម្មំ ចិត្តំ ឧតុ អាហារោ ចេតិ ចត្តារិ រូបសមុដ្ឋានានិ នាម** ប្រែថា កម្ម ចិត្ត ឧតុ អាហារ ទាំង ៤ នេះ ឈ្មោះថា រូបសមុដ្ឋាន បានសេចក្តីថា ធម៌ដែលជាហេតុ-បច្ច័យធ្វើឲ្យរូបកើតឡើង មាន ៤ យ៉ាង គឺ កម្ម ១ ចិត្ត ១ ឧតុ ១ និងអាហារ ១ ។

**១- កម្ម** សំដៅដល់ ការធ្វើដោយកាយវាចាចិត្ត ជាកុសលខ្លះ ជាអកុសលខ្លះ ដែលបានធ្វើរួចមកហើយ ក្នុងអតីតភព ឬក្នុង

បច្ចុប្បន្នភព ។ បើពោលដោយសភាវៈ បានដល់ កម្ម ២៥ គឺ : ចេតនា ដែលប្រកបក្នុងអកុសលចិត្ត ១២ មហាកុសលចិត្ត ៨ និង រូបាវចរកុសលចិត្ត ៥ ។ ចេតនាក្នុងចិត្ត ២៥ ដួងនេះឯង ដែល ជាសមុដ្ឋានធ្វើឲ្យរូបកើតឡើងក្នុងសន្តានរបស់សត្វ នៅក្នុងបញ្ចវោការ ភូមិ ។ រូបដែលកើតឡើងពីកម្មជាសមុដ្ឋាននេះ ហៅថា **កម្មជរូប** ហើយរមែងកើតឡើងក្នុងសត្វទាំងនោះគ្រប់ៗអនុខណៈនៃចិត្ត រាប់ ចាប់តាំងពីបដិសន្ធិចិត្តជាដំបូងមក ។

**២- ចិត្ត** បានដល់ ចិត្ត ៧៥ ដួង ( វៀរទ្វិបញ្ចវិញ្ញាណ ១០ អរូបាវចរវិបាក ៤ បដិសន្ធិចិត្តរបស់សត្វក្នុងបញ្ចវោការភូមិ និង ចុតិចិត្តរបស់ព្រះអរហន្ត ) និងចេតសិក ៥២ ក្នុងបច្ចុប្បន្នភពនេះឯង ធ្វើឲ្យរូបកើតឡើងក្នុងអាការផ្សេងៗ មានការដើរ ឈរ អង្គុយ ដេក រហូតដល់ការពោលចរចា ឬការដកដង្ហើមចេញ-ចូលជាដើម ។ រូប ដែលកើតឡើងពីចិត្តជាសមុដ្ឋាននេះ ហៅថា **ចិត្តជរូប** គឺ រមែង កើតឡើងក្នុងសន្តានរបស់សត្វទាំងនោះ គ្រប់ៗឧប្បាទខណៈនៃចិត្ត រាប់ ចាប់តាំងពីបឋមភវង្គចិត្ត បន្ទាប់ពីបដិសន្ធិចិត្តរលត់ជាដំបូងមក ។

**៣- ឧតុ** បានដល់ **សីតតេជោ** ធាតុត្រជាក់ **ឧណ្ហតេជោ** ធាតុក្តៅ ដែលមាននៅទូទៅក្នុងរូបរាងកាយរបស់សត្វ និង មាននៅ

ទូទៅខាងក្រៅរូបរាងកាយរបស់សត្វ ។ រូបដែលកើតឡើងពីឧតុជាសមុដ្ឋាន នេះហៅថា **ឧតុជរូប** ។

ចំពោះឧតុជរូប ដែលកើតខាងក្នុងរូបរាងកាយនៃសត្វមានជីវិតនោះ រមែងកើតឡើងគ្រប់ៗអនុខណៈនៃចិត្ត រាប់ចាប់តាំងពីឋិតិខណៈនៃបដិសន្ធិចិត្តជាដំបូងមក ។ ចំណែកឧតុនៅខាងក្រៅរាងកាយនៃសត្វ គឺនៅក្នុងវត្ថុដទៃផ្សេងៗ ដូចជា ដី ភ្នំ ដើមឈើជាដើម ពេលណាប្រាកដកើតឡើង រៀបរយហើយ ពេលនោះក៏ធ្វើឲ្យឧតុជរូបកើតឡើងបានជារឿយៗមិនដាច់ខ្សែ ។

**៤- អាហារ** បានដល់ ឱជា ដែលនៅក្នុងអាហារផ្សេងៗ ដែលសត្វបានបរិភោគលេបចូលទៅនោះឯង ។ កាលបានត្រូវរំលាយដោយបាចកតេជោធាតុ(គឺភ្លើងធាតុរំលាយអាហារ) ហើយ ក៏ធ្វើឲ្យរូបកើតឡើងក្នុងរូបរាងកាយរបស់សត្វនោះ រូបដែលកើតឡើងពីអាហារ គឺ ឱជា ដែលជ្រួតជ្រាបទៅនោះជាសមុដ្ឋាននេះ ហៅថា **អាហារជរូប** ហើយរមែងកើតឡើងក្នុងសន្តានរបស់សត្វទាំងឡាយគ្រប់ៗអនុខណៈនៃចិត្ត រាប់ចាប់តាំងពីឱជានៃអាហារនោះជ្រួតជ្រាបចូលទៅក្នុងរូបរាងកាយសត្វនោះៗ រៀបរយហើយ ។

# អធិប្បាយ
# សមុដ្ឋានទាំង ៤ ដែលធ្វើឲ្យរូបកើត

## ១. កម្មសមុដ្ឋាន

តាមពិត **កម្ម** ទាំងអស់មាន ៣៣ គឺ ចេតនាក្នុងអកុសលចិត្ត ១២ និង ក្នុងកុសលចិត្ត ២១ ប៉ុន្តែកម្មដែលជាសមុដ្ឋានឲ្យរូបកើតឡើង នេះយកតែកម្ម ២៥ ប៉ុណ្ណោះ វៀរចេតនាអរូបាវចរកុសលកម្ម ៤ និង លោកុត្តរកុសលកម្ម ៤ ។

ក្នុងការវៀរទាំងនេះ ក៏ព្រោះថា កុសលកម្មទាំងនេះមិនបានធ្វើឲ្យរូបកើតទេ ពោលគឺ អរូបាវចរកុសលកម្ម ៤ ជាកម្មដែលកើតឡើង ដោយអាស្រ័យការចម្រើនអរូបកម្មដ្ឋាន ឃើញទោសក្នុងការមានរូបរាងកាយ គឺជាការចម្រើនរូបវិរាគភាវនា ដែលប្រាសចាកសេចក្តីត្រេកអរក្នុងរូប ។ ដោយអំណាចនៃរូបវិរាគភាវនានេះ កាលចុតិចាកលោកនេះហើយ ក៏កើតក្នុងអរូបភព គឺ ភពដែលមិនមានរូប ។

ចំណែកលោកុត្តរកុសលទាំង ៤ ជាកុសលកម្មដែលកើតឡើង

ដោយការចម្រើនវិបស្សនាកម្មដ្ឋាន ឃើញត្រៃលក្ខណ៍ក្នុងបញ្ចក្ខន្ធ រហូតកើតនូវសេចក្តីនឿយណាយ ប្រាសចាកតម្រេក ក្នុងភពជាតិ ទើបជាកុសលកម្មមួយបែបប៉ុណ្ណោះ រំលត់ភពជាតិ និង កម្មជរូប ដែលជា តួភព តួជាតិ ក្នុងសង្សារវដ្តបាន ដូច្នោះ លោកុត្តរ-កុសលកម្ម ទាំង ៤ នេះ ទើបមិនធ្វើឲ្យរូបកើតឡើងដែរ ។

កម្មជរូបនេះ តែងកើតចំពោះតែសត្វដែលមានរូបក្ខន្ធ គឺសត្វក្នុងភូមិ ២៧ ភូមិ គឺ បញ្ចវោការភូមិ ២៦ និង ឯកវោការភូមិ ១ ។

ការកើតឡើងនៃកម្មជរូបនេះ គឺ កើតឡើង តាំងពីបដិសន្ធិ-ចិត្តនៃសត្វទាំងឡាយជាដំបូងទៅ ហើយកើតគ្រប់ៗ អនុខណៈចិត្ត គឺទាំងឧប្បាទខណៈ ទាំងឋិតិខណៈ និង ទាំងភង្គខណៈ ។

កម្មជរូបនេះទៀត អាចកើតជាប់បន្តជារឿយៗទៅ ក្នុងគ្រប់អនុខណៈនៃចិត្តគ្រប់ៗដួង ។ កាលកើតឡើងហើយ តាំងនៅបានត្រឹម ១៧ ខណៈចិត្តប៉ុណ្ណោះ រួចក៏រលត់ទៅព្រមនឹងចិត្ត កើតរលត់ៗទៅព្រមនឹងចិត្តយ៉ាងនេះ ជារឿយៗតទៅ រហូតដល់ពេលជិតស្លាប់ ចាប់តាំងពី **ឋិតិខណៈនៃចិត្តដួងទី ១៧** ដែលរាប់ត្រឡប់ថយក្រោយ មកពីចុតិចិត្តខណៈនោះ **កម្មជរូបថ្មីឈប់កើតតទៅទៀត** ។ ចំណែកកម្មជរូបដែលកើតឡើងហើយ ត្រង់ក្នុង**ឧប្បាទខណៈនៃ**

**ចិត្តដួងទី ១៧** ដែលរាប់ ថយក្រោយនោះ អាចតាំងនៅបានរហូតដល់ចុតិចិត្ត ក៏នឹង**រលត់ព្រមគ្នាជាមួយនឹងភង្គខណៈនៃចុតិចិត្តនោះ** ។

**កម្មជរូប** គឺ រូបដែលកើតពីកម្មជាសមុដ្ឋាន មាន ១៨ រូប គឺ :

មហាភូតរូប ៤ បសាទរូប ៥ គោចររូប ៣ (វៀរសទ្ទរូប) ភាវរូប ២ ហទយរូប ១ ជីវិតរូប ១ អាហាររូប ១ និង បរិច្ឆេទរូប ១ ។

# ២. ចិត្តសមុដ្ឋាន

**ចិត្ត** ទាំងអស់មានចំនួន ៨៩ ដួង ប៉ុន្តែចិត្តក្នុងបច្ចុប្បន្នភពដែលនឹងជាសមុដ្ឋានឲ្យរូបកើតឡើងបាននោះ មានត្រឹមតែចិត្ត ៧៥ ដួង ប៉ុណ្ណោះ វៀរចិត្ត ១៤ ដួងចេញ គឺ ទ្វិបញ្ចវិញ្ញាណ ១០ និង អរូបវិបាកចិត្ត ៤ ។ បដិសន្ធិចិត្តនៃសត្វក្នុងបញ្ចវោការភូមិ និង ចុតិចិត្តរបស់ព្រះអរហន្ត ក៏មិនអាចជាសមុដ្ឋានឲ្យរូបកើតឡើងបានដែរ ។

ក្នុងការដែលវៀរចិត្ត ១៤ ដួងនេះ ក៏ព្រោះថា ទ្វិបញ្ចវិញ្ញាណ ១០ នោះមានកម្លាំងខ្សោយ (គឺមិនប្រកបរួមដោយអង្គឈាន ទាំង-ឡាយ) ក្នុងការញ៉ាំងរូបឲ្យកើតបាន ។

ឯអរូបវិបាកចិត្ត ៤ នោះ ជាផលដែលកើតពីអរូបាវចរកុសល ដែលប្រាថ្នានូវភពប្រាសចាករូបអស់ហើយ ដូច្នោះទើបមិនអាចធ្វើឲ្យចិត្តជរូបកើតបាន ។

ចំណែកបដិសន្ធិចិត្តរបស់សត្វទាំងឡាយ និង ចុតិចិត្តរបស់ព្រះអរហន្តនោះ មិនមានចំនួនចិត្តដែលនឹងត្រូវវៀរដោយចំពោះទេ ប៉ុន្តែ គឺសំដៅយកខណៈដែលធ្វើនាទីបដិសន្ធិ និង ចុតិ តែប៉ុណ្ណោះ បាន សេចក្តីថា ចិត្តដែលធ្វើនាទីបដិសន្ធិមាន ១៩ ដួង គឺ ឧបេក្ខា-សន្តីរណចិត្ត ២ មហាវិបាកចិត្ត ៨ រូបាវចរវិបាកចិត្ត ៥ អរូបាវចរវិបាកចិត្ត ៤ ទាំងនេះ ចំពោះអរូបាវចរវិបាកចិត្ត ៤ បានអធិប្បាយនៅខាងលើរួចហើយ ចំណែកបដិសន្ធិចិត្តនៅ ១៥ ដួងទៀត គឺ ក្នុងខណៈដែលកើតឡើងគ្រាដំបូងក្នុងភពថ្មីនោះ រមែង មានកម្លាំងខ្សោយ ទើបមិនអាចធ្វើឲ្យចិត្តជរូបកើតបាន និង ចិត្ត ដែលធ្វើនាទីចុតិរបស់ព្រះអរហន្តមាន ១៣ ដួង គឺ មហាវិបាក-ញាណសម្បយុត្តចិត្ត ៤ រូបាវចរវិបាកចិត្ត ៥ អរូបាវចរវិបាកចិត្ត ៤ ទាំងនេះ វៀរអរូបាវចរវិបាកចិត្ត ៤ នៅសល់ចុតិចិត្ត ៩ ដួង គឺ

ជាចុតិចិត្តរបស់ព្រះអរហន្តដែលប្រាសចាកកិលេសអស់ហើយ ទើបមិនធ្វើឲ្យចិត្តជរូបកើតឡើងឡើយ ប៉ុន្តែចុតិចិត្ត ៩ ដួង របស់បុគ្គលក្រៅពីព្រះអរហន្តនេះ រមែងអាចធ្វើឲ្យចិត្តជរូបកើតឡើងបាន ។

ដូច្នោះ ចិត្ត ៧៥ ដួង វៀរចំពោះខណៈបដិសន្ធិរបស់សត្វទាំងឡាយ និង ខណៈចុតិរបស់ព្រះអរហន្តចេញ តែងជាសមុដ្ឋានឲ្យចិត្តជរូបកើតឡើងបាន ។

ចិត្តក្នុងបច្ចុប្បន្នភពដែលធ្វើឲ្យរូបកើត ដែលហៅថា ចិត្តជរូបនេះ ចិត្តជរូបនេះ រមែងកើតឡើង **គ្រប់ៗឧប្បាទខណៈនៃចិត្ត** ប៉ុណ្ណោះ មិនកើតក្នុងឋិតិខណៈ និង ក្នុងភង្គខណៈនៃចិត្តទេ ព្រោះ **ចិត្តមានកម្លាំងត្រង់ឧប្បាទខណៈ** នៃចិត្តប៉ុណ្ណោះ ចំណែក ២ ខណៈក្រោយ ជាចិត្តមិនមានកម្លាំង ទើបមិនធ្វើឲ្យរូបកើតឡើង ។

**ចិត្តជរូប** គឺ រូបដែលកើតពីចិត្តជាសមុដ្ឋាន មាន ១៥ រូប គឺ :

មហាភូតរូប ៤ គោចររូប ៤ អាហាររូប ១ បរិច្ឆេទរូប ១ វិញ្ញត្តិរូប ២ វិការរូប ៣ ។

# ៣. ឧតុសមុដ្ឋាន

**ឧតុ** ដែលជាសមុដ្ឋានឲ្យរូបកើត បានដល់ **តេជោធាតុ** គឺ សីតតេជោ ធាតុត្រជាក់ និង ឧណ្ហតេជោ ធាតុក្តៅ ដែលមាននៅទូទៅក្នុងរាងកាយរបស់សត្វ និង មាននៅទូទៅក្នុងវត្ថុក្រៅពីកាយរបស់សត្វ ។

ឧតុដែលធ្វើឲ្យរូបកើត ក្នុងរាងកាយរបស់សត្វ ហៅថា **អជ្ឈត្តឧតុ** បានដល់ ថាមពល កំដៅ ដែលកើតឡើងក្នុងរាងកាយរបស់សត្វ ។ **ឧតុនេះមានកម្លាំង** គឺ ក្នុង**ខណៈដែលតាំងនៅ**(ឋិតិខណៈ) នោះប៉ុណ្ណោះ ធ្វើឲ្យឧតុជរូបកើតឡើង ហើយនឹងកើតឡើង ក៏កើតឡើងតទៅ**គ្រប់ៗខណៈនៃចិត្ត** ( គឺ គ្រប់ ៗ ៣ ខណៈ នៃចិត្តនីមួយ ៗ ) គឺចាប់ផ្តើមកើតតាំងពីឋិតិខណៈនៃបដិសន្ធិចិត្ត ជាគ្រាដំបូងទៅ ។

ចំពោះឧតុដែលធ្វើឲ្យរូបកើតខាងក្រៅសន្តានរបស់សត្វ ហៅថា **ពហិទ្ធឧតុ** បានដល់ ឧតុដែលនៅក្នុងវត្ថុដទៃៗ ដូចនៅក្នុងភ្នំ ក្នុងផែនដី ក្នុងអាកាស ទន្លេ ស្ទឹង ដើមឈើជាដើម ។ រូបទាំងនេះ

រមែងមានឧតុជាសមុដ្ឋាន ឲ្យកើតឡើងបានជារឿយៗទៅរហូត ទំរាំនឹងវិនាសទៅ ។

**ឧតុជរូប** គឺ រូបដែលកើតពីឧតុ( តេជោធាតុ ) ជាសមុដ្ឋាន មាន ១៣ រូប គឺ :
មហាភូតរូប ៤ គោចររូប ៤ អាហាររូប ១
បរិច្ឆេទរូប ១ វិការរូប ៣ ។

# ៤. អាហារសមុដ្ឋាន

**អាហារ** ដែលជាសមុដ្ឋានឲ្យរូបកើត ឈ្មោះថា **អាហារសមុដ្ឋាន** ។ រូបដែលកើតពីអាហារសមុដ្ឋាន ហៅថា **អាហារជរូប** ។

**អាហារ** គឺ កវឡិង្ការាហារ បានដល់ អាហាររូប គឺ **ឱជា** ដែលមាននៅក្នុងអាហារគ្រប់យ៉ាង ដែលបរិភោគលេបចូលទៅ ។ ហើយមិនមែនចំពោះតែប៉ុណ្ណោះទេ សូម្បីថ្នាំប្រភេទខ្លះដូចជាវីតាមីនផ្សេងៗ ក៏មានឱជានៅដូចគ្នាដែរ ដូច្នេះហើយ ទើបកាលចាក់ថ្នាំក្តី លេបក្តី ឬលាបក្តី ក៏ធ្វើឲ្យអាហារជរូបកើតបានដូចគ្នា ។

ឱជាយ៉ាងនេះឯង ហៅថា **ពហិទ្ធឱជា** ជាឱជាដែលមាននៅខាងក្រៅសន្តាននៃសត្វ គឺ ដែលនៅក្នុងអវិនិព្ភោគរូប ៨ ក្នុងអាហារផ្សេងៗ ដែលកើតពីឧតុ មុនការបានទទួលពីការដុតរំលាយដោយភ្លើងធាតុ បាចកតេជោ ។ កាលត្រូវរំលាយដោយភ្លើងធាតុរំលាយអាហារ គឺ បាចកតេជោហើយ ក៏ធ្វើឲ្យអាហារជរូបកើតឡើង ក្នុងសន្តាននៃសត្វ ។

ចំណែកឱជាមាននៅក្នុងសន្តាននៃសត្វ ហៅថា **អជ្ឈត្តឱជា** គឺ ឱជាដែលនៅក្នុងអវិនិព្ភោគរូប ក្នុងរូបកលាបផ្សេងៗ ដែលកើតពីសមុដ្ឋានទាំង ៤ គឺ ក្នុងកម្មជកលាប ចិត្តជកលាប ឧតុជកលាប និង អាហារជកលាប ។

បណ្ដាឱជាទាំង ២ ប្រភេទនេះ **ពហិទ្ធឱជា** ធ្វើនាទីឲ្យអាហារជរូបកើតឡើងត្រង់ៗ ដោយ **ជនកសត្តិ** និង ជួយឧបត្ថម្ភរូប ដទៃៗទាំង ៤ សមុដ្ឋាន ឲ្យមានកម្លាំងតាំងនៅបានស្រួលដោយ **ឧបត្ថម្ភកសត្តិ** ។ **ឯអជ្ឈត្តឱជា** ធ្វើនាទីឲ្យរូបដទៃៗ ក្នុងកលាបជាមួយខ្លួនកើតឡើងដោយ **ជនកសត្តិ** និង ជួយឧបត្ថម្ភរូបកលាបដទៃៗ ឲ្យតាំងនៅដោយ **ឧបត្ថម្ភកសត្តិ** ។

ក្នុងវិសុទ្ធិមគ្គអដ្ឋកថា សម្តែងថា ក្នុងមនុស្សលោក អ្នកដែលបានបរិភោគអាហារឆ្អែតម្តង អាចរក្សារាងកាយឲ្យតាំងនៅបានក្នុង ៧ ថ្ងៃ ដោយមិនបាច់បរិភោគអ្វីទៀត ។ ចំពោះទេវលោក អាហារទិព្វរបស់ពួកទេវតាដែលសោយម្តង អាចរក្សារាងកាយឲ្យតាំងនៅបានក្នុងរយៈ ១ ខែ ឬ ២ ខែ ដោយមិនបាច់បរិភោគអ្វីទៀតដូចគ្នា ។ ត្រង់ដែលមានសភាពយ៉ាងនេះ ព្រោះថា ឱជា ដែលនៅក្នុងអាហារបរិភោគចូលទៅនោះ គឺ ទៅរួមផ្សំនឹងអជ្ឈត្តឱជាក្នុងរាងកាយហើយ ក៏ធ្វើឲ្យអាហារជរូបអាចកើតឡើងបានក្នុងរយៈ ៧ ថ្ងៃ ចំពោះក្នុងមនុស្សលោក និង អាចកើតឡើងបានក្នុងរយៈ ១ ខែ ឬ ២ ខែ ចំពោះក្នុងទេវលោក ។

ចំពោះពួកគព្ភសេយ្យកសត្វ គឺ សត្វដែលអាស្រ័យគភ៌មាតាកើត អាហារជរូបចាប់ផ្តើមកើតជាគ្រាដំបូង គឺ កើតក្នុងសប្តាហ៍ទី២ ឬទី៣ គិតតាំងពីបដិសន្ធិកាលមក ពោលគឺ កាលមាតាបរិភោគអាហារចូលទៅហើយ ក្នុងរវាងតាំងគភ៌ ឱជាក៏អាចជ្រួតជ្រាបផ្សាយចូលទៅកាន់ រាងកាយរបស់ទារក ដែលនៅជា អព្ពុទៈ ឬជា បេសិនោះ ហើយធ្វើឲ្យអាហារជរូបកើតឡើងបាន ។

ចំណែកពួកសត្វដែលជាសំសេទជៈកំណើត ឬ ជាឱបបាតិកៈកំណើត (ចំពោះពួកដែលត្រូវបរិភោគអាហារ) កាលកើតឡើងមក

នោះ រូបរាងកាយគ្រប់បរិបូរណ៍តែម្តង មិនបានបរិភោគអាហារណាៗឡើយ ប៉ុន្តែអាស្រ័យដោយស្លេស្ម ឬ ទឹកមាត់កន្ទួងបំពង់ក ហើយ ឱជានៃស្លេស្មឬទឹកមាត់នោះ ក៏ជ្រួតជ្រាបចូលទៅកាន់រាងកាយ ធ្វើឲ្យអាហារជរូបកើតឡើង ។ អាហារជរូបនេះ ចាប់ផ្តើមកើតជាគ្រាដំបូង គឺ កើតក្នុងមនោទ្វារវិថីចិត្ត ក្រោយពីបដិសន្ធិចិត្ត និង ភវង្គចិត្ត ។

សរុបសេចក្តីមក អាហារជរូបរមែងកើតឡើងពេលឱជា នៃអាហារផ្សេងៗ បានជ្រួតជ្រាបចូលទៅកាន់រាងកាយរបស់សត្វទាំង-ឡាយ ។ ហើយអាហារជរូបនេះ កាលកើតឡើង ក៏រមែងកើតឡើងរហូតតទៅ**គ្រប់ៗខណៈនៃចិត្ត** (គឺគ្រប់ ៣ ខណៈនៃចិត្តនីមួយៗ) ជាប់បន្តគ្នាមិនដាច់ខ្សែរយៈឡើយ រហូតដល់ចាស់ស្លាប់ ។

**អាហារជរូប** គឺ រូបដែលកើតពីអាហារ មានឱជាជាសមុដ្ឋាន មាន ១២ រូប គឺ : មហាភូតរូប ៤ គោចររូប ៣ ( វៀរសទ្ទរូប ) អាហាររូប ១ បរិច្ឆេទរូប ១ វិការរូប ៣ ។

# សរុប រូប
# ដែលកើតពីសមុដ្ឋាន ៤

១. រូបដែលកើតពីកម្មជាសមុដ្ឋាន ឈ្មោះថា **កម្មជរូប** មាន ១៨ រូប ។

២. រូបដែលកើតពីចិត្តជាសមុដ្ឋាន ឈ្មោះថា **ចិត្តជរូប** មាន ១៥ រូប ។

៣. រូបដែលកើតពីឧតុជាសមុដ្ឋាន ឈ្មោះថា **ឧតុជរូប** មាន ១៣ រូប ។

៤. រូបដែលកើតពីអាហារ គឺ ឱជា ជាសមុដ្ឋាន ឈ្មោះថា **អាហារជរូប** មាន ១២ រូប ។

....................

# សម្តែង
# រូបសមុដ្ឋាន ៤ ដោយប្រាកដ (ឯកន្តៈ) និង មិនប្រាកដ(អនេកន្តៈ)

## ១. កម្មជរូប ១៨

| **ឯកន្តៈ** មាន ៩ រូប គឺ | **អនេកន្តៈ** មាន ៩ រូប គឺ |
|---|---|
| - បសាទរូប ៥ | - មហាភូតរូប ៤ |
| - ភាវរូប ២ | - គោចររូប ៣(វៀរសទ្ទរូប) |
| - ហទយរូប ១ | - អាហាររូប ១ |
| - ជីវិតរូប ១ | - បរិច្ឆេទរូប ១ |

បសាទរូប ៥ ភាវរូប ២ ហទយរូប ១ ជីវិតរូប ១ ទាំង ៩ នេះ កើតបានចំពោះតែក្នុងរាងកាយរបស់សត្វប៉ុណ្ណោះ ព្រោះរូបទាំងនេះកើតមកពីអកុសលកម្ម និង លោកិយកុសលកម្មជាសមុដ្ឋានប្រាកដតែម្យ៉ាង ។ ចំណែករូបដែលនៅសល់ ៩ ទៀតនោះ កើតក្នុង

រាងកាយសត្វក៏បាន កើតក្នុងវត្ថុមិនមានជីវិតទាំងឡាយក៏បាន ព្រោះជារូបដែលកើតពីសមុដ្ឋានមិនប្រាកដ គឺ កើតពីកម្មក៏មាន កើតពីចិត្តក៏មាន កើតពីឧតុក៏មាន កើតពីអាហារក៏មាន ។

# ២. ចិត្តជរូប ១៥

| **ឯកន្តៈ** មាន ២ រូប គឺ | **អនេកន្តៈ** មាន ១៣ រូប គឺ | |
|---|---|---|
| - វិញ្ញត្តិរូប ២ | - អវិនិព្ភោគរូប | ៨ |
| | - សទ្ទរូប | ១ |
| | - បរិច្ឆេទរូប | ១ |
| | - វិការរូប | ៣ |

**វិញ្ញត្តិរូប ២** គឺ ការកម្រើកកាយ និង ការនិយាយចរចាទាំងនេះ រមែងកើតនៅតែ **ក្នុងរាងកាយរបស់សត្វមានជីវិត** ប៉ុណ្ណោះ ព្រោះជារូបដែលកើតឡើងដោយអាស្រ័យ ចិត្ត និងចេតសិកជាសមុដ្ឋានប្រាកដតែម្យ៉ាង ។ ចំណែករូបដែលនៅសល់ ១៣ ទៀតនោះ មិនបានកើតពីចិត្តជាសមុដ្ឋានតែម្យ៉ាងទេ គឺ កើតពីឧតុក៏មាន កើតពី អាហារក៏មាន ដូចជា :

**សទ្ទរូប** បើជាសម្លេងមនុស្សនិយាយ ឬ សម្លេងសត្វយំនោះ មានសមុដ្ឋាន ២ គឺ ចិត្តសមុដ្ឋាន និង ឧតុសមុដ្ឋាន តែបើសម្លេងផ្គរលាន់ ទឹកហូរ ខ្យល់បក់ សម្លេងឡាន រគាំង ជាដើម ទាំងនេះរមែងកើតពីឧតុជាសមុដ្ឋាន ។

**វិការរូប** គឺ ការស្រាលនៃរាងកាយ ការទន់ភ្លន់នៃរាងកាយ និង ការគួរដល់ការងារនៃរាងកាយ ក្នុងការប្រព្រឹត្តិក្តី ក្នុងការនិយាយ ចរចាក្តី ទាំង ៣ រូបនេះ កើតពីចិត្តក៏មាន កើតពីឧតុក៏មាន កើតពីអាហារក៏មាន ដូចពេលសប្បាយចិត្ត ឬពេលបានទទួលធាតុ អាកាសល្អៗ ឬ ពេលបានទទួលទានអាហារឆ្ងាញ់ៗ រាងកាយក៏ដឹង ខ្លួនស្រាល រហ័សរហួន មិនទាស់ក្នុងការងារឡើយ ។ ហើយវិការរូប ៣ នេះ កាលកើតឡើង រមែងកើតឡើងព្រមជាមួយគ្នា និង កើតបានចំពោះរបស់ដែលមានជីវិតប៉ុណ្ណោះ ។

អវិនិព្ភោគរូប ៨ បរិច្ឆេទរូប ១ រួមជា ៩ រូបនេះ ជារូបកើតពីសមុដ្ឋានមិនប្រាកដ ដូចគ្នានឹងកម្មជរូប ៩ មិនប្រាកដដែរ ។

# ៣. ឧតុជរូប ១៣

| ឯកន្តៈ មិនមានទេ | អនេកន្តៈ មាន ១៣ រូប គឺ |
|---|---|
| | - អវិនិព្ភោគរូប ៨ |
| | - សទ្ទរូប ១ |
| | - បរិច្ឆេទរូប ១ |
| | - វិការរូប ៣ |

ក្នុងចំនួនឧតុជរូប ១៣ នេះ រូបដែលកើតពីឧតុជាសមុដ្ឋានតែម្យ៉ាងមិនមាន ដូច្នោះ ឧតុជរូបដោយប្រាកដ ទើបមិនមាន គឺទាំង ១៣ រូបនេះ ជាឧតុជរូបដោយមិនប្រាកដទាំងអស់ ។

# ៤. អាហារជរូប ១២

| ឯកន្តៈ មិនមានទេ | អនេកន្តៈ មាន ១២ រូប គឺៈ |
|---|---|
| | អវិនិព្ភោគរូប ៨ |
| | បរិច្ឆេទរូប ១ |
| | វិការរូប ៣ |

ក្នុងចំនួនអាហារជរូប ១២ នេះ រូបដែលកើតពីអាហារ ជាសមុដ្ឋានតែម៉្យាងមិនមាន ដូច្នេះ អាហារជរូបដោយប្រាកដ ទើបមិនមាន គឺ ទាំង ១២ រូបនេះ ជាអាហារជរូបដោយមិនប្រាកដទាំងអស់ ។

# ការចែករូប ២៨
# តាមសមុដ្ឋាន ៥ ន័យ

**១. ន័យទី ១ ឯកសមុដ្ឋានិករូប** សំដៅដល់ រូបដែលកើតពីសមុដ្ឋានតែ ១ បានមាន ១១ រូប គឺ :

- បសាទរូប ៥
- ភាវរូប ២
- ហទយរូប ១
- ជីវិតរូប ១

} ៩ រូបនេះ កើតពីកម្ម ជាសមុដ្ឋានតែ ១

- វិញ្ញត្តិរូប ២ } កើតពីចិត្តជាសមុដ្ឋានតែ ១

**២. ន័យទី ២ ទ្វិសមុដ្ឋានិករូប** សំដៅដល់ រូបដែលកើតពីសមុដ្ឋានទាំង ២ បានមាន ១ រូប គឺ :

- សទ្ទរូប ១ ➔ កើតពីចិត្ត ឬ ឧតុជាសមុដ្ឋាន ។

**៣. ន័យទី ៣ តិសមុដ្ឋានិករូប** សំដៅដល់ រូបដែលកើតពីសមុដ្ឋានទាំង ៣ បានមាន ៣ រូប គឺ :

- វិការរូប ៣ កើតពីចិត្ត ឬឧតុ ឬអាហារជាសមុដ្ឋាន ។

**៤. ន័យទី ៤ ចតុសមុដ្ឋានិករូប** សំដៅដល់ រូបដែលកើតពីសមុដ្ឋានទាំង ៤ បានមាន ៩ រូប គឺ :

- មហាភូតរូប៤
- រូបារម្មណ៍ ១
- គន្ធារម្មណ៍ ១
- រសារម្មណ៍ ១
- អាហាររូប ១
- បរិច្ឆេទរូប ១

} ៩ រូបនេះកើតពីកម្ម ឬ ចិត្ត ឬឧតុ ឬអាហារ ជាសមុដ្ឋាន ។

**៥. ន័យទី៥ នកុតោចិសមុដ្ឋានិករូប** សំដៅដល់ រូបដែលមិនបានកើតពីសមុដ្ឋានណាមួយឡើយ មាន ៤ គឺ :-

- លក្ខណរូប ៤

លក្ខណរូបទាំង ៤ នេះ មិនបានកើតឡើងពីសមុដ្ឋានណា

មួយទេ ព្រោះលក្ខណរូបទាំង ៤ នេះ ជាសភាពអាការរបស់និប្ផន្នរូប ១៨ ដែលកើតឡើងពីសមុដ្ឋានទាំង ៤ ប៉ុណ្ណោះ គឺ មិនមានសមុដ្ឋានដោយចំពោះឡើយ ។ កាលណា និប្ផន្នរូប ១៨ កើតឡើងដោយអាស្រ័យសមុដ្ឋានទាំង ៤ ណាមួយហើយ ក្នុងតួនៃនិប្ផន្នរូបនោះរមែងមានលក្ខណរូប ទាំង ៤ នៅប្រាកដជាប់ផងដែរ គឺ ការកើតឡើង ការតាំងនៅ ការរលត់ នៃរូបទាំងនោះឯង ។ ដូចមនុស្សយើងដែលកើតមកម្នាក់ៗនោះ រមែងមានលក្ខណៈ ៤ ប្រការ ជាប់ប្រចាំខ្លួនមកជាមួយផងជានិច្ច គឺ **ការកើតឡើង ១ ការធំធាត់ឡើង ១ ការចាស់ ១** និង **ការស្លាប់ ១** ។ ចំពោះការកើត ការចម្រើនធំ ការចាស់ ការស្លាប់ទាំងនេះ មិនមែនមានឡើងបានដោយចំពោះទេ គឺ ចាំបាច់ត្រូវអាស្រ័យរាងកាយរបស់មនុស្ស ឬ សត្វដែលកើតឡើងមកនោះឯង ទើបអាចហៅបានថា **ការកើត** កាលណារាងកាយរបស់ មនុស្ស ឬ សត្វនោះ សន្សឹមៗចម្រើនធំឡើងៗមក ដល់ទីបំផុតក៏បានហៅថា **ការធំធាត់** កាលណារាងកាយរបស់មនុស្ស ឬ សត្វនោះ ចាប់ផ្តើមចាស់ក៏ហៅថា **ការចាស់** និងដល់ កាលណារាងកាយរបស់មនុស្ស ឬ សត្វនោះ ស្លាប់ ក៏ហៅថា **ការស្លាប់** ។ ប្រសិនបើរាងកាយរបស់មនុស្ស ឬ សត្វមិនបានប្រាកដឡើងមកទេ គ្រឿងសំគាល់ទាំង ៤ យ៉ាងនេះ ក៏មិន

អាចប្រាកដឡើងបានដែរ សេចក្ដីនេះយ៉ាងណា រាងកាយរបស់មនុស្ស ឬ សត្វ ក៏ប្រៀបដូចនឹងនិប្ផន្នរូប ដែលកើតមកពីសមុដ្ឋានទាំង ៤ យ៉ាងណាមួយ ឯការកើត ការធំធាត់ ការចាស់ ការស្លាប់របស់មនុស្ស ឬ សត្វនោះ ក៏ប្រៀបដូចលក្ខណរូបទាំង ៤ នេះដូច្នោះ ។ យ៉ាងនេះឯង លក្ខណៈទាំង ៤ នេះ ទើបមិនបានកើតឡើង ដោយអាស្រ័យសមុដ្ឋានយ៉ាងណាមួយបាន ហៅថា **នកុតោ-ចិសមុដ្ឋានិករូប** ៕

…………………

# សរុបសមុដ្ឋានិករូប

| ចំនួនរូប | កម្ម | ចិត្ត | ឧតុ | អាហារ | សេចក្ដីសំគាល់ |
|---|---|---|---|---|---|
| មហាភូតរូប ៤ | ៤ | ៤ | ៤ | ៤ | ទាំង ៤ សមុដ្ឋាន |
| បសាទរូប ៥ | ៥ | | | | កម្មជាសមុដ្ឋាន |
| គោចររូប ៣ | ៣ | ៣ | ៣ | ៣ | ទាំង ៤ សមុដ្ឋាន |
| សទ្ទរូប ១ | | ១ | ១ | | ចិត្ត-ឧតុជាសមុដ្ឋាន |
| ភាវរូប ២ | ២ | | | | កម្មជាសមុដ្ឋាន |
| ហទយរូប ១ | ១ | | | | កម្មជាសមុដ្ឋាន |
| ជីវិតរូប ១ | ១ | | | | កម្មជាសមុដ្ឋាន |
| អាហាររូប ១ | ១ | ១ | ១ | ១ | ទាំង ៤ សមុដ្ឋាន |
| បរិច្ឆេទរូប ១ | ១ | ១ | ១ | ១ | ទាំង ៤ សមុដ្ឋាន |
| វិញ្ញត្តិរូប ២ | | ២ | | | ចិត្តជាសមុដ្ឋាន |
| វិការរូប ៣ | | ៣ | ៣ | ៣ | ចិត្ត,ឧតុ,អាហារ ជាសមុដ្ឋាន |
| លក្ខណរូប ៤ | | | | | មិនមានសមុដ្ឋាន |
| **រួម ២៨** | ១៨ | ១៥ | ១៣ | ១២ | |

# ការចែក
# សមុដ្ឋានិករូបដោយសុត្តន្តន័យ

ក្នុងព្រះសូត្រសម្តែងរូបធម៌ គឺ រាងកាយរបស់សត្វ ដែលប្រកបដោយធាតុ ៤ មាន ដី ទឹក ភ្លើង ខ្យល់ ប្រជុំគ្នា រាប់ដោយអាការ បាន ៤២ អាការ គឺ សសម្ភារបឋវី ២០ អាការ , សសម្ភារអាបោ ១២ អាការ , សសម្ភារតេជោ ៤ អាការ និង សសម្ភារវាយោ ៦ អាការ ។

**១. សសម្ភារបឋវី** ក្នុងសសម្ភារបឋវី ២០ ដែលជាអជ្ឈត្តិកបឋវីនោះ ចែកជា ២ ប្រភេទ គឺ :

- **ឧទរិយំ** អាហារថ្មី ១ **ករីសំ** អាហារចាស់ ១ រួម ២ អាការនេះ មានសមុដ្ឋាន ១ គឺ ឧតុ ជាសមុដ្ឋាន ។

ចំណែកនៅ**សល់ ១៨ អាការ** ទៀតនោះ មានសមុដ្ឋានទាំង ៤ ។

**២. សសម្ភារអាបោ** ក្នុងសសម្ភារអាបោ ១២ ដែលជាអជ្ឈត្តិកអាបោនោះ ចែកជា ៣ ប្រភេទ គឺ :

- **បុព្វោ** ខ្ទុះ **មុត្តំ** ទឹកមូត្រ រួម ២ អាការនេះ មាន សមុដ្ឋាន ១ គឺ ឧតុ ជាសមុដ្ឋាន ។

- **សេទោ** ញើស **អស្សុ** ទឹកភ្នែក **ខេឡោ** ទឹកមាត់ និង **សិង្ឃាណិកា** ទឹកសំបោរ រួម ៤ អាការនេះ មានសមុដ្ឋាន ២ គឺ ចិត្ត និង ឧតុ ជាសមុដ្ឋាន ។

ចំណែកនៅ**សល់ ៦ អាការ** ទៀត គឺ **បិត្តំ** ទឹកប្រមាត់ **សេម្ហំ** ស្លេស្ម៍ **លោហិតំ** ឈាម **មេទោ** ខ្លាញ់ខាប់ **វសា** ខ្លាញ់រាវ និង **លសិកា** ទឹករំអិលនោះ មានសមុដ្ឋានទាំង ៤ ។

**៣. សសម្ភារតេជោ** ក្នុងសសម្ភារតេជោ ៤ ដែលជា អជ្ឈត្តិកតេជោនោះ ចែកជា ២ ប្រភេទ គឺ :-

- **បាចកតេជោ** ភ្លើងរំលាយអាហារ ភ្លើងធាតុនេះមាន សមុដ្ឋាន ១ គឺ កម្ម ជាសមុដ្ឋាន ។

ចំណែកនៅ**សល់ ៣ អាការ** ទៀត គឺ **ឧស្មាតេជោ** ភ្លើងកក់ក្តៅប្រចាំរាងកាយ **សន្តាបនតេជោ** ឬ **ទហនតេជោ** ភ្លើងធ្វើឲ្យគ្រុនក្តៅខ្លាំង និង **ជិរណតេជោ** ភ្លើងធ្វើឲ្យចាស់ជរា

មានសមុដ្ឋានទាំង ៤ ។

**៤. សសម្ភារវាយោ** ក្នុងសសម្ភារវាយោ ៦ ដែលជាអជ្ឈត្តិកវាយោនោះ ចែកជា ២ ប្រភេទ គឺ :-

- **អស្សាសបស្សាស** ខ្យល់ដកដង្ហើមចេញចូល មានសមុដ្ឋាន ១ គឺ ចិត្ត ជាសមុដ្ឋាន ។

ចំណែកនៅ**សល់ ៥ អាការ** ទៀតនោះ មានសមុដ្ឋានទាំង ៤ ។

# ការចែក
# សមុដ្ឋាន ៤ ក្នុងអាការ ៤២

**១.**មាន កម្ម ជាសមុដ្ឋានមាន ១ គឺ បាចកតេជោ ។

**២.**មាន ចិត្ត ជាសមុដ្ឋានមាន ១ គឺ អស្សាសបស្សាសវាយោ ។

**៣.**មាន ឧតុ ជាសមុដ្ឋានមាន ៤ គឺ ឧទរិយំ ករីសំ បុព្វោ និង មុត្តំ ។

**៤.**មាន ចិត្ត និង ឧតុ ជាសមុដ្ឋាន ( គឺ មានសមុដ្ឋាន ២ ) មាន ៤ គឺ សេទោ អស្សុ ខេឡោ និង សិង្ឃាណិកា ។

**៥.** មាន កម្ម ចិត្ត ឧតុ អាហារ ជាសមុដ្ឋាន ( មានសមុដ្ឋានទាំង ៤ ) មាន ៣២ គឺ អាការដែលនៅសល់ **៣២** ៕

# ការប្រព្រឹត្តរបស់ សមុដ្ឋានិករូបនៅក្នុងរាងកាយ

ក្នុងរាងកាយរបស់មនុស្ស និង សត្វតិរច្ឆានទាំងឡាយ ដែលមានរូបរាងសណ្ឋាន អវយវៈផ្សេងៗ ប្រាកដឡើងបាននោះ រមែងអាស្រ័យកម្មជរូប ជាមូលដ្ឋានជាមុនសិន រួចហើយរូបដទៃៗ ទើបជួយទំនុកបម្រុងឲ្យរូបរាងសណ្ឋាន និង អវយវៈប្រាកងច្បាស់ឡើងបាន ។ បើមិនបានកម្មជរូបជាមូលដ្ឋានធានាទេ រាងកាយនោះៗក៏មិនខុសអ្វីពីដើមឈើ ឬ អង្កត់អុសឡើយ ។ រូបដែលជាអ្នកជួយទំនុកបម្រុងឲ្យរូបរាងសណ្ឋានអវយវៈប្រាកដច្បាស់នោះ បានដល់ **ឧតុជរូប ៤** យ៉ាង និង **អាហារជរូប** ។

**ឧតុជរូប** មាន ៤ យ៉ាងនោះ គឺ :

**១.កម្មប្បច្ច័យឧតុជរូប** គឺ ឧតុជរូបដែលមាន កម្មជាបច្ច័យ ។
**២.ចិត្តប្បច្ច័យឧតុជរូប** គឺ ឧតុជរូបដែលមាន ចិត្តជាបច្ច័យ ។

**៣.ឧតុប្បច្ច័យឧតុជរូប** គឺ ឧតុជរូបដែលមាន ឧតុជាបច្ច័យ ។
**៤.អាហារប្បច្ច័យឧតុជរូប** គឺ ឧតុជរូបដែលមាន អាហារ ជាបច្ច័យ ។

ដោយហេតុនេះឯង ទើបមានឧតុជរូបគ្រប់គ្រង នៅទូទៅទាំងអស់ ក្នុងរាងកាយរបស់មនុស្ស និង សត្វតិរច្ឆានទាំងឡាយ ទោះជាសត្វនោះ**ស្លាប់**ក៏ដោយ **ឧតុជរូប** ក៏គង់នៅប្រាកដរហូត ។ ចំណែកឯ កម្មជរូប និង អាហារជរូបនោះ ប្រាកដនៅបានតែក្នុងចន្លោះដែល សត្វមានជីវិតរស់នៅប៉ុណ្ណោះ កាលសត្វនោះស្លាប់ទៅហើយ រូបទាំង ២ នេះ ក៏រលត់គ្មានសល់ទាំងអស់ ។

ចំពោះចិត្តជរូបវិញនោះ ប្រាកដឡើងដោយចំពោះខ្លួនឯង មិនបាន ត្រូវអាស្រ័យកម្មជរូប ឧតុជរូប អាហារជរូប ទាំង ៣ នេះជាទីតាំង ទើបកើតឡើងបាន គឺថា ចិត្តជរូបនេះ ត្រូវអាស្រ័យរាងកាយរបស់សត្វដែលកើតឡើងនោះឯង បើមិនមានរាងកាយទេ ចិត្តជរូប ក៏កើតមិនបានដែរ ។

**ចិត្តជរូប** មាន ៧ យ៉ាង គឺ :

**១. ចិត្តជរូបសាមញ្ញ** បានដល់ ចិត្តជរូបដែលប្រព្រឹត្តទៅ

យ៉ាងធម្មតា ដូចជា ការដកដង្ហើមចេញចូល ការប្រចាប់នៃបេះដូង ការលោតជីពចរ ជាដើម ។

**២.ចិត្តជរូប ដែលទាក់ទងនឹងការសើច** បានដល់ អាការសើច ការញញឹមញញែម ។

**៣.ចិត្តជរូប ដែលទាក់ទងនឹងការយំ** គឺ ការយំនោះឯង ។

**៤.ចិត្តជរូប ដែលទាក់ទងនឹងការកម្រើកឥរិយាបថតូច** បានដល់ ការបត់ចូល លាចេញ ឱន ងើប ងើយ ងាកស្តាំក្រឡេក ឆ្វេង ឈានទៅមុខ ត្រឡប់ថយក្រោយ ពព្រិចភ្នែក ហាមាត់ស្ងាប ទំពា លេប ជាដើម ។

**៥.ចិត្តជរូប ដែលទាក់ទងនឹងការនិយាយ** បានដល់ ការនិយាយ ពោល ថ្លែង អានសៀវភៅ ច្រៀង ជាដើម ។

**៦.ចិត្តជរូប ដែលទាក់ទងនឹងឥរិយាបថធំ** បានដល់ ឥរិយាបថ ទាំង ៤ គឺ ការដើរ ឈរ អង្គុយ ដេក ។

**៧.ចិត្តជរូប ដែលទាក់ទងនឹងឥរិយាបថតាំងមាំ** បានដល់ ការដើរ ឈរ អង្គុយ ដេក នៃបុគ្គលដែលមិនមានជម្ងឺ ឈឺថ្កាត់ រោគ ភ័យបៀតបៀន ដែលប្រព្រឹត្តបានជាធម្មតា ។

ការប្រព្រឹត្តទៅនៃរូប ដែលធ្វើឲ្យមានការដើរ ឈរ អង្គុយ ដេក ឈ្មោះថា ឥរិយាបថ ព្រោះជាកិរិយាកម្រើកតាមផ្លូវកាយ ។

ចំពោះចិត្តជរូប ៧ យ៉ាង ដែលពោលមកនេះ បើសម្តែងដោយអង្គធម៌ គឺបានដល់ ចិត្តជរូប ១៥ នោះឯង ។ ប៉ុន្តែក្នុងចិត្តជរូប ១៥ នេះ រូបដែលប្រាកដឲ្យសង្កេតបាន មាន ១០ រូប គឺ វណ្ណៈ សទ្ទៈ ផោដ្ឋព្វៈ៣ វិការរូប៥ ។ ចំណែក រូបដែលនៅសល់ ៥ ទៀត គឺ អាបោ គន្ធៈ រសៈ អាហារ បរិច្ឆេទ ទាំងនេះមិនប្រាកដឲ្យសង្កេតបានឡើយ ។

# ចំណែកចិត្ត ៧៥ ដួង
# ដោយចិត្តជរូប ៧ យ៉ាង

**១. ចិត្តដែលធ្វើឲ្យចិត្តជរូបសាមញ្ញ** កើតឡើងបាន នោះ មាន ៧៥ ដួង គឺ :

- អកុសលចិត្ត ១២
- អហេតុកចិត្ត ៨
  ( វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ )
- កាមាវចរសោភណចិត្ត ២៤

- មហគ្គតចិត្ត ២៣
( វៀរអរូបវិបាកចិត្ត ៤ )
- លោកុត្តរចិត្ត ៨

**២. ចិត្តដែលធ្វើឲ្យការសើច** កើតឡើងបាន មាន ១៣ ដួង គឺ :

- សោមនស្សលោភមូលចិត្ត ៤
- សោមនស្សហសិតុប្បាទចិត្ត ១
- សោមនស្សមហាកុសលចិត្ត ៤
- សោមនស្សមហាកិរិយាចិត្ត ៤

បើចែកសោមនស្សកាមជវន ១៣ នេះ ដោយបុគ្គល បាន យ៉ាងនេះ គឺ :

◎ **បុថុជ្ជន** សើច ដោយចិត្ត ៨ ដួង គឺ :

- សោមនស្សលោភមូលចិត្ត ៤
- សោមនស្សមហាកុសលចិត្ត ៤

◎ **ផលសេក្ខបុគ្គល ៣** សើច ដោយចិត្ត ៦ ដួង គឺ :

- សោមនស្សលោភមូលចិត្តទិដ្ឋិគតវិប្បយុត្ត ២
- សោមនស្សមហាកុសលចិត្ត ៤

◎ **ព្រះអរហន្ត** ញញឹម ដោយចិត្ត ៥ ដួង គឺ :

- សោមនស្សហសិតុប្បាទចិត្ត ១
- សោមនស្សមហាកិរិយាចិត្ត ៤

ការញញឹមរបស់ព្រះអរហន្ត ដោយហសិតុប្បាទចិត្ត ពេលបានប្រទះនឹងអនិដ្ឋារម្មណ៍ដ៏ល្អិត ដែលបុគ្គលធម្មតាមិនអាចដឹងបាន ។ ប៉ុន្តែបើញញឹមដោយសោមនស្សមហាកិរិយាចិត្ត ដោយបានជួបប្រទះនឹងអនិដ្ឋារម្មណ៍គ្រោតគ្រាត ដែលបុគ្គលទូទៅអាចដឹងបាន ។

**៣. ចិត្តដែលធ្វើឲ្យការយំ** កើតឡើងបាន មាន ២ ដួង គឺ :

- ទោសមូលចិត្ត ២

**៤. ចិត្តដែលធ្វើឲ្យកម្រើកឥរិយាបថតូច** កើតឡើងបាន មាន ៣២ ដួង គឺ :

- មនោទ្វារាវជ្ជនចិត្ត ១
- កាមជវនចិត្ត ២៩
- អភិញ្ញាចិត្ត ២

**៥. ចិត្តដែលធ្វើឲ្យការនិយាយ** កើតឡើងបាន មាន ៣២ ដួង គឺ ដូចគ្នានឹង ខ.បទទី ៤ ។

**៦. ចិត្តដែលធ្វើឲ្យឥរិយាបថធំទាំង ៤** កើតឡើងបាន មាន ៣២ ដួង ដូចគ្នានឹង ខ.បទទី៤ ។

**៧. ចិត្តដែលជួយផ្តល់ឲ្យឥរិយាបថធំទាំង ៤** តាំងមាំ កើតឡើងបាន មាន ៥៨ ដួង គឺ :

| | | |
|---|---|---|
| - | មនោទ្វារាវជ្ជនចិត្ត | ១ |
| - | កាមជវនចិត្ត | ២៩ |
| - | អភិញ្ញាចិត្ត | ២ |
| - | អប្បនាជវនចិត្ត | ២៦ |

◎ អភិញ្ញាចិត្ត ២ ដួងនេះ សង្គ្រោះចូលក្នុងអប្បនាជវនចិត្ត ២៦ គឺ រូបាវចរបញ្ចមជ្ឈានកុសលចិត្ត១-កិរិយាចិត្ត១ នោះឯង ។ ប៉ុន្តែដែលរាប់ដោយចំពោះទៀត ព្រោះអភិញ្ញាចិត្ត មានការដឹងអារម្មណ៍ ពិសេសជាង ៕

# ការចែកចិត្តជរូប ៧ យ៉ាងតាមប្រភេទនៃចិត្ត

**១. ចិត្តជរូប** ដែលកើតពី **សោមនស្សលោភមូលចិត្ត**

**៤ ដួង** ចេតសិក ២២ ដួង **មាន ៦ យ៉ាង** វៀរចិត្តជរូប ដែលទាក់ទងនឹងការយំ ។

**២. ចិត្តជរូប** ដែលកើតពី **ឧបេក្ខាលោភមូលចិត្ត ៤ ដួង** ចេតសិក ២១ ដួង **មាន ៥ យ៉ាង** វៀរចិត្តជរូប ដែលទាក់ទងនឹងការសើច ១ ទាក់ទងនឹងការយំ ១ ។

**៣. ចិត្តជរូប** ដែលកើតពី **ទោមនស្សមូលចិត្ត ២ ដួង** ចេតសិក ២២ ដួង **មាន ៦ យ៉ាង** វៀរចិត្តជរូបដែលទាក់ទងនឹង ការសើច ១ ។

**៤. ចិត្តជរូប** ដែលកើតពី **មោហមូលចិត្ត ២ ដួង** ចេតសិក ១៦ ដួង **មាន ៥ យ៉ាង** វៀរចិត្តជរូបដែលទាក់ទង នឹងការសើច ១ ទាក់ទងនឹងការយំ ១ ។

**៥. ចិត្តជរូប** ដែលកើតពី **ទ្វិបញ្ចវិញ្ញាណ ១០ ដួង** ចេតសិក ៧ ដួង មិនមាន ។

**៦. ចិត្តជរូប** ដែលកើតពី **សម្បដិច្ឆន្នចិត្ត ២ ដួង សន្តីរណចិត្ត៣ ដួង បញ្ចទ្វារាវជ្ជនចិត្ត ១ ដួង** រួមជា ៦ ដួង ចេតសិក ១១ ដួង **មាន ១ យ៉ាង** គឺ ចិត្តជរូបសាមញ្ញ ។

**៧. ចិត្តជរូប** ដែលកើតពី **មនោទ្វារាវជ្ជនចិត្ត ១ ដួង** ចេតសិក ១១ ដួង **មាន ៥ យ៉ាង** វៀរចិត្តជរូបដែលទាក់ទងនឹងការសើច ១ ទាក់ទងនឹងការយំ ១ ។

**៨. ចិត្តជរូប** ដែលកើតពី **ហសិតុប្បាទចិត្ត ១ ដួង** ចេតសិក ១២ ដួង **មាន ៦ យ៉ាង** វៀរចិត្តជរូបដែលទាក់ទងនឹងការយំ ។

**៩. ចិត្តជរូប** ដែលកើតពី **សោមនស្សមហាកុសល-ចិត្ត ៤ ដួង** សោមនស្សមហាកិរិយាចិត្ត ៤ ដួង ចេតសិក ៣៨ ដួង **មាន ៦ យ៉ាង** វៀរចិត្តជរូបដែលទាក់ទងនឹងការយំ ។

**១០. ចិត្តជរូប** ដែលកើតពី **ឧបេក្ខាមហាកុសលចិត្ត ៤ ដួង** ឧបេក្ខាមហាកិរិយាចិត្ត ៤ ដួង ចេតសិក ៣៧ ដួង **មាន ៥ យ៉ាង** វៀរចិត្តជរូបដែលទាក់ទងនឹងការសើច ១ ទាក់ទងនឹងការយំ ១ ។

**១១. ចិត្តជរូប** ដែលកើតពី **មហាវិបាកចិត្ត ៨ ដួង** ចេតសិក ៣៣ ដួង **មាន ១ យ៉ាង** គឺ ចិត្តជរូបសាមញ្ញ ។

**១២. ចិត្តជរូប** ដែលកើតពី **អប្បនាជវន ២៦** ( វៀរ

អភិញ្ញាចិត្ត ២) ចេតសិក ៣៨ ដួង **មាន ២ យ៉ាង :**

- ចិត្តជរូបសាមញ្ញ ១
- ចិត្តជរូបដែលទាក់ទងនឹងឥរិយាបថធំតាំងមាំ ៣ (គឺការឈរ អង្គុយ ដេក)ដែលកើតពី មនោទ្វារាវជ្ជនចិត្ត ១ កាមជវនចិត្ត ២៩ អភិញ្ញាចិត្ត ២ តាំងមាំនៅបានយូរ ១ ។

**១៣. ចិត្តជរូប** ដែលកើតពី **រូបាវចរវិបាកចិត្ត ៥ ដួង** ចេតសិក ៣៥ ដួង **មាន ១ យ៉ាង** គឺ ចិត្តជរូបសាមញ្ញ ១ ។

**១៤. ចិត្តជរូប** ដែលកើតពី **អរូបាវចរវិបាកចិត្ត ៤ ដួង** ចេតសិក ៣០ ដួង មិនមាន ។

**១៥. ចិត្តជរូប** ដែលកើតពី **អភិញ្ញាចិត្ត ២ ដួង** ចេតសិក ៣០ ដួង **មាន ៥ យ៉ាង** វៀរចិត្តជរូបដែលទាក់ទងនឹងការសើច ១ ទាក់ទងនឹងការយំ ១ ៕

......................

# ៤. រូបកលាបន័យ

**រូបកលាបន័យ** ជាន័យសម្តែងពីការកើតឡើង ជាក្រុមៗ របស់រូបធម៌ ។

ក្នុងបរមត្ថទីបនីដីកាសម្តែងថា **កលាបិយន្តិ ឯត្ថាតិ កលាបោ** ប្រែថា ធម្មជាតិដែលកំណត់ គឺ រាប់បានជាក្រុម ជាពួក ជាគណៈ ជាកង ជាសំណុំ ឈ្មោះថា **កលាបៈ** ។

ដូច្នេះ **រូបកលាបៈ** សំដៅដល់ រូបដែលជាពួកៗ ជាក្រុមៗ ជាកង ជាសំណុំ គឺថា បណ្តារូបធម៌ទាំងពួងដែលកើតឡើងនោះ រមែងកើតឡើងជាពួក ជាក្រុម នឹងកើតឡើងចំពោះរូបណាមួយតែឯង ដោយចំពោះនោះ មិនមានឡើយ ។ ដូច្នេះ ក្នុងរូបកលាបៈនីមួយៗ ក្រុមរូប ត្រូវមានសភាពនៃការប្រព្រឹត្តទៅរួមព្រមគ្នា ៣ យ៉ាង ដែលហៅថា **សហវុត្តិ** ។

ការកើតឡើង និង ការប្រព្រឹត្តិរបស់រូបកលាបៈ ដែលហៅថា **សហវុត្តិ** ត្រូវប្រកបព្រមដោយអង្គ ៣ គឺ :

**១. ឯកុប្បាទ** កើតព្រមគ្នា ។

**២. ឯកនិរោធ** រលត់ព្រមគ្នា ។

**៣.ឯកនិស្សយ** មានទីអាស្រ័យ គឺ មហាភូតរូបតែមួយដូចគ្នា ។

កាលណារូបមានការប្រព្រឹត្តិទៅរួមគ្នាទាំង ៣ យ៉ាងនេះហើយ ទើបហៅថា **រូបកលាបៈ** ដែលមានចំនួនពិត ទាំងអស់មាន ២៣ កលាបៈ ។

**កម្មចិត្តោតុកាហារ សមុដ្ឋានា យថាកម្មំ**
**នវដ្ឋ ចតុរោ ទ្វេតិ កលាបាហិ តេវីសតិ**

ប្រែថា រូបកលាបៈដែលមាន កម្ម ចិត្ត ឧតុ អាហារ ជាសមុដ្ឋានទាំងនេះ កាលណាពោលតាមចំនួនដែលពិតប្រាកដហើយ មានតាមលំដាប់ដូចតទៅនេះ គឺ កម្មជ្ជកលាបៈ ៩ , ចិត្តជ្ជ-កលាបៈ ៨ , ឧតុជ្ជកលាបៈ ៤ , អាហារជ្ជកលាបៈ ២ រួមទាំងអស់ជា ២៣ កលាបៈ ។

ហើយក្នុងចំនួនរូបកលាបៈ ២៣ ទាំងនេះទៀត កាលណារាប់ចំនួនរូបហើយ ក៏បានរូប ២៣ រូប គឺ ក្នុងរូប ២៨ នោះវៀរបរិច្ឆេទរូប ១ និង លក្ខណរូប ៤ គង់នៅសល់ ២៣ រូប ។

**កលាបានំ បរិច្ឆេទ លក្ខណត្តា វិចក្ខណា**

## ន កលាបង្គមិច្ចាហុ អាកាសំ លក្ខណានិ ច

ប្រែថា អាកាសរូប ១ និង លក្ខណរូប ៤ បណ្ឌិតទាំងឡាយមិនសម្ដែងថា ជាអង្គនៃកលាបៈទេ ព្រោះរូបទាំង ៥ នេះ ម្យ៉ាងត្រឹមតែជាចំណែកឃាំងរាំងរបស់រូបកលាបៈ គឺ កំណត់ទីដែនបំផុតរវាងរូបកលាបៈ និង រូបកលាបៈ ម្យ៉ាងទៀត ត្រឹមតែជាគ្រឿងកំណត់សំគាល់របស់រូបកលាបៈប៉ុណ្ណោះ ។

# ១. កម្មជកលាបៈ ៩

**១.ចក្ខុទសកកលាបៈ** សំដៅយក កលាបៈដែលមានចំនួនរូប ១០ មានចក្ខុបសាទជាប្រធាន បានដល់ អវិនិព្ភោគរូប ៨ ជីវិតរូប ១ ចក្ខុបសាទរូប ១ ។

**២.សោតទសកកលាបៈ** សំដៅយក កលាបៈដែលមានចំនួនរូប ១០ មានសោតបសាទជាប្រធាន បានដល់ អវិនិព្ភោគរូប ៨ ជីវិតរូប ១ សោតបសាទរូប ១ ។

**៣.ឃានទសកកលាបៈ** សំដៅយក កលាបៈដែលមានចំនួនរូប ១០ មានឃានបសាទជាប្រធាន បានដល់ អវិនិព្ភោគរូប ៨ ជីវិតរូប ១ ឃានបសាទរូប ១ ។

**៤.ជិវ្ហាទសកកលាបៈ** សំដៅយក កលាបៈដែលមានចំនួនរូប ១០ មានជិវ្ហាបសាទជាប្រធាន បានដល់ អវិនិព្ភោគរូប ៨ ជីវិតរូប ១ ជិវ្ហាបសាទរូប ១ ។

**៥.កាយទសកកលាបៈ** សំដៅយក កលាបៈដែលមានចំនួនរូប ១០ មានកាយបសាទជាប្រធាន បានដល់ អវិនិព្ភោគរូប ៨ ជីវិតរូប ១ កាយបសាទរូប ១ ។

**៦.ឥត្ថីភាវទសកកលាបៈ** សំដៅយក កលាបៈដែលមានចំនួនរូប ១០ មានឥត្ថីភាវរូបជាប្រធាន បានដល់ អវិនិព្ភោគរូប ៨ ជីវិតរូប ១ ឥត្ថីភាវរូប ១ ។

**៧.បុរិសភាវទសកកលាបៈ** សំដៅយក កលាបៈដែលមានចំនួនរូប ១០ មានបុរិសភាវរូបជាប្រធាន បាន

ដល់ អវិនិព្ភោគរូប ៨ ជីវិតរូប ១ បុរិសភាវរូប ១ ។

**៨.វត្ថុទសកកលាបៈ** សំដៅយក កលាបៈដែលមានចំនួនរូប ១០ មានហទយវត្ថុរូបជាប្រធាន បានដល់ អវិនិព្ភោគរូប ៨ ជីវិតរូប ១ ហទយវត្ថុរូប ១ ។

**៩.ជីវិតនវកកលាបៈ** សំដៅយក កលាបដែលមានចំនួនរូប ៩ មានជីវិតរូបជាប្រធាន បានដល់ អវិនិព្ភោគរូប ៨ ជីវិតរូប ១ ។

**អវិនិព្ភោគរូប** គឺជារូប ដែលបែកចេញពីគ្នាមិនបាន មាន ៨ គឺ បឋវី អាបោ តេជោ វាយោ វណ្ណៈ គន្ធ រសៈ និង ឱជា ។ រូប ទាំង ៨ នេះ តាមន័យនៃកលាបៈ ត្រូវប្រកបជាមូលដ្ឋាន ប្រចាំក្នុងសមុដ្ឋានទាំង ៤ ទើបឈ្មោះថា **សុទ្ធដ្ឋកកលាបៈ** ។

កម្មជ្ជកលាបៈទាំង ៩ ប្រភេទនេះ ជារូបកលាបៈដែលកើតពី កម្មជាសមុដ្ឋាន គឺ កម្មជ្ជរូប ១៧(រៀបបរិច្ឆេទរូប១) នោះឯង ។ ដូច្នេះ កម្មជ្ជកលាបៈ ៩ នេះ ទើបកើតបានចំពោះតែក្នុងរបស់មាន ជីវិតប៉ុណ្ណោះ ហើយក្នុងមនុស្សម្នាក់ ។ កើតបានយ៉ាងច្រើន ៨

កលាបៈ ព្រោះភាវទសកកលាបៈទាំង ២ នេះ នឹងកើតព្រមគ្នាក្នុងមនុស្សម្នាក់ មិនបាន ។ បើជាប្រុស ក៏ត្រូវវៀរឥត្ថីភាវទសក-កលាបៈចេញ បើជាស្រី ក៏ត្រូវវៀរបុរិសភាវទសកកលាបៈចេញដូច្នេះហើយ ទើបមានត្រឹមតែ ៨ កលាបៈប៉ុណ្ណោះ ។ ក្នុងទីនេះសំដៅយកតែកម្មជកលាបៈ សុទ្ធពិតៗប៉ុណ្ណោះ មិនបានសំដៅយកកម្មប្បច្ច័យឧតុជកលាបៈ គឺ រូបកលាបៈដែលកើតពីឧតុ មានកម្មជាបច្ច័យ ជាសមុដ្ឋានដែរ នោះទេ ។

# សេចក្តីផ្សេងគ្នា
# នៃពាក្យថា កម្មជរូប
# កម្មជកលាបៈ កម្មប្បច្ច័យឧតុជកលាបៈ

**កម្មជរូប** បានដល់ រូបដែលកើតពីកម្ម ជាសមុដ្ឋាន មាន ១៨ រូប ។

**កម្មជកលាបៈ** បានដល់ ក្រុមរូបដែលកើតពីកម្ម មាន ១៧ រូប (វៀរបរិច្ឆេទរូប១) បើរាប់ជាកលាបៈ មាន ៩ កលាបៈ ។

**កម្មប្បច្ច័យឧតុជកលាបៈ** បានដល់ ឧតុជកលាបៈ ដែល

មានកម្មជាបច្ច័យ បានសេចក្ដីថា ក្នុងកម្មជកលាបៈទាំង ៩ នោះ មានឧតុនៅក្នុងនោះដែរ គឺ តេជោធាតុនោះឯង ឧតុបែបនេះកើតឡើង ដោយអាស្រ័យកម្ម ដូច្នេះ ក៏ហៅថា **កម្មជរូប** ។ ចំណែករូបកលាបៈ ដែលកើតពីឧតុ ( គឺ ឧតុជកលាបៈ ) ដែលនៅក្នុងកម្មជកលាបៈទាំងនេះ មិនមែនជារូបកើតពីកម្មដោយត្រង់សុទ្ធទេ គឺកើតឡើងព្រោះមាន កម្ម ចិត្ត និង អាហារ ទាំងនេះជាបច្ច័យ (ជាសមុដ្ឋាន) ទើបឧតុជកលាបៈ នោះហៅថា **កម្មប្បច្ច័យឧតុជ-កលាបៈ** ។ ដូច្នេះ អវយវៈនីមួយៗ ដែលប្រាកដនៅក្នុងរាងកាយរបស់សត្វទាំងឡាយ មាន សក់ រោម ធ្មេញ ក្រចក ស្បែក ស្នែង ភ្លុក ដៃជើងជាដើម ទាំងនេះសុទ្ធតែជា ឧតុជរូបដែលជា កម្ម-ប្បច្ច័យឧតុជកលាបរូបខ្លះ ចិត្តប្បច្ច័យឧតុជរូបខ្លះ ឧតុបច្ច័យឧតុជរូបខ្លះ អាហារប្បច្ច័យឧតុជរូបខ្លះ ប៉ុន្តែមាន កម្មប្បច្ច័យឧតុជរូបជាប្រធាន , ឧតុជរូបនៅសល់ ៣ ទៀត ជាចំណែកប្រកប. សេចក្ដីនេះនឹងដឹងច្បាស់បាន នៅពេលដែលសត្វទាំងឡាយស្លាប់ ព្រោះតាមធម្មតា សត្វទាំងឡាយកាលណាស្លាប់ កម្មជរូបរលត់ព្រមនឹងការស្លាប់ តមកចិត្តជរូបក៏រលត់ និង អាហារជរូបក៏រលត់ មិនមានសល់អ្វីឡើយ គង់នៅសល់តែឧតុជរូបប៉ុណ្ណោះ ។ ឧតុជរូបដែលនៅសល់នេះឯង ជាកម្មប្បច្ច័យឧតុជរូប ចិត្តប្បច្ច័យឧតុជរូប អាហារ-

ប្បច្ច័យឧតុជរូប និង ឧតុបច្ច័យឧតុជរូប រមែងតាំងនៅតាម សមគួរ ស្ងួមរូបទាំងនេះ នឹងកើតឡើងដល់សត្វមានជីវិតក៏ដោយ ក៏មិន មែនកម្មជរូបដោយពិតទេ ដូច្នេះ ទើបពោលថា ក្នុងមនុស្សម្នាក់ៗ មានកម្មជកលាបៈត្រឹមតែ ៨ កលាបៈ យ៉ាងច្រើន ៕

# ការចែកកាយ ៣ ចំណែក

ក្នុងរាងកាយរបស់មនុស្សយើងនេះ ចែកចេញជា ៣ ចំណែក គឺ :

**១.ឧបរិមកាយ** កាយខាងលើ គិតពីក ឡើងទៅដល់ក្បាល ។

**២.មជ្ឈិមកាយ** កាយកណ្តាល គិតពីក ចុះមកដល់ផ្ចិត ។

**៣.ហេដ្ឋិមកាយ** កាយខាងក្រោម គិតពីផ្ចិត ចុះមកដល់ជើង ។

# ស្ថាននៃកម្មជកលាបៈ ៩ ក្នុងកាយ ៣ ចំណែក

**ក្នុងឧបរិមកាយ** កម្មជកលាបកើតបាន ៧ កលាបៈ គឺ :

១. ចក្ខុទសកកលាបៈ ២. សោតទសកកលាបៈ

៣. ឃានទសកកលាបៈ ៤. ជិវ្ហាទសកកលាបៈ

៥. កាយទសកកលាបៈ ៦. ភាវទសកកលាបៈ

៧. ជីវិតនវកកលាបៈ ។

**ក្នុងមជ្ឈិមកាយ** មានកម្មជកលាបៈកើតបាន ៤ កលាបៈ គឺ :

១. កាយទសកកលាបៈ ២. វត្ថុទសកកលាបៈ

៣. ភាវទសកកលាបៈ ៤. ជីវិតនវកកលាបៈ ។

**ក្នុងហេដ្ឋិមកាយ** មានកម្មជកលាបៈកើតបាន ៣ កលាបៈ គឺ :

១. កាយទសកកលាបៈ ២. ភាវទសកកលាបៈ

**៣.** ជីវិតនវកកលាបៈ ។

ដូច្នេះ កលាបៈ ៣ គឺ កាយទសកកលាបៈ ភាវទសក-កលាបៈ ជីវិតនវកកលាបៈ កើតមាននៅទូទៅក្នុងរាងកាយ ទើបហៅថា **សព្វដ្ឋានិកកលាបៈ** ។ ចំណែក **៥ កលាបៈ**ទៀត គឺ ចក្ខុទសកកលាបៈ សោតទសកកលាបៈ ឃានទសកកលាបៈ ជីវ្ហា-ទសកកលាបៈ វត្ថុទសកកលាបៈ មានស្ថានតាំងនៅត្រង់កន្លែងខ្លះៗ ដោយចំពោះ មិនដោយទូទៅ ទើបហៅថា **បទេសកកលាបៈ** ។

# ២. ចិត្តជ្ជកលាបៈ ៨

**ចិត្តជ្ជកលាបៈ** គឺ ជាក្រុមរូបដែលកើតពីចិត្ត ជាសមុដ្ឋាន។ ចិត្តជ្ជកលាបៈនេះ សម្តែងតាមវិសុទ្ធិមគ្គអដ្ឋកថា មាន ៨ កលាបៈ ឯក្នុងអភិធម្មត្ថសង្គហៈសម្តែងត្រឹមតែ ៦ កលាបៈ ប៉ុណ្ណោះ គឺ វៀរសទ្ទនវកកលាបៈ និង សទ្ទលហុតាទិទ្វាទសកកលាបៈ ។

ចិត្តជ្ជកលាបៈ ៨ នោះ គឺ :

**១.សុទ្ធដ្ឋកកលាបៈ** សំដៅយក កលាបៈដែលមានចំនួនរូប ៨ បានដល់ អវិនិព្ភោគរូប ៨ ។

| | |
|---|---|
| ២.សទ្ទនវកកលាបៈ | សំដៅយក កលាបៈដែលមានចំនួនរូប ៩ បានដល់ អវិនិព្ភោគរូប ៨ សទ្ទ-រូប ១ ។ |
| ៣.កាយវិញ្ញត្តិនវក-កលាបៈ | សំដៅយក កលាបៈដែលមានចំនួនរូប ៩ បានដល់ អវិនិព្ភោគរូប ៨ កាយ-វិញ្ញត្តិរូប ១ ។ |
| ៤.វចីវិញ្ញត្តិសុទ្ទទសក-កលាបៈ | សំដៅយក កលាបៈដែលមានចំនួនរូប ១០ បានដល់ អវិនិព្ភោគរូប ៨ វចី-វិញ្ញត្តិរូប ១ សទ្ទរូប ១ ។ |
| ៥.លហុតាទិឯកាទសក-កលាបៈ | សំដៅយក កលាបៈដែលមានចំនួនរូប ១១ បានដល់ អវិនិព្ភោគរូប ៨ វិការ-រូប ៣ ។ |
| ៦.សទ្ទលហុតាទិទ្វា-ទសកកលាបៈ | សំដៅយក កលាបៈដែលមានចំនួនរូប ១២ បានដល់ អវិនិព្ភោគរូប ៨ សទ្ទ-រូប ១ វិការរូប ៣ ។ |
| ៧.កាយវិញ្ញត្តិលហុតា-ទិទ្វាទសកកលាបៈ | សំដៅយក កលាបៈដែលមានចំនួនរូប ១២ បានដល់ អវិនិព្ភោគរូប ៨ |

កាយវិញ្ញត្តិរូប ១ វិការរូប ៣ ។

**៨.វចីវិញ្ញត្តិសទ្ទលហុតា-ទិតេរសកកលាបៈ** សំដៅយក កលាបៈដែលមានចំនួនរូប ១៣ បានដល់ អវិនិព្ភោគរូប ៨ វចី-វិញ្ញត្តិរូប ១ សទ្ទរូប ១ វិការរូប ៣។

ចិត្តជ្ជកលាបៈទាំង ៨ នេះ បានដល់ ចិត្តជ្ជរូប ១៤ (រៀរបរិច្ឆេទរូប១) នោះឯង ដូច្នេះ ចិត្តជ្ជកលាបៈទាំងនេះ រមែងកើតបានចំពោះតែក្នុងវត្ថុដែលមានជីវិតប៉ុណ្ណោះ ។

ក្នុងចិត្តជ្ជកលាបៈទាំង ៨ នោះ គឺ :

**១.សុទ្ធដ្ឋកកលាបៈ** ជារូបដែលកើតឡើង ក្នុងខណៈដែលមិនមានការកម្រើកកាយ មិនមានការនិយាយចរចា ឬ មិនមានការបន្លឺសម្លេងណាមួយចេញមក និង ក្នុងខណៈដែលមានចិត្តខ្សោយកម្លាំង រសេះរសោះ មិនស្វាហាប់ បានដល់ អាការដកដង្ហើមចេញ-ចូល ដែលមានលក្ខណៈអាការយ៉ោងផត ត្រង់ពោះក្នុងខណៈអន់ចិត្ត ក្រោធ ដែលមានលក្ខណៈមុខក្រហម មុខស្លាំង ក្នុងខណៈស្ញើប ភ័យ ខ្លាច ដែលមានអាការព្រឺរោមព្រឺស្បែក ព្រឺសាច់ព្រឺឈាមជាដើម ។

- **សុទ្ធដ្ឋកកលាបៈ** នេះ កាលបើមានវិការរូប ៣ កើត

រួមជាមួយដែរ ក៏ហៅថា **លហុតាទិឯកាទសកកលាបៈ** កើតឡើងក្នុងពេលដែលសប្បាយចិត្ត ឬ ចិត្តស្វាហាប់ បានដល់ អាការដកដង្ហើមចេញ-ចូលនៅពេលដែលស្រួលចិត្ត មានលក្ខណៈអាការមុខមាត់ ស្រស់ស្រាយរីករាយសប្បាយចិត្ត ឬ នៅពេលដែលមានបីតិ មានអាការព្រឺរោមព្រឺស្បែកជាដើម ។

**២.សទ្ទនវកកលាបៈ** កើតនៅពេលដែលមានសម្លេងប្រាកដ ដោយមិនទាក់ទងនឹងការនិយាយចរចា និងកើតនៅពេលដែលចិត្តខ្សោយ ចិត្តរួញរាមិនស្វាហាប់ បានដល់ សម្លេងដែលកើតពីខ្យល់ដកដង្ហើមចេញ-ចូល សម្លេងក្អក កណ្តាស់ ភើ ស្វាប ឬ សម្លេងមមើមមាយ ដែលមិនដឹងរឿងរ៉ាវ ។

**-សទ្ទនវកកលាបៈ** នេះ កាលបើមានវិការរូប ៣ កើតរួមជាមួយដែរ ក៏ហៅថា **សទ្ទលហុតាទិទ្វាទសកកលាបៈ** កើតនៅពេលដែលសប្បាយចិត្ត រីករាយ ស្វាហាប់ បានដល់ សម្លេងបែបតែមួយនឹងសទ្ទនវកកលាបៈ តែសម្លេងនោះលាន់ ឮច្បាស់ជាង និងសម្លេងមមើ ក៏ជារឿងរ៉ាវផ្សេងៗ ។

**៣. កាយវិញ្ញត្តិនវកកលាបៈ** កើតនៅពេលកម្រើកកាយផ្សេងៗដែលមិនជាធម្មតា គឺ នៅពេលដែលចិត្តខ្សោយ អស់កម្លាំង

រសេះរសោះ មិនស្វាហាប់ បានដល់ រូបឥរិយាបថ ផ្សេងៗ ក្នុង ការដើរ ឈរ អង្គុយ ដេក បត់ចូល លាចេញ ងាកក្រឡេក ឈានទៅមុខ ត្រឡប់ថយក្រោយ ពព្រិចភ្នែក ទាំងនេះជាដើម ។

- **កាយវិញ្ញត្តិនវកកលាបៈ** នេះ កាលបើមានវិការរូប ៣ កើតរួមជាមួយដែរ ក៏ហៅថា **កាយវិញ្ញត្តិលហុតាទិទ្វាទសក-កលាបៈ** កើតឡើងក្នុងពេលដែលស្រួលចិត្ត សប្បាយចិត្ត រីករាយ ឬ មានកម្លាំងកំហែង ស្វាហាប់ បានដល់ ការដើរ ឈរ អង្គុយ ដេក ជាដើមពេលដែល ស្រួលបួល រហ័សរហួន ។

**៤.វចីវិញ្ញត្តិសទ្ទទសកកលាបៈ** កើតនៅពេលពោល និយាយចរចា អានសៀវភៅ ច្រៀង សូត្រទន្ទេញជាដើម ដែលមិនជាធម្មតា គឺ នៅពេលដែលមិនសូវសប្បាយចិត្ត ធុញ មិនពេញចិត្តនិយាយ មិនពេញចិត្តអាន ជាដើម ។

- **វចីវិញ្ញត្តិសទ្ទទសកកលាបៈ** នេះ កាលបើមានវិការរូប ៣ កើតរួមជាមួយដែរ ក៏ហៅថា **វចីវិញ្ញត្តិសទ្ទលហុតាទិតេរ-សកលាបៈ** កើតនៅពេលជាធម្មតា ឬ នៅពេលដែលសប្បាយចិត្ត ការនិយាយ ការអាននោះ ក៏ប្រព្រឹត្តទៅបានដោយស្រួល ។

# ចិត្តជរូបនិងចិត្តជកលាបៈ

**ចិត្តជរូប** បានដល់ រូប ដែលកើតពីចិត្តជាសមុដ្ឋាន មាន ១៥ រូប ។

**ចិត្តជកលាបៈ** បានដល់ ក្រុមរូបដែលកើតពីចិត្ត មាន ១៤ រូប (រៀបរបរិច្ឆេទរូប១) បើរាប់ជាកលាបៈ មាន ៨ កលាបៈ ។

ចិត្តជរូបក្តី ចិត្តជកលាបៈក្តី រមែងកើតបានចំពោះសត្វដែលមានខន្ធ ៥ និង កើតបានពីចិត្ត ៧៥ ដួង តាមសមគួរដល់ចិត្តសមុដ្ឋានិករូប ដូចជា :

**១.** ចិត្តជកលាបៈ ដែលឈ្មោះថា សុទ្ធដ្ឋកកលាបៈ តែងកើតបានពីចិត្ត ៧៥ ដួង ។

**២.** ចិត្តជកលាបៈ ដែលឈ្មោះថា សទ្ទនវកកលាបៈ កាយវិញ្ញត្តិនវកកលាបៈ វចីវិញ្ញត្តិសទ្ទទសកកលាបៈ សទ្ទលហុតាទិទ្វាទសកកលាបៈ កាយវិញ្ញត្តិលហុតាទិទ្វាទសកកលាបៈ វចីវិញ្ញត្តិសទ្ទលហុតាទិតេរសកកលាបៈ ទាំង ៦ កលាបៈនេះ កើតបានពីចិត្ត ៣២ ដួង គឺ :

- មនោទ្វារាវជ្ជនចិត្ត ១
- កាមជវនចិត្ត ២៩
- អភិញ្ញាចិត្ត ២

**៣.** ចិត្តជ្ជកលាបៈ ដែលឈ្មោះថា លហុតាទិឯកាទសកកលាបៈ តែងកើតបានពីចិត្ត ៥៨ ដួង គឺ :

- មនោទ្វារាវជ្ជនចិត្ត ១
- កាមជវនចិត្ត ២៩
- អភិញ្ញាចិត្ត ២
- អប្បនាជវនចិត្ត ២៦

# ស្ថាននៃចិត្តជ្ជកលាបៈ ៨ ក្នុងកាយ ៣ ចំណែក

**១. ក្នុងឧបរិមកាយ** កាយចំណែកខាងលើ មានចិត្តជ្ជកលាបៈ កើតបាន ទាំង ៨ កលាបៈ ។

**២. ក្នុងមជ្ឈិមកាយ** និង **ហេដ្ឋិមកាយ** គឺ កាយចំណែកកណ្ដាល និង ចំណែកខាងក្រោម មានចិត្តជ្ជកលាបៈកើតបាន ត្រឹមតែ ៤ កលាបៈ ប៉ុណ្ណោះ គឺ :

- សុទ្ធដ្ឋកកលាបៈ ១
- កាយវិញ្ញត្តិនវកកលាបៈ ១
- លហុតាទិឯកាទសកកលាបៈ ១
- កាយវិញ្ញត្តិលហុតាទិទ្វាទសកកលាបៈ ១

# ៣. ឧតុជ្ជកលាបៈ ៤

**ឧតុជ្ជកលាបៈ** គឺ ជាក្រុមរូបដែលកើតពីឧតុជាសមុដ្ឋាន ។ ឧតុជ្ជកលាបៈ នេះ មាន ៤ កលាបៈ គឺ :

**១.សុទ្ធដ្ឋកកលាបៈ** សំដៅយក កលាបៈដែលមានចំនួនរូប ៨ បានដល់ អវិនិព្ភោគរូប ៨ ។

**២.សទ្ទនវកកលាបៈ** សំដៅយក កលាបៈដែលមានចំនួនរូប ៩ បានដល់ អវិនិព្ភោគរូប ៨ សទ្ទ-រូប ១ ។

**៣.លហុតាទិឯកាទសកកលាបៈ** សំដៅយក កលាបៈដែលមានចំនួនរូប ១១ បានដល់ អវិនិព្ភោគរូប ៨ វិការ-រូប ៣ ។

**៤.សទ្ទលហុតាទិទ្វា-** សំដៅយក កលាបៈដែលមានចំនួនរូប

**ទសកកលាបៈ** ១២ បានដល់ អវិនិព្ភោគរូប ៨ សទ្ទ-
រូប ១ វិការរូប ៣ ។

ឧតុជ្ជកលាបៈទាំង ៤ នេះ បានដល់ ឧតុជ្ជរូប ១២ (រៀរ បរិច្ឆេទរូប១) នោះឯង ។

ឧតុជ្ជកលាបៈនេះ កើតបានទាំងខាងក្នុង និង ខាងក្រៅ រាងកាយរបស់សត្វ គឺ កើតបានទាំងខាងក្នុងវត្ថុដែលមានជីវិត និង ទាំងខាងក្នុងវត្ថុដែលមិនមានជីវិត ។ ឧតុជ្ជកលាបៈដែលកើតខាង ក្នុងរាងកាយរបស់សត្វ គឺ ក្នុងវត្ថុដែលមានជីវិត រមែងកើតបានទាំង ៤ កលាបៈ ចំណែកកើតខាងក្រៅរាងកាយរបស់សត្វ គឺ វត្ថុដែល មិនមានជីវិត រមែងកើតបានត្រឹមតែ ២ កលាបៈប៉ុណ្ណោះ ។

# ឧតុជ្ជកលាបៈ ៤
# ដែលកើតខាងក្នុងរាងកាយសត្វ

**១. សុទ្ធដ្ឋកកលាបៈ** គឺ អវិនិព្ភោគរូប ៨ ដែលកើតនៅ ក្នុងរូបរាងកាយរបស់សត្វ គឺបានដល់ រាងកាយរបស់សត្វទាំងនោះ ឯង ព្រោះឧតុជ្ជកលាបៈនេះ ជាកលាបៈដែលជាមូលដ្ឋានរ៉ាប់រងក្នុង ការរក្សារូបកលាបៈដទៃៗ ប្រសិនបើគ្មានឧតុជ្ជកលាបៈនេះហើយ

រូបកលាបៈដទៃៗមានកម្មជ្ជកលាបៈជាដើម ក៏មិនអាចប្រាកដឡើងបានដែរ ។ ហើយសុទ្ធដ្ឋកកលាបៈនេះ កើតនៅពេលដែលរាងកាយរបស់សត្វនោះៗ មិនជាប្រក្រតី ដូចជាខ្សោយកម្លាំង រសេះរសោះ មិនសប្បាយ ជាដើម ។

- **សុទ្ធដ្ឋកកលាបៈ** នេះកាលបើមាន វិការរូប ៣ កើតរួមជាមួយផង ក៏ហៅថា **លហុតាទិឯកាទសកកលាបៈ** កើតនៅពេលដែលរាងកាយរបស់សត្វនោះៗជាប្រក្រតី សប្បាយ ស្វាហាប់ ។

**២. សទ្ទនវកកលាបៈ** គឺ អវិនិព្ភោគរូប ៨ និង សទ្ទរូប ១ កើតនៅពេលដែលមានសម្លេងប្រាកដចេញមកពីចំណែករាងកាយខ្លះៗ ដូចជា ក្ងរពោះ ស្រមុក ឬ សម្លេងដែលកើតពីការទះដៃផ្ទាត់ដៃ និង សម្លេងដែលកើតពីការវាយ ក្តិចត្រង់កន្លែងណាមួយនៃរាងកាយ ប៉ុន្តែសម្លេងទាំងនោះ មិនសូវជាច្បាស់លាស់ទេ ។

- **សទ្ទនវកកលាបៈ** នេះកាលបើមាន វិការរូប ៣ កើតរួមជាមួយផង ក៏ហៅថា **សទ្ទលហុតាទិទ្វាទសកកលាបៈ** បានដល់ សម្លេងផ្សេងៗដែលបានពោលក្នុងសទ្ទនវកកលាបៈនោះឯង ប៉ុន្តែសម្លេងនោះប្រាកដជាក់ច្បាស់ ។

# ឧតុជ្ជកលាបៈ ២
# ដែលកើតខាងក្រៅសត្វ

**១.សុទ្ធដ្ឋកកលាបៈ** បានដល់ វត្ថុរបស់របរផ្សេង ៗ ដែលមាននៅក្នុងលោកនេះ និង ភ្នំ ដើមឈើ ទឹក ភ្លើង ខ្យល់ ព្រះអាទិត្យ ព្រះចន្ទ ផ្កាយ ពន្លឺ ម្លប់ ជាដើម ។

**២.សទ្ទនវកកលាបៈ** បានដល់ សម្លេងខ្យល់បក់ សម្លេងផ្គរលាន់ សម្លេងទឹកហូរ សម្លេងឡានរគាំង ជាដើម ។

# ឧតុជ្ជរូបនិងឧតុជ្ជកលាបៈ

**ឧតុជ្ជរូប** ជារូបដែលកើតពីឧតុជាសមុដ្ឋាន មាន ១៣ រូប ។

**ឧតុជ្ជកលាបៈ** បានដល់ ក្រុមរូប ដែលកើតពីឧតុជាសមុដ្ឋាន មាន ១២ រូប ( រៀវបរិច្ឆេទរូប ១ ) ។

# ស្ថាននៃឧតុជ្ជកលាបៈ ៤ ក្នុងកាយ ៣ ចំណែក

ក្នុងរាងកាយ ៣ ចំណែក គឺ **ឧបរិមកាយ មជ្ឈិមកាយ** និង **ហេដ្ឋិមកាយ** នោះ ឧតុជ្ជកលាបៈទាំង ៤ រមែងកើតឡើងបាន គឺថា ឧតុជ្ជកលាបៈគ្រប់បែបមាននៅទូទៅ ក្នុងរាងកាយរបស់មនុស្ស ។

ចំពោះ សុទ្ធដ្ឋកកលាបៈ និង លហុតាទិឯកាទសកកលាបៈ រមែងកើតនៅជាប្រចាំជាប្រក្រតី ។

ចំពោះ សទ្ទនវកកលាបៈ និង សទ្ទលហុតាទិទ្វាទសកកលាបៈ មិនបានកើតនៅជាប្រចាំទេ រមែងកើតក្នុងរាងកាយរបស់សត្វ ក្នុងគ្រាខ្លះៗប៉ុណ្ណោះ ។

# ឧតុជ្ជកលាបៈ ៤ យ៉ាងទៀត

**១.កម្មប្បច្ច័យឧតុជ្ជកលាបៈ** បានដល់ ឧតុជ្ជកលាបៈដែលមានកម្មជាបច្ច័យ ។

**២.ចិត្តប្បច្ច័យឧតុជ្ជកលាបៈ** បានដល់ ឧតុជ្ជកលាបៈដែល

មានចិត្តជាបច្ច័យ ។

**៣.ឧតុប្បច្ច័យឧតុជ្ជកលាបៈ** បានដល់ ឧតុជ្ជកលាបៈ ដែលមានឧតុជាបច្ច័យ ។

**៤.អាហារប្បច្ច័យឧតុជ្ជកលាបៈ** បានដល់ ឧតុជ្ជកលាបៈ ដែលមានអាហារជាបច្ច័យ ។

ឧតុជ្ជកលាបៈទាំង ៤ នេះ កាលសត្វនៅមានជីវិត ក៏កើតឡើងក្នុងរាងកាយ គឺ អាការ ៤២ មានសក់ រោម ក្រចក ធ្មេញ ស្បែក ជាដើម រមែងប្រព្រឹត្តទៅតាមការគួរ ។

មែនពិត **ឧតុជ្ជកលាបៈទាំង ៤** នេះ មិនមែនជារូបកើតពី កម្ម ចិត្ត អាហារ ដោយត្រង់ៗទេ គឺ កើតឡើងព្រោះមាន កម្ម ចិត្ត និង អាហារទាំងនោះឯងជាបច្ច័យ ( ជាសមុដ្ឋាន ) ទើបហៅថា **កម្មប្បច្ច័យឧតុជ្ជកលាបៈ** ជាដើម ព្រោះហេតុនោះឯង កាលសត្វនោះស្លាប់ ទើបកម្មជរូបប៉ុណ្ណោះរលត់ព្រមនឹងការ ស្លាប់ បន្ទាប់អំពីនោះ ចិត្តជរូបក៏រលត់ រួចអាហារជរូបក៏រលត់ទៅ តាមលំដាប់ គង់នៅសល់ តែឧតុជ្ជកលាបៈ ដែលនឹងអាចតាំងនៅរហូតនោះ និង បាត់បង់ទៅ ។

# ៤. អាហារជដ្ឋកលាបៈ ២

**អាហារជដ្ឋកលាបៈ** គឺជាក្រុមរូប ដែលកើតពីអាហារ ជាសមុដ្ឋាន ។

អាហារជដ្ឋកលាបៈនេះ មាន ២ កលាបៈ គឺ :

| | |
|---|---|
| **១.សុទ្ធដ្ឋកកលាបៈ** | សំដៅយក កលាបៈដែលមានចំនួន ៨ បានដល់ អវិនិព្ភោគរូប ៨ ។ |
| **២.លហុតាទិឯកា-ទសកកលាបៈ** | សំដៅយក កលាបៈដែលមានចំនួន ១១ បានដល់ អវិនិព្ភោគរូប ៨ និង វិការរូប ៣ ។ |

អាហារជដ្ឋកលាបៈទាំង ២ នេះ បានដល់ អាហារជរូប ១១ (រៀរបរិច្ឆេទរូប១) ដែលកើតបានចំពោះតែខាងក្នុងរាងកាយរបស់សត្វប៉ុណ្ណោះ ការប្រព្រឹត្តិទៅនៃអាហារជដ្ឋកលាបៈទាំង ២ មានយ៉ាងនេះ គឺ :

**១. សុទ្ធដ្ឋកកលាបៈ** កើតពេលដែលបរិភោគអាហារ ឬថ្នាំផ្សេងៗ ល្អក្តី មិនល្អក្តី ចូលទៅហើយមិនទាន់ធ្វើឲ្យរាងកាយ ដឹងខ្លួន ស្រស់បស់ ស្វាហាប់ មានកម្លាំងកំហែង ឬ ពេលដែលបរិភោគ

ចូលទៅហើយ ធ្វើឲ្យរាងកាយដឹងខ្លួនមិនសប្បាយ ស្ពុះស្ពាប់ បានសេចក្ដីថា អាហារជ្ជកលាបៈដែលកើតពីអាហារ ឬ ថ្នាំទាំងនេះ នៅមិនទាន់បានប្រកបដោយ វិការរូបទាំង ៣ នោះឯង ។

**២. លហុតាទិឯកាទសកកលាបៈ** កើតពេលដែលបរិភោគអាហារ ឬ ថ្នាំផ្សេងៗចូលទៅហើយ ធ្វើឲ្យរាងកាយដឹងខ្លួនស្រស់បស់ មានកម្លាំងកំហែង ស្វាហាប់ បានសេចក្ដីថា អាហារ-ជ្ជកលាបៈដែលកើតពីអាហារ ឬ ថ្នាំទាំងនោះ មានវិការរូប ៣ ប្រកបជាមួយ ។

អាហារជ្ជកលាបៈទាំង ២ នេះ កើតនៅខាងក្រៅសត្វ គឺខាងក្រៅវត្ថុដែលមានជីវិត មិនបានទេ ព្រោះអាហារជ្ជកលាបៈនឹងកើតបាននោះ ត្រូវអាស្រ័យ **កម្មជ្ជឱជា** ដែលនៅក្នុងរាងកាយរបស់សត្វ ជាអ្នកឧបការដល់ **ពហិទ្ធឱជា** គឺ ឱជា ដែលនៅក្នុងអាហារផ្សេងៗក្រៅរាងកាយនោះ ។ ដូច្នេះ រូបកលាបៈដែលនៅក្នុងអាហារផ្សេងៗ ដែលនៅមិនទាន់បានបរិភោគចូលទៅនោះ មិនមែនជាអាហារជ្ជកលាបៈទេ គឺជា ឧតុជ្ជកលាបៈទាំងអស់ ។

បណ្ដាដើមឈើផ្សេងៗទាំងឡាយ ដែលចម្រើនលូតលាស់ ធំខ្ពស់ ចេញផ្កា ចេញផ្លែបាន ដោយអាស្រ័យ ដី ទឹក ជីជាតិជាដើម

យ៉ាងនេះ យើងតែងនាំគ្នាយល់ថា ដី ទឹក និង ជីជាតិនោះៗ ធ្វើឲ្យអាហារជ្ជកលាបៈកើតដល់ដើមឈើនោះ ប៉ុន្តែសេចក្ដីពិត ដី ទឹក និង ជីជាតិទាំងនោះ មិនបានធ្វើឲ្យអាហារជ្ជកលាបៈកើតដល់ដើមឈើ ដោយប្រការណាមួយឡើយ គ្រាន់តែធ្វើឲ្យឧតុជ្ជកលាបៈកើតទេតើ ព្រោះដើមឈើស៊ីអាហារដូចសត្វមិនបាន ឯដី ទឹក និង ជីដែលស្រោចទៅនោះ តែងជ្រាបចូលទៅក្នុងតួដើមឈើតាមឫសកែវ ឬ ឫសឃាង របស់ដើមឈើ ដែលប្រព្រឹត្តទៅតាមធម្មតាប៉ុណ្ណោះ ប៉ុន្តែយើងនាំគ្នាហៅ ដោយវោហារថា ដើមឈើស៊ីអាហារ ដូចគ្នានឹងនិយាយថា ឡានស៊ីសាំង ប៉ុន្តែសេចក្ដីពិត គ្រាន់តែប្រើនិយាយដោយសម្មតិវោហារប៉ុណ្ណោះ ។

# អាហារជ្ជរូប
# និង អាហារជ្ជកលាបៈ

**អាហារជ្ជរូប** ជា រូប ដែលកើតពីអាហារជាសមុដ្ឋាន មាន ១២ រូប ។

**អាហារជ្ជកលាបៈ** ជា ក្រុមរូប ដែលកើតពីអាហារ មាន ចំនួន ១១ រូប (វៀរបរិច្ឆេទរូប) ។

# ស្ថាននៃអាហារជ្ជកលាបៈ ២ ក្នុងកាយ ៣ ចំណែក

ក្នុងកាយទាំង ៣ ចំណែកនោះ អាហារជ្ជកលាបៈ ទាំង ២ រមែងកើតបានទូទៅ ក្នុងគ្រប់ចំណែកនៃរាងកាយ ។

# រូបកលាបៈក្នុងអាការ ៤២

រូបកលាបៈដែលកើតពីកម្មមាន ៩ កើតពីចិត្តមាន ៨ កើតពីឧតុមាន ៤ និង កើតពីអាហារមាន ២ រួមជា ២៣ ។ កលាបៈទាំងនោះ កាលនៅមានជីវិត តែងតែកើត ប្រព្រឹត្តទៅក្នុងអាការ ៤២ ដូចនេះ គឺ :

# ១.សសម្ភារបឋវី២០អាការ

ធាតុដីក្នុងរាងកាយ មានសម្តែងរូបកលាបៈទុក ២ ន័យ គឺ :

**ក.** ក្នុងអាការ ២ បានដល់ **ឧទរិយំ** = អាហារថ្មី និង **ករីសំ** = អាហារចាស់ មានរូបកលាបៈកើតបាន **១ កលាបៈ** ចំនួនរូបមាន **៨ រូប** គឺ :

- ឧតុសុទ្ធដ្ឋកកលាបៈ ១ កលាបៈ មាន ៨ រូប

**ខ.** ក្នុងអាការ ១៨ ទៀត (វៀរ ឧទរិយំ ករីសំ) មាន រូបកលាបៈកើតបាន **៥ កលាបៈ** ចំនួនរូបមាន **៤៤ រូប** គឺ :

- កាយទសកកលាបៈ ១ កលាបៈ មាន ១០ រូប
- ភាវទសកកលាបៈ ១ កលាបៈ មាន ១០ រូប
- ចិត្តសុទ្ធដ្ឋកកលាបៈ ១ កលាបៈ មាន ៨ រូប
- ឧតុសុទ្ធដ្ឋកកលាបៈ ១ កលាបៈ មាន ៨ រូប
- អាហារសុទ្ធដ្ឋកកលាបៈ ១ កលាបៈ មាន ៨ រូប

រួម ៥ កលាបៈ មាន ៤៤ រូប ។

# ២.សសម្ភារអាបោ១២អាការ

ធាតុទឹកក្នុងរាងកាយ មានសម្តែងរូបកលាបៈទុក ៣ ន័យ គឺ :

**ក.** ក្នុងអាការ ៦ បានដល់ **បិត្តំ** = ទឹកប្រមាត់ **សេម្ហំ** = ស្លេស្ម៍ **លោហិតំ** = ឈាម **មេទោ** = ខ្លាញ់ខាប់ **វសា** = ខ្លាញ់រាវ **លសិកា** = ទឹករំអិល មានរូបកលាបៈ កើត **៥ កលាបៈ** ចំនួនរូបមាន **៤៤ រូប** ស្មើនឹងខទី ១ខ ។

**ខ.** ក្នុងអាការ ៤ បានដល់ **សេទោ** = ញើស **អស្សុ** = ទឹកភ្នែក **ខេឡោ** = ទឹកមាត់ **សិង្ឃានិកា** = ទឹកសំបោរ មានរូបកលាបះកើតបាន **២ កលាបះ** ចំនួនរូបមាន **១៦ រូប** គឺ :

- ចិត្តសុទ្ធដ្ឋកកលាបៈ ១ កលាបៈ មាន ៨ រូប ។
- ឧតុសុទ្ធដ្ឋកកលាបៈ ១ កលាបៈ មាន ៨ រូប ។

រួម ២ កលាបៈ មាន ១៦ រូប ។

**គ.** ក្នុងអាការ ២ បានដល់ **បុញ្ញោ** = ខ្ទុះ **មុត្តំ** = ទឹកមូត្រ មានរូបកលាបះកើតបាន **១ កលាបះ** ចំនួនរូបមាន **៨ រូប** គឺ :

- ឧតុសុទ្ធដ្ឋកកលាបៈ ១ កលាបៈមាន ៨ រូប ។

# ៣.សសម្ភារតេជោ៤អាការ

ធាតុភ្លើងក្នុងរាងកាយ មានសម្តែងរូបកលាបះទុក ២ ន័យ គឺ :

**ក.** ក្នុងអាការ ៣ បានដល់ **ឧស្មាតេជោ សន្តាប្បនតេជោ** និង **ជិរណតេជោ** មានរូបកលាបះកើតបាន **៤ កលាបះ**

ចំនួនរូបមាន **៣៣ រូប** គឺ :

- ជីវិតនវកកលាបៈ ១ កលាបៈ មាន ៩ រូប ។
- ចិត្តសុទ្ធដ្ឋកកលាបៈ ១ កលាបៈ មាន ៨ រូប ។
- ឧតុសុទ្ធដ្ឋកកលាបៈ ១ កលាបៈ មាន ៨ រូប ។
- អាហារសុទ្ធដ្ឋកកលាបៈ ១ កលាបៈ មាន ៨ រូប ។

រួម ៤ កលាបៈ មាន ៣៣ រូប ។

**ខ.** ក្នុងអាការ ១ ទៀត បានដល់ **បាចកតេជោ** មានរូបកលាបៈកើតបាន **១ កលាបៈ** ចំនួនរូបមាន **៩ រូប** គឺ **ជីវិតនវកកលាបៈ** ។

# ៤.សសម្ភារវាយោ៦អាការ

ធាតុខ្យល់ក្នុងរាងកាយ មានសម្តែងរូបកលាបៈទុក ២ ន័យ គឺ :

**ក.** ក្នុងអាការ ៥ បានដល់ **ឧទ្ធង្គមវាយោ អធោគមវាយោ កុច្ឆិសយវាយោ កោដ្ឋាសយវាយោ អង្គមង្គានុសារិវាយោ** មានរូបកលាបៈកើតបាន **៤ កលាបៈ** ចំនួនរូបមាន **៣៣ រូប** ស្មើនឹង ខទី ៣ក ។

**ខ.** ក្នុងអាការ ១ ទៀត បានដល់ **អស្សាសបស្សាស-វាយោ** = ខ្យល់ដកដង្ហើមចេញ-ចូល មានរូបកលាបៈកើតបាន **១ កលាបៈ** ចំនួនរូបមាន **៩ រូប** គឺ សទ្ទនវកកលាបៈ ។

# រូបកលាបៈក្នុងសសម្ភាររូប ៥

រូបកលាបៈដែលកើតពី កម្ម ចិត្ត ឧតុ អាហារជាសមុដ្ឋានគឺៈ

**១.ក្នុងសសម្ភារចក្ខុ** មានរូបកលាបៈកើតបាន ៦ កលាបៈ ចំនួនរូបមាន **៥៤ រូប** គឺ :

- **ចក្ខុទសកកលាបៈ** ១ កលាបៈ មាន ១០ រូប ។
- **កាយទសកកលាបៈ** ១ កលាបៈ មាន ១០ រូប ។
- **ភាវទសកកលាបៈ** ១ កលាបៈ មាន ១០ រូប ។
- **ចិត្តសុទ្ធដ្ឋកកលាបៈ** ១ កលាបៈ មាន ៨ រូប ។
- **ឧតុសុទ្ធដ្ឋកកលាបៈ** ១ កលាបៈ មាន ៨ រូប ។
- **អាហារសុទ្ធដ្ឋកកលាបៈ** ១ កលាបៈ មាន ៨ រូប ។

រួម ៦ កលាបៈ មាន ៥៤ រូប ។

**២.ក្នុងសសម្ភារសោត ៣-ក្នុងសសម្ភារឃាន ៤-ក្នុង**

**សសម្ភារជិវ្ហា** សសម្ភារទាំង ៣ នេះ មានរូបកលាបៈកើតនីមួយៗ បាន **៦ កលាបៈ** ចំនួនរូបនីមួយៗមាន **៥៤ រូប** ដូចគ្នា និង សសម្ភារចក្ខុ ។

**៥.ក្នុងសសម្ភារកាយ** មានរូបកលាបៈកើតបាន **៥ កលាបៈ** ចំនួនរូបមាន **៤៤ រូប** គឺ :

- **កាយទសកកលាបៈ** ១ កលាបៈ មាន ១០ រូប ។
- **ភាវទសកកលាបៈ** ១ កលាបៈ មាន ១០ រូប ។
- **ចិត្តសុទ្ធដ្ឋកកលាបៈ** ១ កលាបៈ មាន ៨ រូប ។
- **ឧតុសុទ្ធដ្ឋកកលាបៈ** ១ កលាបៈ មាន ៨ រូប ។
- **អាហារសុទ្ធដ្ឋកកលាបៈ** ១ កលាបៈ មាន ៨ រូប ។

រួម ៥ កលាប មាន ៤៤ រូប ។

សសម្ភារកាយមិនមាន ចក្ខុ សោត ឃាន និង ជិវ្ហាបសាទ ទេ ប៉ុន្តែក្នុងសសម្ភារចក្ខុ សោត ឃាន និងជិវ្ហា មានកាយបសាទ កើតរួមជាមួយ ៕

••••••••••••••••••••

# ៥. រូបបវត្តិកមន័យ

**រូបបវត្តិកមន័យ** ជាន័យនៃការសម្តែងអំពីការប្រព្រឹត្តរបស់រូបធម៌តាមលំដាប់ ឬ សម្តែងអំពីការកើត និងការរលត់របស់រូបធម៌តាមលំដាប់ ។

ការប្រព្រឹត្តិ ឬ ការកើត-រលត់របស់រូបធម៌នេះ មានន័យសម្តែងតាមលំដាប់ ដោយអាការ ៣ ប្រការ គឺ :

**១.** តាមន័យនៃ ភូមិ ។

**២.** តាមន័យនៃ កាល ។

**៣.** តាមន័យនៃ កំណើត ។

## ១.តាមន័យនៃភូមិ

**ភូមិ** គឺ កន្លែង ដែលជាទីកើតនៃរូបធម៌ ឯការកើតឡើង និង ការប្រព្រឹត្តិទៅរបស់រូបធម៌ក្នុងភូមិផ្សេងៗនោះ រមែងមានរូបធម៌បានតាមសមគួរដល់ភូមិ និង ភូមិខ្លះ រូបធម៌កើតឡើងមិនបានឡើយ ដូច គាថាសង្គហៈសម្តែងថា :

# គាថាសង្គហៈ

អដ្ឋវីសតិ កាមេសុ ហោន្តិ តេវីស រូបីសុ
សត្តរ សេវា សញ្ញីនំ អរូបេ នត្ថិ កិញ្ចិ បិ

ប្រែថា ក្នុងកាមភូមិ ១១ មានរូបកើតបាន ២៨ រូប ក្នុងរូបភូមិ ១៥ ( វៀរអសញ្ញសត្តភូមិ ) មានរូបកើតបាន ២៣ ក្នុងអសញ្ញសត្តភូមិ ១ មានរូបកើតបាន ១៧ ក្នុងអរូបភូមិមិនមានរូបអ្វីកើតឡើងឡើយ ។

គាថានេះជាគោលនៃការសម្តែងអំពីចំនួនរូប ដែលកើតបាន និង កើតមិនបានក្នុង ៣១ ភូមិ ។

**១. កាមភូមិ ១១** បានដល់ អបាយភូមិ ៤ កាមសុគតិភូមិ ៧ រូបធម៌ទាំង ២៨ តែងកើតបានដោយបរិបូរណ៍ មិនលើស មិន ខ្វះជាងគ្នាឡើយ ប៉ុន្តែបើពោលដោយបុគ្គល ប្រសិនបើជាភេទស្រី ត្រូវវៀរបុរិសភាវៈ ប្រសិនបើភេទប្រុស ក៏ត្រូវវៀរឥត្ថីភាវៈចេញក្រៅពីនេះទៀត បើអ្នកណាមានអវយវៈ ដូចភ្នែក ច្រមុះ ប្រភេទណាមួយ ឬ ពីរបី ខូច ឬ ខ្វោះ ក៏ត្រូវវៀររូបនោះៗចេញទៅតាមសមគួរ ប៉ុន្តែយ៉ាងណាក៏ដោយ កាលណានិយាយរួមហើយ ក្នុង

កាមភូមិ ១១ រូប ទាំង ២៨ រមែងអាចកើតឡើងបាន ដូចគាថា ដែលសម្តែងថា **អដ្ឋវីសតិ កាមេសុ** ។

**២.រូបភូមិ ១៥** បានដល់ បឋមជ្ឈានភូមិ៣ ទុតិយជ្ឈានភូមិ៣ តតិយជ្ឈានភូមិ៣ ចតុត្ថជ្ឈានភូមិ៦ (វៀរអសញ្ញសត្តភូមិ) មានរូបធម៌កើតបានត្រឹមតែ ២៣ រូប ពោលគឺ ក្នុងរូបទាំង ២៨ នោះ រូបធម៌ដែលកើតមិនបានក្នុងរូបភូមិ មាន ៥ រូប គឺ :

ឃានបសាទរូប ១ ជីវ្ហាបសាទរូប ១ កាយបសាទរូប ១ ឥត្ថីភាវរូប ១ និងបុរិសភាវរូប ១ ព្រោះរូបទាំង ៥ នេះ ជារូបដែលឧបត្ថម្ភនូវកាមគុណារម្មណ៍ និង ជាឧបនិស្ស័យនៃកាមរាគៈយ៉ាងខ្លាំងក្លាតែម្យ៉ាង ហើយបណ្តាព្រហ្មទាំងឡាយ ដែលកើតក្នុងរូបភូមិទាំង ១៥ នោះទៀត សុទ្ធតែជាបុគ្គល ដែលកើតឡើងដោយអំណាចនៃរូបជ្ឈានកុសល ដែលប្រាសចាកកាមច្ឆន្ទៈ ដោយអំណាចវិក្ខម្ភនប្បហាន ដូច្នោះ រូបទាំង ៥ នេះ ទើបកើតមិនបានក្នុងបណ្តារូបព្រហ្ម ទាំងឡាយ ។

ឯចក្ខុបសាទ និង សោតបសាទ កើតបានក្នុងរូបព្រហ្មបុគ្គលនោះ ក៏ព្រោះរូបទាំង២នេះ មិនមែនមានទោសតែម្យ៉ាងទេ រមែងមានគុណប្រយោជន៍យ៉ាងច្រើនផងដែរ គឺ ភ្នែក ឬ ចក្ខុបសាទមានគុណប្រយោជន៍ ក្នុងការដែលអាចបានឃើញអ្នកដែលទ្រទ្រង់នូវគុណ

ដ៏ប្រសើរ ខ្ពង់ខ្ពស់ មានព្រះសម្មាសម្ពុទ្ធជាដើម ហៅថា **ទស្សនា-នុត្តរិយគុណ** ។

ត្រចៀក ឬ សោតបសាទ ក៏មានគុណប្រយោជន៍ក្នុងការដែលអាចបានស្តាប់ធម៌ដ៏ប្រសើរ នាំឲ្យបានសម្រេចមគ្គ ផល ផុតចាកវដ្តទុក្ខ ហៅថា **សវនានុត្តរិយគុណ** ។ ដូច្នេះហើយ រូបទាំង ២ គឺ ភ្នែក និង ត្រចៀកនេះ ទើបកើតបានដល់រូបព្រហ្មក្នុងរូបភូមិ ១៥ ។

ចំនួនរូប ២៣ ដែលកើតនឹងពួកព្រហ្មក្នុងរូបភូមិ ១៥ នោះ គឺ មិនមានរូបណាមួយក្នុងរូប ២៣ នោះ ខូច ឬ ខ្វះ ដូចកាម-បុគ្គល មានខ្វាក់ភ្នែក ឬ ត្រចៀកថ្លង់នោះទេ ផ្ទុយទៅវិញ ភ្នែក និង ត្រចៀក ព្រហ្ម រឹងរឹតតែមានកម្លាំងអាច មើលឃើញក្នុងទីឆ្ងាយៗបាន សូម្បីរូបារម្មណ៍ល្អិតក៏ដោយ ហើយនិងអាចឮសម្លេងក្នុងទីឆ្ងាយៗបាន សូម្បីសម្លេងនោះល្អិតក៏ដោយ រហូតដល់ថ្នាក់នាំគ្នាហៅថា ព្រហ្មជាអ្នកមានភ្នែកទិព្វ ត្រចៀកទិព្វ ។

ដូច្នោះ ចំនួនរូបដែលកើតចំពោះព្រហ្ម ទើបមានចំនួនពិតប្រាកដ ២៣ រូប មិនខូចមិនខ្វះ ដូចគាថាសម្តែងថា **ហោន្តិ តេវីស រូបីសុ** ។

**៣. អសញ្ញសត្តភូមិ ១** រមែងមានរូបកើតបានត្រឹមតែ ១៧ រូបប៉ុណ្ណោះ បានដល់ អវិនិព្ភោគរូប ៨ ជីវិតរូប ១ បរិច្ឆេទរូប ១ វិការរូប ៣ និង លក្ខណរូប ៤ រូបដទៃៗក្រៅពីនេះ កើតមិនបាន ទាំងនេះក៏ព្រោះពួកអសញ្ញសត្តព្រហ្មទាំងឡាយមិនមាននាមធម៌ គឺ ចិត្ត និង ចេតសិកកើតឡើងបានទេ ដូច្នោះរូបដែលជាទីអាស្រ័យកើតរបស់ចិត្ត និង ចេតសិក ទើបមិនចាំបាច់កើតដល់អសញ្ញសត្តព្រហ្មឡើយ ចំណែកភាវរូប ២ តែងមិនមានដល់ពួកព្រហ្ម ព្រោះប្រាសចាកកាមរាគៈជានិច្ចហើយ ទើបមិនជាចាំបាច់ដល់ព្រហ្មនោះទេ ។ ដោយហេតុនេះ អសញ្ញសត្តព្រហ្មទើបមានរូបកើតបានត្រឹមតែ ១៧ ប៉ុណ្ណោះ ដូចគាថាសម្ដែងថា **សត្តរសេវាសញ្ញីនំ** ។

**៤. អរូបភូមិ ៤** ជាភូមិរបស់អរូបព្រហ្មទាំងឡាយ កើតឡើងដោយអំណាចការចម្រើនបញ្ចមជ្ឈាន ដែលទាក់ទងដោយរូប-វិរាគ ភាវនា គឺ មិនត្រេកអរ និង មិនប្រាថ្នាក្នុងរូបធម៌ទាំងពួង ។ ដូច្នេះ ពួកអរូបព្រហ្មទាំងឡាយ ទើបមិនមានរូបកើតឡើង រហូតដល់ក្នុងភូមិ ទីនៅ ដែលឈ្មោះថា អរូបភូមិ ក៏មិនមានរូបណាមួយកើតឡើងដូចគ្នា ដូចគាថាដែលសម្ដែងថា **អរូបេ នត្ថិ កិញ្ចិបិ** ៕

# ការចែករូប ២៨ ដែលកើត ក្នុងកាមភូមិ ១១ ដោយសមុដ្ឋាន ៤

រូប ២៨ ដែលកើតបានក្នុងកាមភូមិទាំងអស់នោះ កាលណាចែកដោយសមុដ្ឋានហើយ បានសមុដ្ឋានគ្រប់ទាំង ៤ ទាំងចំនួនសមុដ្ឋានិករូប ក៏កើតឡើងបានគ្រប់ គឺ :

| | | |
|---|---|---|
| -កម្មជរូប | ១៨ | រួមទាំងអស់ ៥៨ រូប |
| -ចិត្តជរូប | ១៥ | |
| -ឧតុជរូប | ១៣ | |
| -អាហារជរូប | ១២ | |

ក្នុងសមុដ្ឋានិករូបទាំង ៤ នេះ សមុដ្ឋាននីមួយៗមានលក្ខណៈទាំង ៤ នៅជាមួយគ្រប់ៗសមុដ្ឋាន គឺ :

ក្នុងកម្មជរូប ១៨ ក៏មានលក្ខណៈរូបទាំង ៤ បានដល់ ឧបចយកម្មជរូប សន្តតិកម្មជរូប ជរតាកម្មជរូប អនិច្ចតាកម្មជរូប រួមជាមួយដែរ ។ ក្នុង ចិត្តជរូប ឧតុជរូប អាហារជរូប ក៏ប្រព្រឹត្តិទៅក្នុងទំនងរបៀបដូចគ្នានេះដែរ ។

កាលណារួមលក្ខណរូប ៤ ដែលនៅក្នុងសមុដ្ឋាន ៤ ក៏បានជារូប ១៦ (=៤×៤) ។ ហើយលក្ខណរូប ១៦ នេះ កាលរួមនឹងសមុដ្ឋានិករូប ៥៨ ក៏បានចំនួនរូប ៧៤ រូប ។

ក្នុងចំនួនរូប ៧៤ នេះ បើគិតតាមធម្មតា បានដល់ រូប ២៨ នោះឯង ៕

**ន័យម៉្យាងទៀត** រាប់សមុដ្ឋានិករូបដោយ**ពិស្តារ** :

**១. កម្មជរូប ១៨** មាននិប្ផន្នរូប ១៧ ( វៀរបរិច្ឆេទរូប ១ ) ប៉ុន្តែនិប្ផន្នរូបនីមួយៗ មានលក្ខណរូប ៤ ទើប :

| | | | |
|---|---|---|---|
| លក្ខណរូប | រួមទាំងអស់មាន | ៦៨ | រូប |
| កម្មជរូប | ទាំងអស់មាន | ១៨ | រូប |
| រួមជាកម្មជរូប | ទាំងអស់ | ៨៦ | រូប |

**២. ចិត្តជរូប ១៥** មាននិប្ផន្នរូប ១៩ ( វៀរ ៦ រូប ) ប៉ុន្តែនិប្ផន្នរូបនីមួយៗ មានលក្ខណរូប ៤ ទើប :

| | | | |
|---|---|---|---|
| លក្ខណរូប | រួមទាំងអស់មាន | ៣៦ | រូប |
| ចិត្តជរូប | ទាំងអស់មាន | ១៥ | រូប |
| រួមជាចិត្តជរូប | ទាំងអស់ | ៥១ | រូប |

**៣. ឧតុជរូប ១៣** មាននិប្ផន្នរូប ៩ ( វៀរ ៤ រូប )

ប៉ុន្តែនិប្ផន្នរូបនីមួយៗ មានលក្ខណរូប ៤ ទើប :

| | | | |
|---|---|---|---|
| លក្ខណរូប | រួមទាំងអស់មាន | ៣៦ | រូប |
| ឧតុជរូប | ទាំងអស់មាន | ១៣ | រូប |
| រួមជាឧតុជរូប | ទាំងអស់ | ៤៩ | រូប |

**៤. អាហារជរូប ១២** មាននិប្ផន្នរូប ៨ ( វៀរ ៤ រូប )
ប៉ុន្តែនិប្ផន្នរូបនីមួយៗ មានលក្ខណរូប ៤ ទើប :

| | | | |
|---|---|---|---|
| លក្ខណរូប | រួមទាំងអស់មាន | ៣២ | រូប |
| អាហារជរូប | ទាំងអស់មាន | ១២ | រូប |
| រួមជាអាហារជរូប | ទាំងអស់ | ៤៤ | រូប |

# ការចែករូប ២៣ ដែលកើត ក្នុងរូបភូមិ ១៥ ដោយសមុដ្ឋាន ៣

រូប ២៣ ដែលកើតបានក្នុងរូបភូមិ ១៥ នោះ កាលណាចែកដោយសមុដ្ឋានហើយ រមែងបានត្រឹមតែ ៣ សមុដ្ឋាន ( វៀរអាហារសមុដ្ឋាន ) ព្រោះថា បណ្ដារូបព្រហ្មទាំងឡាយ មិនបរិភោគអាហារដូចពួកមនុស្ស ឬ ទេវតាទេ ។ ព្រហ្មទាំងឡាយតែងឆ្អែតជានិច្ចដោយបីតិ ដូច្នេះ បីតិទើបទុកដូចជាអាហាររបស់ពួកព្រហ្ម ។

ដោយហេតុនេះឯង រូប ទាំង ២៣ ដែលកើតនឹងរូបព្រហ្មនោះ ទើបមិនមានអាហារជរូប នៅជាមួយឡើយ ។ ក្នុងសមុដ្ឋានទាំង ៣ នោះ គឺ :

**-កម្មជរូប** តែងកើតបាន ១៣ រូប ( វៀរ ឃាន ជីវ្ហា កាយ និង ភាវរូប ២ ) ។

**-ចិត្តជរូប** តែងកើតបានទាំងអស់ ១៥ រូប ។

**-ឧតុជរូប** តែងកើតបានទាំងអស់ ១៣ រូប ។

ដូច្នេះរួមទាំងអស់ រូបកើតបាន ៤១ រូប ហើយរួមទាំង លក្ខណរូប ១២ ទៀត ក៏បានចំនួនរូបដែលកើតក្នុងរូបភូមិ ៥៣ រូប ។ ក្នុងចំនួនរូប ៥៣ រូប នេះ បើគិតតាមធម្មតា បានដល់ រូប ២៣ នោះឯង ៕

# ការចែករូប ១៧ ដែលកើតក្នុង អសញ្ញសត្តភូមិ ១ ដោយសមុដ្ឋាន ២

រូបដែលកើតក្នុងអសញ្ញសត្តព្រហ្មចំនួន ១៧ រូបនោះ កាល ណាចែកដោយសមុដ្ឋានហើយ រមែងបានត្រឹមតែ ២ សមុដ្ឋាន គឺ

កម្មសមុដ្ឋាន និង ឧតុសមុដ្ឋាន ។ ព្រោះអសញ្ញសត្តព្រហ្ម ជាព្រហ្ម ដែលមិនមានចិត្ត និង ចេតសិក ដូច្នេះរូបដែលកើតពីចិត្តជាសមុដ្ឋាន ទើបមិនមាន និង រូបដែលកើតពីអាហារជាសមុដ្ឋាននោះ ក៏មិនមាន ជាធម្មតារបស់ពួករូបព្រហ្មហើយ ដោយហេតុនេះ ចិត្តសមុដ្ឋានិករូប និង អាហារសមុដ្ឋានិករូប ទើបមិនមានដល់អសញ្ញសត្តព្រហ្ម ។

ក្នុងចំនួនរូប ដែលកើតពីសមុដ្ឋានរបស់អសញ្ញសត្តព្រហ្មទាំង ២ នោះ គឺ :

**-កម្មជរូប** តែងកើតបាន ១០ រូប គឺ អវិនិព្ភោគរូប ៨ បរិច្ឆេទរូប ១ ជីវិតរូប ១ ។

**-ឧតុជរូប** តែងកើតបាន ១២ រូប (វៀរសទ្ទរូប) ។

ដូច្នេះរួមទាំងអស់រូបកើតបាន ២២ រូប ហើយរួមទាំងលក្ខណ-រូប ៨ ទៀត ក៏បានចំនួនរូប ៣០ ដែលកើតក្នុងអសញ្ញសត្តភូមិ ។ ក្នុងចំនួនរូប ៣០ រូបនេះ បើគិតតាមធម្មតា បានដល់ រូប ១៧ នោះឯង ៕

•••••••••••••••••••••

# ២.តាមន័យនៃកាល

ការសម្តែងនូវការប្រព្រឹត្តទៅនៃរូប តាមន័យនៃកាលនោះ គឺជាការសម្តែងអំពីរូបទាំង ២៨ នេះ តើរូបណា កើតបានក្នុងកាលណា និង រូបណាកើតមិនបានក្នុងកាលណា ។

កាលវេលា ដែលសម្តែងនូវការប្រព្រឹត្តទៅរបស់រូប មាន ៣ កាល គឺ :

**១.បដិសន្ធិកាល** សំដៅយក វេលាដែលនាម-រូបកើតឡើងគ្រាដំបូងក្នុងភពថ្មី គឺ ឧប្បាទ-ខណៈនៃបដិសន្ធិចិត្ត ។

**២.បវត្តិកាល** សំដៅយក វេលាដែលនាម-រូបកើតរលត់ប្រព្រឹត្តទៅក្នុងភពជាតិនោះៗ គឺតាំងពីឋិតិខណៈ នៃបដិសន្ធិចិត្តជាដើមមក រហូតដល់ឋិតិខណៈនៃចុតិចិត្ត ។

**៣.ចុតិកាល** សំដៅយក វេលាដែលនាម-រូបឃ្លាតចាកភពជាតិនោះៗ គឺ វេលាដែលស្លាប់ចាកភពជាតិនោះៗឯង គឺ ភង្គ-ខណៈនៃចុតិចិត្ត ។

ការសម្តែងនូវការប្រព្រឹត្តិទៅនៃរូប ២៨ ក្នុងកាលទាំង ៣ ថា រូបណាកើតបាន រូបណាកើតមិនបាន ក្នុងកាលណាខ្លះនោះ គប្បីជ្រាបតាមន័យនៃសង្គហគាថា សម្តែងថា :

# គាថាសង្គហៈ

**សទ្ទោ វិការោ ជរតា មរណ្ណ ចោប បត្តិយំ**
**ន លព្ភន្តិ បវត្តេតុ ន កិញ្ចិបិ ន លព្ភន្តិ**

ប្រែថា សទ្ទរូប១ វិការរូប៥ ( គឺ វិញ្ញត្តិរូប២ និង វិការរូប ៣ ) ជរតារូប១ អនិច្ចតារូប១ រួម ៨ រូបនេះ **កើតមិនបានក្នុងបដិសន្ធកាល** ។ ចំណែកក្នុងបវត្តិកាលនោះ រូបណាដែលកើតមិនបាននោះ មិនមានឡើយ រមែងកើតបានទាំងអស់ ។

# អធិប្បាយសេចក្តីសង្គហគាថា

**១.បដិសន្ធិកាល** តាមគាថាខាងដើមដែលសម្តែងថា រូប ៨ នេះ កើតមិនបានក្នុងបដិសន្ធិកាល បានសេចក្តីថា ក្នុងបដិសន្ធិ-ខណៈនៃសត្វទាំងឡាយ សម្លេងនៅមិនទាន់មានទេ ការនិយាយចរចា

ការកម្រើកកាយ រូបស្រាល រូបទន់ រូបគួរដល់ការងារ រហូតដល់រូបកំពុងចាស់ និង រូបកំពុងរលត់ ក៏នៅមិនទាន់មានដែរ ។

ឧបមាដូចថ្នាំងបាយដាក់លើចង្ក្រានភ្លើង កាលដាក់ថ្មីៗ មិនអាចឲ្យបាយនោះក្តៅ ឆ្អិនភ្លាមៗនោះទេ យ៉ាងណាមិញ បដិសន្ធិ-ខណៈរបស់សត្វទាំងឡាយក៏ដូចគ្នា នឹងឲ្យរូបសម្រេចព្រម ក្នុងខណៈកើតដំបូងនោះទេ ក៏រមែងប្រព្រឹត្តទៅមិនបានដូច្នោះដែរ ។

កាលបើសម្តែងថា ចំពោះរូប ៨ រូប មានសទ្ទរូបជាដើមនេះកើតមិនបានក្នុងបដិសន្ធិកាល ដូច្នោះ នឹងអាចយល់បានថា រូបដែលនៅសល់ ២០ រូបទៀត អាចកើតបានក្នុងបដិសន្ធិកាល ។

រូប ២០ រូប ដែលកើតបានក្នុងបដិសន្ធិកាលនោះ បានដល់បសាទរូប ៥ ភាវរូប ២ ហទយរូប ១ ជីវិតរូប ១ អវិនិព្ភោគរូប ៨ បរិច្ឆេទរូប ១ ឧបចយរូប ១ និង សន្តតិរូប ១ ។ រូបទាំង ២០ រូបនេះ ជាកម្មជរូប គឺ ពួករូបដែលកើតពីកម្មជាសមុដ្ឋានតែម្យ៉ាង ចំណែក ចិត្តជរូប ឧតុជរូប និង អាហារជរូបទាំង ៣ ពួករមែងកើតមិនបានក្នុងបដិសន្ធិកាល ការកើតឡើងនៃរូប ២០ ក្នុងបដិសន្ធិកាលនេះ ជាការសម្តែងដល់ចំនួនរូប ដែលនឹងកើតបានទាំងអស់ ក្នុងបដិសន្ធិកាល ប៉ុន្តែបើពោលអំពីឧប្បាទខណៈនៃបដិសន្ធិចិត្ត ចំនួនកម្មជរូបតែងកើតបាន តាមសមគួរដល់ភូមិ និង តាមសមគួរ

ដល់កំណើតនៃសត្វនោះៗ ។

ក្នុងអភិធម្មត្ថសង្គហៈ សម្ដែងរូបដែលកើតមិនបាន ក្នុងបដិសន្ធិកាល ៨ រូប ប៉ុន្តែបើតាមន័យអដ្ឋកថាដីកាវិញ សម្ដែងរូបដែលកើតមិនបាន ៩ រូប គឺ ថែមសន្តតិរូប ១ រូបទៀត ដូច្នេះក្នុងចំនួនរូប ២៨ រូបដែលកើតបានក្នុងបដិសន្ធិកាល មាន ១៩ រូប។

**២.បវត្តិកាល** ក្នុងបវត្តិកាល រូបទាំង ២៨ តែងកើតបានតាមសមគួរដល់ភូមិ និង កំណើតរបស់សត្វនោះៗ ហើយនឹងតែងកើតបាន ទាំង ៤ សមុដ្ឋាន គឺ កម្មជរូប ចិត្តជរូប ឧតុជរូប និងអាហារជរូប ។

**៣.ចុតិកាល** ក្នុងចុតិកាល គឺ ក្នុងវេលាដែលសត្វស្លាប់ រូបដែលកើតមិនបាន គឺ :

- **កម្មជរូប** ទាំងអស់នៃសត្វទាំងពួង ។
- **ចិត្តជរូប** ចំពោះរបស់ព្រះអរហន្ត ។

ចំណែករូបដែលនៅកើតបានក្នុងចុតិកាល គឺ :

**ក.ចិត្តជរូប** ដែលកើតក្នុងឧប្បាទខណៈនៃចុតិចិត្ត របស់សត្វក្នុងបញ្ចវោការភូមិ (វៀរចុតិចិត្តរបស់ព្រះអរហន្ត) អាចគង់តាំងនៅ

រហូតគ្រប់អាយុទើបរលត់ ។

**ខ.អាហារជរូប** ជារូបដែលអាចកើតបាន គ្រប់ៗអនុខណៈនៃចិត្ត ដូច្នេះ ក្នុងភង្គខណៈនៃចុតិចិត្ត អាហារជរូប នៅកើតបានជាគ្រាចុងក្រោយ រួចតាំងនៅបានទៀតប្រមាណស្មើអាយុរបស់ចិត្ត ១៧ ដួង (៥០អនុខណៈនៃចិត្ត) អស់អាយុនៃខ្លួនហើយ ក៏រលត់ទៅ ។

**គ.ឧតុជរូប** គឺជាឧតុជរូប ដែលកើតពីសមុដ្ឋានទាំង ៤ បានដល់ កម្មប្បច្ច័យឧតុជរូប ចិត្តប្បច្ច័យឧតុជរូប ឧតុបច្ច័យឧតុ-ជរូប និង អាហារប្បច្ច័យឧតុជរូប មានសក់ រោម ក្រចក ធ្មេញ ស្បែក ជាដើម រមែងកើតឡើងជារឿយៗ ដល់កាលណា **តិជរូប** គឺ រូបដែល កើតពី កម្ម ចិត្ត អាហារ រលត់អស់ហើយ យ៉ាងនេះ ក៏ដោយការកើតឡើងជាប់បន្តគ្នានៃឧតុជរូប ក៏គង់នៅកើតឡើងបាន ជានិច្ច រហូតដល់សាកសពនោះ វិនាសបាត់បង់ទៅ ៕

# ៣.តាមន័យនៃកំណើត

បណ្តាសត្វទាំងឡាយ ដែលកើតនៅក្នុងភូមិផ្សេងៗនោះ កាលពោលអំពីអាការដែលកើតឡើង ដែលហៅថា “ **កំណើត** ” បាលីថា “ **យោនិ** ” នោះ មានការសម្តែងកំណើតរបស់សត្វទាំងឡាយ

មាន ៣ ឬ ៤ ប្រការ គឺ :

# យោនិកំណើត ៣ ប្រការ

**១.សំសេទជៈកំណើត** សំដៅយក កំណើតដែលកើតក្នុង ញើស ក្អែល ឬ ក្នុងទីដែលស្មោកគ្រោក អាប់អួ ។

**២.ឱបបាតិកៈកំណើត** សំដៅយក កំណើតដែលកើត ផុសឡើង ធំឯងៗភ្លាមៗ ។

**៣.គព្ភសេយ្យកៈកំណើត** សំដៅយក កំណើតដែលកើត ក្នុងគភ៌មាតា ។

គព្ភសេយ្យកកំណើតនេះ ចែកចេញជា ២ យ៉ាង គឺ :

**-អណ្ឌជៈកំណើត** សំដៅយក កំណើតដែលកើតក្នុងស៊ុត។

**-ជលាពុជៈកំណើត** សំដៅយក កំណើតដែលកើតក្នុងសុក។

# យោនិកំណើត ៤ ប្រការ

**១.** សំសេទជៈកំណើត **២.** ឱបបាតិកៈកំណើត

**៣.** អណ្ឌជៈកំណើត **៤.** ជលាពុជៈកំណើត

# ១.សំសេទជៈកំណើត

សត្វដែលបដិសន្ធិដោយសំសេទជៈកំណើតនេះ មិនចាំបាច់អាស្រ័យមានមាតាបិតា ជាបច្ច័យឲ្យកើតទេ ប៉ុន្តែអាស្រ័យកើតពីដើមឈើ ផ្កាឈើ លោហិត ឬ ញើសក្អែល ឬ ទឹកន្លែងស្មោកគ្រោកជាដើម ដូចនាងចិញ្ចមានវិកា កើតពីដើមអំពិល នាងវេឡុវតី កើតពីដើមឫស្សី នាងបទុមវតី កើតពីផ្កាឈូក ឱរសរបស់នាងបទុមវតី ៤៩៩ អង្គ កើតពីលោហិត ទាំងនេះជាដើម ។

សត្វដែលជាសំសេទជៈកំណើតនេះ មិនបានកើត ដោយមានរាងកាយធំឡើងមកភ្លាមៗទេ គឺ កើតមកជាទារកតូចសិន ហើយក៏ធំសន្សឹមៗចម្រើនឡើង ដូចពួកគព្ភសេយ្យកៈកំណើតអ៊ុំចឹង ។

ម្យ៉ាងទៀត សត្វដែលជាសំសេទជៈកំណើតនេះ មានតែក្នុងកាមភូមិទេ គឺ ក្នុងមនុស្សក៏មាន ក្នុងទេវតាជាន់ទាប (ភូម្មដ្ឋទេវតា) ក៏មាន ក្នុងសត្វតិរច្ឆានក៏មាន ក្នុងប្រេត(វៀរពួកនិជ្ឈាមតណ្ហិកប្រេត) ក៏មាន ក្នុងអសុរកាយក៏មាន ។ ចំណែកសត្វនរក ទេវតាជាន់ខ្ពស់ និង ព្រហ្មទាំងឡាយ រមែងមិនមានសត្វសំសេទជៈកំណើតទេ ៕

# ២. ឱបបាតិកៈកំណើត

សត្វដែលបដិសន្ធិដោយឱបបាតិកៈកំណើតនេះ មិនចាំបាច់

អាស្រ័យអ្វីៗកើតទាំងអស់ បានសេចក្តីថា មិនបាច់អាស្រ័យគភ៌មាតា ទាំងដើមឈើ ផ្លែឈើ ផ្កាឈើ ឬ ទីស្មោកគ្រោកអ្វីឡើយ ប៉ុន្តែ អាស្រ័យ**អតីតកម្ម**តែម៉្យាងប៉ុណ្ណោះ ពេលដែលកើតឡើងនោះ ក៏កើត ផុសឡើងមានរាងកាយធំ ពេញកំឡោះ ក្រមុំ អាយុ ១៦ ឆ្នាំតែម្តង ដូចជាវត្ថុដែលធ្លាក់ចុះមកពីអាកាសអ៊ីចឹង ។ សត្វដែលជាឱបបាតិកៈ កំណើតនេះ បានដល់ :

- មនុស្សសម័យដើមកប្ប ។
- ទេវតាទាំង ៦ ជាន់ (វៀរទេវតាជាន់ទាបពួកខ្លះ) ។
- ព្រហ្មទាំងអស់ ។
- ប្រេត រួមទាំងនិជ្ឈាមតណ្ហិកប្រេត ។
- អសុរកាយ និង សត្វនរកទាំងអស់ ។

# ៣.អណ្ឌជៈកំណើត

សត្វដែលបដិសន្ធិដោយអណ្ឌជៈកំណើតនេះ ត្រូវអាស្រ័យ កើតពីគភ៌មាតា ហើយកាលផ្តើមកើត គឺ តាំងពីបដិសន្ធិដំបូងនោះ ត្រូវនៅក្នុងស៊ុតសិន ដល់មាតាសម្រាលពងចេញមក ទើបត្រូវចេញ ពីពងនោះម្តងទៀត ។ សត្វប្រភេទនេះ គេហៅថា **ទ្វិជៈកំណើត** (កើត២ដង) ដូចជា មាន់ ទា ចាប ក្អែក ជីងចក់ តុកកែ ពស់

ជាដើម ។ ការកើតនៃសត្វពួកនេះ នឹងចម្រើនធំឡើងសន្សឹមៗ តាមលំដាប់ ។

ម្យ៉ាងទៀត សត្វដែលជាអណ្ឌជៈកំណើតនេះ បានដល់ សត្វតិរច្ឆាន ប្រេតពួកខ្លះ ទេវតាជាន់ទាបពួកខ្លះ និង មនុស្សដែលជាអណ្ឌជៈកំណើតក៏មាន ដែលសម្តែងទុកក្នុងធម្មបទថា មានភិក្ខុ ២ អង្គនាម ទេព្វាតិកថេរៈ ដែលជាកូនរបស់ កោនតៈកិន្នរី កាលកើតដំបូងជាពងសិន តមកទើបចេញពីពងនោះម្តងទៀត ៕

# ៤.ជលាពុជៈកំណើត

សត្វដែលបដិសន្ធិដោយជលាពុជៈកំណើតនេះ ត្រូវអាស្រ័យកើតពីគភ៌មាតា ប៉ុន្តែមិនបាច់មានពងស្រោបដូច អណ្ឌជៈកំណើតទេ ពេលសម្រាលពីគភ៌មាតាមក ក៏ចេញជាតួខ្លួនពិតៗតែម្តង កើតជាទារកកូនង៉ែតសិន រួចហើយក៏ចម្រើនធំឡើងសន្សឹមៗតាមលំដាប់ បានដល់ មនុស្ស សត្វ តិរច្ឆាន ទេវតាជាន់ទាប (ដែលជាភុម្មដ្ឋទេវតាពួកខ្លះ) ប្រេត(វៀរនិជ្ឈាមតណ្ហិកប្រេត) អសុរកាយពួកខ្លះ ។

# កំណើត ៤ ក្នុងភូមិផ្សេងៗ

ក្នុងសម្មោហវិនោទនីអដ្ឋកថា សម្តែងថា :

**និរយេ ភុម្មវជ្ជេសុ ទេវេសុ ចន យោនិយោ**
**តិស្សោ បុរិមិកា ហោន្តិ ចតស្សោបិ គតិត្តយេ**

ប្រែថា កំណើត ៣ ខាងដើម គឺ ជលាពុជៈកំណើត អណ្ឌជៈកំណើត និង សំសេទជៈកំណើត រមែងមិនមានក្នុងនរក ក្នុងនិជ្ឈាមតណ្ហិកប្រេត និង ទេវភូមិ ៦ (វៀរភូម្មដ្ឋទេវតា)ឡើយ ប៉ុន្តែកំណើតទាំង ៤ រមែងមានក្នុងគតិ ៣ បាន គឺ មនុស្ស សត្វតិរច្ឆាន ប្រេត អសុរកាយ ។

សរុបសេចក្តី សត្វ ២៤ ពួក គឺ សត្វនរក ១ និជ្ឈាមតណ្ហិកប្រេត ១ ទេវតាក្នុងចាតុម្មហារាជិកា ១ ( វៀរពួកភូម្មដ្ឋទេវតា ) ទេវតាក្នុងទេវភូមិខាងលើ ៥ រូបព្រហ្ម ១៦ មានតែឱបបាតិកៈកំណើតតែម្យ៉ាងប៉ុណ្ណោះ ។ ចំពោះមនុស្ស ភូម្មដ្ឋទេវតា សត្វតិរច្ឆាន អសុរកាយ ប្រេត (វៀរនិជ្ឈាមតណ្ហិកប្រេត) មានកំណើតបានទាំង ៤ ។

# ការចែកកំណើត ៤ ដោយ កម្មជ្ជកលាបៈ ៩

សត្វទាំងឡាយដែលកើតក្នុងកាមភូមិ ១១ និង រូបភូមិ ១៦ ចែកដោយកំណើត ៤ ដោយក្រុមរូបដែលកើតពី កម្មជាសមុដ្ឋាន ហៅថា **កម្មជ្ជកលាបៈ** មានដូចតទៅនេះ គឺ :

## ១.ពួកសំសេទជៈកំណើត និង ឱបបាតិកៈកំណើតដែលកើតក្នុងកាមភូមិ

- **ក្នុងបដិសន្ធិកាល** បើពោលដោយ **ឧក្កដ្ឋន័យ** គឺ ន័យដែលកើតបានយ៉ាងច្រើនបំផុត កម្មជ្ជកលាបៈ រមែងកើតបាន ៧ កលាបៈ គឺ :

ចក្ខុទសកកលាបៈ សោតទសកកលាបៈ ឃានទសកកលាបៈ ជីវ្ហាទសកកលាបៈ កាយទសកកលាបៈ វត្ថុទសកកលាបៈ ភាវទស-កកលាបៈ ។

បើពោលដោយ **ឱមកន័យ** គឺ ន័យដែលកើតបានតិចបំផុត

គឺ :

**ក.ពួកសំសេទជៈកំណើត** មានកម្មជ្ជកលាបៈខ្វះ ឬ ខ្វះ មិនហួសពី ៤ កលាបៈទេ គឺ :

ចក្ខុទសកកលាបៈ សោតទសកកលាបៈ ឃានទសកកលាបៈ និង ភាវទសកកលាបៈ ។

**ខ.ពួកទុគ្គតិឱបបាតិកៈកំណើត** មានកម្មជ្ជកលាបៈ ខ្វះ ឬ ខ្វះ ៣ កលាបៈ គឺ :

ចក្ខុទសកកលាបៈ សោតទសកកលាបៈ និង ភាវទសក-កលាបៈ ។

**គ.ពួកសុគតិឱបបាតិកៈកំណើត** ដែលជាមនុស្សសម័យដើមកប្ប មានកម្មជ្ជកលាបៈខ្វះឬខ្វះ ១ កលាបៈ គឺ ភាវទសក-កលាបៈ ។

ចំណែកពួកសុគតិឱបបាតិកៈកំណើត ដែលជាទេវតា មានកម្មជ្ជកលាបៈកើតបាន ៧ កលាបៈ គ្រប់បរិបូរណ៍ មានចក្ខុទសក-កលាបៈ ជាដើម ។

- **ក្នុងបវត្តិកាល** កម្មជ្ជកលាបៈ រមែងកើតបានទៀត ១ កលាបៈ គឺ ជីវិតនវកកលាបៈ កើតបានតាំងពីឋិតិខណៈនៃបដិសន្ធិ-ចិត្តជាដើមទៅ (ព្រោះកលាបៈនេះប្រព្រឹត្តទៅព្រមនឹងបាចកតេជោ)។

# ២.ពួកឱបបាតិកៈកំណើតដែលជាព្រហ្ម
## ( វៀរអសញ្ញសត្តព្រហ្ម )

- **ក្នុងបដិសន្ធិកាល** កម្មជ្ជកលាបៈ រមែងកើតបាន ៤ កលាបៈ គឺ :

ចក្ខុទសកកលាបៈ សោតទសកកលាបៈ វត្ថុទសកកលាបៈ ជីវិតនវកកលាបៈ ។

- **ក្នុងបវត្តិកាល** មិនមានកម្មជ្ជកលាបៈកើតបន្ថែមទៀតទេ មានត្រឹមតែ ៤ កលាបៈ ប៉ុណ្ណោះឯង ។

# ៣. ពួកឱបបាតិកៈ
# កំណើតដែលជាអសញ្ញសត្តព្រហ្ម

ទាំងក្នុងបដិសន្ធិកាល ទាំងក្នុងបវត្តិកាល មានជីវិតនវកកលាបៈ តែ ១ ប៉ុណ្ណោះកើតឡើង ។

# ៤. គព្ភសេយ្យកៈកំណើត

- **ក្នុងបដិសន្ធិកាល** ពោលដោយ**ឧក្កដ្ឋន័យ** កម្មជ្ជ-កលាបៈ រមែងកើតបាន ៣ កលាបៈ គឺ :

កាយទសកកលាបៈ ភាវទសកកលាបៈ និង វត្ថុទសក-កលាបៈ ។

បើពោលដោយ**ឱមកន័យ** កម្មជ្ជកលាបៈរមែងកើតបាន ២ កលាបៈ គឺ :

កាយទសកកលាបៈ និង វត្ថុទសកកលាបៈ ។

ចំណែកភាវទសកកលាបៈនោះ អាចខ្វះឬខ្វោះបាន ដូចអ្នកដែលកើតមកមិនមានភេទ គឺ ខ្ទើយ ។

- **ក្នុងបវត្តិកាល** កម្មជ្ជកលាបៈ រមែងកើតបានទៀត ៥ កលាបៈ គឺ :

ចក្ខុទសកកលាបៈ សោតទសកកលាបៈ ឃានទសកកលាបៈ ជីវ្ហាទសកកលាបៈ និង ជីវិតនវកកលាបៈ ។

ក្នុងចំនួនរូបកលាបៈទាំង ៥ នេះ កលាបៈ ដែលខ្វះ ឬ ខ្វោះបាន មាន ៣ កលាបៈ គឺ ចក្ខុទសកកលាបៈ សោតទសក-

កលាបៈ និង ឃានទសកកលាបៈ ។

សរុបសេចក្តី កម្មជ្ជកលាបៈដែលកើតឡើងនឹងសត្វទាំងឡាយក្នុងកាមភូមិ និង រូបភូមិ ទាំងក្នុងបដិសន្ធិកាល និង បវត្តិកាល មាន ៨ កលាបៈ ហើយក្នុងកាមភូមិអាចមានខ្វះ ឬ ខ្វះបាន ៤ កលាបៈ ដូចបានពោលរួចមកហើយ ។

# សម្តែងការកើតឡើងនៃកម្មជ្ជកលាបៈ ទាំង ៥ របស់ពួកគព្ភសេយ្យកៈកំណើត

ក្នុងបរមត្ថទីបនីដីកា សម្តែងអំពីការកើតឡើងនៃកម្មជ្ជកលាបៈ ៤ មានចក្ខុទសកកលាបៈជាដើម របស់ពួកគព្ភសេយ្យកៈកំណើតក្នុងបវត្តិកាលបន្តពីបដិសន្ធិកាល ទុកថា :

**តតោ បរំ បវត្តិម្ហិ វឌ្ឍមានស្ស ជន្តុនោ**
**ចក្ខុទសកាទយោ ច ចត្តារោ ហោន្តិ សម្ភវា**

ប្រែថា ក្នុងបវត្តិកាល កម្មជ្ជកលាបៈទាំង ៤ មានចក្ខុទសក-កលាបៈជាដើម រមែងកើតឡើងដល់សត្វ ដោយការចម្រើនឡើងសន្សំៗ តាមសមគួរដែលនឹងប្រព្រឹត្តទៅបាន ។

បានសេចក្តីថា បន្ទាប់ពីបដិសន្ធិកាលមក ក្នុងបវត្តិកាល កម្មជ្ជកលាបៈទាំង ៤ មានចក្ខុទសកកលាបៈជាដើម នឹងចម្រើនឡើងដោយសន្សឹមៗ តាមសមគួរដែលនឹងប្រព្រឹត្តទៅបាន មិនបានកំណត់ថា កម្មជ្ជកលាបៈណាកើតមុន ណាកើតក្រោយនោះឡើយ ។

ចក្ខុទសកកលាបៈ សោតទសកកលាបៈ ឃានទសកកលាបៈ ជីវ្ហាទសកកលាបៈ ទាំង ៤ កលាបៈនេះ កើតឡើងក្នុងសប្តាហ៍ ទី ១១ គឺក្នុងរវាង ៧០ ថ្ងៃ ឬ ៧៧ ថ្ងៃ ។ ប៉ុន្តែការកើតឡើងនៃកលាបៈទាំង ៤ នេះ មិនបានកំណត់ថា កលាបៈណាកើតមុន កលាបៈណាកើតក្រោយទេ ព្រោះព្រះពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់សម្តែងពីលំដាប់នៃកម្មជ្ជកលាបៈទាំង ៩ នោះ មិនមែនទ្រង់សម្តែងដោយឧប្បត្តិក្កមន័យទេ គឺ ជាការសម្តែងដោយទេសនាកមន័យ ដូចជាការសម្តែងពីខន្ធ ៥ និង សច្ចៈ ៤ នោះដែរ ។ ដូចជាកថាវត្ថុអដ្ឋកថាសម្តែងថា **សេសានិ ចត្តារិ សត្ត សត្តតិ វត្តិម្ហិ ជាយន្តិ** កម្មជ្ជកលាបៈ ៤ ដែលនៅសល់ពី កាយ ភាវៈ វត្ថុ ជីវិតៈ រមែងកើតឡើងក្នុងវេលា ៧៧ ថ្ងៃ គឺ សប្តាហ៍ទី ១១ ។

ចំពោះ ជីវិតនវកកលាបៈ រមែងកើតឡើងក្នុងសប្តាហ៍ដំបូង ក្រោយពីបដិសន្ធិដំបូងទៅ គឺ ក្នុងចន្លោះ ៧ ថ្ងៃ ។

ចំពោះ ជីវិតនវកកលាបៈ ដែលកើតឡើងក្នុងបវត្តិកាល របស់ពួកសំសេទជៈកំណើត និង ឱបបាតិកៈកំណើត ក្នុងកាមភូមិ នោះ កើតឡើងតាំងពីឋិតិខណៈនៃបដិសន្ធិចិត្តជាដំបូងទៅ ព្រោះ កលាបៈនេះ ប្រព្រឹត្តទៅព្រមនឹងបាចកតេជោ ហើយនិងកើត ព្រោះ អាស្រ័យអាហារដែលលេបចូលទៅ (សម្តែងក្នុង អត្ថយោជនា) ។

# សម្តែងការចម្រើននៃរូប តាំងពីបដិសន្ធិ រហូតដល់មាន អវយវៈគ្រប់គ្រាន់របស់គព្ភសេយ្យកៈកំណើត

ការរីកចម្រើននៃរូបធម៌របស់សត្វជំពូក គព្ភសេយ្យកៈកំណើត តាំងពីបដិសន្ធិកាល រហូតដល់មានអវយវៈគ្រប់គ្រាន់នោះ ក្នុង សគាថវគ្គ យក្ខសំយុត្តបាលី សម្តែងថា :

**បឋមំ កលលំ ហោតិ កលលា ហោតិ អព្ពុទំ**
**អព្ពុទា ជាយតេ បេសិ បេសិ និព្វត្តតេ ឃនោ**
**ឃនា បសាខា ជាយន្តិ កេសា លោមា នខាបិច**

ប្រែថា ក្នុងសប្តាហ៍ដំបូងនៃបដិសន្ធិនោះ កើតជា **កលលរូប**

មានលក្ខណៈជាដំណក់ទឹកថ្លា ដូចដំណក់ប្រេងល្ង ។

ក្នុងសប្តាហ៍ទី ២ ក្រោយពីកលលរូប កើតជា **អព្វុទរូប** មានលក្ខណៈជាពពុះខន់ ពណ៌ដូចទឹកលាងសាច់ ។

ក្នុងសប្តាហ៍ទី ៣ ក្រោយពីអព្វុទរូប កើតជា **បេសិរូប** មានលក្ខណៈជាដុំសាច់រាវៗ ពណ៌ក្រហម ។

ក្នុងសប្តាហ៍ទី ៤ ក្រោយពីបេសិរូប កើតជា **ឃនរូប** មានលក្ខណៈជាដុំ មានសណ្ឋានដូចពងមាន់ ។

ក្នុងសប្តាហ៍ទី ៥ ក្រោយពីឃនរូប កើតជា **បញ្ចសាខា** គឺរូបនោះបែកចេញជាពក ៥ គឺ ដៃ ២ ជើង ២ ក្បាល ១ ។

**តតោ បរំ** បន្តពីនោះមក គឺ ក្នុងរវាង សប្តាហ៍ទី ១២ ដល់ សប្តាហ៍ទី ៤២ សក់ រោម ក្រចក ទាំងនេះក៏ប្រាកដ ។

**+ សង្កេត :** រូបធម៌ដែលកើតមុនដំបូង ក្នុងបដិសន្ធិកាលនោះ សុទ្ធតែកើតមកពីកម្មជាសមុដ្ឋានទាំងអស់ ។ ចំណែករូបដែលកើតពីសមុដ្ឋានដទៃ មានចិត្តជរូប ឧតុជរូប និងអាហារជរូប ក្នុងបដិសន្ធិកាល រូបទាំងនេះកើតមិនទាន់បានទេ ទើបនឹងមកប្រាកដក្នុងបវត្តិកាលនោះឯង ៕

# សម្ដែងការកើតឡើង
# របស់ចិត្តជរូបឧតុជរូប និង អាហារជរូប

បណ្ដាសត្វទាំងឡាយ ដែលកើតឡើងក្នុងបញ្ចវោការភូមិនោះ បដិសន្ធិចិត្តកើតព្រមនឹងកម្មជរូបក្នុងបដិសន្ធិកាល ។ លុះបដិសន្ធិចិត្តរលត់ទៅ ចិត្តដួងទី ២ ដែលកើតបន្ត បានដល់ **បឋមភវង្គចិត្ត-ជរូប** ក៏ផ្ដើមកើតឡើងជាដំបូងត្រង់ឧប្បាទខណៈនៃបឋមភវង្គនេះឯង និង រមែងកើតតទៅ**គ្រប់ៗឧប្បាទខណៈនៃចិត្ត** ចំណែកឋិតិ-ខណៈ និង ភង្គខណៈរបស់ចិត្តនោះ ចិត្តជរូបមិនកើតបានឡើយ ព្រោះធម្មតា ចិត្ត និង ចេតសិក នោះ រមែងមានកម្លាំងនៅត្រង់ឧប្បាទខណៈនៃចិត្ត ប៉ុណ្ណោះ ។

**ឧតុជរូប** ចាប់ផ្ដើមកើតឡើង ជាដំបូងត្រង់ឋិតិខណៈនៃបដិសន្ធិចិត្ត និង រមែងកើតតទៅ**គ្រប់ៗអនុខណៈនៃចិត្ត** ព្រោះឧតុជរូបនេះ កើតឡើងដោយអាស្រ័យឧតុជាសមុដ្ឋាន មិនមែនកើតពីចិត្ត-ចេតសិកជាសមុដ្ឋានទេ ដូច្នេះ ទើបកើតឡើងបាន គ្រប់ៗខណៈនៃចិត្ត ។

**អាហារជរូប** ចំពោះសំសេទជៈ និង ឱបបាតិកៈបុគ្គលនោះ កាលបដិសន្ធិហើយ តពីនោះ ក៏បរិភោគអាហារបានភ្លាម ។ ដូច្នេះ អាហារជរូបនៃបុគ្គល ២ ពួកនេះ ទើបផ្ដើមកើតជាដំបូងត្រង់មនោទ្វារវិថី ដែលកើតឡើងក្រោយពីបដិសន្ធិចិត្ត និង ភវង្គចិត្ត និង រមែងកើតតទៅ**គ្រប់ៗអនុខណៈនៃចិត្ត** ព្រោះអាហារជរូបកើតឡើងដោយអាស្រ័យអាហារជាសមុដ្ឋាន មិនមែនកើតពីចិត្ត-ចេតសិកជាសមុដ្ឋានទេ ដូច្នេះទើបកើតបានគ្រប់ៗខណៈចិត្ត ដូចគ្នានឹងឧតុជរូបនោះដែរ ។

ចំណែកអាហារជរូប ដែលកើតក្នុងពួកគព្ភសេយ្យកៈបុគ្គល រមែងកើតឡើងនៅពេលអាហារផ្សេងៗ ដែលមាតាបរិភោគចូលទៅនោះ ជ្រួតជ្រាបផ្សាយទៅក្នុងរូបរាងកាយ របស់សត្វដែលនៅក្នុងគភ៌របស់មាតា ។ រយៈពេលវេលា ដែលអាហារផ្ដើមជ្រួតជ្រាបផ្សាយទៅចិញ្ចឹមរាងកាយសត្វដែលបដិសន្ធិនោះ ក្នុងសប្ដាហ៍ដំបូងដែលនៅជាកលលៈសត្តាហៈនោះ អាហារផ្សាយទៅមិនទាន់បានទេ គឺដល់**សប្ដាហ៍ទី ២** ឬ **សប្ដាហ៍ទី ៣** ដែលជា**អព្ពុទៈសត្តាហៈ** និង **បេសិសត្តាហៈ** អាហារទើបអាចផ្សាយចូលទៅដល់រាងកាយសត្វនោះបាន ។ កាលអាហារជរូបកើតឡើងហើយ ក៏រមែងកើតតទៅ**គ្រប់ៗអនុខណៈនៃចិត្ត** សមដូចព្រះពុទ្ធជាម្ចាស់សម្ដែងទុក

ក្នុងសគាថវគ្គ យក្ខសំយុត្ត បាលីថា :

**យញ្ចស្ស ភុញ្ជតិ មាតា អន្នំ បានញ្ច ភោជនំ**
**តេន សោ តត្ថ យាបេតិ មាតុ កុច្ឆិគតោ នរោ**

ប្រែថា មាតារបស់ទារកនោះ បរិភោគអាហារណា ជាបាយក្តី គ្រឿងផឹកក្តី ទារកដែលកើតនៅក្នុងគភ៌មាតា ជាគ្រឿងគ្របដណ្តប់នៅនោះ ក៏បានអាហារនេះអាស្រ័យទ្រទ្រង់អត្តភាពឲ្យប្រព្រឹត្តទៅនៅក្នុងគភ៌មាតាបាន ។

ក្នុងអភិធម្មត្ថវិភាវិនី ពោលថា ភាវៈនៃឧតុ និង ឱជា មានកម្លាំងបានតែក្នុង**ឋិតិខណៈ**នៃខ្លួនប៉ុណ្ណោះ ។

# សម្តែងការប្រព្រឹត្តទៅរបស់រូប ដែលកើតពីសមុដ្ឋានទាំង ៤ ក្នុងកាមភូមិ

ក្នុងសគាថវគ្គ យក្ខសំយុត្ត ពោលថា :

**ឥច្ចេវំ បដិសន្ធិមុបាទាយ កម្មសមុដ្ឋានា ទុតិយ-ចិត្តមុបាទាយ ចិត្តសមុដ្ឋានា ឋិតិកាលមុបាទាយ ឧតុ-**

**សមុដ្ឋានា ឱជាផរណមុបាទាយ អាហារសមុដ្ឋានា ចេតិ ចតុសមុដ្ឋានរូបកលាបសន្តតិ កាមលោកេ ទីបជាលា វិយ នទីសោតោ វិយ ច យាវតាយុកមព្ពោច្ឆិន្នា បវត្តតិ ។**

ប្រែថា ដោយន័យដូចបានពោលមកហើយនោះ **កម្មជរូប** រមែងកើតតាំងពី**ឧប្បាទខណៈនៃបដិសន្ធិចិត្ត** **ចិត្តជរូប**កើតតាំងពី**ឧប្បាទខណៈនៃបឋមភវង្គចិត្ត** ឧតុជរូបកើតតាំងពី**ឋិតិខណៈនៃបដិសន្ធិចិត្ត** **អាហារជរូប**កើតតាំងពីខណៈដែលឱជាជ្រួតជ្រាបផ្សាយទូទៅក្នុងរាងកាយ ការបន្តនៃរូបកលាបៈដែលកើតពីសមុដ្ឋាន ៤ ក្នុងកាមភូមិនេះ រមែងកើតបានជាប់ៗបន្តគ្នាទៅមិនចេះដាច់ ប្រហែលនឹងអណ្តាតភ្លើង និង ខ្សែទឹកហូរមិនចេះដាច់ដូច្នោះ រហូតដរាបដល់អស់អាយុ ។

# សម្តែងការរលត់ នៃសមុដ្ឋានិករូបទាំង ៤

ព្រះពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់សម្តែងការរលត់របស់រូបដែលកើតពីសមុដ្ឋានទាំង ៤ ទុក ដូចតទៅនេះ គឺ :

១.មរណកាលេ បន ចុតិចិត្តោបរិសត្តរ សមចិត្តស្ស ឋិតិកាលមុបាទាយ កម្មជរូបានិ ន ឧប្បជ្ជន្តិ បុរេតរ-មុប្បន្នានិ ច កម្មជរូបានិ ចុតិចិត្ត សមកាលមេវ បវត្តិត្វា និរុជ្ឈន្តិ ។

២. តតោ បរំ ចិត្តជាហារជរូបញ្ច វោច្ឆិជ្ជតិ ។

៣. តតោ បរំ ឧតុសមុដ្ឋានរូប បរម្បរា យាវ មតកឡេវរសង្ខាតា បវត្តន្តិ ។

១. ដល់វេលាជិតនឹងស្លាប់ តាំងពី**ឋិតិខណៈនៃចិត្តជួងទី ១៧** រាប់ពីចុតិចិត្តថយចុះទៅ **កម្មជរូប**ថ្មីលែងកើតទៀតហើយ និង កម្មជរូបដែលកើតឡើងត្រង់**ឧប្បាទខណៈ**នៃចិត្តជួងទី ១៧ នេះ រមែងតាំងនៅរហូតដល់ចុតិចិត្តហើយ ក៏រលត់អស់ព្រមនឹង**ចុតិចិត្ត នោះ** ។

**២.** ក្រោយពីកម្មជរូបរលត់អស់ហើយ ចិត្តជរូប និង អាហារជរូប ក៏រលត់អស់ ។

**៣.** ក្រោយពីតិជ្ជរូប គឺ កម្មជ្ជរូប ចិត្តជ្ជរូប និង អាហារ-ជ្ជរូបរលត់អស់ហើយ ការកើតឡើងបន្តជាប់គ្នានៃឧតុជ្ជរូប ក៏កើតឡើងរហូតដល់ក្លាយទៅជាសាកសព ។

# អធិប្បាយ

**ក្នុងបាលីខទី ១** អធិប្បាយថា កម្មជ្ជរូប កាលណាផ្ដើមកើតតាំងពីឧប្បាទខណៈនៃបដិសន្ធិចិត្តហើយ ក៏កើតជាបន្តគ្នា ជារឿយៗ ទៅមិនចេះដាច់គ្រប់ៗខណៈចិត្តជាដរាប ពេលដែលសត្វនោះ នៅមានជីវិតរហូត ដល់ស្លាប់ និង ក្នុងពេលដែលសត្វ នោះជិតនឹងស្លាប់ កម្មជ្ជរូបដែលកើតចុងក្រោយបំផុត កើតត្រង់ឧប្បាទ-ខណៈនៃចិត្តដួងទី ១៧ ដែលរាប់ថយក្រោយមកពីចុតិចិត្ត ហើយក៏លែងកើតតទៅទៀត ។

ចំណែកកម្មជ្ជរូប ដែលកើតចុងក្រោយបំផុតនោះ កាលមានអាយុធៀបស្មើនឹង ១៧ ខណៈនៃចិត្តគ្រប់ហើយ ក៏រលត់អស់ ។ ដូច្នេះ កម្មជ្ជរូបនេះ ទើបរលត់អស់ ព្រមគ្នានឹងចុតិចិត្តរលត់( ក្នុងភង្គខណៈ ) ។

ធម្មតាសត្វដែលនឹងហៅថា ស្លាប់ ក៏គឺ ចុតិចិត្ត និង កម្មជ្ជរូបរលត់អស់ព្រមគ្នា ចុតិចិត្តរលត់ទៅមុន កម្មជ្ជរូបនៅមាន

ក៏មិនបាន កម្មជរូបរលត់អស់ទៅមុន ចុតិចិត្តមិនទាន់កើត ក៏មិនបាន គឺ ប្រព្រឹត្តទៅតាមសភាវៈ មិនមានសភាវៈណាមួយបង្គាប់បញ្ជាបាន ដោយហេតុនេះឯង ទើបការកើតឡើងខាងក្រោយបំផុតនៃកម្មជរូប ត្រូវកើតត្រង់ឧប្បាទខណៈនៃចិត្តដួងទី ១៧ ដែលរាប់ថយក្រោយមកពីចុតិចិត្ត ។

**ក្នុងបាលីខទី ២** អធិប្បាយថា ក្រៅអំពីចុតិចិត្តរបស់ព្រះអរហន្តហើយ ចុតិចិត្តរបស់បុថុជ្ជន និង ព្រះសេក្ខបុគ្គលទាំងឡាយ រមែងធ្វើឲ្យចិត្តជរូបកើតឡើងបាន ដូច្នេះ ការកើតឡើងជាខាងក្រោយបំផុតនៃចិត្តជរូប ទើបកើតឡើងត្រង់ឧប្បាទខណៈនៃចុតិចិត្ត ។

ចំពោះព្រះអរហន្តនោះ ចិត្តជរូប កើតឡើងខាងក្រោយបំផុតត្រង់ឧប្បាទខណៈនៃចិត្តដួងទី២ ដែលរាប់ថយក្រោយមកពីចុតិចិត្ត ។

សេចក្ដីនេះបង្ហាញឲ្យឃើញថា សូម្បីចុតិចិត្តរលត់អស់ គឺ អ្នកនោះស្លាប់ទៅហើយក៏ដោយ ចិត្តជរូបក៏គង់តាំងនៅ តទៅបានមួយភ្លែតទៀត គឺ ចំពោះបុថុជ្ជន ឬ ព្រះសេក្ខបុគ្គលនោះ កាលស្លាប់ហើយ ចិត្តជរូបគង់តាំងនៅតទៅបានទៀត ស្មើនឹងចិត្ត ១៦ ខណៈ ទើបរលត់អស់ ។ បើព្រះអរហន្តវិញនោះ កាលបរិនិព្វានហើយ ចិត្តជរូប គង់តាំងនៅតទៅបានទៀត ស្មើនឹងចិត្ត ១៥ ខណៈ ទើប

រលត់អស់ ។ ការដែលពោលយ៉ាងនេះ គឺជាការពោលតាមសភាវៈ សេចក្ដីប្រព្រឹត្តនៃនាមវិថី និង រូបវិថីប៉ុណ្ណោះ ប៉ុន្តែបើពោលតាមវោហារអ្នកស្រុកវិញ អាចពោលបានថា កាលស្លាប់ហើយ ចិត្តជរូបក៏រលត់ព្រមគ្នាទៅដែរ យ៉ាងនេះក៏ព្រោះថា រយៈពេលដែលធៀបស្មើនឹង ១៥ ខណៈ ឬ ១៦ ខណៈចិត្តនោះ មិនបានស្មើនឹងមួយភាគរយ ( = ១ / ១០០ ) នៃវិនាទីផង ។

ចំពោះអាហារជរូបវិញ កាលដល់ភង្គខណៈនៃចុតិចិត្ត អាហា-រជរូប ក៏នៅកើតឡើងបាន ជាចុងក្រោយបំផុត និង កាលចុតិចិត្តរលត់អស់ គឺ អ្នកនោះស្លាប់ហើយ អាហារជរូប ដែលកើតចុងក្រោយបំផុត ក៏អាចតាំងនៅបានទៀត ១៧ ខណៈចិត្ត ។ ការពោលមកនេះ គឺ ចំពោះកាមបុគ្គលប៉ុណ្ណោះ ចំណែកក្នុងព្រហ្មទាំងឡាយមិនមានអាហារជរូបកើត ទើបមិនបានពោលទុកក្នុងទីនេះទេ ៕

**ក្នុងបាលីខទី ៣** អធិប្បាយថា ឧតុជរូបនោះកើតឡើងបានទៅរហូត សូម្បីស្លាប់ហើយនៅសល់តែសាកសព ក្លាយជាឆ្អឹង ឬ ផេះទៅហើយក៏ដោយ ឧតុជរូបក៏គង់នៅកើតបានជានិច្ច ទាំងនេះក៏ព្រោះឧតុជរូបនេះ កើតបានរហូត ដរាបដល់កាលដែលលោកត្រូវវិនាស ទើបរលត់អស់ ។ ការពោលមកនេះ សំដៅយកតែឧតុជរូបរបស់ សត្វដែលជាសំសេទជៈកំណើត និង គព្ភសេយ្យកៈកំណើត

ប៉ុណ្ណោះ ចំណែកឧតុជរូបរបស់ពួកឱបបាតិកៈកំណើត ដូចជាសត្វនរក ប្រេត អសុរកាយ និង ទេវតាឬព្រហ្ម ទាំងនេះ កាលណាស្លាប់ហើយ ឧតុជរូប រមែងរលត់អស់ព្រមគ្នា ទាំងនេះព្រោះពួកដែលជាឱបបាតិកៈកំណើតនេះ កាលស្លាប់ហើយមិនមានសាកសពនៅសល់ទេ ដូចអណ្ដាតភ្លើងដែលរលត់ដូច្នោះ ។

# គាថាដែលសម្ដែង
# ពីការរង្គាត់ទៅនៃរូបក្នុងសង្សារវដ្ដ

**ឥច្ចេវំ មតសត្តានំ បុនទេវ ភវន្តរេ**
**បដិសន្ធិមុបាទាយ តថា រូបំ បវត្តតិ**

ប្រែថា ក្នុងសន្តាននៃសត្វទាំងឡាយ ដែលស្លាប់ទៅអំពីលោកនេះហើយ រូបទាំង ៤ សមុដ្ឋាន រមែងកើតទៀតក្នុងភពថ្មី តាំងពីបដិសន្ធិចិត្តជាដើមទៅ មានទំនងប្រហែលគ្នា នឹងភពនេះ ដូចដែលបានពណ៌នាមកហើយនោះឯង ៕

( ចប់ រូបបរមត្ថ )

# និព្វានបរមត្ថ

**និព្វាន** ជាបរមត្ថធម៌ គឺ ជាធម៌ដែលមានសេចក្ដីមិនវិបរិត ប្រែប្រួលទៅជាយ៉ាងដទៃ ជាធម៌ល្អិត ប្រណីតជាងនាមធម៌ណាៗ ទាំងអស់ ជាធម៌ជ្រៅ ឃើញបានដោយលំបាក ដឹងតាមបានដោយលំបាក ជាធម៌ស្ងប់ ប្រណីត សន្និដ្ឋានយកមិនបាន ដឹងបានចំពោះតែបណ្ឌិតអ្នកបានសម្រេចហើយ និង គប្បីដឹងបានច្បាស់ដោយខ្លួនឯង ជាអារម្មណ៍របស់មគ្គចិត្ត និង ផលចិត្ត បុថុជ្ជនទាំងឡាយមិនអាចធ្វើឲ្យជាក់ច្បាស់បានឡើយ ។

ម្យ៉ាងទៀត ក្នុងបរមត្ថធម៌ទាំង ៤ ប្រការ បានដល់ ចិត្ត ចេតសិក រូប និង និព្វាន ចិត្ត ចេតសិក និង រូប បានសម្ដែងរួចមកហើយ ឥឡូវនេះនឹងសម្ដែង **អំពីនិព្វាន** តទៅ :

## គាថាសង្គហៈ

**បទ មច្ចុ តមច្ចុន្តំ អសង្ខត មនុត្តរំ**
**និព្វាន មិតិ ភាសន្តិ វានមុត្តា មហេសយោ**

ប្រែថា ព្រះសម្មាសម្ពុទ្ធទាំងឡាយ អ្នកស្វែងរកគុណ ដ៏ធំក្រៃលែង គឺ សីលក្ខន្ធ សមាធិខន្ធ បញ្ញាខន្ធ ទ្រង់បានរួចផុតស្រឡះពីតណ្ហា ជាគ្រឿងរួបរឹតហើយ តែងត្រាស់ហៅ សភាវធម៌មួយបែបដែលចូលដល់បាន មានដោយចំពោះ មិនជាប់ដោយសង្ខតធម៌ មិនមានការស្លាប់ និង ចេញផុតពីខន្ធ ៥ បាន មិនត្រូវតាក់តែងដោយបច្ច័យណាៗ ជាធម៌ដ៏ប្រសើរបំផុតនោះ ថា **និព្វាន** ។

គាថានេះ ព្រះអនុរុទ្ធាចារ្យពណ៌នាគុណនៃព្រះនិព្វាន ទុក ៥ បទ ដើម្បីសម្ដែងឲ្យដឹងថា និព្វាននោះគឺជាអ្វី ?

**១.បទំ** ប្រែថា មួយចំណែក មានន័យថា ជាបរមត្ថធម៌មួយបែបដែលចូលដល់បាន មាននៅដោយចំពោះ មិនច្រឡូកច្រឡំនិង សង្ខតធម៌ បានដល់ **ព្រះនិព្វាន** ។

**២.អច្ចុតំ** ប្រែថា ធម៌ដែលមិនស្លាប់ មានន័យថា មិនមានការកើត និង មិនមានការស្លាប់ ព្រោះសេចក្ដីស្លាប់ មានឡើងបានព្រោះអាស្រ័យការកើត កាលណាមិនមានការកើតហើយ សេចក្ដីស្លាប់ក៏មានមិនបាន ។ ក្នុងបរមត្ថទីបនីដីកា សម្ដែងថា :

**ចវនា ភាវេន អច្ចុតំ** ប្រែថា សភាវធម៌ដែលមិនវិនាសមិនរលត់ ឈ្មោះថា **អច្ចុតះ** បានដល់ **ព្រះនិព្វាន** ។

**៣.អច្ចន្តំ** ប្រែថា ធម៌ដែលទៀងកន្លងផុតចាកខន្ធ ៥ ជាអតីត និង អនាគត មានន័យថា ព្រះនិព្វាននោះកន្លងចាកខន្ធ ៥ ជាអតីត ដែលបានរលត់ទៅហើយ ហៅថា **បុព្វន្តខន្ធ** និង កន្លងចាកខន្ធ ៥ ជាអនាគត ដែលនឹងកើតឡើងខាងមុខជា **អបរន្តខន្ធ** ។ ក្នុងបរមត្ថទីបនីដីកា សម្ដែងថា **បុព្វន្តា បរន្តេ អតិក្កមបវត្តតា អច្ចន្តំ** ប្រែថា សភាវធម៌ដែលកើតឡើង កន្លងផុតអតីត និង អនាគត ឈ្មោះថា **អច្ចន្ត** បានដល់ **ព្រះនិព្វាន** ។ សូម្បីមិនបានសម្ដែងពីការកន្លងចាកខន្ធ ៥ ដែលជាបច្ចុប្បន្ននេះក៏ដោយ ប៉ុន្តែកាលណាបានសម្ដែងការកន្លងចាកខន្ធ ៥ ជាអតីត និង អនាគតហើយ ឯការសម្ដែងការកន្លងចាកខន្ធ ៥ ដែលជាបច្ចុប្បន្ន ក៏ចាត់ទុកថា សម្រេចទៅហើយដែរ ព្រោះថា បើខន្ធ ៥ ដែលកើតរួចហើយ និង ដែលនឹងកើត តទៅខាងមុខ មិនមានហើយ **ខន្ធ ៥** ដែលកំពុងកើតក៏មានមិនបានដែរ ។ ឧបមាដូច មានមនុស្សនិយាយថា “ យើងមិនធ្លាប់បានឃើញ ឈាមក្នុងក្អាម និង តទៅខាងមុខទៀត ក៏នឹងមិនឃើញអ៊ីចឹងដូចគ្នា ” ការនិយាយ យ៉ាងនេះក៏មានន័យថា ក្នុងបច្ចុប្បន្ននេះ គេក៏មិនឃើញយ៉ាងនោះដែរ ។

**ខន្ធ ៥ ដែលជាបច្ចុប្បន្ននេះ** ជាអនាគតខន្ធរបស់ខន្ធ

៥ ដែលបានកន្លងទៅហើយ ក៏នឹងទាំងជាអតីតខន្ធនៃខន្ធ ៥ ដែលនឹងកើតតទៅខាងមុខទៀត ។ ដូច្នេះទើបមិនចាំបាច់ត្រូវសម្តែង ការកន្លង ចាកបច្ចុប្បន្នខន្ធដោយចំពោះឡើយ ហើយនិង ក៏ជាការដឹងបានទៀតថា **ព្រះនិព្វាន** នេះ ជាធម៌ផុតចាកកាលទាំង ៣ ដែលហៅថា **កាលវិមុត្តិ** និង ជាធម៌ផុតចាកខន្ធ ៥ ដែលហៅថា **ខន្ធវិមុត្តិ** ។

**៤.អសង្ខតំ** ប្រែថា ធម៌ដែលមិនត្រូវតាក់តែង ដោយបច្ច័យ ៤ យ៉ាងណាមួយ បានដល់ **ព្រះនិព្វាន** មានន័យថា ព្រះនិព្វាននេះជាធម៌ដែលមិនមែនជាចិត្ត ចេតសិក រូប ព្រោះជាធម្មតា ចិត្ត ចេតសិក រូប ទាំងនេះកើតឡើងបាន ក៏ដោយសារមានបច្ច័យ ៤ គឺ កម្ម ចិត្ត ឧតុ អាហារ យ៉ាងណាមួយ ឬ ២-៣-៤ ជាអ្នកតាក់តែង ។ ក្នុងបរមត្ថទីបនីដីកា សម្តែងថា **សង្ខរណ កិច្ច រហិតត្តា សង្ខតំ** ប្រែថា សភាវធម៌ដែលប្រាសចាកការតាក់តែង ឈ្មោះថា **អសង្ខតៈ** បានដល់ **ព្រះនិព្វាន** ។

ប៉ុន្តែបើពោលដោយទូទៅ **អសង្ខតធម៌** រមែងបានដល់ **ព្រះនិព្វាន** និង **បញ្ញត្តិ** ព្រោះជាធម៌ដែលប្រាសចាកការតាក់តែង

ដែរ តែក្នុងទីនេះ សំដៅយកចំពោះបរមត្ថធម៌ប៉ុណ្ណោះ ដូច្នោះ **អសង្ខតធម៌** ទើបបានដល់ **ព្រះនិព្វាន** តែម្យ៉ាងប៉ុណ្ណោះ ។

**៥.អនុត្តរំ** ប្រែថា ជាធម៌ដ៏ប្រសើរ បានដល់ **ព្រះនិព្វាន** មានន័យថា ធម៌ឯណាៗដែលប្រសើរជាងព្រះនិព្វាន នោះមិនមានឡើយ ។ ក្នុងបរមត្ថទីបនីដីកា សម្តែងថា :

**អត្តនោ ឧត្តរិតស្ស កស្សចិ ធម្មស្ស អភាវតោ អនុត្តរំ** ប្រែថា សភាវធម៌ដែលប្រសើរលើសជាងធម៌ទាំងអស់នោះ ឈ្មោះថា **អនុត្តរំ** បានដល់ **ព្រះនិព្វាន** ។

កាលណាពោលដោយចំណែករួម **អនុត្តរធម៌** ក៏គឺ **លោកុត្តរធម៌** បានដល់ លោកុត្តរចិត្ត ៨ ចេតសិក ៣៦ និព្វាន ប៉ុន្តែក្នុងទីនេះ សំដៅយក **ព្រះនិព្វាន** តែម្យ៉ាង ៕

# វចនត្ថៈរបស់និព្វាន

ពាក្យថា **និព្វាន** មាន ២ បទ គឺ **និ + វាន** ។

**និ** ប្រែថា រួចផុត **វាន** ប្រែថា ធម៌ជាគ្រឿងដោតក្រង សំដៅយក **តណ្ហា** ។ បើបង្រួមទាំង ២ បទចូលគ្នា គឺជា **និវាន**

ប្រែថា ធម៌ដែលរួចផុតពីគ្រឿងដោតក្រង សំដៅយករួចផុតពីតណ្ហា។

ក្នុងអភិធម្មត្ថសង្គហៈបាលី សម្តែងថា :

**វាន សង្ខាតាយ តណ្ហាយ និក្ខន្តត្តា និព្វានំ**

ប្រែថា ធម្មជាតិដែលរួចផុតពីតណ្ហា ជាគ្រឿងដោតក្រងនោះ ហៅថា **និព្វាន** ។

វចនត្ថៈម្យ៉ាងទៀតសម្តែងថា :

**វិនតិ សំសិព្វតីតិ = វានំ**

ប្រែថា ធម្មជាតិឯណា រមែងជាអ្នកចាក់ស្រែះ ដោតក្រងទុក ធម្មជាតិនោះ ឈ្មោះថា **វាន** បានដល់ **តណ្ហា** ។

**វានតោ និក្ខន្តន្តិ = និព្វានំ**

ប្រែថា ធម្មជាតិឯណា រមែងរួចផុតចាកការចាក់ស្រែះ ដោតក្រង ធម្មជាតិនោះ ឈ្មោះថា **និព្វាន** ។

អធិប្បាយថា បណ្តាសត្វទាំងឡាយ ដែលអន្ទោលវិលកើតវិលស្លាប់ក្នុងលោកនេះ សុទ្ធសឹងតែមានការកើត ការស្លាប់ កន្លងមកហើយ យ៉ាងច្រើនអនេកប្រមាណមិនបាន ហើយក៏នឹងត្រូវអន្ទោលត្រាច់រង្គាត់ ស្លាប់កើត តទៅទៀត យូរអង្វែងប៉ុណ្ណា ក៏ដឹងពុំបានដែរ

ត្រង់ដែលការកើត ការស្លាប់ ជារឿយៗទៅយ៉ាងនេះ ក៏ព្រោះតែអាស្រ័យមានតណ្ហា គឺ សេចក្តីត្រេកអរ ជាប់ចិត្ត ប្រាថ្នា ត្រូវការក្នុងអារម្មណ៍ផ្សេងៗនោះឯង ដែលជាអ្នកចាក់ស្រែះ ដោតក្រង ទុកមិនឲ្យរួចផុតពីការកើត ការស្លាប់ទៅបាន ដូចជា ជាងដេរប៉ាក់សំពត់ម្នាក់ ដែលយកសំពត់ច្រើនផុនមកដេរឲ្យជាប់បន្តគ្នា យ៉ាងណា តណ្ហា ក៏ប្រៀបបីដូចជា ជាងដេរប៉ាក់សំពត់ គឺ ដោតចាក់ក្រងសត្វក្នុងភពចាស់ ឲ្យជាប់បន្តទៅនឹងភពថ្មីជារឿយៗដូច្នោះ ដោយហេតុនេះឯង **តណ្ហា** ទើបបានឈ្មោះថា **វាន** ។

ចំពោះ**ព្រះនិព្វាន**នោះ ជាធម្មជាតិដែលរួចផុតពីតណ្ហាទៅហើយ ដូច្នេះ ទើបឈ្មោះថា **និវាន** ។ ពាក្យថា **វាន** ជាឈ្មោះរបស់ធម៌ដែលមិនល្អ លុះមានពាក្យ **និ** ប្រកបនៅខាងមុខហើយ ក៏ក្លាយជាឈ្មោះរបស់ធម៌ ដែលល្អជាទីបំផុតទៅវិញ ។ ដូចគ្នានឹងព្រះអរហន្តទាំងឡាយ ដែលលោកបានឈ្មោះថា **ព្រះខីណាស្រព** ពាក្យថា ខីណាស្រពនេះ កាលបំបែកចេញហើយ បាន ២ បទ គឺ :

**ខីណ** + **អាសវ** , **ខីណ** = អស់ទៅ , **អាសវ** = ធម៌ដែលដេកត្រាំ ឬ ធម៌ដែលហូរទៅបានក្នុងភូមិ ៣១ភូមិ បានដល់ លោភៈ ទិដ្ឋិ មោហៈ ។ ឈ្មោះ **អាសវៈ** ជាឈ្មោះមិនល្អ

ជាឈ្មោះរបស់កិលេសគ្រឿងសៅហ្មង លុះយកពាក្យថា **ខីណៈ** ផ្ដើមខាងមុខហើយ ក៏ត្រឡប់ជារបស់ល្អទៅវិញ គឺ សំដៅដល់ ការអស់ទៅនូវអាសវកិលេស បើពោលដោយបុគ្គល បានដល់ ព្រះអរហន្តទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើម យ៉ាងនេះឯង ។

ក្នុងវិសុទ្ធិមគ្គអដ្ឋកថា សម្ដែងលក្ខណៈរបស់ព្រះនិព្វាន ថា **តយិទំ សន្តិ លក្ខណំ** ប្រែថា និព្វានមានសេចក្ដីសុខ ដែលផុតចាកកិលេស ជាលក្ខណៈ ។

សេចក្ដីសុខរបស់ព្រះនិព្វាននោះ មិនមែនជាសេចក្ដីសុខ ដែលទទួលបានមកពីការសោយអារម្មណ៍នោះទេ ។ សេចក្ដីសុខដែលកើតពីការសប្បាយកាយ សប្បាយចិត្ត ហៅថា **វេទយិតសុខ** គឺ សេចក្ដីសុខ ដែលកើតពីការសោយអារម្មណ៍ ដូច្នេះតាមន័យរបស់សុខ ទើបមាន ២ ប្រការ :

**១.វេទយិតសុខ** បានដល់ សុខ ដែលកើតពីវេទនា(ការសោយអារម្មណ៍) ។

**២.សន្តិសុខ** បានដល់ សុខ ដែលកើតពីការរួចផុតចាកកិលេស គឺ ដែលមិនមានកិលេសកើត ជានិរោធសច្ចៈ បានដល់ សេចក្ដី

សុខ ដែលផុតចាកទុក្ខទាំងពួង ។

# សម្តែងប្រភេទរបស់ព្រះនិព្វាន

ប្រភេទរបស់ព្រះនិព្វាន មានការសម្តែងទុកជាច្រើនន័យដូចៗគ្នា មាន ១ប្រភេទខ្លះ ២ប្រភេទខ្លះ ឬ ៣ប្រភេទខ្លះ ។

ប្រភេទរបស់ព្រះនិព្វាន
- មាន១ → សន្តិលក្ខណៈ
- មាន២
  - សឧបាទិសេសនិព្វាន
  - អនុបាទិសេសនិព្វាន
- មាន៣
  - សុញ្ញតនិព្វាន
  - អនិមិត្តនិព្វាន
  - អប្បណិហិតនិព្វាន

# និព្វានមាន ១ ប្រភេទ

**ព្រះនិព្វាន** កាលណាពោលដោយសភាវលក្ខណៈ មានប្រភេទតែម្យ៉ាង គឺ សន្តិលក្ខណៈ សំដៅដល់ ការស្ងប់ចាកកិលេស និង ខន្ធ ៥ ទាំងឡាយ ។

ការដែលពោលថា ព្រះនិព្វាន ដោយសភាវលក្ខណៈរបស់ខ្លួន

មានតែម្យ៉ាងនោះ មិនដូចគ្នានឹងវត្ថុរបស់របរដែលមានមួយ តែអ្នកប្រើប្រាស់មានច្រើនគ្នា នឹងប្រើប្រាស់ព្រមៗគ្នាមិនបាន ត្រូវតែផលិតប្រើសម្រាប់ម្នាក់ៗ ព្រះនិព្វានមិនមែនជាយ៉ាងនោះទេ ព្រះអរហន្តទាំងឡាយ កាលលោកបរិនិព្វានហើយ រមែងបានចូលដល់សន្តិសុខដូចគ្នាទាំងអស់ គឺ រួចផុតចាកការកើតនិងការស្លាប់ ឬ ដល់នូវការអស់ទៅនៃតណ្ហា ។

ដូច្នោះ បង្ហាញឲ្យឃើញថា **និព្វាន** គឺ សភាពសន្តិសុខនោះរាប់មិនអស់ ស្រេចតែតាមចំនួនព្រះអរហន្តដែលបរិនិព្វានទៅហើយ។

# និព្វានមាន ២ ប្រភេទ

**និព្វាន** កាលបើពោលដោយបរិយាយនៃហេតុ (ការណូបចារន៍យ) ដោយអាការនៃខន្ធហើយមាន ២ ប្រភេទ :

**១.** សឧបាទិសេសនិព្វាន

**២.** អនុបាទិសេសនិព្វាន

# ១. សឧបាទិសេសនិព្វាន

**សឧបាទិសេសនិព្វាន** សំដៅដល់ និព្វានដែលប្រព្រឹត្តទៅ

នឹង ខន្ធ ៥ បានដល់ វិបាក និង កម្មជរូបដែលសល់ពីកិលេស បានប្រហារដោយអរហត្តមគ្គញាណហើយ គឺ បានដល់ និព្វាន របស់ព្រះអរហន្ត ដែលនៅមានជីវិតរស់នៅ ដូចសម្ដែងវចនត្ថៈថា :

**ក. កម្មកិលេសេហិ ឧបាទីយតីតិ = ឧបាទិ (វា) អារម្មណករណវសេន តណ្ហាទិដ្ឋីហិ ឧបាទីយតីតិ = ឧបាទិ ។**

ប្រែថា កម្មនិងកិលេសទាំងនេះ រមែងប្រកាន់នូវខន្ធ ៥ គឺ វិបាក និង កម្មជរូប ថាជារបស់យើង ដូច្នេះខន្ធ ៥ គឺ វិបាក និង កម្មជរូបនេះ ឈ្មោះថា **ឧបាទិ** ។

ឬន័យម្យ៉ាងទៀត តណ្ហានិងទិដ្ឋិទាំងនេះ រមែងប្រកាន់នូវ ខន្ធ ៥ គឺ វិបាកនិងកម្មជរូប ដោយការធ្វើឲ្យជាអារម្មណ៍របស់យើង ដូច្នេះ ខន្ធ ៥ គឺ វិបាកនិងកម្មជរូបនេះ ឈ្មោះថា **ឧបាទិ** ។

**ខ. សិស្សតិ អវសិស្សតីតិ = សេសោ, ឧបាទិ ច សេសោ ចាតិ = ឧបាទិសេសោ**

ប្រែថា ខន្ធ ៥ គឺ វិបាកនិងកម្មជរូប ឈ្មោះថា **សេសៈ**

ព្រោះជាចំណែកដែលនៅសល់អំពីកិលេសដែលត្រូវប្រហារហើយ ។ ខន្ធ ៥ គឺ វិបាកនិងកម្មជរូបនេះ ឈ្មោះថា **ឧបាទិ** ផង ឈ្មោះថា **សេសះ** ផង ព្រោះត្រូវកម្មនិងកិលេសប្រកាន់ថា ជារបស់យើង ឬ ត្រូវតណ្ហា និង ទិដ្ឋិប្រកាន់ដោយការធ្វើឲ្យជាអារម្មណ៍ និង ជាធម៌ដែលនៅសល់អំពីកិលេស ដូច្នេះ ខន្ធ ៥ គឺ វិបាក និង កម្មជរូបទាំងនេះ ឈ្មោះថា **ឧបាទិសេសះ** ។

បានសេចក្តីថា វិបាកនិងកម្មជរូប ដែលអន្ទោលត្រាច់រង្គាត់ក្នុងសង្សារវដ្តទាំងនេះ រមែងមានការកើតមក ជំពាក់ជំពិននឹងកិលេសជានិច្ច ។ លុះដល់អរហត្តមគ្គប្រហារ កិលេសទាំងពួងបានអស់ហើយ មានតែវិបាកនិងកម្មជរូប ដែលជាផលរបស់កិលេសទាំងនោះប៉ុណ្ណោះដែលនៅសល់ ។ ដូច្នេះ វិបាកនិងកម្មជរូបដែលនៅសល់នេះឯង ទើបឈ្មោះថា **ឧបាទិសេសះ** បើពោលដោយបុគ្គលាធិដ្ឋានវិញ ក៏បានដល់ រាងកាយរបស់ព្រះអរហន្ត ដែលនៅសល់មានជីវិតរស់នៅ នោះឯង ។

## គ. សហ ឧបាទិសេសេន យា វត្តតីតិ សឧបាទិសេសា ។

ប្រែថា និព្វានឯណា រមែងកើតព្រមជាមួយវិបាកនិងកម្មជរូប

ដែលនៅសល់អំពីកិលេសទាំងឡាយនោះ និព្វាននោះ ឈ្មោះថា **សឧបាទិសេសៈ** បានដល់ និព្វានរបស់ព្រះអរហន្តទាំងឡាយ ដែលបានចូលទៅ ឃើញច្បាស់ ដឹងច្បាស់ ដោយសភាពជាអារម្មណ៍ ។

ក្នុងសេចក្ដីដែលថា និព្វានដែលកើតព្រមជាមួយវិបាក និងកម្មជ្ជរូបនោះ មិនដូចនឹងចិត្តដែលកើតប្រកបព្រមនឹងចេតសិកទេ គឺសំដៅយក ថា វិបាកនិងកម្មជ្ជរូប ដែលនៅសល់នោះ ជាហេតុឲ្យឃើញច្បាស់ ឲ្យដឹងច្បាស់នូវព្រះនិព្វាន ។

# ២. អនុបាទិសេសនិព្វាន

**អនុបាទិសេសនិព្វាន** សំដៅដល់ និព្វានដែលមិនមានខន្ធ ៥ គឺ មិនមានវិបាកនិងកម្មជ្ជរូបនៅសល់ទេ បានដល់ **និព្វាន** របស់ព្រះអរហន្តដែលបរិនិព្វានហើយ ដូចសម្ដែងវចនត្ថៈថា :

**នត្ថិ ឧបាទិសេសោ យស្សាតិ = អនុបាទិសេសោ**

ប្រែថា ខន្ធ ៥ គឺ វិបាកនិងកម្មជ្ជរូបដែលនៅសល់ មិនមានដល់និព្វានណា ដូច្នេះ និព្វាននោះ ឈ្មោះថា **អនុបាទិសេសៈ** ។

ក្នុងបរមត្ថទីបនីដីកា សម្ដែងថា **ចុតិ អនន្តរេ ខន្ធានំ**

**អនុប្បាទោ អនុបាទិសេស នាម ។**

ប្រែថា សភាពដែលមិនកើតនូវខន្ធ ក្រោយពីការរលត់របស់ព្រះអរហន្តនោះ ឈ្មោះថា **អនុបាទិសេសនិព្វាន ។**

ការសម្តែងនិព្វានមាន ២ ប្រភេទ ដោយការណែបចារន័យ គឺ ដោយបរិយាយនៃហេតុនេះ បានសេចក្តីថា វិបាក និង កម្មជរូប ដែលនៅសល់ និង មិនមាននៅសល់ ទាំង ២ ប្រភេទនេះ ជាហេតុឲ្យដឹងដល់នូវសភាវៈរបស់ព្រះនិព្វាន ។ ដោយហេតុនេះ ព្រះពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់សម្តែងថា ព្រះនិព្វានមាន ២ តាមហេតុដូចដែលបានពោលមកនោះ ប៉ុន្តែជាការសម្តែងដោយបរិយាយ មិនមែនសម្តែងដោយត្រង់ៗ ចំៗនោះទេ ។

ប្រការមួយទៀត សឧបាទិសេសនិព្វាន នោះ នឹងហៅថា ទិដ្ឋធម្មនិព្វាន ក៏បាន ព្រោះព្រះអរហន្តទាំងឡាយ អ្នកចូលទៅឃើញច្បាស់ ដឹងច្បាស់នូវព្រះនិព្វាននោះ នៅមានជីវិតនៅឡើយ មិនទាន់បរិនិព្វានទេ ។

ចំណែក អនុបាទិសេសនិព្វាន នឹងហៅថា សម្បរាយិកនិព្វាន ក៏បាន ព្រោះព្រះអរហន្តទាំងឡាយ កាលណាបរិនិព្វានហើយ ទើប

ចូលដល់ព្រះនិព្វាននោះ ។

# និព្វានមាន ៣ ប្រភេទ

និព្វាននោះ កាលណាពោលដោយអាការចូលដល់(សម្រេច) និង ដោយអាការប្រព្រឹត្តដោយសាមញ្ញលក្ខណៈ ក្នុងព្រះនិព្វាន ហើយ ក៏មាន ៣ ប្រភេទ គឺ :

**១.** អនិមិត្តនិព្វាន ។

**២.** អប្បណិហិតនិព្វាន ។

**៣.** សុញ្ញតនិព្វាន ។

# ១. អនិមិត្តនិព្វាន

**អនិមិត្តនិព្វាន** សំដៅដល់ ភាវៈរបស់ព្រះនិព្វាននោះ មិនមាននិមិត្តគ្រឿងចំណាំ រូបរាងសណ្ឋាន ពណ៌វណ្ណៈ យ៉ាងណាឡើយ។

ក្នុងបរមត្ថទីបនីដីកា សម្តែងថា :

**កិលេសានំ ជរាមរណា ទីនញ្ច វត្ថុ ភូតស្ស**
**និមិត្តស្ស អភាវា អនិមិត្តោ នាម**

ប្រែថា ការស្ងាត់ចាកនិមិត្តារម្មណ៍ ដែលនាំឲ្យកើតកិលេស ឬ ជរាមរណធម៌ជាដើមនោះ ឈ្មោះថា **អនិមិត្តនិព្វាន** ។

បានសេចក្ដីថា ព្រះយោគាវចរ អ្នកចម្រើនវិបស្សនាភាវនានោះ រមែងឃើញការកើតការរលត់នៃនាមរូប ដោយសភាពជាត្រៃលក្ខណ៍ មុនការឃើញច្បាស់នូវព្រះនិព្វាន ។ បើការឃើញត្រៃលក្ខណ៍នោះ ឃើញដោយសភាពមិនទៀង ជាអនិច្ចំ ប្រាសចាកនិមិត្តគ្រឿងសំគាល់ ក្នុងអារម្មណ៍វិបស្សនានោះ ហើយក៏ពិចារណាកំណត់អារម្មណ៍ដោយសភាពជា អនិច្ចំ តទៅ រហូតបានសម្រេចមគ្គផល មាននិព្វានជាអារម្មណ៍ ។ និព្វានដែលជាអារម្មណ៍ ដល់យោគាវចរ អ្នកឃើញដោយសភាពជាអនិច្ចំនោះ ឈ្មោះថា **អនិមិត្តនិព្វាន** ហើយអ្នកដែលនឹងមានអនិមិត្តនិព្វានជាអារម្មណ៍នេះ ត្រូវអាស្រ័យបុញ្ញាធិការពីជាតិមុន បានអប់រំទុកដ៏យ៉ាងមានកម្លាំងដោយសីល ។ ធម្មតា អារម្មណ៍របស់អ្នកចម្រើនវិបស្សនានោះ រមែងមានរូបនាមជាអារម្មណ៍ ហើយរូប គឺ រូបក្ខន្ធនោះ រមែងមានរូបកលាបកើតនៅរួមគ្នា ដូច្នេះ រូបរាងសណ្ឋាន ពណ៌វណ្ណៈទើបប្រាកដបាន ។ ចំណែកនាម គឺ នាមក្ខន្ធ ៤ មានចិត្ត និងចេតសិកកើតរួមគ្នា សូម្បីថារូបរាងសណ្ឋាន ពណ៌វណ្ណៈ ប្រាកដមិនបានដូចរូបក្ខន្ធក៏ពិតមែន ប៉ុន្តែការកើតបន្តជាប់គ្នានៃនាមក្ខន្ធទាំង ៤

នេះ ព្រះសម្មាសម្ពុទ្ធ និង បរចិត្តវិជាននអភិញ្ញាលាភីបុគ្គលទាំងឡាយ រមែងកំណត់ដឹងបាន ឃើញបាន ដោយអំណាចនៃបញ្ញាថា នាមក្ខន្ធទាំង ៤ នេះ ប្រហែលនឹងមានរូបសណ្ឋាន ដូច្នេះ ទើបនៅមាននិមិត្តគ្រឿងសំគាល់ ប៉ុន្តែចំពោះសភាពនៅរបស់ព្រះនិព្វាននោះ មិនដូចជារូប ជានាមនោះ ដោយប្រការណាៗឡើយ ទើបបានឈ្មោះថា **អនិមិត្តនិព្វាន** ។

# ២. អប្បណិហិតនិព្វាន

**អប្បណិហិតនិព្វាន** បានដល់ ភាវៈរបស់ព្រះនិព្វាននោះ មិនមានអារម្មណ៍ដែលគួរជាទីប្រាថ្នាដោយលោភៈ និង មិនមានតណ្ហា ដែលជាតួត្រូវការ នៅក្នុងនិព្វានអារម្មណ៍នោះ ។

ក្នុងបរមត្ថទីបនីដីកា មានវចនត្ថៈថា :

**សព្វទុក្ខានំ និទានភូតស្ស អាសាទុក្ខស្ស**
**អភាវា អប្បណិហិតោ នាម ។**

ប្រែថា ការស្ងាត់ចាកសេចក្តីរន្ធត់ ដែលជាហេតុឲ្យកើតទុក្ខទាំងពួងនោះ ឈ្មោះថា **អប្បណិហិតនិព្វាន** ។

បានសេចក្ដីថា ព្រះយោគាវចរអ្នកចម្រើនវិបស្សនាភាវនា រហូតបានឃើញត្រៃលក្ខណ៍ ដោយអាការជាទុក្ខ គឺ ភារៈដែលធន់នៅមិនបាន ត្រូវផ្លាស់ប្ដូរ ដោះស្រាយរកនូវបណិធិដែលមាំមួនមិនបាន យ៉ាងនេះហើយ កំណត់ពិចារណាអារម្មណ៍វិបស្សនា ដោយសភាពជាទុក្ខតទៅ រហូតបានសម្រេចមគ្គផល មានព្រះនិព្វានជាអារម្មណ៍និព្វាន ដែលជាអារម្មណ៍នោះ ឈ្មោះថា **អប្បណិហិត-និព្វាន** ហើយអ្នកដែលមានអប្បណិហិតនិព្វានជាអារម្មណ៍នេះ ត្រូវអាស្រ័យបុញ្ញាធិការពីជាតិមុន បានអប់រំទុកដ៏យ៉ាងមានកម្លាំងដោយសមាធិ ។

សង្ខតធម៌ទាំងឡាយ ដែលបានដល់ រូបធម៌ក្ដី នាមធម៌ក្ដី ទាំងនេះ ត្រូវមានសភាព **បណិហិតៈ** គឺ មានអារម្មណ៍គួរជាទីប្រាថ្នាដោយ លោភៈ ឬ មានតណ្ហាយ៉ាងណាមួយ ឬ មានទាំង ២ យ៉ាង សូម្បីថាលោកុត្តរចិត្ត និង ចេតសិកប្រកបទាំងនេះ នឹងមិនមាននូវអារម្មណ៍គួរជាទីប្រាថ្នាដោយលោភៈ និង មិនមានតួតណ្ហាក៏ពិតមែន ប៉ុន្តែនៅមិនទាន់ផុតចាកសភាពជាបណិហិតធម៌ទេ ព្រោះត្រូវកើតអាស្រ័យបុគ្គល ប៉ុន្តែនិព្វាននោះ មិនបានកើតនៅក្នុងបុគ្គលទេ ជាធម៌ខាងក្រៅតែមួយចំណែកប៉ុណ្ណោះ ដូច្នេះ ទើបឈ្មោះថា **អប្បណិហិតៈ** គឺជាសភាវៈដែលមិនត្រូវអាស្រ័យ តាំងនៅលើកង

ទុក្ខ គឺ រូបនាម នោះឯង ។

## ៣. សុញ្ញតនិព្វាន

**សុញ្ញតនិព្វាន** សំដៅដល់ ភាវៈរបស់ព្រះនិព្វាននោះ សូន្យអស់ចាកកិលេស និង ឧបាទានក្ខន្ធ ៥ មិនមានអ្វីនៅសល់ ជាវត្ថុជាប់ជំពាក់កង្វល់ឡើយ ។

ក្នុងបរមត្ថទីបនីដីកា សម្ដែងថា :

**សព្វបលិពោធេហិ វិវិត្តត្តា សុញ្ញតំ**

ប្រែថា សេចក្ដីស្ងាត់ចាកបលិពោធធម៌ទាំងពួងនោះ ឈ្មោះថា **សុញ្ញតនិព្វាន** ។

មានសេចក្ដីថា ព្រះយោគាវចរអ្នកចម្រើនវិបស្សនាភាវនា រហូតបានឃើញត្រៃលក្ខណ៍ ដោយសភាពជាអនត្តា គឺ ឃើញភាវៈដែលមិនមែនតួខ្លួន និង បង្គាប់បញ្ជាមិនបាន យ៉ាងនេះហើយ កំណត់ពិចារណាអារម្មណ៍រូបនាម ដោយសភាពជាអនត្តា តទៅ រហូតបានសម្រេចមគ្គផល មានព្រះនិព្វានជាអារម្មណ៍ និព្វានដែលជាអារម្មណ៍នោះ ឈ្មោះថា **សុញ្ញតនិព្វាន** ហើយអ្នកចម្រើនវិបស្សនាកម្មដ្ឋានដែលមានសុញ្ញតនិព្វានជាអារម្មណ៍នេះ ត្រូវអាស្រ័យបុញ្ញាធិការពីជាតិ

មុន បានអប់រំទុកដ៏យ៉ាងមានកម្លាំងដោយបញ្ញា គឺ បានសាងសន្សំបញ្ញាបារមីទុក មកជាច្រើនពីអតីតនោះឯង ។

និព្វានប្រភេទនីមួយៗ ដែលបានសម្តែងហើយនោះ បានមកពីការប្រព្រឹត្តដោយ**សាមញ្ញលក្ខណៈ** និង ដោយការចូលដល់ ។ កាលណាពោលដោយវិសេសលក្ខណៈរបស់ព្រះនិព្វាន ដោយចំពោះហើយ ក៏មានត្រឹមតែ ៣ ប្រការ គឺ លក្ខណៈ រស បច្ចុប្បដ្ឋានប៉ុណ្ណោះ ចំណែកឯ បទដ្ឋាន គឺ ហេតុជិតឲ្យកើតនោះ មិនមានដូចព្រះបាលីសម្តែងថា :

**សន្តិលក្ខណមច្ចុតរសំ និព្វាន អមតំ**
**អនិមិត្តំ ឧបដ្ឋានំ បទដ្ឋានំ ន លព្ភតិ**

ម្យ៉ាងទៀត ក្នុងអភិធម្មាវតារ ពោលទុកថា :

**សន្តិ លក្ខណំ អច្ចុតិរសំ អស្សាសករណរសំ វា**
**អនិមិត្ត បច្ចុប្បដ្ឋានំ និស្សរណ បច្ចុប្បដ្ឋានំ វា**

# វិសេសលក្ខណៈរបស់ព្រះនិព្វាន

- **សន្តិ លក្ខណំ** មានការស្ងប់ចាកកិលេស និង ខន្ធ ៥

ជាលក្ខណៈ ។

**- អច្ចុត រសំ** មានការមិនរលត់ ជាកិច្ច ។

**អស្សាសករណ រសំ វា** ឬ មានការធ្វើឲ្យធូរស្រាល ជាកិច្ច ។

**- អនិមិត្ត បច្ចុប្បដ្ឋានំ** មានការមិនមាននិមិត្ត គ្រឿងសំគាល់ ជាអាការប្រាកដ ។

**និស្សរណ បច្ចុប្បដ្ឋានំ វា** ឬ មានការរលាស់ចេញបានពីភព ជាអាការប្រាកដ ។

**- បទដ្ឋានំ ន លព្ភតិ** ព្រះនិព្វានមិនមានហេតុជិត ឲ្យកើត (ព្រោះព្រះនិព្វាន ជាធម៌ផុតចាកហេតុ ចាកបច្ច័យទាំងពួងតាក់តែង) ។

**និព្វាន** មាន ៤ កាលបើពោលដោយប្រភេទនៃមគ្គ មាន ៤ ប្រការ គឺ និព្វានរបស់សោតាបត្តិមគ្គ សកទាគាមិមគ្គ អនាគាមិមគ្គ និង អរហាត្តមគ្គ ។

**និព្វានមាន ៥** ដោយអំណាចការរំលត់កាមគុណទាំង ៥ គឺ រំលត់សេចក្តីត្រេកអរ ក្នុងរូប ក្នុងសម្លេង ក្នុងក្លិន ក្នុងរស ក្នុង

ផោដ្ឋព្វៈ ។

**និព្វានមាន ៦** ដោយអំណាចការរំលត់តណ្ហា ៦ ប្រការ គឺ ការរំលត់ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា និង ធម្មតណ្ហា ។

ព្រះមានព្រះភាគ ព្រះអង្គទ្រង់សម្ដែងសេចក្ដីមិនមាននៃតណ្ហា ដែលកើតតាមទ្វារ ៦ ដែលអរិយមគ្គកាត់ផ្ដាច់ហើយ ដោយអាស្រ័យព្រះនិព្វានជាអារម្មណ៍ ដោយប្រៀបធៀបទៅនឹងបុរស ឃើញវល្លិ៍ននោងល្វីងដុះក្នុងស្រែ ក៏ស្រាវរកឫសតាំងពីចុងទៅ ហើយកាត់ចោល ។ វល្លិ៍ននោងល្វីងនោះ ក៏ក្រៀមស្វិតដល់នូវភាពមិនមានបញ្ញត្តិតទៅ យ៉ាងណា តណ្ហាកើតក្នុងអារម្មណ៍ទាំងឡាយ តាមផ្លូវភ្នែកជាដើម ដែលជា **បិយរូប សាតរូប** ត្រូវអរិយមគ្គដកឫសឡើងហើយ ព្រោះអាស្រ័យព្រះនិព្វាន ក៏យ៉ាងនោះដែរ ។

# និព្វានមិនមាននិមិត្ត

**ព្រះនិព្វានធាតុ** ព្រះដ៏មានព្រះភាគព្រះអង្គទ្រង់បដិសេធសង្ខារធម៌ទាំងអស់គ្រប់យ៉ាង មិនមែនដី ទឹក ភ្លើង ខ្យល់ មិនមែនវិញ្ញាណ មិនមែនចិត្ត-ចេតសិក មិនមែន សីល សមាធិ បញ្ញា

មិនមែនសត្វបុគ្គល មិនមែនលោកនេះ-លោកខាងមុខ មិនមែនភពណាៗ មិនមែនអ្វីណាៗដែលមាននៅក្នុងលោកទាំងអស់នេះឡើយ ។

តើយើងនឹងបានដឹងដូចម្ដេចថា ព្រះនិព្វាននោះមានពិតមែន ?

ការដែលនឹងដឹងថា ព្រះនិព្វាននោះមានពិត ក៏ត្រូវអាស្រ័យការសម្រេចរបស់បុគ្គល អ្នកចូលទៅឃើញច្បាស់ដោយការចម្រើនមគ្គ ដែលសមគួរដល់ការសម្រេចនូវព្រះនិព្វាននោះ មានដែរ ។ ប្រសិនបើព្រះនិព្វានមិនមានទេ ការបដិបត្តិ គឺ មគ្គ ឬ មជ្ឈិមា-បដិបទា នឹងដល់នូវសេចក្ដីព្យាយាម ទៅយ៉ាងណា ក៏គ្មានផលដែរ ។

ប្រការម្យ៉ាងទៀត ការដែលនឹងជឿ ឬ គួរនឹងឃើញថា ព្រះនិព្វានមានពិតនោះ ក៏ព្រោះថា គុណរបស់ព្រះនិព្វានមានប្រចក្សនៅ ការរំលត់កិលេសមាននៅ ការរួចផុតស្រឡះមាននៅ និង អ្នករំលត់កិលេសមាននៅ ឬ អ្នករួចផុតស្រឡះក៏មាននៅ ដោយន័យដូចពោលមកនេះ ការបញ្ញត្តិនាមនៃ**គុណរបស់ព្រះនិព្វាន** ទើបមានដោយច្រើនប្រការ ។

# គុណនាមរបស់ព្រះនិព្វាន

**១.អសេសវិរាគនិរោធ** ជាធម៌ដែលរំលត់ទុក្ខ ដោយប្រាសចាក

ភាគៈមិនមានសេសសល់ ។

២.អសេសភវនិរោធោ ជាធម៌ដែលរំលត់ភព មិនមានសេស-សល់ ។

៣.ចាគោ ជាធម៌ដែលរលាស់ពីតណ្ហាទាំងពួង ។

៤.បដិនិស្សគ្គោ ជាធម៌ដែលរួចផុតចាកភព ។

៥.មុត្តិ ជាធម៌ដែលរួចផុតចាកកិលេស ។

៦.អនាលយោ ជាធម៌ដែលមិនមានសេចក្ដីអាល័យ ។

៧.រាគក្ខយោ ជាធម៌ដែលអស់ទៅនៃរាគៈ ។

៨.ទោសក្ខយោ ជាធម៌ដែលអស់ទៅនៃទោសៈ ។

៩.មោហក្ខយោ ជាធម៌ដែលអស់ទៅនៃមោហៈ ។

១០.តណ្ហក្ខយោ ជាធម៌ដែលអស់ទៅនៃតណ្ហា ។

១១.អនុប្បាទោ ជាធម៌ដែលរំលត់ខន្ធទាំង ៥ ។

១២.អបវត្តំ ជាធម៌ដែលរំលត់នាមរូប ។

១៣.អនិមិត្តំ ជាធម៌ដែលប្រាសចាកសង្ខារនិមិត្ត ។

១៤.អប្បណិហិតំ ជាធម៌ប្រាសចាកសេចក្ដីត្រូវការ ។

១៥.សុញ្ញតំ ជាធម៌ដែលសូន្យចាកទុក្ខបានពិតមែន។

| | |
|---|---|
| ១៦.អប្បដិសន្ធិ | ជាធម៌ដែលមិនមានការកើតបន្ត ។ |
| ១៧.អនុប្បត្តិ | ជាធម៌ដែលមិនមានទីទៅ ។ |
| ១៨.អនាយូហនំ | ជាធម៌ដែលមិនមានការព្យាយាម ។ |
| ១៩.អជាតំ | ជាធម៌ដែលមិនមានការកើត ។ |
| ២០.អជរំ | ជាធម៌ដែលមិនមានការចាស់ ។ |
| ២១.អព្យាធិ | ជាធម៌ដែលមិនមានការឈឺចាប់ ។ |
| ២២.អគតិ | ជាធម៌ដែលមិនមានគតិ ។ |
| ២៣.អមតំ | ជាធម៌ដែលមិនមានការស្លាប់ ។ |
| ២៤.អសោកំ | ជាធម៌ដែលមិនមានសេចក្ដីសោក ។ |
| ២៥.អបរិទេវំ | ជាធម៌ដែលមិនមានសេចក្ដីខ្សឹកខ្សួល ។ |
| ២៦.អនុបាយាសោ | ជាធម៌ដែលមិនមាន សេចក្ដីចង្អៀតចង្អល់ចិត្ត ។ |
| ២៧.អសង្កិលិដ្ឋំ | ជាធម៌ដែលមិនមានសេចក្ដីសៅហ្មង ។ |
| ២៨.អសង្ខតំ | ជាធម៌ដែលមិនមានបច្ច័យតាក់តែង ។ |
| ២៩.និវានំ | ជាធម៌ដែលផុតចាកគ្រឿងដោតក្រង ។ |
| ៣០.សន្តិ | ជាធម៌ដែលស្ងប់ចាកទុក្ខទាំងពួង ។ |

គុណនាមរបស់ព្រះនិព្វាន ដោយសង្ខេបទាំងនេះ អាស្រ័យគុណធម៌របស់លោកអ្នកដែលបានសម្រេចនូវព្រះនិព្វានហើយ ទើបថា ព្រះនិព្វានមានពិតមែន ។

**ព្រះនិព្វាន** សង្គ្រោះចូលក្នុង នាមធម៌ ប៉ុន្តែមិនមែនជានាមក្ខន្ធទេ ព្រោះនិព្វានផុតចាកការរាប់ថាជាខន្ធ ព្រោះជា **អសង្ខតធម៌** ។ ប៉ុន្តែព្រះនិព្វានជា អាយតនៈ គឺ **ធម្មាយតនៈ** ព្រោះហេតុថា ជាអារម្មណ៍របស់មគ្គចិត្ត និង ផលចិត្ត មគ្គចិត្ត និងផលចិត្តនោះ ជា **មនាយតនៈ** ។

**ព្រះនិព្វាន** ជាធម្មធាតុ ព្រោះហេតុថា ជាអារម្មណ៍របស់មនោវិញ្ញាណធាតុ និង មគ្គចិត្ត ផលចិត្ត ជា**មនោវិញ្ញាណធាតុ** ។

**ព្រះនិព្វាន** ជាអរិយសច្ចៈ គឺ **និរោធសច្ចៈ** ព្រោះថា ព្រះនិព្វាន ជាធម៌ដែលរំលត់នូវទុក្ខសច្ចៈ និង សមុទយសច្ចៈ ។

**ព្រះនិព្វាន** ជា**ធម្មារម្មណ៍** ជាអារម្មណ៍របស់មគ្គចិត្ត និង ផលចិត្ត ដូច្នេះ ព្រះនិព្វានជាបរមត្ថធម៌ ដែលមានពិតមែន ៕

# សេចក្តីប្រាថ្នា
# ព្រះនិព្វានចាត់ថាជាវិភវតណ្ហា

អ្នកដែលមិនយល់ ក្នុងសភាវៈរបស់ព្រះនិព្វាន បានល្អិតល្អន់ល្អទេ កាលបានឮថា ព្រះនិព្វាននោះ មិនមានសេចក្តីទុក្ខតាមផ្លូវកាយ និង ទុក្ខតាមផ្លូវចិត្ត គឺ មានតែសេចក្តីសុខសុទ្ធសាធ ព្រោះជាធម៌រួចផុតចាកលោក ដូច្នេះហើយ ក៏កើតចំណង់ចង់បានព្រះ-និព្វាន ព្រោះត្រូវការសុខកាយសប្បាយចិត្ត ដែលមិនជំពាក់ជំពិននឹងលោក និង មិនត្រូវការកើតចាស់ ឈឺ ស្លាប់ផង ។ ប៉ុន្តែគិតមិនដល់ថា តើសភាព ការមិនកើតរបស់ព្រះនិព្វាននោះ គឺអ្វី ? ធម្មតាសេចក្តីសុខកាយ សប្បាយចិត្តនឹងកើតឡើង ដោយមិនទាក់ទងក្នុងការកើតជាមនុស្ស ទេវតា ព្រហ្ម ដែលនៅក្នុងលោកនោះ មិនមានឡើយ ។

ដូច្នោះ សេចក្តីប្រាថ្នាចង់បានព្រះនិព្វាន របស់បុគ្គលពួកនេះចាត់ជា **វិភវតណ្ហា** ៕

# គាថាសង្គហៈ

## ឥតិ ចិត្តំ ចេតសិកំ រូបំ និព្វាន មច្ចិបី
## បរមត្ថំ បកាសេន្តិ ចតុធាវ តថាគតា

ប្រែថា ព្រះតថាគតទាំងឡាយ ទ្រង់ប្រកាស បរមត្ថធម៌ ដោយសង្ខេប ៤ ប្រការ គឺ ចិត្ត ចេតសិក រូប និង និព្វាន ទុកដោយប្រការយ៉ាងនេះ ។

# អវសានគាថា

## ឥច្ចានុរុទ្ធ រចិតេ អភិធម្មត្ថសង្គហេ
## ឆដ្ឋមោ បរិច្ឆេទោយំ សមាសេនេវនិដ្ឋិតោ

បរិច្ឆេទទី ៦ រូបសង្គហវិភាគ ក្នុងបករណ៍ដែលព្រះអនុរុទ្ធាចារ្យ រួបរួមរចនាទុកនូវអត្ថនៃព្រះអភិធម្ម ចប់ដោយសង្ខេប ដោយប្រការ យ៉ាងនេះឯង ៕

( ចប់បរិច្ឆេទទី ៦ )

ដោយចេតនាដែលជាកុសលសម្បទា បំពេញកុសលជាធម្មទាន ក្នុងឱកាសនេះ សូមចូរជាបច្ច័យបញ្ញាបារមី ឲ្យសាធុជនទាំងឡាយ ដល់នូវសេចក្តីសុខក្សេមក្សាន្ត សំរាន្តស្រួល ផុតចាកទុក្ខភ័យទាំងពួង អស់កាលជានិច្ច តទៅហោង ៕

បាត់ដំបង ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០០
ដោយលោកគ្រូ
បណ្ឌិតធម្មាចារ្យ **រស់ សុផាត**

••••••••••••••••••••••

# មាតិកា

| រឿង | ទំព័រ |
|---|---|
| គាថាសង្គហៈ............................... | ១ |
| រូបសមុទ្ទេសន័យ............................ | ៣ |
| អង្គធម៌របស់រូប ២៨............................ | ៨ |
| ទីកើតនៃរូប ២៨ ក្នុងរាងកាយសត្វ............... | ១០ |
| រូប ១១ ពួក ទី១ អំពីមហាភូតរូប ៤............ | ១២ |
| បឋវីធាតុ........................................ | ១២ |
| លក្ខណាទិចតុករបស់បឋវី........................ | ១៤ |
| បឋវីធាតុមាន ៤ យ៉ាង.......................... | ១៤ |
| អាបោធាតុ....................................... | ១៦ |
| លក្ខណាទិចតុករបស់អាបោ....................... | ១៨ |
| អាបោធាតុមាន ៤.............................. | ១៩ |
| តេជោធាតុ...................................... | ២០ |
| លក្ខណាទិចតុករបស់តេជោ....................... | ២១ |
| តេជោធាតុមាន ៤ យ៉ាង............................ | ២១ |

# មាតិកា

| រឿង | ទំព័រ |
| --- | --- |
| វាយោធាតុ.................................... | ២៣ |
| លក្ខណាទិចតុករបស់វាយោ........................... | ២៥ |
| វាយោធាតុមាន ៤ យ៉ាង........................... | ២៥ |
| អំពីបសាទរូប ៥.................................. | ២៧ |
| ចក្ខុបសាទ.................................... | ២៧ |
| លក្ខណាទិចតុករបស់ចក្ខុបសាទ.................... | ២៨ |
| ចក្ខុមាន ២ ប្រភេទ............................ | ២៩ |
| សោតបសាទរូប................................ | ៣១ |
| លក្ខណាទិចតុករបស់សោតបសាទ.................. | ៣២ |
| សោតមាន ៣ យ៉ាង........................... | ៣៣ |
| ឃានបសាទរូប................................ | ៣៣ |
| លក្ខណាទិចតុករបស់ឃានបសាទ.................. | ៣៥ |
| ជីវ្ហាបសាទរូប................................. | ៣៦ |
| លក្ខណាទិចតុករបស់ជីវ្ហាបសាទរូប.................. | ៣៧ |
| កាយបសាទរូប................................. | ៣៧ |
| កាយ ៤ យ៉ាង.................................... | ៣៨ |

# មាតិកា


| រឿង | ទំព័រ |
|---|---|
| កាយ ៤ យ៉ាងទៀត................................. | ៣៩ |
| លក្ខណាទិចតុករបស់កាយបសាទ...................... | ៤០ |
| អំពីវិសយរូប ឬគោចររូប ៧......................... | ៤១ |
| រូបារម្មណ៍............................................ | ៤២ |
| លក្ខណាទិចតុករបស់រូប.......................... | ៤៣ |
| សទ្ទារម្មណ៍...................................... | ៤៣ |
| លក្ខណាទិចតុករបស់សទ្ទះ......................... | ៤៤ |
| គន្ធារម្មណ៍....................................... | ៤៥ |
| គន្ធះ ៤ យ៉ាង..................................... | ៤៥ |
| លក្ខណាទិចតុករបស់គន្ធះ......................... | ៤៦ |
| រសារម្មណ៍....................................... | ៤៦ |
| រសមាន ៤ យ៉ាង.............................. | ៤៧ |
| លក្ខណាទិចតុករបស់រស.......................... | ៤៨ |
| ផោដ្ឋព្វារម្មណ៍..................................... | ៤៨ |
| លក្ខណាទិចតុករបស់ផោដ្ឋព្វារម្មណ៍................. | ៥០ |
| អំពីភាវរូប ២ ....................................... | ៥១ |

# មាតិកា


| រឿង | ទំព័រ |
| --- | --- |
| ឥត្ថីភាវរូប.................................... | ៥១ |
| លក្ខណាទិចតុករបស់ឥត្ថីភាវៈ.......................... | ៥២ |
| បុរិសភាវរូប.................................... | ៥៣ |
| លក្ខណាទិចតុករបស់បុរិសភាវរូប..................... | ៥៤ |
| អំពីហទយរូប................................ | ៥៦ |
| លក្ខណាទិចតុករបស់ហទយរូប..................... | ៥៨ |
| អំពីជីវិតរូប.................................... | ៥៩ |
| លក្ខណាទិចតុករបស់ជីវិតរូប........................ | ៦១ |
| អំពីអាហាររូប................................ | ៦១ |
| លក្ខណាទិចតុករបស់អាហាររូប.................... | ៦៣ |
| អំពីបរិច្ឆេទរូប................................ | ៦៤ |
| អាកាស ៤ យ៉ាង............................ | ៦៥ |
| លក្ខណាទិចតុករបស់បរិច្ឆេទរូប.................... | ៦៦ |
| អំពីវិញ្ញត្តិរូប ២................................ | ៦៨ |
| កាយវិញ្ញត្តិរូប................................ | ៦៩ |
| លក្ខណាទិចតុករបស់កាយវិញ្ញត្តិរូប..................... | ៧០ |

# មាតិកា


| រឿង | ទំព័រ |
|---|---|
| វចីវិញ្ញត្តិរូប.................................... | ៧១ |
| លក្ខណាទិចតុករបស់វចីវិញ្ញត្តិរូប...................... | ៧២ |
| អំពីវិការរូប ៣.................................... | ៧៥ |
| រូបលហុតា.................................... | ៧៥ |
| លក្ខណាទិចតុករបស់រូបលហុតា..................... | ៧៦ |
| រូបមុទុតា.................................... | ៧៦ |
| លក្ខណាទិចតុករបស់រូបមុទុតា...................... | ៧៧ |
| រូបកម្មញ្ញតា.................................... | ៧៧ |
| លក្ខណាទិចតុករបស់រូបកម្មញ្ញតា.................... | ៧៨ |
| អំពីលក្ខណរូប ៤............................. | ៨០ |
| ឧបចយរូប.................................... | ៨២ |
| លក្ខណាទិចតុករបស់ឧបចយរូប.................... | ៨៣ |
| ជរតារូប.................................... | ៨៤ |
| លក្ខណាទិចតុករបស់ជរតារូប...................... | ៨៤ |
| អនិច្ចតារូប.................................... | ៨៥ |
| លក្ខណាទិចតុករបស់អនិច្ចតារូប...................... | ៨៦ |

# មាតិកា


| រឿង | ទំព័រ |
|---|---|
| រូបវិភាគន័យ........................................ | ៨៩ |
| គូទី១ អជ្ឈត្តិករូប និងពាហិររូប..................... | ៩១ |
| គូទី២ វត្ថុរូប និងអវត្ថុរូប.......................... | ៩២ |
| គូទី៣ ទ្វាររូប និងអទ្វាររូប.......................... | ៩៣ |
| គូទី៤ ឥន្ទ្រិយរូប និងអនិន្ទ្រិយរូប................... | ៩៥ |
| គូទី៥ ឱឡារិករូប និងសុខុមរូប..................... | ៩៧ |
| គូទី៦ សន្តិកេរូប និងទូរេរូប....................... | ៩៨ |
| គូទី៧ សប្បដិឃរូប និងអប្បដិឃរូប................. | ៩៩ |
| គូទី៨ ឧបាទិន្នករូប និងអនុបាទិន្នករូប............... | ១០០ |
| គូទី៩ សនិទស្សនរូប និងអនិទស្សនរូប............... | ១០១ |
| គូទី១០ គោចរគាហិករូប និងអគោចរគាហិករូប...... | ១០២ |
| គូទី១១ អវិនិព្ភោគករូប និងវិនិព្ភោគរូប............. | ១០៥ |
| រូបសមុដ្ឋានន័យ.................................... | ១០៦ |
| អធិប្បាយសមុដ្ឋានទាំង ៤ ដែលធ្វើឲ្យរូបកើត...... | ១០៩ |
| កម្មសមុដ្ឋាន......................................... | ១០៩ |
| ចិត្តសមុដ្ឋាន........................................ | ១១២ |

# មាតិកា


| រឿង | ទំព័រ |
|---|---|
| ឧតុសមុដ្ឋាន.................................. | ១១៤ |
| អាហារសមុដ្ឋាន.............................. | ១១៥ |
| តារាងរូបសមុដ្ឋានន័យ......................... | ១២០ |
| សរុបរូបដែលកើតពីសមុដ្ឋាន ៤...................... | ១២១ |
| សម្តែងរូបសមុដ្ឋាន ៤ ដោយប្រាកដ (ឯកន្ត) និងដោយមិនប្រាកដ (អនេកន្ត) | ១២១ |
| កម្មជរូប ១៨................................... | ១២១ |
| ចិត្តជរូប ១៥................................. | ១២២ |
| ឧតុជរូប ១៣................................... | ១២៤ |
| អាហារជរូប ១២................................ | ១២៤ |
| ចំណែករូប ២៨ តាមសមុដ្ឋាន ៥ ន័យ............. | ១២៥ |
| តារាងសរុបសមុដ្ឋានិករូប........................ | ១២៨ |
| ចំណែកសមុដ្ឋានិករូបដោយសុត្តន្តន័យ............. | ១២៩ |
| ចំណែកសមុដ្ឋាន ៤ ក្នុងអាការ ៤២............. | ១៣១ |
| ការប្រព្រឹត្តរបស់សមុដ្ឋានិករូបនៅក្នុងរាងកាយ...... | ១៣១ |
| ចិត្តជរូបមាន ៧ យ៉ាង.......................... | ១៣៣ |

# មាតិកា


| រឿង | ទំព័រ |
| --- | --- |
| ចំណែកចិត្ត ៧៥ ដួង ដោយចិត្តជរូប ៧ យ៉ាង..... | ១៣៥ |
| ចំណែកចិត្តជរូប ៧ យ៉ាងតាមប្រភេទនៃចិត្ត.......... | ១៣៨ |
| រូបកលាបន័យ.............................. | ១៤០ |
| កម្មជកលាប ៩................................. | ១៤៣ |
| សេចក្តីផ្សេងគ្នានៃពាក្យថា កម្មជរូប កម្មជកលាប កម្មប្បច្ច័យឧតុជកលាប.......... | ១៤៥ |
| ចំណែកកាយ ៣ ចំណែក..................... | ១៤៧ |
| ស្ថាននៃកម្មជកលាប ៩ ក្នុងកាយ ៣ ចំណែក... | ១៤៨ |
| ចិត្តជកលាប ៨................................ | ១៤៩ |
| ចិត្តជរូបនិងចិត្តជកលាប........................ | ១៥៣ |
| ស្ថាននៃចិត្តជកាលាប ៨ ក្នុងកាយ ៣ ចំណែក.. | ១៥៥ |
| ឧតុជកលាប ៤ ដែលកើតខាងក្នុងរាងកាយសត្វ... | ១៥៧ |
| ឧតុជកលាប ២ ដែលកើតខាងក្រៅសត្វ.......... | ១៥៨ |
| ឧតុជរូបនិងឧតុជកលាប........................ | ១៥៩ |
| ស្ថាននៃឧតុជកលាប ៤ ក្នុងកាយ ៣ ចំណែក... | ១៥៩ |
| ឧតុជកលាប ៤ យ៉ាងទៀត...................... | ១៦០ |

# មាតិកា


| រឿង | ទំព័រ |
|---|---|
| អាហារជ្ជកលាប ២.................................. | ១៦១ |
| អាហារជ្ជរូបនិងអាហារជ្ជកលាប...................... | ១៦៣ |
| ស្ថាននៃអាហារជ្ជកលាប ២ ក្នុងកាយ ៣ ចំណែក.. | ១៦៤ |
| រូបកលាបក្នុងអាការ ៤២............................ | ១៦៤ |
| សសម្ភារបឋវី ២០ អាការ.......................... | ១៦៤ |
| សសម្ភារអាបោ មាន ១២ អាការ................... | ១៦៥ |
| សសម្ភារតេជោ ៤ អាការ........................ | ១៦៦ |
| សសម្ភារវាយោ ៦ អាការ....................... | ១៦៧ |
| រូបកលាបក្នុងសសម្ភាររូប ៥...................... | ១៦៨ |
| រូបបវត្តិកមន័យ.................................. | ១៦៩ |
| តាមន័យនៃភូមិ.................................. | ១៧០ |
| គាថាសង្គហៈ.................................... | ១៧០ |
| តារាងកាមភូមិ ១១ រូបកើតបាន ២៨............ | ១៧៥ |
| ចំណែករូប ២៨ ដែលកើតក្នុង- កាមភូមិ ១១ ដោយសមុដ្ឋាន ៤ .......... | ១៧៦ |

## មាតិកា


| រឿង | ទំព័រ |
|---|---|
| ចំណែករូប ២៣ ដែលកើតក្នុង-រូបភូមិ ១៥ ដោយសមុដ្ឋាន ៣ ............. | ១៧៨ |
| រូបភូមិ ១៥ (វៀរអសញ្ញីសត្វភូមិ) រូបកើតបាន ២៣. | ១៨០ |
| ចំណែករូប ១៧ ដែលកើតក្នុង-អសញ្ញសត្វភូមិ ១ ដោយសមុដ្ឋាន ៣ ......... | ១៨១ |
| ក្នុងអសញ្ញីសត្វភូមិ ១ រូបកើតបាន ១៧............ | ១៨៣ |
| តាមន័យនៃកាល.................................. | ១៨៤ |
| គាថាសង្គហៈ................................ | ១៨៥ |
| អធិប្បាយសេចក្តីសង្គហគាថា...................... | ១៨៥ |
| តាមន័យនៃកំណើត.......................... | ១៨៨ |
| យោនិកំណើត ៣ ប្រការ...................... | ១៨៩ |
| យោនិកំណើត ៤ ប្រការ....................... | ១៨៩ |
| សំសេទជៈកំណើត............................ | ១៩០ |
| ឱបបាតិកៈកំណើត............................ | ១៩១ |
| អណ្ឌជៈកំណើត................................ | ១៩២ |
| ជលាពុជៈកំណើត.............................. | ១៩២ |

## មាតិកា

| រឿង | ទំព័រ |
|---|---|
| កំណើត ៤ ក្នុងភូមិផ្សេងៗ........................ | ១៩៣ |
| ចំណែកកំណើត ៤ ដោយកម្មជកលាប ៩........... | ១៩៤ |
| ពួកឱបបាតិកៈកំណើតដែលជាព្រហ្ម (វៀរអសញ្ញសត្វព្រហ្ម) ........... | ១៩៦ |
| ពួកឱបបាតិកៈកំណើតដែលជាអសញ្ញសត្វព្រហ្ម ....... | ១៩៦ |
| គព្ភសេយ្យកៈកំណើត................................ | ១៩៧ |
| សម្តែងការកើតឡើងនៃកម្មជកលាប- ទាំង ៥ របស់ពួកគព្ភសេយ្យកៈកំណើត ........ | ១៩៨ |
| សម្តែងការចម្រើននៃរូបតាំងពីបដិសន្ធិ រហូតដល់- មានអវយវៈគ្រប់គ្រាន់របស់គព្ភសេយ្យកៈកំណើត | ២០០ |
| សម្តែងការកើតឡើងរបស់ចិត្តជរូប ឧតុជរូប និងអាហារជរូប .......... | ២០២ |
| សម្តែងការប្រព្រឹត្តទៅរបស់រូបដែលកើតពី- សមុដ្ឋានទាំង ៤ ក្នុងកាមភូមិ .... | ២០៤ |
| សម្តែងការរលត់នៃសមុដ្ឋានិករូបទាំង ៤........... | ២០៥ |
| គាថាដែលសម្តែងពីការរង្គាត់ទៅនៃរូបក្នុងសង្សារវដ្ត | ២០៩ |

# មាតិកា


| រឿង | ទំព័រ |
|---|---|
| និព្វានបរមត្ថ...................................... | ២១១ |
| គាថាសង្គហៈ........................................ | ២១១ |
| វចនត្ថៈរបស់និព្វាន................................ | ២១៥ |
| សម្តែងប្រភេទរបស់ព្រះនិព្វាន........................ | ២១៩ |
| និព្វានមាន ១ ប្រភេទ.............................. | ២១៩ |
| និព្វានមាន ២ ប្រភេទ.............................. | ២២០ |
| សឧបាទិសេសនិព្វាន............................... | ២២០ |
| អនុបាទិសេសនិព្វាន............................... | ២២៣ |
| និព្វានមាន ៣ ប្រភេទ........................... | ២២៤ |
| អនិមិត្តនិព្វាន...................................... | ២២៥ |
| អប្បណិហិត្តនិព្វាន.................................. | ២២៧ |
| សុញ្ញតនិព្វាន....................................... | ២២៨ |
| វិសេសលក្ខណៈរបស់ព្រះនិព្វាន.................... | ២៣០ |
| និព្វានមិនមាននិមិត្ត.............................. | ២៣២ |
| គុណនាមរបស់ព្រះនិព្វាន.......................... | ២៣៣ |
| សេចក្តីប្រាថ្នាព្រះនិព្វានចាត់ថាជាវិភវតណ្ហា........ | ២៣៦ |

# មាតិកា


| រឿង | ទំព័រ |
|---|---|
| គាថាសង្គហៈ.................................... | ២៣៦ |
| អវសានគាថា.................................... | ២៣៧ |